## រាជរដ្ឋាភិបាលកម្ពុជា

## គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

# របាយការណ៍ត្រួតពិនិត្យវឌ្ឍនភាព
# នៃការអនុវត្តកម្មវិធីកែទម្រង់
# ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈឆ្នាំ២០១៧

សម្របសម្រួល និងរៀបចំដោយ
អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់
ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

# បុព្វកថា

កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ជាកម្មវិធីកែទម្រង់ស្នូលមួយ នៃកម្មវិធីកែទម្រង់សំខាន់ៗរបស់រាជរដ្ឋាភិបាលកម្ពុជា ដើម្បីឈានឆ្ពោះទៅពង្រឹងអភិបាលកិច្ច ។ កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ គឺមានចក្ខុវិស័យប្រកបដោយមហិច្ឆិតា និងប្រាកដនិយម ពោលគឺកសាងប្រព័ន្ធហិរញ្ញវត្ថុសាធារណៈកម្ពុជាឱ្យស្រប តាមស្តង់ដារអន្តរជាតិ ដែលមានគោលដៅផ្លាស់ប្តូរប្រព័ន្ធដែលផ្តោតលើធាតុចូល និងមានលក្ខណៈមជ្ឈការ ឆ្ពោះទៅប្រព័ន្ធដែលផ្តោតលើធាតុចេញ ឬលទ្ធផល និងវិមជ្ឈការ ។ និយាយម្យ៉ាងទៀត ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរឹងមាំ នឹងឈានទៅសម្រេចបានលទ្ធផលចុងក្រោយទាំង ៣ រួមមាន បូរណភាពនៃការគោរពវិន័យថវិកា, ប្រសិទ្ធភាពនៃថវិកា ទាំងក្នុងផ្នែកវិភាជន៍ ទាំងក្នុងផ្នែកប្រតិបត្តិការ និងស័ក្តិសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ ។

រាជរដ្ឋាភិបាលនីតិកាលទី៥ នៃរដ្ឋសភា ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** បានផ្តល់អាទិភាព និងចាត់ទុកភាពរឹងមាំនៃប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ គឺជាឆ្អឹងខ្នងនៃការអនុវត្តកម្មវិធីគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជាឱ្យសម្រេចបានប្រកបដោយជោគជ័យ និងចីរភាព ។ ក្នុងន័យនេះ កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ពិតជាមានសារៈសំខាន់ក្នុងការជំរុញ ដើម្បីឱ្យមានការរីកចម្រើនប្រកបដោយ ជវភាព, វិបុលភាព និងបរិយាប័ន្ន ។ អាស្រ័យហេតុនេះ បណ្តាដៃគូអភិវឌ្ឍន៍ រួមមាន មូលនិធិរូបិយវត្ថុអន្តរជាតិ, ធនាគារពិភពលោក និងធនាគារអភិវឌ្ឍន៍អាស៊ីវាយតម្លៃខ្ពស់លើការខិតខំកែទម្រង់របស់រាជរដ្ឋាភិបាល និងមានជំនឿថាសេដ្ឋកិច្ចកម្ពុជា នៅតែអាចបន្តកំណើនខ្ពស់ និងរឹងមាំ ក្នុងរយៈពេលខ្លី និងមធ្យម ខាងមុខនេះ ។

កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី៣ ត្រូវបានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (គ.ហ.ស.) កំណត់ និងដាក់ចេញនូវគោលដៅអាទិភាពចំនួន ៣ រួមមាន (១).ពង្រឹងការគ្រប់គ្រង និងអនុវត្តផែនការប្រមូលចំណូល, (២). ពង្រឹង និងពង្រីកការដាក់ឱ្យអនុវត្តប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់គ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (Financial Management Information System-FMIS) និង (៣). ពង្រឹង និងពង្រីកការអនុវត្តថវិកាកម្មវិធី ។

ទន្ទឹមនេះ អនុលោមតាមសារាចរណែនាំរបស់រាជរដ្ឋាភិបាលលេខ ០៩ សរ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១៥ ស្តីពី "វិធាន និងនីតិវិធីនៃការរៀបចំ ការអនុវត្ត ការត្រួតពិនិត្យ តាមដាន និងការវាយតម្លៃលើការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ" គ.ហ.ស. បានធ្វើការត្រួតពិនិត្យវឌ្ឍនភាព និងបានរៀបចំរបាយការណ៍ត្រួតពិនិត្យ ជាប្រចាំត្រីមាស និងប្រចាំឆ្នាំ ។ ជាក់ស្តែង ក្នុងការរៀបចំរបាយការណ៍ត្រួតពិនិត្យវឌ្ឍនភាពនៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈឆ្នាំ២០១៧ គ.ហ.ស. មិនត្រឹមតែធ្វើការត្រួតពិនិត្យសមិទ្ធកម្មនៃអង្គភាពចូលរួមអនុវត្តប៉ុណ្ណោះទេ តែថែមទាំងធ្វើការវាយតម្លៃលើប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈទាំងមូលផងដែរ ដើម្បីកំណត់ភាពខ្លាំង និងភាពខ្សោយ សំដៅពង្រឹង និងបន្តកែលម្អប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈពីមួយឆ្នាំទៅមួយឆ្នាំ ។

តាមរយៈលទ្ធផលនៃការត្រួតពិនិត្យវឌ្ឍនភាពនៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ បានឆ្លុះបញ្ចាំងនូវវឌ្ឍនភាព ដូចខាងក្រោម÷

១. ការអនុវត្តយុទ្ធសាស្ត្រកៀរគរចំណូលប្រកបដោយភាពដ៏មុឹងម៉ាត់និងមុតស្រួចនេះ បានធ្វើឱ្យកំណើនចំណូលកើនឡើងជាលំដាប់ បើគិតជាមធ្យមចាប់ពីឆ្នាំ២០១៣-២០១៧ ចំណូលបានកើនឡើងប្រមាណ ០,៩៦ ពិន្ទុភាគរយនៃ ផ.ស.ស. ក្នុងមួយឆ្នាំ ។

២. ប្រព័ន្ធ FMIS ត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្តដំណាក់កាលទី១ នៅឆ្នាំ២០១៤ និងដំណាក់កាលទី២ នៅឆ្នាំ២០១៧ ។ មុខងារស្នូល និងចំណាត់ថ្នាក់ថវិកា ត្រូវបានរៀបចំដាក់បញ្ចូលក្នុងប្រព័ន្ធ FMIS ជាបន្តបន្ទាប់ទៅតាមផែនការពង្រីកការអនុវត្តប្រព័ន្ធ FMIS ។ ជាក់ស្តែង មុខងារស្នូលនៃប្រព័ន្ធនេះ មានចំនួន៦ រួមមាន (១). មុខងារវិភាជន៍ថវិកា, (២). មុខងារគណនីត្រូវសង, (៣). មុខងារគណនីត្រូវទារ, (៤). មុខងារគ្រប់គ្រងសាច់ប្រាក់, (៥). មុខងារទិញ និង (៦). មុខងារសៀវភៅធំ ។ ទន្ទឹមនេះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានធ្វើការកែសម្រួលប្លង់គណនេយ្យថ្មីឱ្យស្របតាមស្តង់ដារអន្តរជាតិ និងបានរៀបចំ និងដាក់ឱ្យអនុវត្តប្រកាសស្តីពីការដាក់ឱ្យអនុវត្តចំណាត់ថវិកាថ្នាក់ទាំង ៧ រួមមាន (១). ចំណាត់ថ្នាក់អង្គភាពប្រតិបត្តិ និងរដ្ឋបាល, (២). ចំណាត់ថ្នាក់ភូមិសាស្ត្រ, (៣). ចំណាត់ថ្នាក់សេដ្ឋកិច្ច, (៤). ចំណាត់ថ្នាក់កម្មវិធី, (៥). ចំណាត់ថ្នាក់មុខងារ, (៦). ចំណាត់ថ្នាក់គម្រោង និង (៧). ចំណាត់ថ្នាក់មូលនិធិ ។ រីឯការអនុវត្តចំណាត់ថ្នាក់ថវិកានេះ គឺត្រូវធ្វើជាដំណាក់កាល ស្របតាមទិសដៅនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។ បន្ថែមពីនេះ នៅឆ្នាំ២០១៨ ក្រសួង ស្ថាប័នចំនួន ១០ នឹងអនុវត្តប្រព័ន្ធ FMIS រួមមាន ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ក្រសួងអប់រំ យុវជន និងកីឡា, ក្រសួងសុខាភិបាល, ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ, ក្រសួងកិច្ចការនារី, ក្រសួងបរិស្ថាន, ក្រសួងមុខងារសាធារណៈ, ក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ។

៣. ការអនុវត្តថវិកាកម្មវិធី ត្រូវបាននិងកំពុងដាក់ឱ្យអនុវត្តនៅគ្រប់ក្រសួង ស្ថាប័ន និងគ្រប់រដ្ឋបាលរាជធានី ខេត្ត ។ ជាវឌ្ឍនភាព ក្រសួង ស្ថាប័ន ចំនួន ១០ អនុវត្តថវិកាកម្មវិធីសម្រាប់ឆ្នាំ ២០១៥, ក្រសួង ស្ថាប័ន ចំនួន ១៥ បន្ថែមសម្រាប់ឆ្នាំ ២០១៦ និងក្រសួង ស្ថាប័ន ចំនួន ១១ បន្ថែមសម្រាប់ឆ្នាំ ២០១៧ និងក្រសួង ស្ថាប័ន ចំនួន ៣ បន្ថែមសម្រាប់ឆ្នាំ ២០១៨ ដែលសរុបចំនួន ៣៩ ។ រីឯ គ្រប់រដ្ឋបាលរាជធានី ខេត្ត ត្រូវបានដាក់ឱ្យអនុវត្តថវិកាកម្មវិធីចាប់ពីឆ្នាំ២០១៧-២០២០ ។ ជាមួយគ្នានេះ ដើម្បីកំណត់ទិសដៅប្រព័ន្ធថវិកាឱ្យបានច្បាស់លាស់ និងប្រាកដនិយម, ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានរៀបចំយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ២០១៨-២០២៥ ហើយដែលត្រូវបានអនុម័តដោយគណៈរដ្ឋមន្ត្រី នៅថ្ងៃទី១២ ខែមករា ឆ្នាំ ២០១៨ ដោយកំណត់ប្រព័ន្ធថវិកាកម្ពុជា គឺជាប្រព័ន្ធថវិកាព័ត៌មានសមិទ្ធកម្ម ឬថវិកាសមិទ្ធកម្ម ។

ជារួម តាមរយៈលទ្ធផលនៃការត្រួតពិនិត្យវឌ្ឍនភាពកម្មវិធីកែទម្រង់ឆ្នាំ២០១៧ គ.ហ.ស. មានសុទិដ្ឋិនិយម និងវាយតម្លៃជារួមថា (១). ភាពជឿទុកចិត្តនៃថវិកានៅតែរក្សាបានជាសារវន្ត ប៉ុន្តែទាមទារឱ្យមានការពង្រឹងការព្យាករ និងការអនុវត្តកម្មវិធីចំណូល-ចំណាយប្រចាំត្រីមាស, (២). ប្រព័ន្ធគណនេយ្យភាពបាននិងកំពុងកសាងតាមរយៈការដាក់ឱ្យអនុវត្តប្រព័ន្ធ FMIS ដំណាក់កាលទី២ ជាមួយនឹងភាពប្រុងប្រយ័ត្នខ្ពស់, (៣). ការពង្រឹង និងពង្រីកការអនុវត្តថវិកាកម្មវិធី ជាមូលដ្ឋានគ្រឹះសម្រាប់រៀបចំ និងកំណត់ការផ្លាស់ប្តូរប្រព័ន្ធថវិកាកម្ពុជា, (៤). យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ២០១៨-២០២៥ ជាសមាសធាតុសំខាន់សម្រាប់កំណត់ទិសដៅនៃគណនេយ្យភាពសមិទ្ធកម្ម ដែលជាគោលដៅចុងក្រោយនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និង (៥). ការរៀបចំប្រព័ន្ធលើកទឹកចិត្ត នឹងជំរុញការធ្វើស្ថាប័ននីយកម្មឱ្យស្របតាមទិសដៅនៃការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។

ជាចុងបញ្ចប់ ក្នុងនាម គ.ហ.ស. និងរូបខ្ញុំផ្ទាល់ សូមធ្វើការវាយតម្លៃខ្ពស់ និងកោតសរសើរចំពោះក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៃក្រសួង ស្ថាប័ន និងអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលបានផ្ដល់កិច្ចសហការ និងចូលរួមអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ជាពិសេស អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលបានខិតខំបំពេញមុខងាររបស់ខ្លួនជាឧត្តមសេនាធិការជូន គ.ហ.ស. ទាំងការងារដឹកនាំ, សម្របសម្រួល, គាំទ្រ និងត្រួតពិនិត្យនិងវាយតម្លៃវឌ្ឍនភាពកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈទាំងប្រចាំត្រីមាស និងប្រចាំឆ្នាំ ប្រកបដោយភាពគ្រប់ជ្រុងជ្រោយ ដោយឆ្លុះបញ្ចាំងទាំងទិដ្ឋភាពការងារកែទម្រង់ និងប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈទាំងមូល ។

ថ្ងៃ ពុធ ១១រោច ខែ ចេត្រ ឆ្នាំរកា នព្វស័ក ព.ស.២៥៦១

រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ មេសា ឆ្នាំ២០១៨

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធាន**
**គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**

**បណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

# អារម្ភកថា

អនុលោមតាមសារាចរណែនាំរបស់រាជរដ្ឋាភិបាលលេខ ០៩ សរ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១៥ ស្តីពី “វិធាន និងនីតិវិធីនៃការរៀបចំ ការអនុវត្តការត្រួតពិនិត្យ តាមដាន និងការវាយតម្លៃលើការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ” អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (អ.គ.ហ.) ជាសេនាធិការជូន គ.ហ.ស. នឹងរៀបចំរបាយការណ៍ត្រួតពិនិត្យវឌ្ឍនភាពត្រួតពិនិត្យ ជាប្រចាំត្រីមាស និងប្រចាំឆ្នាំ ដើម្បីដាក់ឆ្លងកិច្ចប្រជុំ គ.ហ.ស. ដើម្បីពិនិត្យ និងសម្រេច ។ ជាក់ស្តែង របាយការណ៍ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈឆ្នាំ២០១៧ គឺជាការបោះជំហានមួយដ៏ធំ ពោលគឺមិនត្រឹមតែធ្វើការត្រួតពិនិត្យវឌ្ឍនភាព នៃអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួង ស្ថាប័នប៉ុណ្ណោះទេ តែថែមទាំងវាយតម្លៃភាពខ្លាំង និងភាពខ្សោយនៃប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ផងដែរ ។

ទន្ទឹមនេះ ដោយមានការអនុញ្ញាតពី គ.ហ.ស., អ.គ.ហ. បានជ្រើសរើសវិធីសាស្ត្រចំនួនបី ដើម្បីធ្វើការសិក្សា និងរៀបចំរបាយការណ៍នេះឡើង រួមមាន (១).ការត្រួតពិនិត្យ និងបូកសរុបវឌ្ឍនភាពស្របតាមក្របខ័ណ្ឌផែនការសកម្មភាពរួម ដំណាក់កាលទី៣ ឆ្នាំ២០១៧-២០២០, (២). ការចុះជួបពិភាក្សាជាមួយក្រសួង ស្ថាប័ន និងរដ្ឋបាលរាជធានី ខេត្ត និង(៣). ការសិក្សាអំពីភាពខ្លាំង និងភាពខ្សោយនៃប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដោយប្រើប្រាស់ក្របខ័ណ្ឌចំណាយសាធារណៈ និងគណនេយ្យភាពហិរញ្ញវត្ថុ (PEFA) ឆ្នាំ២០១១ ដែលត្រូវបានវាយតម្លៃដោយក្រុមការងារផ្ទៃក្នុងនៃ អ.គ.ហ. ។ ជាមួយគ្នានេះ របាយការណ៍បានបញ្ចូលវឌ្ឍនភាពគ្រប់ក្រសួង ស្ថាប័ន និងរចនាសម្ព័ន្ធនៃរបាយការណ៍ត្រួតពិនិត្យវឌ្ឍនភាពនៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈឆ្នាំ២០១៧ នេះ ត្រូវបានបែងចែកជា ២ ជំពូក ដូចខាងក្រោម ÷

- ជំពូកទី១ “លទ្ធផលនៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈឆ្នាំ២០១៧” ដោយរំលេចទាំងវឌ្ឍនភាពស្របតាមក្របខ័ណ្ឌផែនការសកម្មភាពរួម ដំណាក់កាលទី៣, សមិទ្ធកម្មអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួង ស្ថាប័ន;
- ជំពូកទី២ “លទ្ធផលនៃការវាយតម្លៃប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ” ឆ្លុះបញ្ចាំងអំពីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈកម្ពុជា ធៀបនឹងស្តង់ដារអន្តរជាតិ ។

ជារួម តាមរយៈលទ្ធផលនៃការត្រួពិនិត្យវឌ្ឍនភាពកម្មវិធីកែទម្រង់ឆ្នាំ២០១៧ អ.គ.ហ. យល់ឃើញថា វឌ្ឍនភាពដែលបានកំពុងលេចរូបរាងឡើងនេះ បានពង្រឹងព្រ័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈជាបណ្តើរៗ និងអាចធ្វើការវាយតម្លៃជារួមបានថា (១).ថវិកាកាន់តែមានភាពជឿទុកចិត្ត និងបានក្លាយជាចលករនៃកំណើនសេដ្ឋកិច្ច, (២).បុរេលក្ខណៈសំខាន់ៗត្រូវបានកសាង និងពង្រឹងបន្ថែម ដើម្បីធានាគណនេយ្យភាពហិរញ្ញវត្ថុ, (៣).ក្របខ័ណ្ឌថវិកាកម្មវិធី ត្រូវបានរៀបចំ ពង្រឹង និងពង្រីកការអនុវត្ត ដែលជាឧបករណ៍សំខាន់សម្រាប់ផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយរបស់រាជរដ្ឋាភិបាល, (៤).សមត្ថភាពមន្ត្រីក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ត្រូវបានពង្រឹង និង (៥).ការយល់ដឹង និងការចូលរួមអនុវត្តកម្មវិធីកែទម្រង់កើនឡើងជាលំដាប់ ។

ទន្ទឹមនេះ ខ្ញុំរំពឹងថា របាយការណ៍ត្រួតពិនិត្យវឌ្ឍនភាពនៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈឆ្នាំ២០១៧នេះ នឹងក្លាយជាធាតុចូលមួយសំខាន់សម្រាប់ក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៃក្រសួង ស្ថាប័ន និង ក្រុមការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៃអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុសម្រាប់ធ្វើរៀបចំ និងកែសម្រួលផែនសកម្មភាព (MAP/GDAP) ឱ្យកាន់តែមានគុណភាពស្របតាមក្របខ័ណ្ឌផែនការសកម្មភាពរួម ដំណាក់កាលទី៣ ព្រមទាំងអនុវត្ត MAP/GDAP ប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព ។ ទន្ទឹមនេះ ខ្ញុំក៏សង្ឃឹមថា របាយការណ៍នេះ នឹងក្លាយជាផ្នែកមួយនៃការសិក្សាស្រាវជ្រាវសម្រាប់មន្ត្រីរាជការ, អ្នកសិក្សាស្រាវជ្រាវ សិស្ស និស្សិត និងសាធារណៈជនទូទៅ ដើម្បីឈ្វេងយល់បន្ថែមលើការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ទាំងសមិទ្ធផលសម្រេចបាន, បញ្ហាប្រឈម និងទិសដៅត្រូវធ្វើបន្ត ។

ជាចុងបញ្ចប់ ក្នុងនាម អ.គ.ហ. និងរូបខ្ញុំផ្ទាល់សូមសម្តែងកតញ្ញូតាធមិដ៍ជ្រាលជ្រៅជូនឯកឧត្តមបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធាន គ.ហ.ស. ដែលតែងតែផ្តល់អនុសាសន៍ណែនាំដ៏មានតម្លៃ និងតម្រង់ទិសដល់ អ.គ.ហ. និងក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ទាំងការរៀបចំ និងការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ឱ្យសម្រេចបានប្រកបដោយជោគជ័យ និងចីរភាព ។

ថ្ងៃ ចន្ទ ០៩រោច ខែ ចេត្រ ឆ្នាំរកា នព្វស័ក ព.ស.២៥៦១

រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ មេសា ឆ្នាំ២០១៨

**អគ្គលេខាធិការ**

**អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារ**

**កែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**

**រស់ សីលវ៉ា**

## មាតិកានុក្រម


**បុព្វកថា** ........................................ i

**អារម្ភកថា** ........................................ iv

**សេចក្តីសង្ខេប** ........................................ xi

**ជំពូកទី១÷ លទ្ធផលនៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈឆ្នាំ២០១៧** ............ ១

**១.១.សេចក្តីផ្តើម** ........................................ ១

**១.១.១. ស្ថានភាពសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈ** ........................................ ១

**១.១.២. ទិដ្ឋភាពទូទៅ នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ** ........................................ ២

**១.១.៣. គោលបំណងនៃការរៀបចំរបាយការណ៍** ........................................ ២

**១.១.៤. វិសាលភាព និងដែនកំណត់** ........................................ ៣

**១.១.៥. វិធីសាស្រ្តត្រួតពិនិត្យនិងវាយតម្លៃ និងការរៀបចំរបាយការណ៍** ........................................ ៣

**១.២. វឌ្ឍនភាពនៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ប្រចាំឆ្នាំ២០១៧** ......... ៥

**១.២.១. លទ្ធផលនៃការអនុវត្តក្របខ័ណ្ឌសូចនាករសមិទ្ធកម្មសហភាពអឺរ៉ុប** ........................................ ៥

**១.២.២. វឌ្ឍនភាពនៃការអនុវត្តផែនការសកម្មភាពរួមឆ្នាំ២០១៧-២០២០** ........................................ ៩

**ក.វឌ្ឍនភាពនៃការអនុវត្តផែនការសកម្មភាពរួម របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ** ........................ ៩

**ក.១. ផ្នែកទី១ “បន្តពង្រឹងភាពជឿទុកចិត្តនៃថវិកា”** ........................................ ៩

**ក.២. ផ្នែកទី២ “ការពង្រឹងគណនេយ្យភាពហិរញ្ញវត្ថុ”** ........................................ ១៥

**ក.៣. ផ្នែកទី៣ “ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ”** ........................................ ២០

**ក.៤. ផ្នែកទី៤ “គណនេយ្យភាពសមិទ្ធកម្ម”** ........................................ ២៦

**ក.៥. ផ្នែកទី៥ “ការគាំទ្រដល់ការអនុវត្តកម្មវិធីកែទម្រង់ប្រកបដោយជោគជ័យ និងចីរភាព”** ........ ២៧

**ខ. សមិទ្ធកម្មតាមក្រសួង ស្ថាប័ន** ........................................ ៣០

**គ. លទ្ធផលនៃការសិក្សាស្រាវជ្រាវស្តីពីការអនុវត្ត** PFMRP **ដំណាក់កាលទី៣** ........................ ៣៣

**គ.១. សេចក្តីផ្តើម** ........................................ ៣៣

**គ.២. លទ្ធផលនៃការសិក្សាស្រាវជ្រាវ** ........................................ ៣៤

១.៣. បញ្ហាប្រឈម.......... ៣៧
១.៣.១. ផ្នែកសម្របសម្រួល.......... ៣៧
១.៣.២. ផ្នែកបច្ចេកទេស.......... ៣៧
១.៤. សំណើដំណោះស្រាយ.......... ៣៨
១.៤.១. ផ្នែកសម្របសម្រួល.......... ៣៨
១.៤.២. ផ្នែកបច្ចេកទេស.......... ៣៨
១.៥. សន្និដ្ឋាន.......... 39
ជំពូកទី២៖ លទ្ធផលនៃការវាយតម្លៃប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ.......... ៤១
២.១. វិន័យថវិកា.......... ៤១
២.២. យុទ្ធសាស្ត្រវិភាជន៍ធនធាន.......... ៤៣
២.៣. ប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ.......... ៤៤
២.៤. ភាពគ្រប់ជ្រុងជ្រោយនៃព័ត៌មានថវិកា.......... ៤៤
ឧបសម្ព័ន្ធ.......... ៤៧
ឧបសម្ព័ន្ធទី១៖ តារាងភាគរយសមិទ្ធកម្មតាមអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ.......... ៤៨
ឧបសម្ព័ន្ធទី២៖ វឌ្ឍនភាពសង្ខេបតាមផ្នែកនីមួយៗ នៃ CAP3.......... ៤៩
ឧបសម្ព័ន្ធទី៣៖ សេចក្តីសង្ខេបសូចនាករនៃក្របខ័ណ្ឌវាស់សមិទ្ធកម្មនៃ PFM.......... ៨២
ឧបសម្ព័ន្ធទី៤ ÷ តារាងតាមដានការអនុវត្តអនុសាសន៍ គ.ហ.ស........... ១១៦

## បញ្ជីដ្យាក្រាម


ដ្យាក្រាម 1: ភាគរយសម្រេចបានតាមគោលបំណងនៃផ្នែកនីមួយៗនៃ CAP3 ........ ៩

ដ្យាក្រាម 2: ការកៀរគរចំណូលក្នុងស្រុក និងកំណើនចំណូលចរន្តឆ្នាំ២០១៣-២០១៧........ ១០

ដ្យាក្រាម 3: លទ្ធផលនៃការអនុវត្តថវិកាគាំទ្រកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ........ ៣១


## បញ្ជីតារាង


តារាង 1: ការប្រែប្រួលក្របខ័ណ្ឌផែនការសកម្មភាពរួមដំណាក់កាលទី២ ដល់ដំណាក់កាលទី៣........ ២

តារាង 2: លទ្ធផលនៃការអនុវត្តក្របខ័ណ្ឌសូចនាករសមិទ្ធកម្មសហភាពអឺរ៉ុប........ ៥

តារាង 3: ការកែសម្រួលគោលដៅសូចនាករសមិទ្ធកម្មគន្លឹះឆ្នាំ២០១៨........ ៧

តារាង 4: លទ្ធផលនៃការអនុវត្តថវិកា និងសមិទ្ធកម្មរបស់ក្រសួង ស្ថាប័ន........ ៣១

តារាង 5: បម្រែបម្រួលលើលទ្ធផល/ សមិទ្ធកម្ម ធៀបនឹងការវាយតម្លៃឆ្នាំ២០១៥........ ៤៤


## បញ្ជីប្រអប់


ប្រអប់ 1: វិធីសាស្ត្រត្រួតពិនិត្យ និងវាយតម្លៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ........ ៤

ប្រអប់ 2: ការងារត្រូវធ្វើបន្តនៃផ្នែកទី១ “បន្តពង្រឹងភាពជឿទុកចិត្តនៃថវិកា” ........ ១៤

ប្រអប់ 3: វឌ្ឍនភាពនៃការរៀបចំបញ្ជីសារពើភណ្ឌគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋឆ្នាំ២០១៧........ ១៨

ប្រអប់ 4: ការងារត្រូវធ្វើបន្តនៃផ្នែកទី២ “បន្តពង្រឹងគណនេយ្យភាពហិរញ្ញវត្ថុ” ........ ២០

ប្រអប់ 5: វឌ្ឍនភាពនៃការផ្ទេរហិរញ្ញវត្ថុទៅរដ្ឋបាលថ្នាក់ក្រោមជាតិ........25

ប្រអប់ 6: ការងារត្រូវធ្វើបន្តនៃផ្នែកទី៣ “ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ” ........ ២៦

ប្រអប់ 7: ការងារត្រូវធ្វើបន្តនៃផ្នែកទី៤ “គណនេយ្យភាពសមិទ្ធកម្ម”........ ២៧

ប្រអប់ 8: ការងារត្រូវធ្វើបន្តនៃផ្នែកទី៥ “ការគាំទ្រកម្មវិធីកែទម្រង់ប្រកបដោយជោគជ័យ និងចីរភាព” ........ ៣០

# អក្សរកាត់

| | | |
|---|---|---|
| ASYCUDA | Automated System for Customs Data | ប្រព័ន្ធស្វ័យប្រវត្តិកម្មគយ |
| ADB | Asian Development Bank | ធនាគារអភិវឌ្ឍន៍អាស៊ី |
| BSP | Budget Strategic Plan | ផែនការយុទ្ធសាស្ត្រថវិកា |
| BSRS | Budget System Reform Strategy | យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកា |
| CAP | Consolidated Action Plan | ផែនការសកម្មភាពរួម |
| CoA | Chart of Accounts | ប្លង់គណនេយ្យ |
| DMFAS | Debt Management and Financial Analysis System | ប្រព័ន្ធវិភាគហិរញ្ញវត្ថុ និងគ្រប់គ្រងបំណុល |
| GDICDM | General Department of Cooperation and Debt Management | អគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិនិង គ្រប់គ្រងបំណុល (អ.ស.ប.) |
| FMIS | Financial Management Information System | ប្រព័ន្ធព័ត៌មានវិទ្យាគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ |
| GDB | General Department of Budget | អគ្គនាយកដ្ឋានថវិកា (អ.ថ.) |
| GDCE | General Department of Customs and Excise | អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា (អ.គ.រ.) |
| GDP | General Department of Policy | អគ្គនាយកដ្ឋានគោលនយោបាយ (អ.គ.ប.) |
| GDIA | General Department of Internal Audit | អគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង (អ.ស.ក.) |
| GDNT | General Department of National Treasury | អគ្គនាយកដ្ឋានរតនាគារជាតិ |
| GDPP | General Department of Public Procurement | អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ |
| GDSNAF | General Department of Sub-National Administration Finance | អគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ |
| GDSPNTR | General Department of State Property and Non-Tax Revenue | អគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែន សារពើពន្ធ (អ.ទ.ច.) |
| GDT | General Department of Taxation | អគ្គនាយកដ្ឋានពន្ធដារ (អ.ព.ដ.) |
| GDP | Gross Domestic Product | ផលិតផលក្នុងស្រុកសរុប (ផ.ស.ស.) |
| GFS | Government Financial Statistics | ស្ថិតិហិរញ្ញវត្ថុរដ្ឋាភិបាល |
| GSC | General Secretariat of Public Financial Management Reform Steering Committee | អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារ កែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (អ.គ.ហ.) |
| IMF | International Monetary Fund | មូលនិធិរូបិយវត្ថុអន្តរជាតិ |
| KIT | Khmer Information Technology | បច្ចេកវិទ្យាព័ត៌មានខ្មែរ |
| LM | Line ministry | ក្រសួង ស្ថាប័ន |
| MEF | Ministry of Economy and Finance | ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (កសហវ) |
| MTBF | Medium-Term Expenditure Framework | ក្របខ័ណ្ឌថវិការយៈពេលមធ្យម |
| MTFF | Medium-Term Fiscal Framework | ក្របខ័ណ្ឌហិរញ្ញវត្ថុរយៈពេលមធ្យម |
| NAA | National Audit Authority | អាជ្ញាធរសវនកម្មជាតិ |

| | | |
|---|---|---|
| NIS | National Institute of Statistics | វិទ្យាស្ថានស្ថិតិជាតិ |
| NSDP | National Strategic Development Plan | ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ |
| OCM | Office of the Council of Ministers | ទីស្ដីការគណៈរដ្ឋមន្ត្រី |
| PCA | Post Clearance Audit | សវនកម្មក្រោយបញ្ចេញទំនិញពីគយ |
| PEFA | Public Expenditure and Financial Accountability | ចំណាយសាធារណៈនិងគណនេយ្យភាពហិរញ្ញវត្ថុ |
| PFM | Public Financial Management | ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ |
| PI | Performance Indicator | សូចនាករសមិទ្ធកម្ម |
| PPP | Public-Private Partnership | ភាពជាដៃគូរវាងរដ្ឋ និងឯកជន |
| TOFE | Table of Fiscal and Economic Operations of the Government | តារាងប្រតិបត្តិការសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរដ្ឋាភិបាល |
| WB | World Bank | ធនាគារពិភពលោក |

# សេចក្តីសង្ខេប

១. សុខភាពប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ គឺជាឆ្អឹងខ្នងក្នុងការគាំទ្រការអនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជាឱ្យអនុវត្តបានប្រកបដោយជោគជ័យ និងចីរភាព ។ ចាប់តាំពីឆ្នាំ២០១៥ រហូតមកដល់បច្ចុប្បន្ន កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ បាននិងកំពុងកសាង "ប្រព័ន្ធ, យន្តការ, ក្របខ័ណ្ឌគតិយុត្ត និងធនធានមនុស្ស" ដែលជាកត្តាគន្លឹះកំណត់ជោគជ័យ, ធានាវិន័យ, តម្លាភាព, គណនេយ្យភាព ស័ក្តិសិទ្ធភាព និងប្រសិទ្ធភាព នៃប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ។

២. គោលបំណងនៃការរៀបចំរបាយការណ៍ត្រួតពិនិត្យវឌ្ឍនភាពនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ឆ្នាំ២០១៧ គឺដើម្បីពិនិត្យវឌ្ឍនភាពសម្រេចបានឆ្នាំ២០១៧ និងវាយតម្លៃការប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ព្រមទាំងឆ្លុះបញ្ចាំងនូវសមិទ្ធផលម្រេចបានក្នុងរយៈពេល ៥ ឆ្នាំ ចាប់ពីឆ្នាំ២០១៣-២០១៧ និងទិសដៅសម្រាប់រយៈពេល ៥ឆ្នាំ បន្ទាប់ ។ កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី៣ គឺផ្តោតលើអាទិភាពចំនួន ៣ រួមមាន (១). ការពង្រឹងការគ្រប់គ្រង និងអនុវត្តផែនការប្រមូលចំណូល, (២). ការពង្រឹង និងពង្រីកការដាក់ឱ្យអនុវត្តប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (Financial Management Information System-FMIS) និង (៣). ការពង្រឹង និងពង្រីកការអនុវត្តថវិកាកម្មវិធី ។

៣. រាជរដ្ឋាភិបាលកម្ពុជានីតិកាលទី៥ នៃរដ្ឋសភា បានយកចិត្តទុក និងពង្រឹងការអនុវត្តយុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យម ២០១៤-២០១៨ ។ តាមរយៈយុទ្ធសាស្ត្រនេះ រាជរដ្ឋាភិបាល អនុវត្តដូចតទៅ (១). មិនមានការបង្កើនអត្រាពន្ធ ឬបង្កើតពន្ធថ្មី, (២). ពង្រឹងច្បាប់ និងបទប្បញ្ញត្តិដែលមានស្រាប់, (៣). ពង្រឹងការគ្រប់គ្រងការប្រមូលចំណូលឱ្យអស់សក្តានុពលដែលមានស្រាប់ និងធានាឱ្យបាននូវភាពងាយស្រួល និងភាពត្រឹមត្រូវនៃការបង់ពន្ធ ។ ការអនុវត្តយុទ្ធសាស្ត្រកៀរគរចំណូលនេះដ៏ម៉ឺងម៉ាត់នេះ នាំឱ្យកំណើនចំណូលកើនឡើងជាលំដាប់ ដោយជាមធ្យមពីឆ្នាំ២០១៣-២០១៧ ចំណូលកើនឡើងប្រមាណ ០,៩៦ ពិន្ទុភាគរយនៃ ផ.ស.ស.។ ជាទិសដៅបន្ទាប់ កសហវ នឹងរៀបចំក្របខ័ណ្ឌគោលនយោបាយពន្ធឆ្នាំ២០១៩-២០២៣ ។

៤. ប្រព័ន្ធព័ត៌មានវិទ្យាគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS) ត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្តដំណាក់កាលទី១ នៅឆ្នាំ២០១៤ និងដំណាក់កាលទី២ នៅឆ្នាំ២០១៧ ។ មុខងារស្នូល និងចំណាត់ថ្នាក់ថវិកាត្រូវបានដាក់បញ្ចូលក្នុងប្រព័ន្ធ FMIS ជាបន្តបន្ទាប់ស្របតាមជំហានយុទ្ធសាស្ត្រនៃប្រព័ន្ធ។ ជាក់ស្តែង មុខងារស្នូលទាំង ៦ រួមមាន (១). មុខងារវិភាជន៍ថវិកា, (២). មុខងារគណនីត្រូវសង, (៣). មុខងារគណនីត្រូវទារ, (៤). មុខងារគ្រប់គ្រងសាច់ប្រាក់, (៥). មុខងារទិញ និង (៦). មុខងារសៀវភៅធំ ។ សម្រាប់ជំហានបន្ទាប់ មុខងារ ៤ បន្ថែមទៀត រួមមាន មុខងាររៀបចំថវិកា, មុខងារលទ្ធកម្ម, មុខងារគ្រប់គ្រងទ្រព្យសម្បត្តិ និង មុខងារគ្រប់គ្រងសន្និធិ ។ ទន្ទឹមនេះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានធ្វើការកែសម្រួលប្លង់គណនេយ្យថ្មីឱ្យស្របតាមស្តង់ដារអន្តរជាតិ និងបានរៀបចំ និងដាក់ឱ្យអនុវត្តប្រកាសស្តីពីការដាក់ឱ្យអនុវត្តចំណាត់ថ្នាក់ទាំង៧ រួមមាន (១). ចំណាត់ថ្នាក់អង្គភាពប្រតិបត្តិ និងរដ្ឋបាល, (២). ចំណាត់ថ្នាក់ភូមិសាស្ត្រ, (៣). ចំណាត់

ថ្នាក់សេដ្ឋកិច្ច, (៤).ចំណាត់ថ្នាក់កម្មវិធី, (៥).ចំណាត់ថ្នាក់មុខងារ, (៦).ចំណាត់ថ្នាក់គម្រោង និង (៧). ចំណាត់ថ្នាក់មូលនិធិ។ ជាក់ស្តែង ការអនុវត្តចំណាត់ថ្នាក់នេះ គឺត្រូវធ្វើជាដំណាក់កាល ស្របតាមទិសដៅនៃកម្មវិធីកែទម្រង់។ រហូតមកដល់ឆ្នាំ២០១៧ នេះ ចំណាត់ថ្នាក់ចំនួន ៣ ត្រូវបានអនុវត្ត រួមមាន (១). ចំណាត់ថ្នាក់អង្គភាពប្រតិបត្តិ និងរដ្ឋបាល (ត្រឹមកម្រិត ១), (២).ចំណាត់ថ្នាក់សេដ្ឋកិច្ច, (៣).ចំណាត់ថ្នាក់កម្មវិធី ។

៥. នៅឆ្នាំ២០១៨ ក្រសួង ស្ថាប័នចំនួន ១០ នឹងអនុវត្តប្រព័ន្ធ FMIS រួមមាន ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ក្រសួងអប់រំ យុវជន និងកីឡា, ក្រសួងសុខាភិបាល, ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ,ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ, ក្រសួងកិច្ចការនារី, ក្រសួងបរិស្ថាន, ក្រសួងមុខងារសាធារណៈ, ក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ។ បន្ថែមពីនេះ អង្គភាពហិរញ្ញវត្ថុ និងគ្រប់អង្គភាពថវិកាដែលជាអាណាប័កផ្ទេរសិទ្ធិ គឺត្រូវអនុវត្តប្រព័ន្ធ FMIS នេះ ។

៦. ការអនុវត្តថវិកាកម្មវិធី ត្រូវបាននិងកំពុងដាក់ឱ្យអនុវត្តគ្រប់ក្រសួង ស្ថាប័ន និងគ្រប់រដ្ឋបាលរាជធានី ខេត្ត។ ជាវឌ្ឍនភាព ក្រសួង ស្ថាប័ន ចំនួន១០ អនុវត្តថវិកាកម្មវិធី សម្រាប់ឆ្នាំ២០១៥, ក្រសួង ស្ថាប័ន ចំនួន ១៥ សម្រាប់ឆ្នាំ២០១៦ និងក្រសួង ស្ថាប័ន ចំនួន ១១ សម្រាប់ឆ្នាំ២០១៧ និង ក្រសួង ស្ថាប័ន ចំនួន ៣ សម្រាប់ឆ្នាំ២០១៨ ដែលសរុបចំនួន ៣៩ ។ រីឯ រដ្ឋបាលរាជធានី ខេត្ត ត្រូវបានដាក់ឱ្យអនុវត្តថវិកាកម្មវិធីចាប់ពីឆ្នាំ២០១៧-២០២០ ដោយក្នុងនោះរដ្ឋបាលខេត្តចំនួន ៦ ចូលអនុវត្តថវិកាកម្មវិធីត្រូវបានដាក់ឱ្យអនុវត្តនៅឆ្នាំ២០១៧ និង ៦ ទៀត ត្រូវបានដាក់ឱ្យអនុវត្តនៅឆ្នាំ២០១៨ ។ ក្នុងន័យនេះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានបណ្តុះបណ្តាលលើការរៀបចំផែនការយុទ្ធសាស្ត្រថវិកា, ការរៀបចំ និងអនុវត្តថវិកាកម្មវិធី, នីតិវិធីអនុវត្តកិច្ចលទ្ធកម្មសាធារណៈ និងនីតិវិធីចំណាយរជ្ជទេយ្យបុរេប្រទាន ជាដើម ។ ជាជំហានបន្ទាប់ កសហវ នឹងធ្វើជ្រើសរើសក្រសួង ស្ថាប័ន សម្រាប់ធ្វើការត្រួតពិនិត្យលើសូចនាករលទ្ធផលក្នុងឆ្នាំការអនុវត្តថវិកាកម្មវិធីនិងអង្គភាពថវិកាដើម្បីកំណត់នូវចំណុចខ្លាំង និងចំណុចខ្សោយ ព្រមទាំងផ្តល់អនុសាសន៍សម្រាប់ធ្វើការពង្រឹង និងពង្រីកការអនុវត្តថវិកាកម្មវិធី ។ ជាមួយគ្នានេះ ដើម្បីកំណត់ទិសដៅកែទម្រង់ប្រព័ន្ធថវិកាឱ្យបានច្បាស់-លាស់ និងប្រាកដនិយម, កសហវ បានរៀបចំយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ២០១៨-២០២៥ ហើយត្រូវបានគណៈរដ្ឋមន្ត្រីអនុម័តនៅថ្ងៃ១២ ខែមករា ឆ្នាំ២០១៨។ តាមយៈយុទ្ធសាស្ត្រនេះ ប្រព័ន្ធថវិកាកម្ពុជា គឺជាប្រព័ន្ធថវិកាព័តិមានសមិទ្ធកម្ម ឬថវិកាសមិទ្ធកម្ម ។

៧. ជារួម តាមរយៈលទ្ធផលនៃការត្រួតពិនិត្យវឌ្ឍនភាពនៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ អាចសន្និដ្ឋានជារួម ដូចខាងក្រោម÷
   - ភាពជឿទុកចិត្តនៃថវិកានៅតែរក្សាបានជាសារវន្ត ប៉ុន្តែទាមទារឱ្យមានការពង្រឹងការព្យាករ និងការអនុវត្តកម្មវិធីចំណូល-ចំណាយប្រចាំត្រីមាស
   - ប្រព័ន្ធគណនេយ្យភាពបាននិងកំពុងកសាងតាមរយៈការដាក់ ឱ្យអនុវត្តប្រព័ន្ធ FMIS ដំណាក់កាលទី២ ជាមួយភាពប្រុងប្រយ័ត្ន
   - ការពង្រឹង និងពង្រីកការអនុវត្តថវិកាកម្មវិធី ជាមូលដ្ឋានគ្រឹះសម្រាប់រៀបចំ និងកំណត់ការផ្លាស់ប្តូរប្រព័ន្ធថវិកាកម្ពុជា

- យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាកម្ពុជាជាសមាសធាតុសំខាន់សំរាប់កំណត់ទិសដៅគណនេយ្យ-ភាពសមិទ្ធកម្ម ដែលជាគោលដៅចុងក្រោយនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- ការរៀបចំប្រព័ន្ធលើកទឹកចិត្ត នឹងជំរុញការធ្វើស្ថាប័ននីយកម្មឱ្យស្របតាមកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។

# ជំពូកទី១÷ លទ្ធផលនៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រង ហិរញ្ញវត្ថុសាធារណៈឆ្នាំ២០១៧

## ១.១.សេចក្តីផ្តើម

### ១.១.១. ស្ថានភាពសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈ

ក្នុងរយៈពេលពីរទសវត្សរ៍កន្លងមកនេះ កំណើនសេដ្ឋកិច្ចនៃប្រទេសកម្ពុជា គឺនៅបន្តភាពរឹងមាំ និងត្រូវបាន ធនាគារពិភពលោក (World Bank-WB) បានចាត់ទុកជាប្រទេសចំណូលមធ្យមកម្រិតទាបនៅឆ្នាំ ២០១៥ ។ ទោះបីជាសេដ្ឋកិច្ចពិភពលោក បាននិងកំពុងស្ថិតក្នុងភាពមិនប្រាកដប្រជា ព្រមទាំងមានហានិភ័យ និងបញ្ហាប្រឈម ទាំងក្នុងប្រទេសអភិវឌ្ឍន៍ និងប្រទេសកំពុងអភិវឌ្ឍន៍ ប៉ុន្តែសេដ្ឋកិច្ចកម្ពុជានៅតែអាចបន្តកំណើនខ្ពស់ និងរឹងមាំ ក្នុងរយៈពេលខ្លី និងមធ្យមខាងមុខនេះ ។ ក្នុងន័យនេះ ធនាគារអភិវឌ្ឍន៍អាស៊ី (Asian Development Bank-ADB) បានចាត់ទុកប្រទេសកម្ពុជា ជាប្រទេសមួយក្នុងចំណោមប្រទេស ដែលមានកំណើនសេដ្ឋកិច្ចលឿនបំផុតនៅតំបន់អាស៊ី ព្រមទាំងបានប្រសិទ្ធនាមថា “**ខ្លាសេដ្ឋកិច្ចថ្មីនៅអាស៊ី**” នៅឆ្នាំ២០១៦ ។

យោងរបាយការណ៍របស់មូលនិធិរូបិយវត្ថុអន្តរជាតិ (International Monetary Fund-IMF) ឆ្នាំ២០១៧ បានបង្ហាញថា សេដ្ឋកិច្ចនៃប្រទេសកម្ពុជាបន្តភាពរឹងមាំ ខណៈពេលដែលអតិផរណាជាមធ្យមបានកើនឡើងដល់ ៣% នៅឆ្នាំ ២០១៦ ។ ទន្ទឹមនេះ យោងរបាយការណ៍របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុឆ្នាំ ២០១៨ សេដ្ឋកិច្ចកម្ពុជា ក្នុងឆ្នាំ ២០១៧ ត្រូវបានប៉ាន់ស្មានថា នឹងរក្សាបានកំណើនក្នុងរង្វង់ ៧,០% ដោយក្នុងនោះ វិស័យឧស្សាហកម្មនៅតែមានកំណើនរឹងមាំប្រមាណ ៩,៩%, សេវាកម្មប្រមាណ ៧,១% និងកសិកម្មប្រមាណ ១,៦% ។

ជាមួយនឹងកំណើនរឹងមាំក្នុងឆ្នាំ ២០១៧ នេះ ផ.ស.ស ថ្លៃបច្ចុប្បន្នត្រូវបានប៉ាន់ស្មានថា នឹងកើនឡើងដល់ ២២,១៦ ប៊ីលានដុល្លារអាមេរិក ដែលធ្វើឱ្យ ផ.ស.ស សម្រាប់មនុស្សម្នាក់អាចនឹងកើនឡើងដល់ ១ ៤២៧ ដុល្លារអាមេរិក។ លើសពីនេះ កម្ពុជាអាចរក្សាបាននូវអតិផរណា ដែលស្ថិតក្នុងកម្រិតទាប និងអាចគ្រប់គ្រងបាន ដោយ អតិផរណាជាមធ្យមប្រចាំឆ្នាំ ត្រូវបានប៉ាន់ស្មានថា នឹងមានអត្រា ២,៩% ក្នុងឆ្នាំ ២០១៧ ។ ជាមួយគ្នានេះដែរ អត្រាប្តូរប្រាក់នៅបន្តមានស្ថិរភាពជាមួយនឹងការរំពឹងទុកថា ប្រាក់រៀលនឹងនៅបន្តរក្សាបាននូវតម្លៃប្រមាណ ៤ ០៤៥ រៀល ក្នុង ១ ដុល្លារអាមេរិក នៅក្នុងឆ្នាំ ២០១៧ នេះ ។

ក្នុងក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈ លទ្ធផលប្រមូលចំណូលនៅតែមានភាពរឹងមាំ ដែលចំណូលមានការកើនឡើងក្នុងចន្លោះ ១៥%-២០% ក្នុងមួយឆ្នាំ ក្នុងរយៈពេល ៥ ឆ្នាំចុងក្រោយ ដោយត្រូវបានស្ថាប័នអន្តរជាតិនានាវាយតម្លៃថា ជាសមិទ្ធផលមួយ ដែលមិនធ្លាប់មានពីមុនមកក្នុងបណ្តាប្រទេសក្នុងតំបន់ និងបណ្តាប្រទេស ដែលមានកម្រិតអភិវឌ្ឍន៍ប្រហាក់ប្រហែល។ ចំណូលចរន្តថវិកាជាតិបានកើនឡើងពីប្រមាណ ១៥,០៦% នៃ ផសស ក្នុងឆ្នាំ ២០១៣ ដល់ ១៩,៦៤%នៃ ផ.ស.ស. ក្នុងឆ្នាំ ២០១៧ ពោលគឺកើនឡើងជិត ២ ដង ឬប្រមាណ ៤,៥៨ ពិន្ទុភាគរយនៃ ផ.ស.ស. ។

ទន្ទឹមនេះ ថវិកាចំណាយបានកើនប្រមាណ១,៨ ដង ហើយការវិភាជថវិកាត្រូវបានគិតគូរលើវិស័យអាទិភាពសំខាន់ៗ និងការអនុវត្តថវិកាផ្នែកចំណាយក៏កាន់តែមានប្រសិទ្ធភាព ទាំងកម្រិតវិភាជន៍ និងកម្រិតប្រតិបត្តិការ[1] ។

**១.១.២. ទិដ្ឋភាពទូទៅ នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**

កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី៣ ត្រូវបានដាក់ឱ្យអនុវត្តនៅឆ្នាំ២០១៦ ដោយ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ។ កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី៣ ត្រូវបានកំណត់គោលដៅអាទិភាពចំនួន ០៣ ដោយ គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ រួមមាន (១). ការពង្រឹងការគ្រប់គ្រង និងអនុវត្តផែនការប្រមូលចំណូល, (២). ការពង្រឹង និងពង្រីកការដាក់ឱ្យអនុវត្តប្រព័ន្ធ FMIS និង (៣). ការពង្រឹង និងពង្រីកការអនុវត្តថវិកាកម្មវិធី ។ ក្នុងន័យនេះ ការត្រួតពិនិត្យ តាមដាន និងវាយតម្លៃសមិទ្ធកម្ម នឹងឆ្ពោះទៅការធានាឱ្យមានតម្លាភាព គណនេយ្យភាព និងការទទួលខុសត្រូវច្បាស់លាស់ដើម្បីគ្រប់គ្រងផ្តោតលើធាតុចេញ (វិសហមជ្ឈការ និងវិមជ្ឈការ) ប្រកបដោយស័ក្តិសិទ្ធភាព និងប្រសិទ្ធភាព ។

របាយការណ៍ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈឆ្នាំ២០១៧ គឺជាការបោះជំហានមួយដ៏ធំសម្រាប់ការឈានឆ្ពោះទៅ មិនត្រឹមតែការគ្រប់គ្រងសមិទ្ធកម្ម នៃអង្គភាពក្រោមឱវាទកសហវ និងក្រសួង ស្ថាប័ន ប៉ុន្តែថែមទាំងប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ផងដែរ ។ ការត្រួតពិនិត្យ និងវាយតម្លៃនេះ គឺអនុលោមតាមសារាចរណែនាំរបស់រាជរដ្ឋាភិបាលលេខ ០៩ ចុះថ្ងៃទី២៨ ធ្នូ ២០១៥ ស្តីពី "វិធាន និងនីតិវិធីនៃការរៀបចំ ការអនុវត្តការត្រួតពិនិត្យ តាមដាន និងការវាយតម្លៃលើការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ" ។

តារាង 1: ការប្រែប្រួលក្របខ័ណ្ឌផែនការសកម្មភាពរួមដំណាក់កាលទី២ ដល់ដំណាក់កាលទី៣

| រចនាសម្ព័ន្ធ CAP | CAP2 | CAP2 New | CAP3 2016-2020 | CAP3 2017-2020 |
|---|---|---|---|---|
| ផ្នែក | ៣ | ៤ | ៥ | ៥ |
| គោលបំណង | ១៤ | ១៦ | ២១ | ២២ |
| ចង្កោមសកម្មភាព | ៦២ | ៧១ | ៦៨ | ៦៩ |

**១.១.៣. គោលបំណងនៃការរៀបចំរបាយការណ៍**

ក្នុងដំណាក់កាលទី៣ នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ តួនាទីរបស់ក្រសួង ស្ថាប័ន ចូលរួមចំណែកក្នុងការគាំទ្រកម្មវិធីកែទម្រង់ឱ្យប្រកបដោយជោគជ័យ និងចីរភាព។ ក្នុងន័យនេះ គ.ហ.ស. គឺមានតម្រូវការជាចាំបាច់ធ្វើការត្រួតពិនិត្យលើប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ។

[1] ក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈ សម្រាប់រៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៩

គោលបំណង នៃការរៀបចំរបាយការណ៍ត្រួតពិនិត្យការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនេះ គឺធ្វើការពិនិត្យនូវភាពខ្លាំង និងភាពខ្សោយនៃប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក៏ដូចជាដើម្បីពង្រឹងការអនុវត្ត និងកែលម្អក្របខ័ណ្ឌផែនការសកម្មភាពរួមសម្រាប់អនុវត្តនាឆ្នាំបន្តបន្ទាប់ទៀត ។ របាយការណ៍នេះ នឹងឆ្លុះបញ្ចាំងនូវភាពគ្រប់ជ្រុងជ្រោយនៃប្រព័ន្ធ ព្រមទាំងលទ្ធផលក្នុងឆ្នាំ (Outputs) និងលទ្ធផលចុងក្រោយ (Outcomes) ។

### ១.១.៤. វិសាលភាព និងដែនកំណត់

របាយការណ៍នេះ គឺផ្អែកលើការសិក្សាស្រាវជ្រាវរបស់ក្រុមការងាររៀបចំរបាយការណ៍ នៃ អ.គ.ហ. តាមរយៈការចុះជួបពិភាក្សាជាមួយក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៃក្រសួង ស្ថាប័ន ចំនួន ៤ និងរដ្ឋបាលរាជធានី ខេត្ត បន្ថែមពីការត្រួតពិនិត្យវឌ្ឍនភាពនៃការអនុវត្តផែនការសកម្មភាពគាំទ្រកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ របស់អង្គភាពក្រោមឱវាទ កសហវ (GDAP) និងផែនការសកម្មភាពរបស់ក្រសួង ស្ថាប័ន (MAP) ទាំង ៤០ ។

ដើម្បីធ្វើការវិភាគឱ្យបានស៊ីជម្រៅ អ.គ.ហ. ក៏បានប្រើប្រាស់ឧបករណ៍ PEFA ឆ្នាំ២០១១ ដោយធ្វើការប្រៀបធៀបរវាងពិន្ទុទទួលបានក្នុងរបាយការណ៍ឆ្នាំ២០១៥ ដែលប្រើប្រាស់ទិន្នន័យឆ្នាំ២០១១, ២០១២ និង២០១៣ និងពិន្ទុទទួលបានក្នុងរបាយការណ៍ឆ្នាំ២០១៧ ដែលប្រើប្រាស់ទិន្នន័យឆ្នាំ២០១៤, ២០១៥ និង២០១៦ ។ ការវាយតម្លៃ PEFA ឆ្នាំ២០១៧ នេះ គឺត្រូវបានរៀបចំឡើងដោយក្រុមការងារផ្ទៃក្នុង នៃ អ.គ.ហ. ប៉ុណ្ណោះ ដើម្បីពិនិត្យសុខភាពនៃប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។ ទន្ទឹមនេះ សូចនាករពាក់ព័ន្ធដៃគូអភិវឌ្ឍន៍ចាប់ពី D1-D3 គឺមិនត្រូវបានធ្វើការវាយតម្លៃ ដែលស្ថិតនៅក្រៅវិសាលភាពនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។

### ១.១.៥. វិធីសាស្ត្រត្រួតពិនិត្យនិងវាយតម្លៃ និងការរៀបចំរបាយការណ៍

ដោយមានការអនុញ្ញាតពី គ.ហ.ស., អ.គ.ហ. បានជ្រើសរើសវិធីសាស្ត្រចំនួន ៣ ដើម្បីធ្វើការសិក្សារៀបចំរបាយការណ៍នេះឡើង រួមមាន ÷

១. ត្រួតពិនិត្យ និងប្រមូលសរុបវឌ្ឍនភាពស្របតាមក្របខ័ណ្ឌផែនការសកម្មភាពរួម ដំណាក់កាលទី៣ ឆ្នាំ២០១៧-២០២០

២. ចុះជួបពិភាក្សាជាមួយក្រសួង ស្ថាប័ន និងរដ្ឋបាលរាជធានី ខេត្ត

៣. សិក្សាអំពីភាពខ្លាំង និងភាពខ្សោយនៃប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដោយប្រើប្រាស់ក្របខ័ណ្ឌ PEFA ឆ្នាំ២០១១ ។

រចនាសម្ព័ន្ធនៃរបាយការណ៍ត្រួតពិនិត្យវឌ្ឍនភាពនៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈឆ្នាំ២០១៧ នេះ ត្រូវបានបែងចែកជា ២ ជំពូក ដូចខាងក្រោម ÷

- **ជំពូកទី១ "លទ្ធផលនៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈឆ្នាំ២០១៧"** បង្ហាញនូវវឌ្ឍនភាពនៃការអនុវត្ត CAP3, សមិទ្ធកម្មតាមអង្គភាពក្រោមឱវាទ កសហវ, សមិទ្ធកម្មតាមក្រសួង ស្ថាប័ន និងលទ្ធផលនៃការសិក្សាប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់ក្រសួង ស្ថាប័ន

- **ជំពូកទី២ “លទ្ធផលនៃការវាយតម្លៃប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ”** បង្ហាញអំពីការប្រើប្រាស់ឧបករណ៍ PEFA ដើម្បីកំណត់ភាពខ្លាំង និងភាពខ្សោយនៃប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។

ប្រអប់ 1: វិធីសាស្ត្រត្រួតពិនិត្យ និងវាយតម្លៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

១. ក្នុងន័យនេះ ការត្រួតពិនិត្យវឌ្ឍនភាពប្រចាំឆ្នាំ២០១៧ នៃការអនុវត្តផែនការសកម្មភាពរួម ដំណាក់កាលទី៣ គឺអនុលោមតាមសារាចរលេខ ០៩ ដោយប្រើប្រាស់ទម្ងន់តាមកម្រិតចង្កោមសកម្មភាព, គោលបំណង និងផ្នែកដូចខាងក្រោម÷

-ទី១÷ **វឌ្ឍនភាពតាមចង្កោមសកម្មភាព** → បូកសរុបជាមធ្យមនូវវឌ្ឍនភាពគ្រប់សកម្មភាពដែលអង្គភាពក្រោមឱវាទ កសហវ

-ទី២÷ **វឌ្ឍនភាពតាមគោលបំណង** → វឌ្ឍនភាពតាមចង្កោមសកម្មភាព គុណនឹងទម្ងន់តាមចង្កោម → បូកសរុបលទ្ធផលតាមចង្កោមសកម្មភាព នៃគោលបំណង

-ទី៣÷ **វឌ្ឍនភាពតាមផ្នែក**→ វឌ្ឍនភាពតាមគោលបំណង គុណនឹងទម្ងន់តាមតាមគោលបំណង → បូកសរុបលទ្ធផលតាមគោលបំណងនៃផ្នែក

-ទី៤÷ **វឌ្ឍនភាពកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ** → វឌ្ឍនភាពតាមផ្នែក គុណនឹងទម្ងន់តាមផ្នែក → បូកសរុបផ្នែកទាំង ៥ ។

**រូបមន្តនៃការដាក់ពិន្ទុ**

ពិន្ទុសម្រេចបាន = ទម្ងន់ X លទ្ធផលសម្រេចបាន

| ពិន្ទុសម្រេចបាន | និទ្ទេស |
|---|---|
| ៩៦% - ១០០% | ល្អប្រសើរ |
| ៨៦% - ៩៥% | ល្អ |
| ៧១% - ៨៥% | ល្អបង្គួរ |
| ៦១% - ៧០% | មធ្យម |
| 0% -៦0% | ខ្សោយ |

២. ក្រុមការងាររៀបចំរបាយការណ៍ត្រួតពិនិត្យ និងវាយតម្លៃវឌ្ឍនភាពកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៃ អ.គ.ហ. ក៏បានចុះជួបពិភាក្សាជាមួយក្រសួងចំនួនអនុវត្តចរិកម្មវិធី ដោយក្នុងនោះ រួមមាន ១. ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ, ២.ក្រសួងអប់រំ យុវជន និងកីឡា, ៣.ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និង ៤.ក្រសួងមុខងារសាធារណៈ និងរដ្ឋបាលរាជធានីភ្នំពេញនិងកំពង់ស្ពឺ ។

៣. ដើម្បីបូកសរុបវឌ្ឍនភាពជារួមនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ អ.គ.ហ. បានប្រើប្រាស់ឧបករណ៍ក្របខ័ណ្ឌ PEFA ឆ្នាំ២០១១ សម្រាប់ធ្វើការវាស់ស្ទង់អំពីសុខភាពនៃប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ ការប្រើប្រាស់ក្របខ័ណ្ឌ PEFA ឆ្នាំ២០១១ គឺដើម្បីឱ្យ អ.គ.ហ. មានមូលដ្ឋានធ្វើការប្រៀបធៀបបានជាមួយរបាយការណ៍ PEFA ឆ្នាំ២០១៥ ដែលរៀបចំឡើងដោយ អ.គ.ហ. សហការជាមួយជំនាញការអន្តរជាតិ ។

## ១.២. វឌ្ឍនភាពនៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ប្រចាំឆ្នាំ ២០១៧

### ១.២.១. លទ្ធផលនៃការអនុវត្តក្របខ័ណ្ឌសូចនាករសមិទ្ធកម្មសហភាពអឺរ៉ុប

តាមរយៈការវាយតម្លៃបឋមប្រចាំឆ្នាំ២០១៧ គឺបង្ហាញថា គ្រប់គោលដៅសូចនាករសមិទ្ធកម្មគន្លឹះឆ្នាំ២០១៧ សម្រេចបានតាមគោលដៅកំណត់ ដូចមានបង្ហាញក្នុងតារាងខាងក្រោម។

តារាង 2: លទ្ធផលនៃការអនុវត្តក្របខ័ណ្ឌសូចនាករសមិទ្ធកម្មសហភាពអឺរ៉ុប

| ល.រ | លទ្ធផលចុងក្រោយ | អង្គភាពទទួលខុសត្រូវ | សូចនាករឆ្នាំ២០១៧ | លទ្ធផលសម្រេចបាន |
|---|---|---|---|---|
| ១ | កែលម្អគុណភាពស្ថិតិជាតិ | NIS | ស្ថិតិគណនេយ្យជាតិឆ្នាំ ២០១៦ ត្រូវបានផ្សព្វផ្សាយក្នុងខែតុលា ឆ្នាំ២០១៧ | ***សម្រេចបាន ១០០%:*** ស្ថិតិគណនេយ្យជាតិឆ្នាំ ២០១៦ ត្រូវបានផ្សព្វផ្សាយនៅថ្ងៃទី២៥ ខែតុលា ឆ្នាំ ២០១៧ ។[2] |
| ២ | កែលម្អប្រព័ន្ធព័ត៌មានវិទ្យាគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ | FMWG | ១. ប្រព័ន្ធ FMIS ផលិតរបាយការណ៍ស្រប តាមស្តង់ដារ IPSAS សម្រាប់របាយការណ៍ហិរញ្ញវត្ថុរដ្ឋាភិបាលឆ្នាំ ២០១៦ | ***សម្រេចបាន ១០០% :*** បានបញ្ចប់ការកសាងរបាយការណ៍ IPSAS (1) R30_IPSAS Budget Expenditure, (2) R29_IPSAS Budget Revenue និង (៣) R09_IPSAS Cash Flow Statement ព្រមទាំងបានធ្វើតេស្តសាកល្បងដោយអគ្គនាយកដ្ឋានរតនាគារជាតិ សម្រាប់របាយការណ៍ឆ្នាំ២០១៦ ។ |
| | | | ២. ឧបករណ៍តម្រូវការ និងអជ្ញាប័ណ្ណសម្រាប់ប្រព័ន្ធ FMIS ដំណាក់កាលទី២ ត្រូវបានដាក់ដេញថ្លៃ | ***សម្រេចបាន ១០០% :*** ការដេញថ្លៃលើកញ្ចប់ផ្គត់ផ្គង់ឧបករណ៍សម្រាប់អ្នកប្រើប្រាស់ចុងក្រោយនិងកញ្ចប់ផ្គត់ផ្គង់ហេដ្ឋារចនាសម្ព័ន្ធ WAN/LAN ត្រូវបានបញ្ចប់ ។ កញ្ចប់ Bandwidth នឹងប្រកាសដាក់ដេញថ្លៃនៅក្នុងសប្តាហ៍ទី៣ ឬ ទី៤ ខែតុលា ឆ្នាំ ២០១៧ ។ រីឯ កញ្ចប់ DATA Center ត្រូវបានរៀបចំឯកសារដេញថ្លៃរួចរាល់។ |

[2] តំណរភ្ជាប់ទាញយកស្ថិតិគណនេយ្យជាតិឆ្នាំ ២០១៦ https://www.nis.gov.kh/nis/NA/NA2016_Tab.htm

| ល.រ | លទ្ធផលចុងក្រោយ | អង្គភាពទទួលខុសត្រូវ | សូចនាករឆ្នាំ២០១៧ | លទ្ធផលសម្រេចបាន |
|---|---|---|---|---|
| ៣ | ពង្រឹងសុក្រឹតភាព និងតម្លាភាពថវិកា នៃការផ្ទេរថវិកាទៅថ្នាក់ក្រោមជាតិ | អគ្គ.ហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ | ចំណូលថវិការដ្ឋបាលក្រុង-ស្រុក និងរដ្ឋបាលឃុំសង្កាត់នៃខេត្ត ត្រូវបានបង្កើនតាមរយៈការចែករំលែកចំណូលសារពើពន្ធរបស់រដ្ឋបាលខេត្ត ។ នៅឆ្នាំ២០១៨ យ៉ាងតិច ៣% នៃចំណូលសារពើពន្ធរបស់រដ្ឋបាលខេត្តត្រូវបានចែករំលែកជូនរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងយ៉ាងតិច ១% នៃចំណូលសារពើពន្ធរបស់រដ្ឋបាលខេត្តត្រូវបានចែករំលែកជូនរដ្ឋបាលឃុំសង្កាត់នៃខេត្ត ។ | *សម្រេចបាន ១០០%:*<br><br>ប្រកាសស្តីពីការបែងចែកចំណូលសារពើពន្ធរបស់រាជធានី ខេត្ត នឹងត្រូវចែករំលែកជូនរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងឃុំសង្កាត់ត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្តនៅថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៧ ។<br><br>អនុលោមប្រកាសនេះ ៣% និង ១% នៃចំណូលសារពើពន្ធរបស់រាជធានី ខេត្ត នឹងត្រូវចែករំលែកជូនរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់។ |
| ៤ | ពង្រឹងតម្លាភាពថវិកា | អ.ថ. | របាយការណ៍ត្រួតពិនិត្យថវិកាប្រចាំឆមាសត្រូវបានផ្សព្វផ្សាយលើគេហទំព័រមិនយឺតជាង ៣ខែ ក្រោយពេលរបាយការណ៍ត្រូវបានបញ្ចប់ | *សម្រេចបាន ១០០% :*<br>បានផ្សព្វផ្សាយរបាយការណ៍ត្រួតពិនិត្យថវិកាពាក់កណ្តាលឆ្នាំលើគេហទំព័ររបស់អគ្គនាយកដ្ឋានថវិកា នៅថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០១៧ ។[3] |
| ៥ | បង្កើនការអនុវត្តថវិកាឆ្ពោះទៅសមិទ្ធកម្ម | អ.ថ. | យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ២០១៨-២០២៥ ត្រូវបានរៀបចំ និងអនុម័ត | *សម្រេចបាន ១០០% :*<br>យុទ្ធសាស្ត្រ នៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ២០១៨-២០២៥ ត្រូវបានគណៈរដ្ឋមន្ត្រីពិនិត្យ និងអនុម័ត នៅថ្ងៃទី១២ ខែមករា ឆ្នាំ២០១៨ |

[3] តំណរភ្ជាប់ទាញយករបាយការណ៍ត្រួតពិនិត្យថវិកាពាក់កណ្តាលឆ្នាំ២០១៧
https://docs.google.com/a/servingweb.com/viewer?url=http://gdb.mef.gov.kh/items/Mid-Year_Review_Budget_to_N_A.pdf

| ល.រ | លទ្ធផលចុងក្រោយ | អង្គភាពទទួលខុសត្រូវ | សូចនាករឆ្នាំ២០១៧ | លទ្ធផលសម្រេចបាន |
|---|---|---|---|---|
| ៦ | ពង្រឹងប្រសិទ្ធភាព និងមុខងារសវនកម្ម | អ.ស.ក. | ក្រុមការងារត្រួតពិនិត្យដោយអគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង ក្នុងអង្គភាពសវនកម្មផ្ទៃក្នុង យ៉ាងហោចណាស់ ៥០%នៃចំណាយចរន្តរដ្ឋាភិបាលដោយរួមបញ្ចូលក្រសួងអប់រំ យុវជន និងកីឡា | *សម្រេចបាន ១០០%:* បានត្រួតពិនិត្យមុខងារក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ, ក្រសួងសុខាភិបាល និងក្រសួងអប់រំ យុវជន និងកីឡា, ក្រសួងការពារជាតិ, ទីស្តីការគណៈរដ្ឋមន្ត្រី និងក្រសួងមហាផ្ទៃ ព្រមទាំងបានរៀបចំជារបាយការណ៍ដាក់ជូនថ្នាក់ដឹកនាំពិនិត្យនិងសម្រេច។ |
| ៧ | ពង្រឹងការប្រមូលចំណូល | អ.គ.ប. | ចំណូលចរន្តប្រចាំឆ្នាំកើនឡើងជាពិន្ទុភាគរយនៃ ផ.ស.ស | *សម្រេចបាន១០០% :* កំណើនចំណូលចរន្តសម្រេចបាន១,០៤ ពិន្ទុភាគរយនៃ ផ.ស.ស (ឆ្នាំ២០១៦=១៨,៨៥% នៃ ផ.ស.ស និង ឆ្នាំ២០១៧ = ១៩,៥៩% នៃ ផ.ស.ស.) |
| ៨ | បង្កើនតម្លាភាពលទ្ធកម្មសាធារណៈ | អគ្គ.លទ្ធកម្មសាធារណៈ | របាយការណ៍ត្រួតពិនិត្យលទ្ធកម្មសាធារណៈតាមក្រោយត្រូវបានផ្សព្វផ្សាយលើគេហទំព័រ អគ្គ.លទ្ធកម្មសាធារណៈ | *សម្រេចបាន ១០០%:* បានរបាយការណ៍ត្រួតពិនិត្យលទ្ធកម្មសាធារណៈ តាមក្រោយលើគេហទំព័ររបស់ អគ្គ.លទ្ធកម្មសាធារណៈ នៅថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១៧ ។[4] |

ដើម្បីឱ្យការអនុវត្តគោលដៅសូចនាករសមិទ្ធកម្មឆ្នាំ២០១៨ ប្រកបដោយជោគជ័យ, ក្រុមការងារបច្ចេកទេស ដែលដឹកនាំដោយ អ.គ.ហ. បានត្រួតពិនិត្យលើគោលដៅសូចនាករសមិទ្ធកម្មឆ្នាំ២០១៨ និងបានកំណត់ដើម្បីស្នើសុំឱ្យមានកែសម្រួល ដូចមានក្នុងតារាងដូចខាងក្រោម ។

**តារាង 3: ការកែសម្រួលគោលដៅសូចនាករសមិទ្ធកម្មគន្លឹះឆ្នាំ២០១៨**

| ល.រ | លទ្ធផលចុងក្រោយ | អង្គភាពទទួលខុសត្រូវ | គោលដៅសូចនាករសមិទ្ធកម្មគន្លឹះឆ្នាំ២០១៨ ក្នុងកិច្ចព្រមព្រៀង | គោលដៅសូចនាករសមិទ្ធកម្មគន្លឹះឆ្នាំ២០១៨ (កែសម្រួលថ្មី) |
|---|---|---|---|---|
| ៤ | ពង្រឹងតម្លាភាពថវិកា | អគ្គ.រតនាគារជាតិ | របាយការណ៍ប្រចាំឆ្នាំត្រូវបានផ្សព្វផ្សាយ ក្រោយពេលរបាយការណ៍ត្រូវបានបញ្ចប់ | ច្បាប់ស្តីពីការទូទាត់ថវិការបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៧ ត្រូវបានផ្សព្វផ្សាយលើគេហទំព័រ |

[4] តំណរភ្ជាប់ទាញយករបាយការណ៍ត្រួតពិនិត្យលទ្ធកម្មសាធារណៈតាមក្រោយប្រចាំឆ្នាំ http://gdpp.gov.kh/law_regulation

| ល.រ | លទ្ធផលចុងក្រោយ | អង្គភាពទទួលខុសត្រូវ | គោលដៅសូចនាករ សមិទ្ធកម្មគន្លឹះឆ្នាំ២០១៨ ក្នុងកិច្ចព្រមព្រៀង | គោលដៅសូចនាករ សមិទ្ធកម្មគន្លឹះឆ្នាំ២០១៨ (កែសម្រួលថ្មី) |
|---|---|---|---|---|
| | | | | អគ្គនាយកដ្ឋានរតនាគារជាតិមិនលើសពី ១ ខែ បន្ទាប់ពីមានព្រះរាជក្រមប្រកាសឱ្យប្រើច្បាប់ស្តីពីការទូទាត់ថវិការបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៧ |
| ៥ | បង្កើនការអនុវត្តថវិកាឆ្ពោះទៅសមិទ្ធកម្ម | អ.ថ. | ក្រសួងអនុវត្តថវិកាកម្មវិធីត្រូវបានត្រួតពិនិត្យនិងផ្តល់អនុសាសន៍សម្រាប់អនុវត្តថវិកាកម្មវិធី | គោលការណ៍ណែនាំស្តីពីការរៀបចំថវិកាសមិទ្ធកម្មត្រូវបានរៀបចំនិងអនុម័តឱ្យមុនដំណាច់ឆ្នាំ២០១៨ |
| ៦ | ពង្រឹងប្រសិទ្ធភាពនិងមុខងារសវនកម្ម | អគ្គ.សវនកម្មផ្ទៃក្នុង | យ៉ាងហោចណាស់ ៧៥% នៃផែនការសវនកម្មគឺត្រូវបានបំពេញ។ ទន្ទឹមនេះ ត្រូវមានភ័ស្តុតាងបង្ហាញនូវប្រសិទ្ធភាព និងភាពទាន់ពេលវេលាតាមដាននៃលទ្ធផលរកឃើញដោយសវនកម្មផ្ទៃក្នុងពីថ្នាក់ដឹកនាំ។ | ការត្រួតពិនិត្យលើមុខងាររបស់អង្គភាពសវនកម្មផ្ទៃក្នុងនៃក្រសួង ស្ថាប័ន ដោយអគ្គនាយដ្ឋានសវនកម្មផ្ទៃក្នុងនៃ កសហវ ដែលចំនួនក្រសួង ស្ថាប័នត្រូវបានត្រួតពិនិត្យមុខងារសវនកម្មផ្ទៃក្នុង គឺគ្របដណ្តប់យ៉ាងហោចណាស់ ៧០% នៃចំណាយចរន្តរដ្ឋាភិបាលដោយរួមបញ្ចូលទាំងក្រសួងអប់រំ យុវជន និងកីឡា។ |
| ៨ | បង្កើនតម្លាភាពលទ្ធកម្មសាធារណៈ | អគ្គ.លទ្ធកម្មសាធារណៈ | ទិន្នន្នានៃលទ្ធកម្មសាធារណៈត្រូវបានបង្កើត និងស្ថិតិលទ្ធកម្មត្រូវបានផ្សព្វផ្សាយលើគេហទំព័ររបស់អគ្គ.លទ្ធកម្មសាធារណៈ។ | សេចក្តីព្រាងចុងក្រោយស្តីពីយុទ្ធសាស្ត្រកែទម្រង់ប្រព័ន្ធលទ្ធកម្មសាធារណៈឆ្នាំ២០១៩-២០២៥ ត្រូវបានរៀបចំនិងដាក់ជូនឯកឧត្តមបណ្ឌិតសភាចារ្យទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី កសហវ យ៉ាងយូរត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨។ |

### ១.២.២. វឌ្ឍនភាពនៃការអនុវត្តផែនការសកម្មភាពរួមឆ្នាំ២០១៧-២០២០

### ក.វឌ្ឍនភាពនៃការអនុវត្តផែនការសកម្មភាពរួម របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

តាមរយៈការត្រួតពិនិត្យវឌ្ឍនភាព នៃអនុវត្តផែនការសកម្មភាពប្រចាំឆ្នាំ២០១៧ បានបង្ហាញថា ផ្នែកទី១ "បន្តពង្រឹងភាពជឿទុកចិត្តនៃថវិកា" សម្រេចបាន ៩១%, ផ្នែកទី២ "ពង្រឹងគណនេយ្យភាពហិរញ្ញវត្ថុ" សម្រេចបាន ៩៤%, ផ្នែកទី៣ "ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ" សម្រេចបាន ៩៤% និងផ្នែកទី៤ "គណនេយ្យភាពសមិទ្ធកម្ម" សម្រេចបាន ៩២% និងផ្នែកទី៥ "ការគាំទ្រកម្មវិធីកែទម្រង់ប្រកបដោយជោគជ័យ និងចីរភាព" សម្រេចបាន ៩២% ។

ដ្យាក្រាម 1: ភាគរយសម្រេចបានតាមគោលបំណងនៃផ្នែកនីមួយៗនៃ CAP3




ប្រភព÷ ក្រុមការងារនៃ អ.គ.ហ.

### ក.១. ផ្នែកទី១ "បន្តពង្រឹងភាពជឿទុកចិត្តនៃថវិកា"

ភាពជឿទុកចិត្តនៃថវិកាសំដៅសមត្ថភាពរបស់រដ្ឋាភិបាលក្នុងការអនុវត្តថវិកា ដើម្បីសម្រេចបាននូវរបៀបវារៈគោលនយោបាយរបស់រាជរដ្ឋាភិបាល ។ ភាពជឿទុកចិត្តនៃថវិកា គឺត្រូវបន្តពង្រឹងអនុវត្តនៅក្នុងកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដំណាក់កាលទី៣ ដែលមានគោលដៅចម្បងពង្រឹងប្រព័ន្ធថវិកាឱ្យរឹងមាំ និងស្ថិរភាពជាពិសេស ផ្តោតការយកចិត្តទុកដាក់ខ្ពស់ រួមមាន (១). ការអនុវត្តចំណូល និងចំណាយប្រចាំត្រីមាសមានភាពរលូន និងអាចប៉ាន់ស្មានបាន (កម្រិតលម្អៀងនៃការអនុវត្តមិនលើសពី +/-៥% ធៀបទៅនឹងកម្មវិធីចំណូល-ចំណាយ) និង (២). ការគ្រប់គ្រងបំណុលត្រូវសង និងបំណុលត្រូវទារក្នុងឆ្នាំប្រកបដោយប្រសិទ្ធភាព ។

តាមរយៈលទ្ធផលផ្នែកទី១ នេះ ភាពជឿទុកចិត្តនៃថវិកា គឺនៅតែរក្សាបានជាសារវន្ត។ ក្នុងន័យនេះ កំណើននៃចំណូលចរន្តសម្រេចបានលើសពីគោលដៅ ០,៥ ពិន្ទុភាគរយនៃ ផ.ស.ស. ដោយក្នុងឆ្នាំ២០១៧ មានកំណើន ១,០៤ ពិន្ទុភាគរយ នៃ ផ.ស.ស. ។ រីឯចំណាយស្ថិតក្នុងរង្វង់ +/-៥% នៃច្បាប់ថវិកា ដោយឆ្នាំ២០១៧ ការអនុវត្ត

ថវិកាជាតិសម្រេចបាន ៩៨,៧%នៃច្បាប់ថវិកា ។ ទន្ទឹមនេះ ការគ្រប់គ្រងសាច់ប្រាក់ គឺស្ថិតក្នុងស្ថានភាពល្អប្រសើរ ពោលគឺមិនមានការកកើតឡើងវិញនៃបំណុលកកស្ទះ ។

ដ្យាក្រាម 2: ការកៀរគរចំណូលក្នុងស្រុក និងកំណើនចំណូលចរន្តឆ្នាំ២០១៣-២០១៧







ប្រភព÷ អគ្គនាយកដ្ឋានរតនាគារជាតិ និងអគ្គនាយកដ្ឋានគោលនយោបាយ

ទន្ទឹមនេះ អង្គភាពពាក់ព័ន្ធក្រោមឱវាទ កសហវ ត្រូវពន្លឿនរៀបចំបញ្ចប់ការងារដែលនៅសេសសល់ក្នុងឆ្នាំ ២០១៧ រួមមាន (១). ការរៀបចំម៉ូដែលព្យាករចំណូលរបស់គយ និងទម្រង់ព្យាករណ៍ចំណូលមិនមែនសារពើពន្ធ, (២). ការរៀបចំបញ្ចប់សេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ, (៣). រៀបចំអនុក្រឹត្យស្តីពីគោលការណ៍ណែនាំរួមសម្រាប់គ្រប់គ្រងគម្រោងវិនិយោគសាធារណៈ និង (៤). ការពន្លឿនការរៀបចំយុទ្ធសាស្ត្រគោលនយោបាយស្តីពីការបង្ក្រាបអំពើរត់គេចពន្ធ និងបទល្មើសឆ្លងដែនពាក់ព័ន្ធនឹងគយ ។

វឌ្ឍនភាពតាមគោលបំណងនៃផ្នែកទី១ "បន្តពង្រឹងភាពជឿទុកចិត្តនៃថវិកា" បង្ហាញដូចតទៅ÷

### គោលបំណង ១១ "បន្តពង្រឹងការគ្រប់គ្រងចំណូលនិងការអនុវត្តផែនការប្រមូលចំណូល"

ដើម្បីពង្រឹងប្រសិទ្ធភាពនៃការគ្រប់គ្រងចំណូល (ចំណូលសារពើពន្ធ និងចំណូលមិនមែនសារពើពន្ធ) ការរៀបចំគោលនយោបាយចំណូល និងយុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យម គឺជាកត្តាគន្លឹះដើម្បីធានានូវការលុបបំបាត់ឱនភាពសាច់ប្រាក់ទាំងស្រុង, ភាពរលូននៃលំហូរចំណូល និងអាចប៉ាន់ប្រមាណបាន ។

ជាលទ្ធផលនៃការប្រមូលចំណូលឆ្នាំ២០១៧ បង្ហាញថា កំណើនចំណូលចរន្តកើនឡើងប្រមាណ ១,០៤ ពិន្ទុភាគរយនៃ ផ.ស.ស.។ ចំណូលនេះ កើនឡើងដោយហេតុថា កំណើនសេដ្ឋកិច្ចដ៏រឹងមាំ, ការកែសម្រួលអត្រាពន្ធមួយចំនួន និងជាពិសេសការពង្រឹងប្រសិទ្ធភាពរដ្ឋបាលសារពើពន្ធ ដើម្បីប្រមូលចំណូលឱ្យអស់លទ្ធភាព ។ ជាមួយគ្នានេះ បានពង្រឹងការតាមដានការអនុវត្តយុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យមឆ្នាំ២០១៤-២០១៨ ដោយបានរៀបចំរបាយការណ៍វឌ្ឍនភាពប្រចាំឆមាស និងប្រចាំឆ្នាំ ។

ទន្ទឹមនេះ ដើម្បីបម្រើសេវាពន្ធដារឱ្យកាន់ល្អប្រសើរក្នុងការរួមចំណែកបង្កើនវប្បធម៌បង់ពន្ធ អគ្គនាយកដ្ឋានពន្ធដារ (អ.ព.ដ.) បានរៀបចំសិក្ខាសាលាជាបន្តបន្ទាប់ស្តីពីវប្បធម៌នៃការបង់ពន្ធ, កាតព្វកិច្ចពន្ធលើប្រាក់ចំណូល

និងរបៀបបំពេញលិខិតប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ, ការពង្រឹង ការអនុវត្តកាតព្វកិច្ចរបស់ភ្នាក់ងារសេវាកម្មពន្ធដារ សំដៅធ្វើយ៉ាងណាឱ្យអ្នកជាប់ពន្ធ គោរពឱ្យបានខ្ជាប់ខ្ជួននូវការអនុវត្តច្បាប់ស្តីពីសារពើពន្ធ និងចៀសវាងកំហុសឆ្គងដោយប្រការណាមួយ ដែលអាចនាំឱ្យទៅដល់ការផាកពិន័យ និងទោសទណ្ឌផ្សេងៗ ពីរដ្ឋបាលសារពើពន្ធ។

បន្ថែមពីនេះ អ.ព.ដ. បានរៀបចំប្រព័ន្ធព័ត៌មានវិទ្យាដើម្បីសម្រួលដល់អ្នកជាប់ពន្ធ រួមមាន ការដាក់ឱ្យដំណើរការនូវការដាក់លិខិតប្រកាស និងបង់ប្រាក់ពន្ធតាមប្រព័ន្ធអេឡិកត្រូនិក (E-PAYMENT), ដាក់ឱ្យអនុវត្តប្រព័ន្ធ Call Center ដើម្បីផ្តល់ការពិគ្រោះយោបល់ និងសេវាអ្នកបង់ពន្ធតាមរយៈទូរសព្ទ Hotline: ១២៧៧ និង ០២៣ ៨៨៦ ៦៦៨ ព្រមទាំងកម្មវិធី Tax Live Chat ដែលអាចទាញយកបានពី iOS ឬ Android ដាក់ក្នុងទូរសព្ទស្មាតហ្វូន និងគ្រោងនឹងដាក់ឱ្យដំណើការប្រព័ន្ធ E-filling នាពេលឆាប់ៗនេះ។ កសហវ បានលុបបំបាត់របបម៉ៅការ និងរបបបំព្រួញ ហើយសព្វថ្ងៃនេះ គឺមានតែរបបស្វ័យប្រកាស។ នៅឆ្នាំ២០១៧ កសហវ បានចេញប្រកាសលេខ ០២៥ សហវ.ប្រក.អពដ ស្តីពីការសម្រួលចំណាត់ថ្នាក់អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស។ ការកែសម្រួលចំណាត់ថ្នាក់អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស គឺដើម្បីគ្រប់គ្រងនិងប្រមូលចំណូលពន្ធគ្រប់ប្រភេទតាមរបស់ស្វ័យប្រកាស ដែលក្នុងគោលបំណងជំរុញចុះបញ្ជីអ្នកជាប់ពន្ធធំ មធ្យម និងតូច ព្រមទាំងបានចុះធ្វើការអង្កេតសហគ្រាសនៅតាមបណ្តាខណ្ឌនៃរាជធានីភ្នំពេញ និងខេត្តអាទិភាព រួមមាន សៀមរាប, បាត់ដំបង, ព្រះសីហនុ, កំពង់ចាម, កំពង់ស្ពឺ និងកណ្តាល ។

ដើម្បីបំពេញកង្វះចន្លោះនៃលិខិតបទដ្ឋានគតិយុត្ត និងអនុវត្តគោលនយោបាយរបស់រដ្ឋាភិបាល អ.ព.ដ. បានខិតខំរៀបចំលិខិតបទដ្ឋានគតិយុត្តបន្ថែម ដោយក្នុងនោះ រួមមាន÷

១. អនុក្រឹតស្តីពីការលើកលែងពន្ធ និងអនុគ្រោះពន្ធប្រថាប់ត្រា ត្រូវបានអនុម័ត និងដាក់ឱ្យអនុវត្ត
២. អនុក្រឹតស្តីពីការលើកទឹកចិត្តផ្នែកពន្ធដារសម្រាប់សហគ្រាសធុនតូច និងមធ្យម ចំពោះការចុះបញ្ជីពន្ធដារដោយស្ម័គ្រចិត្ត ត្រូវបានអនុម័ត និងដាក់ឱ្យអនុវត្ត
៣. ប្រកាសស្តីពីលក្ខណៈវិនិច្ឆ័យនៃការកាន់បញ្ជិកាគណនេយ្យមិនត្រឹមត្រូវនិងនីតិវិធីក្នុងការបង់ពន្ធអប្បបរមា ត្រូវបានដាក់ឱ្យអនុវត្ត
៤. ប្រកាសស្តីពីវិធាន និងនីតិវិធី នៃការប្រមូលពន្ធលើប្រាក់ចំណូលសម្រាប់សាខាក្រុមហ៊ុនបរទេស ត្រូវបានដាក់ឱ្យអនុវត្ត
៥. សៀវភៅណែនាំស្តីពីសវនកម្មលើវិស័យទូរគមនាគមន៍ និងសៀវភៅណែនាំស្តីពីសវនកម្មលើលើវិស័យដឹកជញ្ជូន ត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត
៦. បទប្បញ្ញត្តិស្តីពីពន្ធលើប្រតិបត្តិការប្រេងកាតនិងធនធានរ៉ែត្រូវបានរៀបចំ ពិនិត្យសម្រេចដោយ កសហវ និងបញ្ជូនទៅគណៈរដ្ឋមន្ត្រី
៧. សេចក្តីព្រាងប្រកាសស្តីពីការអនុវត្តការប្រមូលពន្ធលើប្រតិបត្តិការប្រេងកាត និងធនធានរ៉ែ ត្រូវបានពិនិត្យនិងសម្រេចកម្រិត អ.ព.ដ.
៨. ប្រកាសស្តីពីវិធាននិងនីតិវិធីនៃការបង់ពន្ធលើប្រាក់ចំណូលសម្រាប់សហគ្រាសធានារ៉ាប់រង ត្រូវបានរៀបចំ។

ជាមួយគ្នានេះ ដើម្បីបង្កើនវប្បធម៌បង់ពន្ធ អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជាបានអនុវត្ត រួមមាន÷ (១). ធ្វើការផ្សព្វផ្សាយគ្រប់លិខិតបទដ្ឋានគតិយុត្តិលើគេហទំព័ររបស់ www.gdce.gov.kh ដែលអាចស្វែងរកបាននូវលិខិត

បទដ្ឋានគតិយុត្ត (ច្បាប់ អនុក្រឹត្យ ប្រកាស សារាចរ) ជាភាសាខ្មែរនិងភាសាអង់គ្លេស, (២). រៀបចំកិច្ចប្រជុំភាពជាដៃគូរវាងគយ និងវិស័យឯកជន ដែលរៀបចំឡើងក្នុង១ លើក ១ឆ្នាំ ហើយតាមរយៈយន្តការនេះ គឺអាចដោះស្រាយកង្វល់ និងបញ្ហាប្រឈមរបស់ធុរជន, (៣). បង្កើនសមត្ថភាពបន្ថែមដល់ជើងសារគយនឹងត្រូវពង្រឹងសមត្ថភាពបន្ថែម និង (៤). បង្កើនភាពងាយស្រួលដល់ធុរជនលើការបង់ប្រាក់ ដោយចាប់ផ្តើមសិក្សា និងបង្កើតប្រព័ន្ធ E-Payment ។

បន្ថែមពីនេះ សព្វថ្ងៃនេះការបង្កើតក្រុមការងារត្រួតពិនិត្យការបញ្ចេញគយ (Post Clearance Audit-PCA) គឺមាន ៦ ក្រុម ដោយធ្វើការត្រួតពិនិត្យសំខាន់លើរោងចក្រកាត់ដេរ និងវាយនភ័ណ្ឌនៅកម្ពុជា។ ជាទិសដៅ ក្រុមការងារ PCA នេះ នឹងបង្កើតរហូតដល់ ៩ ក្រុម ដើម្បីធ្វើការពង្រីកវិសាលភាពដល់ក្រុមហ៊ុននីអារហ័ណ និងអារហ័ណ។ ការពង្រឹងការចុះត្រួតពិនិត្យនេះ គឺដើម្បីពង្រឹងអនុលោមភាពផងដែរ។ ដើម្បីពង្រឹងសមត្ថភាពបន្ថែម ក្រុមការងារ PCA ទទួលបានការបណ្តុះបណ្តាលពីជំនាញការពីទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន (JICA) ។

ដោយឡែក ដើម្បីពង្រឹងការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ អគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ (អ.ទ.ច.) បានជំរុញឱ្យគ្រប់អង្គភាពប្រមូលចំណូលមិនមែនសារពើពន្ធគឺប្រើប្រាស់បង្កាន់ដៃបង់ចំណូល និងរៀបចំប្រកាសអន្តរក្រសួង ដើម្បីកំណត់លើតំលៃសេវាសាធារណៈ និងគ្រប់គ្រងចំណូលប្រកបដោយតម្លៃភាព ។ ក្នុងន័យនេះ អ.ទ.ច. បាននិងកំពុងរៀបចំប្រព័ន្ធព័ត៌មានវិទ្យាគ្រប់គ្រងការប្រមូលចំណូលមិនមែនសារពើ-ពន្ធ និងដាក់ឱ្យអនុវត្តជាដំណាក់កាលចាប់ពីត្រីមាសទី១ ឆ្នាំ២០១៨ ។

ទន្ទឹមនេះ ការងារពាក់ព័ន្ធនឹងការគ្រប់គ្រងការប្រមូលចំណូលមិនមែនពន្ធ អ.ទ.ច. និងអគ្គនាយកដ្ឋានឧស្សា-ហកម្មហិរញ្ញវត្ថុ សម្រេចបានលទ្ធផល ដូចតទៅ÷

១. សេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងល្បែងពាណិជ្ជកម្មត្រូវបានដាក់ប្រជុំឆ្លងជាមួយអន្តរក្រសួង
២. សេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ ត្រូវបានរៀបចំតាក់តែងជាសេចក្តីព្រាងចុងក្រោយនៃកម្រិតបច្ចេកទេស
៣. សេចក្តីព្រាងអនុក្រឹត្យស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ ត្រូវបានរៀបចំតាក់តែងជាសេចក្តីព្រាងចុងក្រោយនៃកម្រិតបច្ចេកទេស ។

ទោះបីជាយ៉ាងណាក៏ដោយ ការព្យាករចំណូលពន្ធនិងមិនមែនពន្ធ អង្គភាពប្រមូលចំណូលមិនទាន់មានម៉ូដែលព្យាករណ៍ដែលប្រកបដោយលក្ខណៈវិទ្យាសាស្ត្រនៅឡើយ លើកលែងតែអគ្គនាយកដ្ឋានពន្ធដារ រីឯការព្យាករសព្វថ្ងៃនេះ គឺផ្អែកលើប្រវត្តិនៃទិន្នន័យតែប៉ុណ្ណោះ ។ ដើម្បីដោះស្រាយបញ្ហានៃការព្យាករនេះ អគ្គនាយកដ្ឋានគោលនយោបាយគួរសហការជាមួយអង្គភាពប្រមូលចំណូល ដើម្បីធ្វើការរៀបចំ និងបណ្តុះបណ្តាលលើជំនាញព្យាករណ៍នេះ ដោយត្រូវរៀបចំបញ្ចប់នៅក្នុងឆ្នាំ២០១៨ ។

### គោលបំណង ១២ "បន្តពង្រឹងការគ្រប់គ្រងបំណុល"

ការគ្រប់គ្រងបំណុលសាធារណៈ សំដៅដល់ការគ្រប់គ្រងលើរាល់ប្រតិបត្តិការរបស់រដ្ឋាភិបាលពាក់ព័ន្ធនឹងការខ្ចីប្រាក់ពីគេ, ការឱ្យប្រាក់គេខ្ចី, ការបោះផ្សាយនិងការដាក់លក់មូលបត្ររដ្ឋ, ការបោះផ្សាយនិងដាក់លក់ប័ណ្ណរដ្ឋអធិបតេយ្យ, ការធានា, កាតព្វកិច្ចបំណុលជាយថាហេតុ, ការទូទាត់សេវាបំណុល, ការរៀបចំរចនាសម្ព័ន្ធបំណុលឡើងវិញ, ការគ្រប់គ្រងហានិភ័យ, ការវិនិយោគដោយប្រើអតិរេកសាច់ប្រាក់ ឬអតិរេកថវិកា និងប្រតិបត្តិការផ្សេងៗទៀត

ពាក់ព័ន្ធនឹងបំណុលសាធារណៈ ។ យោងទិន្នន័យរបស់ អគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងគ្រប់គ្រងបំណុល (អ.ស.ប.) ការគ្រប់គ្រងបំណុលសាធារណៈ (អនុបាតតម្លៃបច្ចុប្បន្ននៃបំណុលធៀបនឹង ផ.ស.ស.) បង្ហាញថា ២០,៦% នៃ ផ.ស.ស. (មិនរួមបញ្ចូលបំណុលមរតក) និង ២២,៨% នៃ ផ.ស.ស. (រួមបញ្ចូលបំណុលមរតក) ដែលទាបជាងកម្រិតហានិភ័យ ៤០% នៃ ផ.ស.ស. ។

ទន្ទឹមនេះ ដើម្បីពង្រឹងការគ្រប់គ្រង និងតម្លាភាពនៃបំណុលសាធារណៈ អ.ស.ប. បានផ្សព្វផ្សាយព្រឹត្តិបត្រស្ថិតិបំណុលសាធារណៈ លេខរៀងទី៣ និងទី៤ ។ បន្ថែមពីនេះ អ.ស.ប. បានរៀបចំសេចក្តីព្រាងទី២នៃស្តង់ដារនីតិវិធីប្រតិបត្តិការសម្រាប់ការគ្រប់គ្រងបំណុលសាធារណៈ, សេចក្តីព្រាងទី២ នៃរបាយការណ៍ ស្តីពីការវាយតម្លៃប្រតិបត្តិការនៃការគ្រប់គ្រងបំណុលសាធារណៈ, សេចក្តីព្រាងទី២ នៃប្រកាសស្តីពីគោលការណ៍ និងនីតិវិធីគ្រប់គ្រងការគាំទ្រហិរញ្ញវត្ថុ និងការធានារបស់រដ្ឋលើគម្រោងវិនិយោគសាធារណៈ តាមយន្តការភាពជាដៃគូរវាងរដ្ឋនិងឯកជន និងសេចក្តីព្រាងបឋមយុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុលសាធារណៈឆ្នាំ២០១៩-២០២៣ ។

### គោលបំណង ១៣ "ពង្រឹងការគ្រប់គ្រងសាច់ប្រាក់ និង គណនី"

ការពង្រឹងការគ្រប់គ្រងសាច់ប្រាក់ និងគណនី មានគោលដៅអនុវត្តផែនការសាច់ប្រាក់ប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព ដែលរួមមានប្រសិទ្ធភាពនៃការអនុវត្តផែនការសាច់ប្រាក់ប្រកបដោយប្រសិទ្ធភាពជាប្រចាំត្រីមាស ប្រចាំខែ និងឈានទៅរកប្រចាំសប្តាហ៍និងថ្ងៃ, ការទូទាត់ប្រតិបត្តិការចំណូលចំណាយតាមប្រព័ន្ធធនាគារ, យន្តការប្រមូលផ្តុំបូកសរុបរបាយការណ៍អនុវត្តថវិការបស់ដៃគូអភិវឌ្ឍន៍ដែលនៅក្រៅប្រព័ន្ធរតនាគារជាតិ, ប្រព័ន្ធតាមដាន និងកត់ត្រាបំណុលកកស្ទះ និងការទូទាត់ថវិកាបុរេប្រទានទាន់ពេលវេលា ជាដើម ។

ដើម្បីពង្រឹងមុខងារគ្រប់គ្រងសាច់ប្រាក់ អគ្គនាយកដ្ឋានរតនាគារជាតិ បានពង្រឹងការរៀបចំរបាយការណ៍នៃការព្យាករលំហូរសាច់ប្រាក់រយៈពេល៣ខែ រំកិលត្រូវបានរៀបចំនិងកែលម្អ, ការព្យាករចំណូលនិងចំណាយត្រូវបានពង្រឹង និងកែលម្អឱ្យកាន់តែប្រសើរឡើង និងការបើកប្រាក់បៀវត្សតាមប្រព័ន្ធធនាគារ ។ ជាពិសេស បំណុលកកស្ទះត្រូវបានលុបបំបាត់ទាំងស្រុងផងដែរ ។ *បច្ចុប្បន្ននេះ ការងារពាក់ព័ន្ធនឹងការគ្រប់គ្រងគណនីធនាគារ គឺត្រូវបានពង្រឹង និងត្រូវបានក្លាយជាការងារប្រចាំថ្ងៃ ។*

ជាមួយគ្នានេះ ប្លង់គណនេយ្យសាធារណៈ ត្រូវបានផ្សព្វផ្សាយ និងសាកល្បងដាក់ឱ្យអង្គភាពចំនួនមួយ ដែលអនុវត្តថវិកាគម្រោងរបស់ដៃគូអភិវឌ្ឍន៍ និងធ្វើសមាហរណកម្មបំណុលនិងការធ្វើបច្ចុប្បន្នភាព និងកត់ត្រាតួលេខបំណុលនឹងត្រូវធ្វើឡើងតាមប្រព័ន្ធ FMIS ដោយសមាហរណកម្មជាមួយនឹងប្រព័ន្ធ ASYCUDA និង DMFAS ។

### គោលបំណង ១៤ "កែលម្អការអនុវត្តថវិកា និងពង្រឹងការអនុវត្តផែនការចំណាយ"

កម្មវិធីចំណូល-ចំណាយ គឺជាឧបករណ៍មួយ សម្រាប់ធ្វើការប៉ាន់ស្មានអំពីតម្រូវការថវិកាប្រចាំត្រីមាស ។ កម្មវិធីចំណូល-ចំណាយពុំទាន់ត្រូវបានចាត់ទុកជាការងារអាទិភាពនៅឡើយ ។

ទន្ទឹមនេះ កសហវ បាននិងកំពុងកំពុងត្រួតពិនិត្យឡើងវិញនៃច្បាប់ស្តីពីសម្បទាន និងច្បាប់ពាក់ព័ន្ធនឹងការអនុវត្តយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន ដើម្បីលើសំណើធ្វើវិសោធនកម្ម ឬសេចក្តីព្រាងច្បាប់ថ្មីស្តីពីយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន ព្រមយកចិត្តទុកលើការរៀបចំក្របខ័ណ្ឌវិនិយោគសាធារណៈ។

រីឯ ពាក់ព័ន្ធនឹងការរៀបចំក្របខ័ណ្ឌវិនិយោគសាធារណៈ ការងារមួយចំនួនមានវឌ្ឍនភាព គួរឱ្យកត់សម្គាល់ រួមមាន÷

១. សេចក្តីព្រាងនីតិវិធីការធ្វើអត្តសញ្ញាណកម្ម និងជ្រើសរើសគម្រោង តាមយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន ត្រូវបានរៀបចំ, ដាក់ឱ្យពិភាក្សា និងកែសម្រួល

២. សេចក្តីព្រាងនីតិវិធីមូលនិធិអភិវឌ្ឍន៍គម្រោងតាមយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជនត្រូវបានរៀបចំ ដាក់ឱ្យពិភាក្សា និងកែសម្រួល

៣. សេចក្តីព្រាងនីតិវិធី កិច្ចលទ្ធកម្មគម្រោងផ្នែកទី១ ផ្នែកទី២ និងផ្នែកទី៣ តាមយន្តការភាពជាដៃគូ រវាងរដ្ឋ និងឯកជន ត្រូវបានរៀបចំ ដាក់ឱ្យពិភាក្សាពិនិត្យ និងកែសម្រួល

៤. កិច្ចព្រមព្រៀងហិរញ្ញប្បទានផ្តល់ជំនួយបច្ចេកទេសសម្រាប់គម្រោង Strengthening Capacity for Improved Implantation of Externally-Funded Projects in Cambodia ត្រូវបានចុះហត្ថលេខារវាងធនាគារអភិវឌ្ឍន៍អាស៊ី ជាមួយ កសហវ

៥. សេចក្តីព្រាងលើកទី៤ នៃសារាចរណែនាំស្តីពីការរៀបចំ អនុវត្ត និងគ្រប់គ្រងការងារជួសជុលថែទាំហេដ្ឋា-រចនាសម្ព័ន្ធសាធារណៈហិរញ្ញប្បទានដោយថវិកាជាតិត្រូវបានរៀបចំ។

ប្រអប់ 2: ការងារត្រូវធ្វើបន្តនៃផ្នែកទី១ “បន្តពង្រឹងភាពជឿទុកចិត្តនៃថវិកា”

**ការងារត្រូវធ្វើបន្ត**

កសហវ នឹងរៀបចំក្របខ័ណ្ឌគោលនយោបាយពន្ធឆ្នាំ២០១៩-២០២៣ ដើម្បីជំរុញការកៀរគរចំណូលឱ្យអស់សក្តានុពល។ រីឯពាក់ព័ន្ធនឹងការរៀបចំលិខិតបទដ្ឋានគតិយុត្តវិញ កសហវ នឹងរៀបចំបញ្ចប់ច្បាប់ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ និងអនុក្រឹត្យស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ, ច្បាប់ស្តីពីការគ្រប់គ្រងល្បែងពាណិជ្ជកម្ម និងប្រកាសស្តីពីការផ្ទេរថ្លៃ (Transfer Pricing Guideline) ជាដើម ។

ជាមួយគ្នានេះ អ.ព.ដ នឹងបន្តធ្វើទំនើបកម្មលើប្រព័ន្ធគ្រប់គ្រងការប្រមូលពន្ធគ្រប់ប្រភេទ, អ.គ.រ. នឹងរៀបចំប្រព័ន្ធ E-Payment និង អ.ទ.ច. បានកំពុងរៀបចំបញ្ចប់ប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់គ្រប់គ្រងចំណូលមិនមែនសារពើពន្ធ ដាក់ឱ្យអនុវត្តជាជំហានៗ ចាប់ពីឆ្នាំ២០១៨ ។

ទន្ទឹមនេះ ប្រព័ន្ធពន្ធដារ និងប្រព័ន្ធ FMIS នឹងត្រូវធ្វើសន្ធានកម្ម ហើយប្រព័ន្ធ FMIS និងប្រព័ន្ធបៀវត្សនឹងត្រូវធ្វើសន្ធានកម្ម ផងដែរ។

### ក.២. ផ្នែកទី២ "ការពង្រឹងគណនេយ្យភាពហិរញ្ញវត្ថុ"

ការពង្រឹងគណនេយ្យភាពហិរញ្ញវត្ថុ សំដៅលើគណនេយ្យភាពដែលពាក់ព័ន្ធនឹងការរៀបចំប្រព័ន្ធ និងនីតិវិធីគ្រប់គ្រងថវិកា និងហិរញ្ញវត្ថុ ស្របតាមច្បាប់និងគោលការណ៍ហិរញ្ញវត្ថុសាធារណៈ។ ដើម្បីធានាបាននូវគណនេយ្យភាពហិរញ្ញវត្ថុ ការរៀបចំប្រព័ន្ធតាមដាន, កត់ត្រា និងការរៀបចំរបាយការណ៍ដោយភាពសុក្រឹត និងទាន់ពេលវេលា គឺជាកម្មវត្ថុ ចំបងសម្រាប់ជំហានទី២ ។

ក្រុមការងារ FMWG បានកំពុងដោះស្រាយបញ្ហាសេសសល់នៃប្រព័ន្ធ FMIS ដំណាក់កាលទី១ រួមមាន ការបិទបញ្ជីហិរញ្ញវត្ថុឆ្នាំ២០១៦, អ្នកប្រើប្រាស់មានភាពស្ទិតប្រព័ន្ធ FMIS, ការកែតម្រូវកាលបរិច្ឆេទក្នុង FMIS និងប្រព័ន្ធ FMIS អាចផលិតរបាយការណ៍ហិរញ្ញវត្ថុតាមស្តង់ដារមូលដ្ឋានសាច់ប្រាក់ IPSAS ។ ក្រុមការងារ FMWG បានធ្វើការដោះស្រាយបញ្ហាដែលនៅសេសសល់នៅដំណាក់កាលទី១ ជាបណ្តើរ និងសម្រេចបានលទ្ធផល ដូចតទៅ÷ (១). ប្រព័ន្ធ FMIS នឹងអាចបិទបញ្ជីហិរញ្ញវត្ថុឆ្នាំ២០១៧ បាន ដោយគ្រប់ប្រតិបត្តិការគឺឆ្លងតាមប្រព័ន្ធ និង (២).របាយការណ៍ហិរញ្ញវត្ថុមូលដ្ឋានសាច់ប្រាក់ IPSAS អាចទាញចេញតាមប្រព័ន្ធ FMIS។

ចាប់ពីឆ្នាំ២០១៦ មក អគ្គនាយកដ្ឋានរតនាគារជាតិបានបោះបង់ចោល និងឈប់ប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានខ្មែរ (Khmer Information Technology-KIT) និងចាប់ផ្តើមអនុវត្តតាមប្រព័ន្ធ FMIS ទាំងមូល ។ ទន្ទឹមនេះ អគ្គនាយកដ្ឋានរតនាគារជាតិ បានធ្វើបច្ចុប្បន្នភាពប្លង់គណនេយ្យថ្មី ត្រូវបានរៀបចំ និងដាក់បញ្ចូលក្នុងប្រព័ន្ធ FMIS ព្រមទាំងបានរៀបចំប្លង់គណនេយ្យថ្មីសម្រាប់គ្រឹះស្ថានសាធារណៈរដ្ឋបាលផងដែរ ។ ទន្ទឹមនេះ សមាសធាតុនៃ FMIS ត្រូវបានដាក់បញ្ចូលក្នុងប្រព័ន្ធបន្ថែមទៀត រួមទាំងមុខងារស្ទូល និងចំណាត់ថ្នាក់ថវិកា។ ពាក់ព័ន្ធចំណាត់ថ្នាក់ថវិកា ត្រូវបានដាក់បញ្ចូល និងអនុវត្ត រួមមាន ចំណាត់ថ្នាក់សេដ្ឋកិច្ច, កម្មវិធី និងអង្គភាពប្រតិបត្តិ និងរដ្ឋបាល (ត្រឹមកម្រិត ១) ។ រីឯ ចំណាត់ថ្នាក់ផ្សេងទៀត (មុខងារ, ភូមិសាស្ត្រ, ប្រភពមូលនិធិ និងគម្រោង) ត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត តាមរយៈប្រកាស កសហវ ។ សម្រាប់ចំណាត់មុខងារ ក្រុមការងារបានរៀបចំបញ្ចប់នូវឧបសម្ព័ន្ធមុខងាររួចរាល់ហើយ ត្រៀមដាក់ឱ្យអនុវត្តនៅឆ្នាំ២០១៨ ។

ជាមួយគ្នានេះ ប្រព័ន្ធ FMIS ដំណាក់កាលទី២ ត្រូវបានដាក់ឱ្យអនុវត្តនៅឆ្នាំ២០១៦ ហើយឧបករណ៍សម្រាប់គាំទ្រប្រព័ន្ធ ត្រូវបានដាក់ឱ្យដេញថ្លៃ និងបំពាក់បន្ថែម ដោយក្នុងនោះ រួមមាន ការដេញថ្លៃលើកញ្ចប់ផ្គត់ផ្គង់ឧបករណ៍សម្រាប់អ្នកប្រើប្រាស់ចុងក្រោយនិងកញ្ចប់ផ្គត់ផ្គង់ហេដ្ឋារចនាសម្ព័ន្ធ WAN/LAN និងកញ្ចប់ Bandwidth។ រីឯ កញ្ចប់មជ្ឈមណ្ឌលទិន្នន័យ (Data Center) ត្រូវបានរៀបចំឯកសារដេញថ្លៃរួចរាល់ ហើយអាចនឹងទទួលទំនិញនៅពាក់កណ្តាលឆ្នាំ២០១៨ ។ នៅឆ្នាំ២០១៨ ក្រសួង ស្ថាប័នចំនួន ១០ នឹងត្រូវដាក់ឱ្យអនុវត្តប្រព័ន្ធ FMIS រួមមាន កសហវ, ក្រសួងអប់រំ យុវជន និងកីឡា, ក្រសួងសុខាភិបាល, ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ,ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ, ក្រសួងកិច្ចការនារី, ក្រសួងបរិស្ថាន, ក្រសួងមុខងារសាធារណៈ, ក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍។ បន្ថែមពីនេះ ក្រសួង ស្ថាប័នចំនួន ១០ បន្ថែម និងមន្ទីរ សហវ រាជធានី ខេត្តទាំង ២៥ នឹងត្រូវដាក់ឱ្យអនុវត្តគម្រោងប្រព័ន្ធ FMIS ក្នុងឆ្នាំ២០១៨។ ក្នុងដំណាក់កាលនេះ ទាំងក្រសួង ស្ថាប័ន និងមន្ទីរ សហវ នឹងត្រូវទទួលបាននូវការបញ្ជ្រាបការយល់ដឹង, ការបណ្តុះបណ្តាល, ដំឡើងឧបករណ៍បរិក្ខានិងប្រព័ន្ធ និងការចុះសិក្សាអំពីនីតិវិធីប្រតិបត្តិការ (SOP) ដោយក្រុមការងារ FMWG។ បន្ទាប់មក ក្រសួង ស្ថាប័ន និង

មន្ទីរ សហវ នឹងដាក់ឱ្យប្រព័ន្ធនៅឆ្នាំ២០១៩ ។ នៅឆ្នាំ២០១៩ ក្រសួង ស្ថាប័នចំនួន ១៧ ដែលនៅសេសសល់នឹងដាក់ឱ្យអនុវត្តគម្រោងប្រព័ន្ធ FMIS និងអនុវត្តប្រព័ន្ធ FMIS នៅឆ្នាំ២០២០ ។

ទោះបីជាយ៉ាងណាក៏ដោយ ការងារចំនួន ៣ មានភាពយឺតយ៉ាវក្នុងផ្នែកទី២ នេះ ដោយការងារទាំងនេះ គឺចាំបាច់ត្រូវការជំនួយបច្ចេកទេស រួមមាន (១). ការរៀបចំបទដ្ឋានគតិយុត្តកំណត់ Fixed Asset Threshold, (២). ប្រកាសស្តីពីការដាក់ឱ្យប្រើស្តង់ដារគណនេយ្យសាធារណៈតាម IPSAS Cash Basis ពុំទាន់បានអនុម័ត និង (៣). ការដាក់ឱ្យប្រើស្តង់ដារគណនេយ្យមូលដ្ឋានសាច់ប្រាក់ ។

វឌ្ឍនភាពតាមគោលបំណងនៃផ្នែកទី២ "បន្តពង្រឹងគណនេយ្យភាពហិរញ្ញវត្ថុ" បង្ហាញដូចតទៅ÷

### គោលបំណង ២១ "ពង្រឹងការអនុវត្តមាតិកាថវិកាថ្មី និងប្លង់គណនេយ្យថ្មី"

ការអនុវត្តមាតិកាថវិកាថ្មី និងប្លង់គណនេយ្យថ្មី ត្រូវបន្តកែលម្អដើម្បីធានាឱ្យមានសង្គតិភាពនិងអនុវត្តតាមស្តង់ដារអន្តរជាតិ និងចំណាត់ថ្នាក់ថវិកាទាំង ០៧ (ភូមិសាស្ត្រ, អង្គភាពប្រតិបត្តិ និងរដ្ឋបាល, កម្មវិធី, សេដ្ឋកិច្ច, មុខងារ, មូលនិធិ និងគម្រោង) ត្រូវបានដាក់ឱ្យអនុវត្តពេញលេញ ដើម្បីធានាឱ្យបាននូវគ្រប់ជ្រុងជ្រោយនៃព័ត៌មាន និងការវិភាគសម្រាប់វិភាជន៍ថវិកា។ ជារួម ការអនុវត្តគោលបំណងនេះ គឺមានវឌ្ឍនភាព ដូចតទៅ÷

១. សមាសភាពក្រុមការងារ FMIS សម្រាប់អនុវត្តបរិបទថ្មីនៃប្រព័ន្ធ FMIS ដែលនឹងត្រូវដាក់ឱ្យអនុវត្តក្នុងជំហានទី២ ត្រូវបានរៀបចំកែសម្រួល
២. ប្រកាសស្តីពីការកែសម្រួល និងបំពេញបន្ថែមចំណាត់ថ្នាក់ភូមិសាស្ត្រនៃមាតិកាថវិកាត្រូវបានអនុម័ត និងដាក់ឱ្យអនុវត្ត
៣. សេចក្តីណែនាំស្តីពីបច្ចុប្បន្នភាពចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកាពាក់ព័ន្ធនឹងរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានដាក់ឱ្យអនុវត្ត
៤. ប្លង់គណនេយ្យរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាលត្រូវបានរៀបចំ
៥. ឧបសម្ព័ន្ធចំណាត់ថ្នាក់មុខងារត្រូវបានរៀបចំ
៦. ក្រសួង ស្ថាប័នត្រូវបានណែនាំ និងផ្តល់យោបល់ជាប្រចាំអំពីបរិបទថ្មីនៃប្រព័ន្ធ FMIS នៅពេលមានសំណើសុំធានាចំណាយ និងសំណើសុំទូទាត់ ព្រមទាំងលំហូរឯកសារពាក់ព័ន្ធនឹងប្រព័ន្ធ FMIS ។

### គោលបំណង ២២ "ពង្រឹងការអនុវត្តប្រព័ន្ធថវិការថ្មី និងដំណើរការប្រតិបត្តិការថ្មី"

ការពង្រឹងការអនុវត្តប្រព័ន្ធអនុវត្តថវិកាថ្មី និងប្រតិបត្តិការថ្មី មានគោលដៅដើម្បីកាត់បន្ថយពេលវេលាសម្រាប់សំណើសុំធានាចំណាយ និងការទូទាត់នៅតាមក្រសួង ស្ថាប័ន និងកែលម្អកម្រិតប្រតិបត្តិការនៅក្នុង កសហវ ដោយពង្រឹងការអនុវត្តប្រព័ន្ធថវិកាថ្មី តាមរយៈការបង្កើនកម្រិតយល់ដឹង, ភាពជាម្ចាស់, ការចូលរួម និងសមត្ថភាពផ្នែក FMIS ទាំង កសហវ និងក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ។

ដោយមានការប្តេជ្ញា និងភាពជាម្ចាស់របស់ កសហវ នៅឆ្នាំ២០១៧ ការអនុវត្តប្រព័ន្ធ FMIS ត្រូវបានចូលរួមប្រកបដោយប្រសិទ្ធភាព ពោលគឺរាល់ប្រតិបត្តិការចំណូល-ចំណាយ ការបិទបញ្ជីហិរញ្ញវត្ថុ និងការរៀបចំរបាយការណ៍ចំណូល-ចំណាយត្រូវបានអនុវត្តក្នុង FMIS ជំនួសប្រព័ន្ធ KIT ទាំងស្រុង ។

ក្នុងឆ្នាំ២០១៨ ក្រសួង ស្ថាប័ន ចំនួន ១០ នឹងត្រូវដាក់ឱ្យអនុវត្តប្រព័ន្ធ FMIS ក្នុងន័យនេះ ក្រុមការងារ FMIS បានជួយបណ្តុះបណ្តាលដល់ក្រសួង ស្ថាប័ន១០ មានមន្ត្រីប្រមាណ២០០ រូបបានទទួលការបណ្តុះបណ្តាលការប្រើ-ប្រាស់ប្រព័ន្ធ FMIS នឹងបានសាកល្បងប្រើប្រាស់ប្រព័ន្ធ FMIS ដើម្បីត្រៀមលក្ខណៈអនុវត្តប្រព័ន្ធ FMIS ជាផ្លូវការចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០១៨ តទៅ។ ទន្ទឹមនេះ ហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យាព័ត៌មានបានកសាងរួចរាល់នៅក្រសួង ស្ថាប័នចំនួន ១០ ដែលអាចទ្រទ្រង់បានសម្រាប់អ្នកប្រើប្រាស់ជាង ២០០រូប ដែលរួមមាន ការដំឡើងរួចរាល់នូវបណ្តាញតភ្ជាប់ WAN/LAN ពីក្រសួង ស្ថាប័នទាំង១០ មកមជ្ឈមណ្ឌលទិន្នន័យរួមរបស់ FMIS ។

ទន្ទឹមនេះ គោលបំណងនេះ មានវឌ្ឍនភាព គួរឱ្យកត់សម្គាល់រួមមាន÷

១. សិក្ខាសាលាស្តីពីវឌ្ឍនភាពនៃប្រព័ន្ធ FMIS ត្រូវបានរៀបចំ ដើម្បីពង្រីកការយល់ដឹង ពង្រឹងការគាំទ្រ និងបង្កើនភាពជាម្ចាស់លើប្រព័ន្ធ FMIS ដល់រតនាគារ និងមន្ទីរ សហវ រាជធានី ខេត្ត

២. ការយល់ដឹងពី FMIS ត្រូវបានផ្សព្វផ្សាយតាមប្រព័ន្ធផ្សព្វផ្សាយនានា ដូចជា វីដេអូខ្លីៗ, ទូរទស្សន៍ និងបណ្តាញសារព័ត៌មានផ្សេងៗ ជូនមន្ត្រីរាជការ និងសាធារណៈជនទូទៅ

៣. ការកសាងសមត្ថភាពមន្ត្រី នៃក្រុមការងារ FMWG ត្រូវបានធ្វើឡើងតាមរយៈការបណ្តុះបណ្តាលផ្នែក Soft Skill ផ្នែកគ្រប់គ្រងគម្រោងព័ត៌មានវិទ្យា PRINCE2 Practitioner និងគ្រប់គ្រងការផ្លាស់ប្តូរនៅប្រទេសសិង្ហបុរី និងវគ្គបណ្តុះបណ្តាលមូលដ្ឋានលើមុខងារ (Oracle PeopleTools, Oracle Database, Oracle ZFS Storage, Oracle Solaris, Programming និង Cisco Networking)

៤. ការកសាងសមត្ថភាពមន្ត្រីនៃ កសហវ និងក្រសួង ស្ថាប័នលើការប្រើប្រាស់ប្រព័ន្ធ FMIS ត្រូវបានធ្វើឡើងតាមរយៈការរៀបចំវគ្គបណ្តុះបណ្តាលបំប៉នបន្ថែមស្តីពី FMIS Refreshment Training មូលដ្ឋានគ្រឹះផ្នែកព័ត៌មានវិទ្យា និងការប្រើប្រាស់ប្រព័ន្ធ FMIS សម្រាប់ត្រៀមអនុវត្តប្រព័ន្ធ FMIS ក្នុងជំហានទី២

៥. ក្រុមការងារ FMWG បាននិងកំពុងសិក្សាស្រាវជ្រាវបន្ថែម ដើម្បីរៀបចំនិងកសាងប្រព័ន្ធ FMIS លើមុខងារបន្ថែមថ្មីគឺការគ្រប់គ្រងការរៀបចំថវិកា, ការធ្វើលទ្ធកម្មនិងគ្រប់គ្រងកិច្ចសន្យា, ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ និងការគ្រប់គ្រងសន្និធិ

៦. សេចក្តីព្រាងបរិបទនៃប្រតិបត្តិការចំណាយមូលធន និងជួសជុលថែទាំ (សំណើសុំធានាចំណាយ, កិច្ចលទ្ធកម្ម និងសំណើសុំទូទាត់) នៅតាមក្រសួងស្ថាប័ន ត្រូវបានរៀបចំ ឱ្យស្របតាមប្រព័ន្ធ FMIS របស់នាយកដ្ឋានវិនិយោគ

៧. លិខិតបទដ្ឋានគតិយុត្តថ្នាក់ក្រោមជាតិ ត្រូវបានរៀបចំរួចរាល់ក្នុងនោះ មានសេចក្តីណែនាំកិច្ចបញ្ជិការរជ្ជ-ទេយ្យចំណូលសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ដើម្បីពង្រឹងការអនុវត្តថវិកា និងធ្វើបច្ចុប្បន្នភាព នីតិវិធីអនុវត្តថវិកានៅរដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ

៨. ការបណ្តុះបណ្តាលនិងផ្សព្វផ្សាយណែនាំអំពីនីតិវិធី នៃការអនុវត្តចំណូល-ចំណាយថវិកា អនុលោមតាមលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធទាំងឡាយដល់មន្ត្រីជំនាញពាក់ពន្ធ័នៃអគ្គនាយកដ្ឋានរតនាគាជាតិ ដើម្បីត្រួតពិនិត្យលើការអនុវត្តថវិកា ជាពិសេសក្រសួង ស្ថាប័នពាក់ព័ន្ធនានាដើម្បីឱ្យការអនុវត្តថវិកាមានភាពត្រឹមត្រូវស្របតាមនីតិវិធីហិរញ្ញវត្ថុជាធរមាន ។

**គោលបំណង ២៣ “ពង្រឹងការអនុវត្តប្រព័ន្ធគណនេយ្យថ្មី, ប្រព័ន្ធកត់ត្រាថ្មី, ប្រព័ន្ធរបាយការណ៍ថ្មី”**

ក្នុងគោលបំណងនេះ ប្រព័ន្ធគណនេយ្យថ្មី ប្រព័ន្ធកត់ត្រាថ្មី និងប្រព័ន្ធរបាយការណ៍ថ្មី ត្រូវបានរៀបចំដោយតម្រូវរៀបចំស្តង់ដារគណនេយ្យសាធារណៈស្របតាមស្តង់ដារ IPSAS ដោយផ្សារភ្ជាប់ទៅនឹងការប្រើប្រាស់ FMIS និងបង្កើតជម្រើសសម្រាប់ការអនុវត្តជាជំហានៗទៅរកការអនុវត្តគណនេយ្យបង្គរ, ការកែលម្អទម្រង់របាយការណ៍ការអនុវត្តថវិកាត្រូវរៀបចំសម្រាប់គណៈរដ្ឋមន្ត្រី, ស្ថាប័ននីតិប្បញ្ញត្តិ និងសាធារណៈជន និងការចុះបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋ និងធ្វើបច្ចុប្បន្នភាពជាប្រចាំ ។

ក្នុងន័យនេះ ប្រព័ន្ធ FMIS អាចផលិតបាយការណ៍ហិរញ្ញវត្ថុផ្អែកលើមូលដ្ឋានសាច់ប្រាក់ព្រមទាំងទទួលបានការបញ្ជាក់ពីអ្នកជំនាញការនៃធនាគារពិភពលោក ដោយធ្វើការវាយតម្លៃថា របាយការណ៍ហិរញ្ញវត្ថុផ្អែកលើមូលដ្ឋានសាច់ប្រាក់ គឺស្របតាមស្តង់ដារអន្តរជាតិប្រមាណ ៩០% ។

រីឯការងារពាក់ព័ន្ធនឹងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋវិញ អ.ទ.ច. បានរៀបចំប្រព័ន្ធគ្រប់គ្រងទិន្នន័យបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ និងប្រព័ន្ធគ្រប់គ្រងទិន្នន័យបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ ត្រូវបានរៀបចំក្នុងដំណាក់កាលដំបូង និងកំពុងធ្វើការសាកល្បងប្រើប្រាស់ ដោយមន្ត្រីរបស់នាយកដ្ឋានជំនាញ។ ជាមួយគ្នានេះ អនុក្រឹត្យស្តីពីវិធាន និងនីតិវិធីនៃការគ្រប់គ្រងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋត្រូវបានចុះហត្ថលេខា និងចូលជាធរមាននៅថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១៧ និងត្រូវបានធ្វើសិក្ខាសាលាផ្សព្វផ្សាយដល់គ្រប់ក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ និងនីតិបុគ្គលសាធារណៈ ។

ប្រអប់ 3: វឌ្ឍនភាពនៃការរៀបចំបញ្ជីសារពើភណ្ឌគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋឆ្នាំ២០១៧

**ការរៀបចំបញ្ជីសារពើភណ្ឌគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ**

យោងរបាយការណ៍របស់ អ.ទ.ច. ស្តីពីលទ្ធផលនៃការរៀបចំបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋរបស់ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិបានបង្ហាញថា អាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរដ្ឋនៅទូទាំងប្រទេសចំនួន ១.១៩៧ អង្គភាព ត្រូវជា ១.០២៦ អង្គភាព ស្មើនឹង ៨៦% ដែលបានប្រគល់បញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋឆ្នាំ ២០១៦ (តារាងប្រៀបធៀបកើនឡើងថយចុះទ្រព្យសម្បត្តិរដ្ឋឆ្នាំ២០១៦) ជូន កសហវ ។ ពិនិត្យជារួម បង្ហាញថា ÷

១. ក្រសួង ស្ថាប័នទាំង ៣៧ មានចំនួន២០៨ អង្គភាព ហើយមានអង្គភាពចំនួន ១៩៤ ស្មើនឹង ៩៣% បានផ្ញើបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋមក កសហវ។ រីឯ អង្គភាពចំនួន ១៤ ស្មើនឹង ៧% មិនទាន់បានផ្ញើមក កសហវ ។

២. មន្ទីរជំនាញ និងអង្គភាពជុំវិញរាជធានី ខេត្ត មានចំនួន ៧៦៥ អង្គភាព ហើយមានអង្គភាពចំនួន ៦៧៨ ស្មើនឹង ៨៩% បានផ្ញើបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋមក កសហវ ។ រីឯ អង្គភាពចំនួន ៨៧ ស្មើនឹង ១១% មិនទាន់បានផ្ញើមក កសហវ ។

៣. ថ្នាក់ក្រោមជាតិ មានចំនួន ២២៤ អង្គភាព ហើយមានអង្គភាពចំនួន ១៥៤ ស្មើនឹង ៦៩% បានផ្ញើបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋមក កសហវ ។ រីឯ អង្គភាពចំនួន ៧០ ស្មើនឹង ៣១% មិនទាន់បានផ្ញើមក កសហវ ។

**គោលបំណង ២៤ "ពង្រឹងការអនុវត្តឧបករណ៍ និងយន្តការដើម្បីបង្កើនការទទួលខុសត្រូវ និងគណនេយ្យភាព (ប្រព័ន្ធត្រួតពិនិត្យ)"**

សង្គតិភាពនៃប្រព័ន្ធគណនេយ្យភាពលើវិស័យហិរញ្ញវត្ថុសាធារណៈ គឺជំរុញឱ្យអនុវត្តលិខិតបទដ្ឋានគតិយុត្ត ប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព ។ ក្នុងន័យនេះ អាណាប័កថវិកា នឹងមានការទទួលខុសត្រូវលើហិរញ្ញវត្ថុ និងសមិទ្ធកម្មរបស់អង្គភាពរបស់ខ្លួន។ បន្ថែមពីនេះ ក្រុមប្រឹក្សានីតិកម្ម បាននិងកំពុងសិក្សារៀបចំសេចក្តីព្រាងកម្រងទណ្ឌកម្មរដ្ឋបាលក្នុងវិស័យហិរញ្ញវត្ថុសាធារណៈ ដែលកម្រងនេះ នឹងក្លាយជាមូលដ្ឋានសម្រាប់ស្រាវជ្រាវបញ្ចូលជាទណ្ឌកម្ម ក្នុងសេចក្តីព្រាងច្បាប់វិសោធនកម្មច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ នាឆ្នាំ២០១៨ ខាងមុខវិញ ។

**គោលបំណង ២៥ "បង្កើនតម្លាភាពថវិកា"**

រាជរដ្ឋាភិបាលកម្ពុជាបានចាត់ទុកថាតម្លាភាពថវិកា គឺជាឧបករណ៍មួយដ៏សំខាន់ ដើម្បីជំរុញគណនេយ្យភាព និងអភិបាលកិច្ចក្នុងវិស័យហិរញ្ញវត្ថុសាធារណៈ ។ ជាក់ស្តែង ក្រសួង ស្ថាប័ន គឺធ្វើការផ្សព្វផ្សាយឯកសារថវិកាជាប្រចាំឆ្នាំជូនសាធារណៈជនទូទៅ និងអ្នកសិក្សាស្រាវជាវមានលទ្ធភាពធ្វើការវិភាគ ព្រមទាំងសិក្សាស្វែងយល់បន្ថែមអំពីថវិកាប្រចាំឆ្នាំ ដែលត្រូវប្រើប្រាស់ដើម្បីអនុវត្តអាទិភាពនៃគោលនយោបាយ ។

តម្លាភាពថវិកាត្រូវបានបង្កើនជាលំដាប់ ដោយទាំង កសហវ និង អាជ្ញាធរសវនកម្មជាតិបានផ្សព្វផ្សាយនូវឯកសារថវិកា ដូចខាងក្រោម÷

១. ថវិកាសង្ខេប២០១៧ ត្រូវបានផ្សព្វផ្សាយគេហទំព័រ
២. សំណើថវិកាសង្ខេបជាតិប្រចាំឆ្នាំ២០១៨ ត្រូវបានផ្សព្វផ្សាយបន្ទាប់ពីគណៈរដ្ឋមន្ត្រីអនុម័ត និងមុនបញ្ជូនថវិកាទៅស្ថាប័ននីតិបញ្ញត្តិ
៣. សារាចរណែស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកា និងកញ្ចប់ថវិកាត្រូវបានផ្សព្វផ្សាយ លើគេហទំព័រ
៤. របាយការណ៍អនុវត្តថវិកាក្នុងឆ្នាំត្រូវបានផ្សព្វផ្សាយលើគេហទំព័រ
៥. របាយការណ៍ត្រួតពិនិត្យថវិកាពាក់កណ្តាលឆ្នាំ២០១៧ ត្រូវបានផ្សព្វផ្សាយលើគេហទំព័រ
៦. ច្បាប់ស្តីពីការទូទាត់ថវិកាទូទៅឆ្នាំ២០១៦ ត្រូវបានរៀបចំនិងផ្សព្វផ្សាយលើគេហទំព័រ
៧. ព្រឹត្តបត្រស្ថិតិបំណុលសាធារណៈកម្ពុជាត្រូវផ្សព្វផ្សាយលើគេហទំព័រចំនួន ២ ដង/ឆ្នាំ
៨. ផែនការលទ្ធកម្ម, សេចក្តីជូនដំណឹងការដេញថ្លៃ និងការប្រគល់កិច្ចសន្យាលទ្ធកម្មត្រូវបានផ្សព្វផ្សាយ លើគេហទំព័រ
៩. របាយការណ៍ត្រួតពិនិត្យកិច្ចលទ្ធកម្មសាធារណៈតាមក្រោយ ដែលស្ថិតនៅក្រោមសិទ្ធិសម្រេចលើស្ថាប័នអនុវត្តលទ្ធកម្ម/អង្គភាពថវិកាប្រចាំឆ្នាំ២០១៦ លើការិយបរិច្ឆេទឆ្នាំ២០១៥ ត្រូវបានផ្សព្វផ្សាយលើគេហទំព័រ
១០. របាយការណ៍សវនកម្មលើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈឆ្នាំ២០១៥ ត្រូវបានផ្សព្វផ្សាយលើគេហទំព័រ ។

បន្ថែមពីនេះ កសហវ តែងតែរៀបចំកិច្ចប្រជុំវេទិកាសាធារណៈស្តីពីក្របខ័ណ្ឌសេដ្ឋកិច្ច និងហិរញ្ញវត្ថុជាប្រចាំឆ្នាំ ដោយមានការចូលរួមពីក្រសួង ស្ថាប័ន, ដៃគូអភិវឌ្ឍន៍, គ្រឹះស្ថានសិក្សា, អ្នកសិក្សាស្រាវជ្រាវ និង អង្គការមិនមែនរដ្ឋាភិបាល ។ ទន្ទឹមនេះ ដើម្បីធ្វើការវិភាជថវិកាប្រចាំឆ្នាំឱ្យចំគោលដៅអាទិភាព កសហវ បានផ្តួចផ្តើមធ្វើការរៀបចំ

កិច្ចប្រជុំពិគ្រោះយោបល់លើសេដ្ឋកិច្ច ដោយផ្តោតលើវិស័យកសិកម្ម, អប់រំ, បណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និងឡូជីស្ទីក ។

ដោយឡែក អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ បាននិងកំពុងរៀបចំប្រព័ន្ធគ្រប់គ្រងលទ្ធកម្មសាធារណៈតាមប្រព័ន្ធព័ត៌មានវិទ្យា (Public Procurement Management Information System- PPMIS) សម្រាប់ប្រើប្រាស់ផ្ទៃក្នុងនៃអគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ ត្រូវបង្កើតរួចរាល់នូវមុខងារគ្រប់គ្រងផែនការលទ្ធកម្ម និងបានដាក់ឱ្យមន្ត្រីពាក់ព័ន្ធនៃការិយាល័យផែនការ ស្ថិតិ និងព័ត៌មានវិទ្យាអនុវត្ត។

ប្រអប់ 4: ការងារត្រូវធ្វើបន្តនៃផ្នែកទី២ "បន្តពង្រឹងគណនេយ្យភាពហិរញ្ញវត្ថុ"

**ការងារត្រូវធ្វើបន្ត**

កសហវ នឹងដាក់ឱ្យអនុវត្តចំណាត់ថ្នាក់ថវិកាជាបន្តបន្ទាប់ ។ នៅឆ្នាំ២០១៨ ចំណាត់ថ្នាក់មុខងារ, ចំណាត់ថ្នាក់អង្គភាពប្រតិបត្តិ និងរដ្ឋបាល និងចំណាត់ថ្នាក់គម្រោង នឹងត្រូវដាក់ឱ្យអនុវត្ត ។ អគ្គនាយកដ្ឋានរតនាគារជាតិ នឹងរៀបចំបទដ្ឋានគតិយុត្តកំណត់ Fixed Asset Threshold និងការដាក់ឱ្យប្រើស្តង់ដាគណនេយ្យមូលដ្ឋានសាច់ប្រាក់ (IPSAS Cash Basis) និងរៀបចំបញ្ចប់សេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រង ការប្រើប្រាស់ និងការចាត់ចែងលើទ្រព្យសម្បត្តិរដ្ឋ ។

បន្ថែមពីនេះ ក្រសួង ស្ថាប័នចំនួន ១០ និងមន្ទីរ សហវ រាជធានី ខេត្តចំនួន ២៥ នឹងត្រូវដាក់ឱ្យអនុវត្តគម្រោងប្រព័ន្ធ FMIS ក្នុងឆ្នាំ២០១៨ ។ ក្នុងដំណាក់កាលនេះ ទាំងក្រសួង ស្ថាប័ន និងមន្ទីរ សហវ នឹងត្រូវទទួលបាននូវការបញ្ជ្រាបការយល់ដឹង, ការបណ្តុះបណ្តាល, ដំឡើងឧបករណ៍បរិក្ខានិងប្រព័ន្ធ និងការចុះសិក្សាអំពីនីតិវិធីប្រតិបត្តិការ (SOP) ដោយក្រុមការងារ FMWG ។

### គ.៣. ផ្នែកទី៣ "ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ"

ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ គឺជាជំហានដ៏សំខាន់សម្រាប់ការអនុត្តក្នុងកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី៣ ។ ការអនុវត្តថវិកាកម្មវិធីប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព គឺទាមទារឱ្យក្រសួង ស្ថាប័ន កំណត់នូវគោលបំណងគោលនយោបាយ កម្មវិធី និងអនុកម្មវិធីឱ្យច្បាស់លាស់, សមានគតិភាព និងសង្គតិភាពជាមួយយុទ្ធសាស្ត្រចតុកោណ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ។ បន្ថែមពីនេះ កសហវ ត្រូវរៀបចំក្របខ័ណ្ឌហិរញ្ញវត្ថុរយៈពេលមធ្យម (Medium term financial framework-MTFF) និងក្របខ័ណ្ឌថវិការយៈពេលមធ្យម (Medium term budget framework-MTBF) ដើម្បីកំណត់ពិដានថវិកាសម្រាប់តាមវិស័យ និងឈានទៅការរៀបចំពិដានសម្រាប់ក្រសួង ស្ថាប័ន ។ ទន្ទឹមនេះ ក្រសួង ស្ថាប័ន ត្រូវរៀបចំ និងកែលម្អផែនការយុទ្ធសាស្ត្រ និងកញ្ចប់ថវិកាប្រចាំឆ្នាំ ។ ផ្នែកនេះ ផ្តោតការយកចិត្តទុកដាក់ខ្ពស់លើ (១). ក្របខ័ណ្ឌថវិការយៈពេលមធ្យម (២). ផែនការយុទ្ធសាស្ត្រថវិកា និង (៣). ថវិកាកម្មវិធី និងអង្គភាពថវិកានៅគ្រប់ក្រសួង ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ។

ជាលទ្ធផល គ្រប់ក្រសួង ស្ថាប័នត្រូវបានដាក់ឱ្យអនុវត្តថវិកាកម្មវិធីសាកល្បងពេញលេញ ចាប់ពីឆ្នាំ២០១៥ ដល់ឆ្នាំ២០១៨ ។ ជាលទ្ធផល ឆ្នាំ២០១៥ មានចំនួន ១០ ក្រសួង ស្ថាប័ន, ឆ្នាំ២០១៦ មាន ១៥ ក្រសួង ស្ថាប័នបន្ថែម, ឆ្នាំ២០១៧ មាន ១១ ក្រសួង ស្ថាប័នបន្ថែម និងឆ្នាំ២០១៨ មាន ៣ ក្រសួង ស្ថាប័នបន្ថែម ដែលសរុបមាន ៣៩ ក្រសួង ស្ថាប័ន ។ គិតត្រឹមឆ្នាំ២០១៧ ការអនុវត្តថវិកាកម្មវិធី មានក្រសួង ស្ថាប័នចំនួន ៣៦ ត្រូវបានដាក់ឱ្យអនុវត្តថវិកាកម្មវិធីសាកល្បងពេញលេញ ដែលមានអង្គភាពថវិកាចំនួន ៨៤៨ ដែលក្នុងនោះថ្នាក់កណ្តាលមានចំនួន ២៤៦ និងថ្នាក់មូលដ្ឋានមានចំនួន ៦០២ ។

វឌ្ឍនភាពតាមគោលបំណងនៃផ្នែកទី៣ "ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ" បង្ហាញដូចតទៅ÷

**គោលបំណង ៣១ "ការពង្រឹង និងពង្រីកការអនុវត្តថវិកាកម្មវិធី"**

ការអនុវត្តថវិកាកម្មវិធីជាឧបករណ៍ជំរុញឱ្យមានការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយបម្រើឱ្យយុទ្ធសាស្ត្រចតុកោណ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ។ ជាក់ស្តែង សារាចរណែនាំស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រឆ្នាំ ២០១៨-២០២០ គឺមានកំណត់នូវពិដានចំណាយចរន្តតាមវិស័យនីមួយៗ ដែលកត្តានេះ គឺជាការចាប់ផ្តើមជំរុញឱ្យគ្រប់ក្រសួង ស្ថាប័ន ធ្វើការគិតគូរអំពីគោលបំណងគោលនយោបាយ និងកម្មវិធីអាទិភាព ដើម្បីរៀបចំថវិកាប្រចាំឆ្នាំ និងរយៈពេលមធ្យមឱ្យផ្សារភ្ជាប់ទៅនឹងគោលនយោបាយ ។

ដើម្បីឱ្យការអនុវត្តថវិកាកម្មវិធីឱ្យកាន់តែមានភាពរលូន កសហវ បានធ្វើបច្ចុប្បន្នភាពគោលការណ៍ណែនាំស្តីពីការរៀបចំ និងដាក់ឱ្យអនុវត្តថវិកាកម្មវិធី និងកែសម្រួលសិទ្ធិអំណាចរបស់អង្គភាពថវិកា និងអង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធ ដោយក្នុងនោះមាន (១). ការផ្តល់សិទ្ធប្រើប្រាស់រជ្ជទេយ្យបុរេប្រទានក្នុងការទិញផ្ទាល់ពីក្រុមហ៊ុន, (២). សិទ្ធិរបស់មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុក្នុងការចូលរួមរៀបចំ និងតាមដានលើអនុវត្តថវិកា និង (៣). សិទ្ធិចាត់ចែងលើការរៀបចំនិងអនុវត្តថវិការបស់អង្គភាពថវិកា ។

ទោះបីយ៉ាងក៏ដោយ ចាប់តាំងពីការអនុវត្តថវិកាកម្មវិធីនៅឆ្នាំ២០១៥ មក អគ្គនាយកដ្ឋានថវិកា នៃ កសហវ ពុំទាន់ចាប់ផ្តើមធ្វើការត្រួតពិនិត្យ និងវាយតម្លៃលទ្ធផលនៃក្រសួង ស្ថាប័ន ដោយធ្វើការប្រៀបធៀបនឹងផែនការដែលមានបញ្ជាក់សូចនាករជាមួយលទ្ធផលសម្រេចតាមគោលបំណងគោលនយោបាយ, កម្មវិធី និងអនុកម្មវិធី ។

**គោលបំណង ៣២ "ការរៀបចំថវិកាឱ្យមានលក្ខណៈគ្រប់ជ្រុងជ្រោយ និងធ្វើសមាហរណកម្មថវិកា"**

ការរៀបចំថវិកាគ្រប់ជ្រុងជ្រោយ សំដៅដល់ថវិកាពេញលេញដែលឆ្លុះបញ្ចាំងគ្រប់ប្រភពចំណូល និងគ្រប់មុខសញ្ញា ។ ការរៀបចំច្បាប់ថវិកាប្រចាំ គួរតែរំលេចនូវប្រតិបត្តិការចំណូល និងចំណាយទាំងអស់ ហើយការធ្វើសមាហរណកម្មនៃថវិកាមូលធន និងថវិកាចរន្ត ។ ការរៀបចំផែនការយុទ្ធសាស្ត្ររយៈពេល ៣ឆ្នាំរំកិល អនុញ្ញាតឱ្យក្រសួង ស្ថាប័ន មានលទ្ធភាពបញ្ចូលទាំងចំណាយចរន្ត និងចំណាយមូលធន ។

ជាមួយគ្នានេះ អ.ថ. បានធ្វើបច្ចុប្បន្នភាពគោលការណ៍ណែនាំស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកា ។ ដើម្បីបញ្ចូលទិន្នន័យចំណាយរបស់គម្រោងដែលទទួលហិរញ្ញប្បទានដោយដៃគូអភិវឌ្ឍន៍ អ.ស.ប. និងអគ្គនាយកដ្ឋានរតនាគារជាតិបានដាក់ជ្រើសរើស អ.គ.ហ. ឱ្យអនុវត្តមាតិកាគណនីនៃប្លង់គណនេយ្យថវិកា (COA) ថ្មីសម្រាប់គម្រោង/កម្មវិធីហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍ ។

**គោលបំណង ៣៣ "រៀបចំនិងដាក់ឱ្យអនុវត្តប្រព័ន្ធបន្ទាត់គណនេយ្យភាព (រវាងស្ថាប័ននីតិប្បញ្ញត្តិ និងស្ថាប័ននីតិប្រតិបត្តិ, រវាងកសហវ និងក្រសួង ស្ថាប័ន និងនៅក្នុងក្រសួង ស្ថាប័ន"**

នៅពេលថវិកាកម្មវិធីត្រូវបានដាក់ឱ្យអនុវត្តយ៉ាងទូលំទូលាយ ហើយអង្គភាពថវិកាត្រូវបានធ្វើវិមជ្ឈការអំណាច និងការទទួលខុសត្រូវ ប្រព័ន្ធបន្ទាត់គណនេយ្យភាព គួរត្រូវបានកំណត់ឱ្យបានច្បាស់លាស់រវាងនីតិបញ្ញត្តិ និងនីតិ-ប្រតិបត្តិរវាង កសហវ និងក្រសួង ស្ថាប័ន និងផ្ទៃក្នុងក្រសួង ស្ថាប័ន ។ ក្នុងន័យនេះ ក្រសួង ស្ថាប័ន អនុវត្តថវិកាកម្មវិធី ត្រូវបែងចែកការទទួលខុសត្រូវក្នុងការអនុវត្តការងារផ្ទាល់ និងបង្កើនការផ្ទេរថវិកានៅរដ្ឋបាលកណ្តាល ក៏ដូចជា នៅតាមមូលដ្ឋានឱ្យបានច្បាស់លាស់ស្របតាមគោលការណ៍នៃការរៀបចំ និងអនុវត្តថវិកាកម្មវិធី ។

ដើម្បីពិនិត្យលើការអនុវត្ត និងការទទួលខុសត្រូវរបស់ក្រសួង ស្ថាប័ន អនុវត្តថវិកាកម្មវិធី អគ្គនាយកដ្ឋានថវិកា បានរៀបចំកិច្ចប្រជុំជាមួយក្រសួង ស្ថាប័ន ហើយរៀបចំជាបាយការណ៍ដាក់ជូនឯកឧត្តមបណ្ឌិតសភាចារ្យទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី កសហវ ពិនិត្យ និងផ្តល់ការណែនាំ ។ ក្នុងន័យនេះ របាយការណ៍បានបង្ហាញអំពីការផ្លាស់ប្តូររចនាសម្ព័ន្ធនិង ការផ្លាស់ប្តូរមន្ត្រីនៅក្នុងក្រសួង ស្ថាប័ន ធ្វើឱ្យប៉ះពាល់ដល់ការគោលកាណ៍ និងនីតិវិធីអនុវត្តថវិកាកម្មវិធី ពោលគឺ មន្ត្រីចូលបម្រើការងារថ្មី ពុំទាន់យល់ច្បាស់ និងទាមទារឱ្យមានការបណ្តុះបណ្តាលបន្ថែម ។

ដោយឡែក គោលបំណងនេះ មានវឌ្ឍនភាពផ្សេងទៀត គួរឱ្យកត់សម្គាល់រួមមាន៖

១. អគ្គនាយកដ្ឋានរតនាគារជាតិបានប្រមូលចងក្រងនិងរៀបចំជាសៀវភៅកម្រងនីតិវិធីណែនាំអំពីសិទ្ធអំណាច និងការទទួលខុសត្រូវរបស់អង្គភាពថវិកា ដែលមាន ៦ ផ្នែកធំៗ រួមមាន (១). បទបញ្ញត្តិទូទៅនៃគណនេយ្យសាធារណៈ, (២). នីតិវិធីរជ្ជទេយ្យចំណូល និង កិច្ចបញ្ជិកាគណនេយ្យកាន់កាប់ដោយរជ្ជទេយ្យករចំណូល, (៣). នីតិវិធីរជ្ជទេយ្យបុរេប្រទាន និងកិច្ចបញ្ជិកាគណនេយ្យកាន់កាប់ដោយរជ្ជទេយ្យករបុរេប្រទាន, (៤). គ្រឹះស្ថានសាធារណៈរដ្ឋបាល, (៥). ចំណាត់ថ្នាក់ថវិកា និងប្លង់គណនេយ្យ, (៦). បទបង្ហាញសម្រាប់បណ្តុះ-បណ្តាលដល់ក្រសួង ស្ថាប័ន និងមន្ទីរ ដែលជាអង្គភាពអនុវត្តថវិកាកម្មវិធី ។

២. ប្រកាសលេខ ១៧១ សហវ.ប្រក ចុះថ្ងៃទី ១៦ ខែកម្ភៈ ឆ្នាំ២០១៧ ស្តីពីនីតិវិធីអនុវត្តថវិការបស់គ្រឹះស្ថានសាធារណៈរដ្ឋបាលត្រូវបានផ្សព្វផ្សាយជូនគ្រឹះស្ថានសាធារណៈរដ្ឋបាលទាំងអស់ដែលមាននៅតាមក្រសួង ស្ថាប័ន ។

**គោលបំណង៣៤ "ពង្រឹងការរៀបចំគោលនយោបាយនិងការធ្វើផែនការហិរញ្ញវត្ថុសាធារណៈ "**

យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ២០១៨-២០២៥ គឺបញ្ជាក់អំពីក្របខ័ណ្ឌពេលវេលា ដើម្បីការរៀបចំក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈ (MTFF) និងក្របខ័ណ្ឌថវិការយៈពេលមធ្យម (MTBF) ដោយត្រូវចាប់ផ្តើមពីឆ្នាំ ២០១៨-២០២១ ។ តាមរយៈការសម្រេចរបស់ថ្នាក់ដឹកនាំ កសហវ, អគ្គនាយកដ្ឋានគោលនយោបាយទទួលបន្ទុករៀបចំ MTFF និងអគ្គនាយកដ្ឋានថវិការៀបចំ MTBF ។ ទន្ទឹមនេះ សម្រាប់ការងារឆ្នាំ២០១៧ អគ្គនាយកដ្ឋានគោល-នយោបាយ សម្រេចបានដូចខាងក្រោម៖

១. ស្ថិតិតាមស្តង់ដារ GFS (GFS 2014 framework) ត្រូវបានពិនិត្យ និងផ្ទៀងផ្ទាត់ដោយជំនាញការ GFS របស់ IMF និងមានទិន្នន័យប្រតិបត្តិការហិរញ្ញវត្ថុថ្នាក់ក្រោមជាតិ GFS ឆ្នាំ២០១៦ ដោយបានសាកល្បង

បញ្ចូលទិន្នន័យ Extra-budgetary (ទិន្នន័យគំរូ) ក្នុង GFS ថ្នាក់ជាតិនៃអង្គភាពសាធារណៈរដ្ឋបាល (សាកល្បងទិន្នន័យឆ្នាំ ២០១៦)

២. ស្តង់ដារស្ថិតិប្រតិបត្តិការហិរញ្ញវត្ថុ TOFE ថ្នាក់ក្រោមជាតិ ត្រូវបានរៀបចំ និងសិក្ខាសាលាផ្សព្វផ្សាយ TOFE និង GFS និង ពង្រឹងការប្រមូលទិន្នន័យពីស្ថាប័នពាក់ព័ន្ធថ្នាក់ជាតិនិងក្រោមជាតិក្នុង១ ឆ្នាំ១ដង

៣. ក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច ត្រូវបានកែសម្រួលផ្នែកលើការវិភាគ និងវាយតម្លៃស្ថានភាពម៉ាក្រូសេដ្ឋកិច្ចពាក់កណ្តាលឆ្នាំ ២០១៧ និងបានដាក់ជូនថ្នាក់ដឹកនាំពិនិត្យ និងសម្រេច

៤. ម៉ូដែលព្យាករម៉ាក្រូសេដ្ឋកិច្ចកម្ពុជា (Cambodia Macroeconomic Forecasting Model - CMFM) ត្រូវបានធ្វើបច្ចុប្បន្នកម្ម និងប្រើប្រាស់ (version ២.0) សម្រាប់ព្យាករណ៍សេដ្ឋកិច្ច

៥. ទិន្នន័យវិស័យចំនួន ៤ ក្នុងទម្រង់ Financial Programming and Policies ត្រូវបានធ្វើបច្ចុប្បន្នកម្ម និងមានរបាយការណ៍ប្រចាំឆ្នាំស្តីពីលទ្ធផលវិភាគសេដ្ឋកិច្ចតាមរយៈការប្រើប្រាស់ទម្រង់ FPP ។

**គោលបំណង ៣៥ "ការរៀបចំប្រព័ន្ធត្រួតពិនិត្យ"**

នៅក្នុងប្រព័ន្ធថវិកាកម្មវិធី, ប្រព័ន្ធត្រួតពិនិត្យនិងវាយតម្លៃ ពិតជាមានសារៈសំខាន់ដែលទាមទារឱ្យមានការរៀបចំក្របខ័ណ្ឌជាបណ្តើរៗ សម្រាប់ការអនុវត្តថវិកាកម្មវិធីសាកល្បងពេញលេញ នៅគ្រប់ក្រសួង ស្ថាប័ន នៅក្នុងឆ្នាំ ២០១៨ ។ ក្នុងន័យនេះ សវនកម្មផ្ទៃក្នុង ត្រូវបានបង្កើតឡើងនៅតាមក្រសួង ស្ថាប័ន ជាបណ្តើរៗ នៅក្នុងដំណាក់កាលទី២ និងកំពុងត្រូវបានពង្រឹងមុខងារបន្ថែមទៀត ស្របពេលដែលមុខងារអធិការកិច្ចហិរញ្ញវត្ថុ ក៏កំពុងត្រូវបានកែលម្អផងដែរ ។

ទន្ទឹមនេះ អគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង នៃ កសហវ បានរៀបចំសៀវភៅគោលការណ៍ណែនាំស្តីពីសវនកម្មផ្ទៃក្នុង ដោយបញ្ជាក់អំពីនីតិវិធីលម្អិតនៃការធ្វើសវនកម្ម ព្រមទាំងធ្វើការផ្សព្វផ្សាយជូនគ្រប់អង្គភាពសវនកម្មនៃក្រសួងស្ថាប័ន។ យ៉ាងណាក៏ដោយ តាមរយៈការត្រួតពិនិត្យសុខភាពមុខងារសវនកម្មផ្ទៃក្នុងចំពោះក្រសួង ស្ថាប័នចំនួន ០៦ រួមមាន ក្រសួងអប់រំយុវជននិងកីឡា, ក្រសួងសុខាភិបាល, ក្រសួងមហាផ្ទៃ, ក្រសួងការពារជាតិ, ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងទីស្តីការគណៈរដ្ឋមន្ត្រី បានបង្ហាញថា ការពង្រឹងសមត្ថភាពបន្ថែម និងការអនុវត្តតាមស្តង់ដារសវនកម្មជាការងារអាទិភាពដើម្បីពង្រឹងមុខងារសវនកម្ម ។

ទោះបីយ៉ាងណាក៏ដោយ ការធ្វើសុខដុមនីយកម្មរវាងមុខងារសវនកម្ម និងអធិការកិច្ចនៅមិនទាន់រៀបចំរួចរាល់នៅឡើយ ដែលនេះ គឺជាការងារអាទិភាព ។ ទន្ទឹមនេះ លទ្ធផលសម្រេចបានក្នុងគោលបំណងនេះ រួមមាន÷

១. សេចក្តីព្រាងនីតិវិធីនៃផែនការចុះសវនកម្ម និងសេចក្តីព្រាងនីតិវិធីនៃការអនុវត្តសវនកម្មផ្ទៃក្នុង ត្រូវបានរៀបចំ

២. សេចក្តីព្រាងចុងក្រោយស្តីពីវិធាននិងនីតិវិធីនៃការគ្រប់គ្រងនិងអនុវត្តអធិការកិច្ចហិរញ្ញវត្ថុកម្រិតបច្ចេកទេសអន្តរអគ្គនាយកដ្ឋាន ត្រូវបានរៀបចំ ហើយដាក់ឆ្លងកិច្ចប្រជុំអន្តរក្រសួង

៣. មុខងារផលិត "ឧបសម្ព័ន្ធនៃរបាយការណ៍ចុះធ្វើអធិការកិច្ចហិរញ្ញវត្ថុ" ក្នុងប្រព័ន្ធ FIDS ត្រូវបានដាក់ប្រើប្រាស់ក្នុងការិយាល័យ និងនីតិវិធីការងារ "គ្រប់គ្រងដំណើរការ ការងារផ្ទៃក្នុង" និងមុខងារ "គ្រប់គ្រង

ដំណើរការការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈអគ្គាធិការដ្ឋាន" ក្នុងប្រព័ន្ធ FIDS ត្រូវបានរៀបចំបញ្ចប់

៤. សេចក្តីព្រាងសៀវភៅគោលស្តីពីការគ្រប់គ្រងការងារអធិការកិច្ចហិរញ្ញវត្ថុតាមបច្ចេកវិទ្យាព័ត៌មាន ត្រូវបានបញ្ចប់ និងឆ្លងយោបល់ថ្នាក់ដឹកនាំអគ្គាធិការដ្ឋាន

៥. សេចក្តីព្រាងសៀវភៅគោលស្តីពីការងារអធិការកិច្ចហិរញ្ញវត្ថុ ករណីបណ្តឹងតវ៉ា និងបរិហារ ត្រូវបានបញ្ចប់កិច្ចពិភាក្សាកម្រិតថ្នាក់ដឹកនាំអគ្គាធិការដ្ឋាន និងត្រូវដាក់ឱ្យប្រើប្រាស់

៦. សៀវភៅណែនាំនីតិវិធីសវនកម្មផ្ទៃក្នុងជូនក្រសួង ស្ថាប័ន មានសិក្ខាកាមចូលរួមចំនួន ១២៥ នាក់ ត្រូវបានចងក្រង និងរៀបចំសិក្ខាសាលាផ្សព្វផ្សាយ ។

## គោលបំណង ៣៦ "ពង្រឹងការអនុវត្តគោលនយោបាយវិមជ្ឈការហិរញ្ញវត្ថុ"

ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈគ្របដណ្តប់ទាំងហិរញ្ញវត្ថុសាធារណៈថ្នាក់ជាតិ និងហិរញ្ញវត្ថុសាធារណៈថ្នាក់ក្រោមជាតិ។ ការពង្រឹងការអនុវត្តគោលនយោបាយវិមជ្ឈការហិរញ្ញវត្ថុ ជាចំណុចគន្លឹះនៃការកែលម្អការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅថ្នាក់ក្រោមជាតិ។

រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ នឹងត្រូវដាក់អោយអនុវត្តថវិកាកម្មវិធីពេញលេញជាបណ្តើរៗតាមគោលការណ៍ស្ម័គ្រចិត្តចាប់ពីឆ្នាំ២០១៧ ដើម្បីធានាថាគ្រប់រដ្ឋបាលរាជធានី ខេត្តទាំង២៥ អនុវត្តថវិកាកម្មវិធីពេញលេញនៅឆ្នាំ ២០២០។ ជាក់ស្តែង នៅក្នុងឆ្នាំ២០១៧ កន្លងមកនេះ រដ្ឋបាលខេត្តចំនួន ៦ ត្រូវបានជ្រើសរើសអោយអនុវត្តថវិកាកម្មវិធី ដែលរួមមាន កែប, កោះកុង, កំពង់ស្ពឺ, ក្រចេះ, ប៉ៃលិន និងស្ទឹងត្រែង ហើយរដ្ឋបាលខេត្តចំនួន ៦ ផ្សេងទៀត ដូចជា កំពង់ឆ្នាំង, ពោធិ៍សាត់, កំពត, តាកែវ, ព្រៃវែង និងរតនគិរី នឹងត្រូវជ្រើសរើសបន្ថែម ដើម្បីអនុវត្ត ថវិកាកម្មវិធីចាប់ពីឆ្នាំ២០១៨ ហើយនៅឆ្នាំ២០២០ រដ្ឋបាលរាជធានី ខេត្តទាំងអស់នឹងត្រូវអនុវត្តថវិកាកម្មវិធី ។

ទន្ទឹមនេះ អគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ បានរៀបចំលិខិតបទដ្ឋានគតិយុត្ត ដែលមានវឌ្ឍន-ភាពដូចខាងក្រោម÷

១. អនុក្រឹត្យស្តីពីការកំណត់ប្រាក់ឧបត្ថម្ភសមាជិកក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបានរៀបចំរួច និងដាក់ឱ្យអនុវត្ត

២. ប្រកាសស្តីពីការបែងចែកពន្ធលើអចលនទ្រព្យជូនរដ្ឋបាលខណ្ឌ និងសង្កាត់ត្រូវបានអនុម័តនិងដាក់ឱ្យអនុវត្ត

៣. គោលការណ៍ណែនាំស្តីពីការវាយតម្លៃលក្ខណៈសម្បត្តិប្រចាំឆ្នាំ (APA) សម្រាប់រដ្ឋបាលស្រុក ត្រូវបានផ្សព្វផ្សាយនិងបណ្តុះបណ្តាលប្រកបដោយប្រសិទ្ធភាព

៤. គោលការណ៍ណែនាំស្តីពីការរៀបចំថវិកាកម្មវិធីត្រូវបានបន្តកែលំអឱ្យបានគ្រប់ជ្រុងជ្រោយ និង ត្រូវបានបណ្តុះបណ្តាលជូនរដ្ឋបាលខេត្តប្រកបដោយប្រសិទ្ធភាពសម្រាប់រដ្ឋបាលខេត្ត ដែលត្រូវបានជ្រើសរើសបន្ថែម

៥. គោលការណ៍ណែនាំស្តីពីនីតិវិធីអនុវត្តថវិកាកម្មវិធីសម្រាប់រដ្ឋបាលខេត្តដែលត្រូវបានជ្រើសរើសបន្ថែម ត្រូវបានបណ្តុះបណ្តាលជូនរដ្ឋបាលខេត្ត ។

ដើម្បីពង្រឹងផ្ទេរហិរញ្ញវត្ថុទៅថ្នាក់ក្រោមជាតិ អគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ សម្រេចបានដូចតទៅ÷

១. ជ្រើសរើសរដ្ឋបាលស្រុកចំនួនយ៉ាងតិច ១៩ សម្រាប់ការវាយតម្លៃបឋមរួច ដើម្បីអនុវត្តមូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិ

២. គោលការណ៍ណែនាំស្តីពីផែនការយុទ្ធសាស្ត្រថវិកាត្រូវបានធ្វើបច្ចុប្បន្នភាព និងដាក់ឱ្យអនុវត្ត និងត្រូវបានផ្សព្វផ្សាយ និងបណ្តុះបណ្តាល ជូនរដ្ឋបាលរាជធានី ខេត្តទាំង២៥

៣. អនុក្រឹត្យស្តីពីការផ្ទេរធនធានហិរញ្ញវត្ថុមានភ្ជាប់លក្ខខណ្ឌ ត្រូវបានផ្សព្វផ្សាយប្រកបដោយប្រសិទ្ធភាព

៤. មានរបាយការណ៍វាយតម្លៃលទ្ធផលនៃការអនុវត្តការផ្ទេរធនធានហិរញ្ញវត្ថុមានភ្ជាប់លក្ខខណ្ឌជូនរដ្ឋបាលថ្នាក់ក្រោមជាតិ (ក្រសួងបរិស្ថាន និងក្រសួងអភិវឌ្ឍន៍ជនបទ)

៥. ប្រកាសស្តីពីការដាក់ឱ្យអនុវត្តគោលការណ៍ណែនាំស្តីពីនីតិវិធីអនុវត្តថវិកាកម្មវិធីរបស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានរៀបចំរួច និងដាក់ឱ្យអនុវត្ត ព្រមទាំងត្រូវបានបណ្តុះបណ្តាលជូនរដ្ឋបាលរាជធានី ខេត្តទាំង៦

៦. ប្រកាសដាក់រដ្ឋបាលខេត្តចំនួន ៦ អនុវត្តថវិកាកម្មវិធីឆ្នាំ២០១៨ ត្រូវបានរៀបចំរួច និងដាក់ឱ្យអនុវត្ត ។

ប្រអប់ 5: វឌ្ឍនភាពនៃការផ្ទេរហិរញ្ញវត្ថុទៅរដ្ឋបាលថ្នាក់ក្រោមជាតិ

**ការផ្ទេរហិរញ្ញវត្ថុទៅរដ្ឋបាលថ្នាក់ក្រោមជាតិ**

ការផ្ទេរហិរញ្ញវត្ថុទៅរដ្ឋបាលថ្នាក់ក្រោមជាតិ បានបង្ហាញថាចំណូលឧបត្ថម្ភពីថ្នាក់ជាតិចំនួន ៧៣៧ ៨៧០ លានរៀល ដែលការឧបត្ថម្ភនេះមានកំណើន ១៥,៦% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០១៧ ក្នុងនោះ÷ (១). ឧបត្ថម្ភរាជធានី ខេត្ត ចំនួន ១៤៨ ៨១៤ លានរៀល (ស្មើនឹង ០,៩៦% នៃចំណូលចរន្តជាតិឆ្នាំ២០១៧) និងធៀបនឹងឆ្នាំ២០១៣ ដែលមានត្រឹមតែ ៧០ ២៧០ លានរៀល, (២). ឧបត្ថម្ភមូលនិធិក្រុង ស្រុក ចំនួន ១៥៥ ០១៥ លានរៀល (ស្មើនឹង ១% នៃចំណូលចរន្តជាតិឆ្នាំ២០១៧) និងធៀបនឹងឆ្នាំ២០១៣ ដែលមានត្រឹមតែ ៥៨ ៤០៥ លានរៀល និង (៣). ឧបត្ថម្ភមូលនិធិឃុំ សង្កាត់ ចំនួន ៤៣៤ ០៤១ លានរៀល (ស្មើនឹង ២,៨% នៃចំណូលចរន្តជាតិឆ្នាំ២០១៧) ធៀបនឹងឆ្នាំ២០១៣ ដែលមានត្រឹមតែ ២០៤ ៤១៨ លានរៀល ។

ប្រអប់ 6: ការងារត្រូវធ្វើបន្តនៃផ្នែកទី៣ "ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ"

**ការងារត្រូវធ្វើបន្ត**

កសហវ នឹងធ្វើការរៀបចំ MTFF និង MTBF ។ ទន្ទឹមនេះ កសហវ នឹងបន្តសហការជាមួយក្រសួង ស្ថាប័ន ដើម្បីពង្រឹង និងកែលម្អគុណភាពនៃការរៀបចំផែនការយុទ្ធសាស្ត្រថវិកា ព្រមទាំងពង្រឹងសមត្ថភាពបន្ថែមលើការគ្រប់គ្រងស្ថិតិជាតិ និងការព្យាករ ។ បន្ថែមពីនេះ កសហវ ក៏នឹងរៀបចំយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាថ្នាក់ក្រោមជាតិឆ្នាំ២០១៩-២០២៥ ដើមបន្សុីនឹង BSRS ឆ្នាំ២០១៨-២០២៥។

### គ.៤. ផ្នែកទី៤ "គណនេយ្យភាពសមិទ្ធកម្ម"

ផ្នែកទី៤ ត្រូវបានបង្កើតឡើង ក្នុងការត្រៀមខ្លួនសម្រាប់ជំហានបន្ទាប់។ ក្នុងន័យនេះ ការត្រៀមខ្លួនសម្រាប់ជំហានបន្ទាប់ កសហវ ត្រូវរៀបចំក្របខ័ណ្ឌទទួលខុសត្រូវ និងបង្កើនភាពជាម្ចាស់ និងឈានទៅបង្កើនប្រសិទ្ធភាពនៃការរៀបចំផែនការកសាងសមត្ថភាព។ ទន្ទឹមនេះ ក្រសួង ស្ថាប័ន ត្រូវរៀបចំតាមដាន ត្រួតពិនិត្យ និងវាយតម្លៃនៃការអភិវឌ្ឍសមត្ថភាពមន្ត្រីរាជការ និងកែលម្អតម្រូវការផែនការបណ្តុះបណ្តាលផ្នែកសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ផ្នែកនេះ គួរតែផ្តោតការយកចិត្តទុកដាក់ខ្ពស់លើ (១). ក្របខ័ណ្ឌគោលនៃសវនកម្មផ្អែកលើសមិទ្ធកម្ម (២). ក្របខ័ណ្ឌគោលនៃគោលការណ៍ថវិកាផ្អែកលើសមិទ្ធកម្ម និង (៣). ការរៀបចំផែនការកសាងសមត្ថភាពផ្នែកសេដ្ឋកិច្ច និងហិរញ្ញវត្ថុនៅគ្រប់ក្រសួង ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ។

ដើម្បីកំណត់ទិសដៅច្បាស់លាស់នៃប្រព័ន្ធថវិកាកម្ពុជា យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ២០១៨-២០២៥ ត្រូវបានរៀបចំនិងដាក់ឱ្យអនុវត្ត និងរៀបចំផែនការយុទ្ធសាស្ត្រស្តីពីការកសាង និងអភិវឌ្ឍន៍សមត្ថភាពក្នុងក្របខ័ណ្ឌកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។

អ.គ.ហ. បានធ្វើការកែសម្រួលក្របខ័ណ្ឌផែនការសកម្មភាពរួម ដំណាក់កាលទី៣ ឱ្យស្របតាមទិសដៅនៃយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ២០១៨-២០២៥ ដោយក្នុងនោះផ្នែកទី៤ "គណនេយ្យភាពហិរញ្ញវត្ថុ" មានសូចនាករផ្នែកចំនួនបី និងមានសូចនាករវាស់វែងចំនួន ៣ រួមមាន (១). ក្របខ័ណ្ឌគណនេយ្យភាព នៃថវិកាសមិទ្ធកម្ម រួមមាន ក្របខ័ណ្ឌសមិទ្ធកម្មនៃក្រសួង ស្ថាប័ន និងក្របខ័ណ្ឌសមិទ្ធកម្មនៃមន្ត្រី ត្រូវបានរៀបចំ, (២). ក្របខ័ណ្ឌសវនកម្មសមិទ្ធកម្ម (គ្រប់អង្គភាពសវនកម្មផ្ទៃក្នុងនៃក្រសួង ស្ថាប័នមានផែនការយុទ្ធសាស្ត្រសវនកម្មផ្ទៃក្នុង និងផែនការសវនកម្មផ្ទៃក្នុងប្រចាំឆ្នាំ និងមានសមត្ថភាពធ្វើសវនកម្មហិរញ្ញវត្ថុ, អនុលោមភាពតាមក្របខ័ណ្ឌគតិយុត្ត, ប្រព័ន្ធព័ត៌មានវិទ្យា និងសមិទ្ធកម្ម) ត្រូវបានរៀបចំ និង (៣). ក្របខ័ណ្ឌត្រួតពិនិត្យនិងវាយតម្លៃ នៃថវិកាសមិទ្ធកម្ម រួមទាំងយន្តការប្រតិគុល្យការរវាងស្ថាប័ននីតិប្រតិបត្តិ និងស្ថាប័ននីតិបញ្ញត្តិ ត្រូវបានរៀបចំ ។ ទន្ទឹមនេះ ផ្នែកនេះ បានធ្វើការបែងចែកជា ៤ គោលបំណង រួមមាន ៤១. បង្កើតក្របខ័ណ្ឌថវិកាព័ត៌មានសមិទ្ធកម្ម (Performance-Informed Budgeting), ៤២. រៀបចំ និងដាក់ឱ្យអនុវត្តក្របខ័ណ្ឌគណនេយ្យភាពសមិទ្ធកម្ម, ៤៣. ពង្រឹងប្រសិទ្ធភាពប្រព័ន្ធត្រួតពិនិត្យ និង ៤៤. ពង្រឹងសមត្ថភាពបន្ថែមសម្រាប់ស្ថាប័ននីតិបញ្ញត្តិ និងអាជ្ញាធរសវនកម្មជាតិលើប្រព័ន្ធប្រតិគុល្យភាព លើការរៀបចំច្បាប់ស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុប្រចាំឆ្នាំ និងច្បាប់ស្តីពីការទូទាត់ថវិកាប្រចាំឆ្នាំ ។

ប្រអប់ 7: ការងារត្រូវធ្វើបន្តនៃផ្នែកទី៤ "គណនេយ្យភាពសមិទ្ធកម្ម"

**ការងារត្រូវធ្វើបន្ត**

កសហវ នឹងធ្វើការរៀបចំផែនការសកម្មភាពលម្អិតនៃ BSRS ឆ្នាំ២០១៨-២០២៥ ជាពិសេស ការងារសំខាន់ៗ ដែលត្រូវអនុវត្តរួមមាន ការរៀបចំគោលការណ៍ណែនាំស្តីពីការរៀបចំថវិកាសមិទ្ធកម្ម, គោលការណ៍ណែនាំស្តីពីការអនុវត្តថវិកាសមិទ្ធកម្ម។ ទន្ទឹមនេះ កសហវ នឹងពិនិត្យ និងធ្វើវិសោធនកម្មច្បាប់ស្តីពីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងអនុក្រឹត្យលេខ ៨១ ស្តីពីការបង្កើតការត្រួតពិនិត្យហិរញ្ញវត្ថុលើការចំណាយថវិការដ្ឋនៅតាមក្រសួង ខេត្ត ក្រុង ក្រុងស្វយ័តរាជធានីភ្នំពេញ និងគ្រឹះស្ថានសាធារណៈរដ្ឋបាល និងអនុក្រឹត្យលេខ ៨២ ស្តីពីបទបញ្ញត្តិទូទៅ នៃគណនេយ្យសាធារណៈ ។

ចំណែកឯ ការងារពាក់ព័ន្ធនឹងការងារពង្រឹងមុខងារសវនកម្មវិញ អ.ស.ក. នឹងធ្វើការរៀបចំគោលការណ៍ស្តីពីសវនកម្មតាមប្រព័ន្ធព័ត៌មានវិទ្យា និងគោលការណ៍ណែនាំស្តីពីសវនកម្មផ្អែកលើសមិទ្ធកម្ម ព្រមទាំងត្រួតពិនិត្យមុខងារគ្រប់ក្រសួង ស្ថាប័ន ។

## ក.៥. ផ្នែកទី៥ "ការគាំទ្រដល់ការអនុវត្តកម្មវិធីកែទម្រង់ប្រកបដោយជោគជ័យ និងចីរភាព"

ការគាំទ្រដល់ការអនុវត្តកម្មវិធីកែទម្រង់ប្រកបដោយជោគជ័យ និងចីរភាព សំដៅដល់ការចូលរួមគាំទ្រក្នុងកម្មវិធីកែទម្រង់ចាប់តាំងពីជំហាននៃការរៀបចំ ការអនុវត្ត ការត្រួតពិនិត្យ និងវាយតម្លៃ នៃផែនការសកម្មភាពកែទម្រង់ ។ កត្តានេះ ឆ្លុះបញ្ចាំងពីសមត្ថភាពដឹកនាំ គ្រប់គ្រង និងឆន្ទៈ របស់ក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដើម្បីជំរុញការអនុវត្តផែនការសកម្មភាពប្រកបដោយជវភាព ។ ទន្ទឹមនេះ ការពង្រឹងសមត្ថភាព និងការរៀបចំយន្តការលើកទឹកចិត្តជូនគ្រប់ក្រុមការងារកែទម្រង់ទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលជាមូលដ្ឋានគ្រឹះក្នុងការត្រៀមខ្លួនសម្រាប់ជំហានបន្ទាប់នៃកម្មវិធីកែទម្រង់ ។

ដោយមានការចង្អុលបង្ហាញ និងការណែនាំពីឯកឧត្តមបណ្ឌិតសភាចារ្យទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី កសហវ និងជាប្រធានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ អ.គ.ហ. បានធ្វើរៀបចំមូលនិធិនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងកំពុងរៀបចំនីតិវិធីលម្អិត។ គោលបំណងនៃការរៀបចំមូលនិធិនេះ គឺដើម្បីមានមូលនិធិថវិកាគ្រប់ជ្រុងជ្រោយមួយ ដែលអាចគាំទ្រកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងលើកកម្ពស់ភាពជាម្ចាស់របស់រាជរដ្ឋាភិបាលលើកម្មវិធីកែទម្រង់របស់ខ្លួន ក្នុងបរិបទដែលថវិការបស់ដៃគូអភិវឌ្ឍន៍កាន់តែមានការថមថយចុះជាបណ្តើរៗ ។

ទន្ទឹមនេះ កសហវ បានរៀបចំសារាចរលេខ ០៤ ដើម្បីពង្រឹងការអនុវត្តប្រកាសលេខ ៦១៦ សហវ.ប្រក ស្តីពីមូលនិធិលើកទឹកចិត្តស្តីពីគោលការណ៍ យន្តការ នីតិវិធី និងការត្រួតពិនិត្យសម្រាប់ផ្តល់ការលើកទឹកចិត្ត ។ អនុលោមតាមសារាចរលេខ០៤ កសហវ នឹងកាត់ប្រាក់ឧបត្ថម្ភមុខងារសម្រាប់ការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈប្រចាំត្រីមាស ដោយផ្អែកលើសមិទ្ធកម្មរបស់អង្គភាពនីមួយៗ ។

បន្ថែមពីនេះ វិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានរៀបចំផែនការយុទ្ធសាស្ត្រស្តីពីការកសាង និងអភិវឌ្ឍន៍សមត្ថភាពក្នុងក្របខ័ណ្ឌកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនិងបានទទួលការឯកភាពពីឯកឧត្តមបណ្ឌិត

សភាចារ្យទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី កសហវ នៅថ្ងៃទី០៥ ខែមករា ឆ្នាំ២០១៨ ។ ម្យ៉ាងទៀត តាមរយៈការចូលរួមការអនុវត្តកម្មវិធីកែទម្រង់នេះ ក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៃ កសហវ បានទទួលការបណ្តុះបណ្តាលទាំងក្នុង និងក្រៅប្រទេស ព្រមទាំងទស្សនកិច្ចសិក្សានៅបរទេសពាក់ព័ន្ធការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, ការគ្រប់គ្រងចំណូលពន្ធ, ទ្រព្យសម្បត្តិរដ្ឋ, សេដ្ឋកិច្ច និងភាពជាអ្នកដឹកនាំ ។ល។

វឌ្ឍនភាពតាមគោលបំណងនៃផ្នែកទី៥ "ការគាំទ្រដល់ការអនុវត្តកម្មវិធីកែទម្រង់ប្រកបដោយជោគជ័យ និងចីរភាព" បង្ហាញដូចតទៅ÷

**គោលបំណង ៥១ "បង្កើនភាពជាអ្នកដឹកនាំ សមត្ថភាព គ្រប់គ្រង និង បណ្តុះឆន្ទៈកំណែទម្រង់ព្រមទាំងបង្កើនភាពជាម្ចាស់ និងការទទួលខុសត្រូវ"**

គោលបំណងនេះ មានគោលដៅឱ្យគ្រប់អង្គភាពទាំងអស់ពង្រឹងសមត្ថភាពជាអ្នកដឹកនាំ និងបណ្តុះឆន្ទៈការងារកែទម្រង់ប្រកបដោយភាពទទួលខុសត្រូវគ្រប់កម្រិត ។

អ.គ.ហ. សហការជាមួយអង្គភាពក្រោមឱវាទ កសហវ ធ្វើការរៀបចំសិក្ខាសាលា/វគ្គបណ្តុះបណ្តាល/កម្មវិធីផ្សព្វផ្សាយជាច្រើនក្នុងគោលដៅលើកកម្ពស់ការយល់ដឹងលើ PFMRP ជូនដល់មន្ត្រីរាជការគ្រប់ក្រសួង ស្ថាប័ន និងគ្រប់រដ្ឋបាលរាជធានី ខេត្ត ។

បន្ថែមពីនេះ ក្រុមប្រឹក្សានីតិកម្មនៃ កសហវ បានធ្វើការរៀបចំកម្រងសម្រង់បទប្បញ្ញត្តិគតិយុត្តពាក់ព័ន្ធឧស្សាហកម្មហិរញ្ញវត្ថុ, កម្រងសម្រង់បទប្បញ្ញត្តិគតិយុត្តពាក់ព័ន្ធគណនេយ្យ ព្រមទាំងបានរៀបចំ និងដាក់ឱ្យដំណើរការកម្មវិធីបច្ចេកវិទ្យាព័ត៌មានតាមវឌ្ឍនភាពនៃកម្រងសម្រង់នីមួយៗ ។

ដើម្បីជំរុញការអនុវត្តការគ្រប់គ្រងការផ្លាស់ប្តូរ នៅតាមក្រសួង ស្ថាប័ន ក្រុមការងារ FMIS បានរៀបចំផែនការបង្កើនកម្រិតយល់ដឹង ភាពជាម្ចាស់ការចូលរួម និងសមត្ថភាពផ្នែក FMIS ដល់ កសហវ ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ព្រមទាំងឧបករណ៍វាយតម្លៃលទ្ធផលនៃការអនុវត្តផែនការបណ្តុះបណ្តាលក្រុមការងារគ្រប់គ្រង និងក្រុមការងារ FMWG និងមន្ត្រីអនុវត្តប្រព័ន្ធ FMIS ។

**គោលបំណង ៥២ "បង្កើនប្រសិទ្ធភាពនៃការកសាងសមត្ថភាព និងវិធានការលើកទឹកចិត្ត"**

គោលបំណងនេះ សំដៅដល់ការរៀបចំនូវយន្តការលើកទឹកចិត្តដែលមានប្រសិទ្ធភាព ក្នុងការជំរុញការអនុវត្តនូវការងារកែទម្រង់របស់អ្នកចូលរួមអនុវត្ត ។

ជារួម គោលបំណងនេះ មានវឌ្ឍនភាព ដូចតទៅ÷

១. ប្រកាសស្តីពីវិធាន និងនីតិវិធី នៃការរៀបចំ ការអនុវត្ត ការត្រួតពិនិត្យ និងវាយតម្លៃ នៃការអភិវឌ្ឍសមត្ថភាពមន្ត្រីរាជការ នៃកសហវ ត្រូវបានដាក់ជូនថ្នាក់ដឹកនាំ ពិនិត្យ និងសម្រេច

២. ផែនការបណ្តុះបណ្តាលសម្រាប់ឆ្នាំ២០១៧-២០១៨ របស់អគ្គលេខាធិការដ្ឋាន កសហវ ត្រូវបានអនុម័ត ។

**គោលបំណង៥៣"ពង្រឹងការកសាងសមត្ថភាពសម្រាប់អនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី៣"**

គោលបំណងនេះ សំដៅដល់ពង្រឹងនូវសមត្ថភាពរបស់ស្ថាប័ន ទាំងក្នុងក្របខ័ណ្ឌនៃការរៀបចំលិខិតបទដ្ឋានគតិយុត្ត និងប្រព័ន្ធអនុវត្តការងារ ដែលជាការត្រៀមលក្ខណៈគ្រប់គ្រាន់រួចរាល់សម្រាប់សម្រេចបាននូវការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី៣ ។

ជាវឌ្ឍនភាព អង្គភាពក្រោមឱវាទ កសហវ សម្រេចបាននូវសូចនាករសំខាន់ៗមាន÷

១. អង្គភាពក្រោមឱវាទ កសហវ បានធ្វើការសិក្សា និងធ្វើការវិភាគមុខងារ
២. សៀវភៅណែនាំស្តីពីការគ្រប់គ្រងមន្ត្រីពន្ធដារត្រូវបានដាក់ឱ្យអនុវត្តនិងផ្សព្វផ្សាយដល់មន្ត្រីនៃនាយកដ្ឋានថ្នាក់កណ្តាល និងសាខាពន្ធដារខេត្ត ខណ្ឌ
៣. ប្រព័ន្ធវាយតម្លៃលទ្ធផលការងាររបស់មន្ត្រីពន្ធដារត្រូវបានដាក់ឱ្យអនុវត្តជាផ្លូវការនៅគ្រប់អង្គភាពពន្ធដារ
៤. មន្ត្រីរាជការពន្ធដារទាំងអស់ត្រូវបានទទួលការបណ្តុះបណ្តាលដើម្បីមានសមត្ថភាពធ្វើការផ្លាស់ប្តូរព័ត៌មានផ្ទាល់ខ្លួននៅក្នុងប្រព័ន្ធគ្រប់គ្រងមន្ត្រីរាជការពន្ធដារទៅតាមគោលការណ៍ដែល អ.ព.ដ. បានកំណត់
៥. យន្តការនៃការគ្រប់គ្រងបញ្ជីបៀវត្សរបស់មន្ត្រី កសហវ ត្រូវបានបង្កើត និងកែលម្អ និងប្រព័ន្ធផ្តល់ព័ត៌មានបៀវត្សនិងបណ្តឹងតវ៉ាត្រូវបានបង្កើត
៦. ប្រព័ន្ធគ្រប់គ្រងទិន្នន័យមន្ត្រីរាជការ ត្រូវបានសាកល្បងប្រើប្រាស់ និងរក្សាទុកឯកសារពាក់ព័ន្ធប្រវត្តិរូបមន្ត្រីរាជការក្នុងទម្រង់អេឡិកត្រូនិក
៧. ផែនការកសាងសមត្ថភាពមន្ត្រី កសហវ លើផ្នែកព័ត៌មានវិទ្យាកម្រិតមូលដ្ឋាន បានរៀបចំរួចរាល់ និងផ្ញើជូនអង្គភាពរៀបចំការបណ្តុះបណ្តាលសម្រាប់ការអនុវត្ត និងមានឧបករណ៍វាយតម្លៃ ការអនុវត្តផែនការកសាងសមត្ថភាពមន្ត្រី កសហវ លើចំណេះដឹងមូលដ្ឋានផ្នែកបច្ចេកវិទ្យាព័ត៌មាន ត្រូវបានរៀបចំ និងចងក្រងរួចរាល់
៨. មន្ត្រីរាជការចំនួន ៧៧៥ នាក់ នៃក្រសួង ស្ថាប័ន ចំនួន ១១ និងមន្ទីរអង្គភាពក្រោមឱវាទនៅថ្នាក់មូលដ្ឋាននៃរាជធានី ខេត្ត ដែលត្រូវអនុវត្តថវិកាកម្មវិធីពេញលេញសាកល្បងនៅឆ្នាំ២០១៧ ទទួលបានការបណ្តុះបណ្តាលស្តីពីនីតិវិធីអនុវត្តថវិកាកម្មវិធីសម្រាប់អង្គភាពថវិកា ។

យោងតាមរបាយការណ៍វឌ្ឍនភាពរបស់គ្រប់អង្គភាពក្រោមឱវាទ កសហវ បានបង្ហាញឱ្យឃើញថាមន្ត្រីពាក់ព័ន្ធគ្រប់អគ្គនាយកដ្ឋានបានចូលរួមក្នុងវគ្គបណ្តុះបណ្តាលជំនាញពាក់ព័ន្ធជាបន្តបន្ទាប់ ដែលរួមទាំងជំនាញដឹកនាំ និងជំនាញបច្ចេកទេសខណៈឧបករណ៍វាយតម្លៃការអភិវឌ្ឍន៍ធនធានមនុស្សក្នុងក្របខ័ណ្ឌមួយចំនួនត្រូវបានបង្កើតឡើង។ លើសពីនេះ ការផ្សារភ្ជាប់នីតិវិធីការងារបច្ចុប្បន្នជាមួយប្រព័ន្ធព័ត៌មានវិទ្យានៅអង្គភាពមួយចំនួនត្រូវបានបង្កើតឡើងដើម្បីបង្កលក្ខណៈងាយស្រួល និងចំណេញពេលវេលានៅពេលអនុវត្ត ។

ប្រអប់ 8: ការងារត្រូវធ្វើបន្តនៃផ្នែកទី៥ "ការគាំទ្រកម្មវិធីកែទម្រង់ប្រកបដោយជោគជ័យ និងចីរភាព"

**ការងារត្រូវធ្វើបន្ត**

ដើម្បីគាំទ្រការអនុវត្តកម្មវិធីកែទម្រង់ប្រកបដោយជោគជ័យ និងចីរភាព កសហវ នឹងកសាងសមត្ថភាពផ្ទៃក្នុង និងមន្ត្រីនៅតាមក្រសួង ស្ថាប័ន ឱ្យក្លាយជាមន្ត្រីវិភាគថវិកា ។ ជាជំហានដំបូង អ.ថ. នឹងធ្វើការសិក្សា និងរៀបចំកម្មវិធីបណ្តុះបណ្តាលសម្រាប់មន្ត្រីផ្ទៃក្នុង ដើម្បីឱ្យក្លាយជាគ្រូបង្គោល និងជាកិច្ចបន្ទាប់ អ.ថ. នឹងចាប់ផ្តើមបណ្តុះបណ្តាលមន្ត្រីបង្គោលនៅគ្រប់ក្រសួង ស្ថាប័ន ។

## ខ. សមិទ្ធកម្មតាមក្រសួង ស្ថាប័ន

របាយការណ៍វឌ្ឍនភាពនៃការផែនការសកម្មភាព (MAP) របស់ក្រសួង ស្ថាប័នទាំង៤០ ត្រូវបែងចែកជា ៥ ស្ថាប័ន រួមមាន÷

១. ស្ថាប័នសេវាសេដ្ឋកិច្ច

២. ស្ថាប័នសេវាហិរញ្ញវត្ថុ ការបរទេស និងសេវាសាធារណៈទូទៅ

៣. ស្ថាប័នសេវាការពារជាតិ សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ

៤. ស្ថាប័នសេវាសង្គមកិច្ច

៥. ស្ថាប័នសេវាកំពូល និងឯករាជ្យ ។

វឌ្ឍនភាពរបស់ក្រសួង ស្ថាប័ន នីមួយៗ ជាភាគរយ (%) មិនមានន័យថា ជាការប្រៀបធៀបក្រសួង ស្ថាប័នមួយទៅក្រសួង ស្ថាប័នមួយទៀតទេ ដោយសារតែគុណភាពនៃការរៀបចំផែនការសកម្មភាពក្រសួង ស្ថាប័នមួយចំនួនមានកម្រិតសកម្មភាពគាំទ្រតិច និងការងារជាប្រចាំថ្ងៃ រីឯក្រសួង ស្ថាប័នផ្សេងទៀត មានសកម្មភាពច្រើន និងជាប្រភេទការងារកែទម្រង់ ។

គ្រប់ក្រសួង ស្ថាប័ន គឺធ្វើការរៀបចំផែនការសកម្មភាព (MAP) ស្របតាមទម្រង់នៃក្របខ័ណ្ឌផែនការសកម្មភាពរួមដំណាក់កាលទី៣ ។ ជាគោលការណ៍ គ.ហ.ស. បានធ្វើការសម្រេចកំណត់ពិដានថវិកាក្នុងមួយក្រសួង ស្ថាប័ន ផ្តល់ជូនចំនួន ១២០ លានរៀល ដើម្បីគាំទ្រលើការងារអាទិភាពចំនួន ៣ រួមមាន (១). ពង្រឹងការគ្រប់គ្រងការប្រមូលចំណូល, (២). ពង្រឹងការអនុវត្តប្រព័ន្ធ FMIS និង (៣).ការពង្រឹងការអនុវត្តថវិកាកម្មវិធី។ ក្នុងន័យនេះ ក្រសួង ស្ថាប័ន ធ្វើការរៀបចំ និងអនុវត្តផែនការសកម្មភាពប្រចាំឆ្នាំ២០១៧ ពាក់ព័ន្ធនឹងការបណ្តុះបណ្តាលលើវិស័យហិរញ្ញវត្ថុសាធារណៈ ជាពិសេសលើការងារថវិកាកម្មវិធី, ផែនការយុទ្ធសាស្ត្រថវិកា, លទ្ធកម្មសាធារណៈ និងកិច្ចការគណនេយ្យសាធារណៈ ដើម្បីបង្កើនសមត្ថភាពជំនាញឱ្យស្របតាមបរិបទកែទម្រង់ប្រព័ន្ធថវិកាថ្មី។ រីឯ ការអនុវត្តថវិកាឆ្នាំ២០១៧ របស់ក្រសួង ស្ថាប័ន គាំទ្រកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ សម្រេចបានចំនួន ២ ៨៦២ លានរៀល ស្មើនឹង ៦០% នៃកញ្ចប់ថវិកាអនុវត្តសរុប ប៉ុន្តែប្រសិនបើគិតទាំងបុរេប្រទាន និងលទ្ធកម្មមិនទាន់ទូទាត់សម្រេចបានចំនួន ៣ ៨៨៨ លានរៀល ស្មើនឹង ៨១,៥% នៃកញ្ចប់ថវិកាអនុវត្តសរុប ។

ដ្យាក្រាម 3: លទ្ធផលនៃការអនុវត្តថវិកាគាំទ្រកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ




ប្រភព÷ អ.គ.ហ.

ទន្ទឹមនេះ ក្រសួង ស្ថាប័នចំនួន ៦ មិនមានតម្រូវការថវិកានៃកម្មវិធីកែទម្រង់ឆ្នាំ២០១៧ រួមមានក្រសួងយុត្តិធម៌, សាលាឧទ្ធរណ៍មហាអយ្យការ, ក្រសួងពត៌មាន, ក្រសួងព្រះបរមរាជវាំង, អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ និង អគ្គលេខាធិការដ្ឋានតុលាការកំពូល ។

តារាង 4: លទ្ធផលនៃការអនុវត្តថវិកា និងសមិទ្ធកម្មរបស់ក្រសួង ស្ថាប័ន

| វិស័យ | ក្រសួង ស្ថាប័ន | ថវិកាអនុម័ត (លានរៀល) | ថវិកាអនុវត្ត (លានរៀល) | ចំនួនសកម្មភាពសម្រេចបាន | ពិន្ទុទទួលបាន (%) |
|---|---|---|---|---|---|
| ស្ថាប័នសេវាសេដ្ឋកិច្ច | រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល | 121 | 45.53 | 17/25 | 59 |
| | ក្រសួងឧស្សាហកម្ម និងសិប្បកម្ម | 120 | 123.5 | 11/25 | 64 |
| | ក្រសួងរ៉ែ និងថាមពល | 124 | 66.96 | 15/20 | 87 |
| | ក្រសួងពាណិជ្ជកម្ម | 124 | 43.46 | 23/39 | 90 |
| | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | 113 | 115.58 | 33/43 | 76 |
| | ក្រសួងអភិវឌ្ឍន៍ជនបទ | 117 | 98.74 | 21/29 | 94 |
| | ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | 107 | 81.52 | 21/32 | 91 |
| | ក្រសួងសាធារណការ និងដឹកជញ្ជូន | 128 | 112.96 | 20/55 | 50 |
| | ក្រសួងទេសចរណ៍ | 115 | 32.6 | 15/24 | 92 |
| | ក្រសួងធនធានទឹក និងឧតុនិយម | 126 | 68.88 | 15/18 | 83 |

| វិស័យ | ក្រសួង ស្ថាប័ន | ថវិកាអនុម័ត (លានរៀល) | ថវិកាអនុវត្ត (លានរៀល) | ចំនួនសកម្មភាពសម្រេចបាន | ពិន្ទុទទួលបាន (%) |
|---|---|---|---|---|---|
| | ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ | 137 | 116.67 | 15/19 | 91 |
| ស្ថាប័នសេវាហិរញ្ញវត្ថុ ការបរទេសនិងសេវាសាធារណៈទូទៅ | ទីស្ដីការគណៈរដ្ឋមន្ត្រី | 49 | 0.4 | 4/10 | 82 |
| | ក្រសួងមុខងារសាធារណៈ | 118 | 129.84 | 35/35 | 100 |
| | ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | 82 | 9.83 | 11/12 | 86 |
| | ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច | 119 | 128.32 | 13/14 | 98 |
| | ក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ | 0 | 0 | 10/19 | 71 |
| | ក្រសួងពត៌មាន | 120 | 0 | 5/8 | 94 |
| | ក្រសួងផែនការ | 322 | 292.54 | 27/37 | 91 |
| | គណៈកម្មការមូលបត្រកម្ពុជា | 93 | 68.97 | 3/4 | 91 |
| ស្ថាប័នសេវាការពារជាតិ សន្តសុខ និងសណ្ដាប់ធ្នាប់សាធារណៈ | ក្រសួងការពារជាតិ | 117 | 110.37 | 19/19 | 100 |
| | ក្រសួងមហាផ្ទៃ-ផ្នែកសន្តិសុខ | 116 | 34.7 | 23/25 | 99 |
| | ក្រសួងមហាផ្ទៃ-ផ្នែករដ្ឋបាលទូទៅ | 123 | 132.83 | 19/19 | 100 |
| | ក្រសួងបរិស្ថាន | 119 | 122.09 | 16/18 | 98 |
| | ក្រសួងរៀបចំដែនដី នគរូបនីកម្ម និងសំណង់ | 119 | 0 | 13/19 | 98 |
| ស្ថាប័នសេវាសង្គមកិច្ច | ក្រសួងសុខាភិបាល | 120 | 110.44 | 14/16 | 92 |
| | ក្រសួងអប់រំ យុវជន និងកីឡា | 135 | 120.89 | 26/35 | 95 |
| | ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | 94 | 127.22 | 18/19 | 95 |
| | ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា | 91 | 56.03 | 13/17 | 88 |
| | ក្រសួងធម្មការ និង សាសនា | 115 | 63.38 | 26/29 | 86 |
| | ក្រសួងកិច្ចការនារី | 110 | 113.09 | 11/13 | 98 |
| | ក្រសួងព្រះបរមរាជវាំង | 120 | 0 | 9/15 | 64 |
| | អគ្គលេខាធិការដ្ឋាន | 120 | 0 | 2/9 | 62 |

| វិស័យ | ក្រសួង ស្ថាប័ន | ថវិកាអនុម័ត (លានរៀល) | ថវិកាអនុវត្ត (លានរៀល) | ចំនួនសកម្មភាពសម្រេចបាន | ពិន្ទុទទួលបាន (%) |
|---|---|---|---|---|---|
| ស្ថាប័នសេវាកំពូល និងឯករាជ្យ | ក្រុមប្រឹក្សាធម្មនុញ្ញ | | | | |
| | អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា | 20 | 0 | 12/19 | 95 |
| | អគ្គលេខាធិការដ្ឋានរដ្ឋសភា | 122 | 0 | 3/30 | 14 |
| | សាលាឧទ្ធរណ៍មហាអយ្យការ | 120 | 0 | 3/6 | 21 |
| | ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម | 94 | 89.06 | 5/5 | 100 |
| | គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត | 69 | 20.99 | 20/20 | 100 |
| | អាជ្ញាធរសវនកម្មជាតិ | 289 | 140.13 | 26/29 | 96 |
| | អង្គភាពប្រឆាំងអំពើពុករលួយ | 82 | 83.06 | 3/5 | 85 |
| | អគ្គលេខាធិការដ្ឋាននៃតុលាការកំពូល | 120 | 0 | ពុំទាន់ទទួលឯកសារផ្លូវការ | |
| | ក្រសួងយុត្តិធម៌ | 120 | 0 | 14/20 | 70 |

## គ. លទ្ធផលនៃការសិក្សាស្រាវជ្រាវស្តីពីការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី៣

### គ.១. សេចក្តីផ្តើម

ថវិកាកម្មវិធីត្រូវបានដាក់ឱ្យអនុវត្តសាកល្បងក្នុងឆ្នាំ២០០៨ ដោយអនុវត្តមិនពេញលេញចំពោះក្រសួង ស្ថាប័នចំនួន ៨ ។ ស្របតាមទស្សនាទានស្តីពីការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ២០១៣-២០២០ រាជរដ្ឋាភិបាលកម្ពុជាបានដាក់ឱ្យក្រសួង ស្ថាប័ន អនុវត្តថវិកាកម្មវិធីសាកល្បងពេញលេញជាដំណាក់កាលពីឆ្នាំ២០១៥-២០១៨ ។ ថវិកាកម្មវិធីគឺជាឧបករណ៍ដើម្បីផ្សារភ្ជាប់រវាងយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៣ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ២០១៤-២០១៨ ។ តួយ៉ាងក្រសួងចំនួន ១០ ដែលត្រូវបានដាក់ឱ្យអនុវត្តថវិកាកម្មវិធីពេញលេញនៅឆ្នាំ២០១៥។ រហូតមកដល់ពេលនេះ គ្រប់ក្រសួង ស្ថាប័ន ត្រូវបានដាក់ឱ្យអនុវត្តថវិកាកម្មវិធីសាកល្បងពេញលេញ ដែលក្នុងនោះ នៅឆ្នាំ២០១៥ មាន ១០ ក្រសួង ស្ថាប័ន, ឆ្នាំ២០១៦ បន្ថែម ១៥ ក្រសួង ស្ថាប័ន, ឆ្នាំ២០១៧ បន្ថែម ១១ ក្រសួង ស្ថាប័ន និងឆ្នាំ២០១៨ បន្ថែម ៣ ក្រសួង ស្ថាប័ន ដែលសរុបមានចំនួន ៣៩ ។ ចំណែកឯ គ្រប់រដ្ឋបាលរាជធានី ខេត្តទាំង ២៥ ត្រូវបានដាក់ឱ្យអនុវត្តថវិកាកម្មវិធីចាប់ពីឆ្នាំ២០១៧-២០២០។

ក្រុមការងាររៀបចំរបាយការណ៍ត្រួតពិនិត្យ និងវាយតម្លៃវឌ្ឍនភាពកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៃ អ.គ.ហ.បានចុះជួបពិភាក្សា និងស្វែងយល់បន្ថែមអំពីបទពិសោធន៍របស់ក្រសួងទាំង ៤ អនុវត្តថវិកម្មវិធី

ដោយក្នុងនោះ រួមមាន (១).ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ, (២).ក្រសួងអប់រំ យុវជន និងកីឡា, (៣).ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និង (៤).ក្រសួងមុខងារសាធារណៈ និងរដ្ឋបាលរាជធានី ខេត្ត រួមមាន (១).ភ្នំពេញ និង (២). កំពង់ស្ពឺ ។

**គ.២. លទ្ធផលនៃការសិក្សាស្រាវជ្រាវ**

ឆ្លងតាមរយៈការដាក់ឱ្យអនុវត្តថវិកាកម្មវិធីនេះ ជាបទពិសោធឃើញថា ក្រសួង ស្ថាប័ន និងរដ្ឋបាលរាជធានី ខេត្ត ស្វាគមន៍ចំពោះអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធាណៈ ដោយដាក់ឱ្យអនុវត្តថវិកាកម្មវិធី ។ ទន្ទឹមនេះ ក្រសួង ស្ថាប័ន បានព្យាយាមបន្សុី/តម្រឹមរវាងយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៣, ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ ជាតិឆ្នាំ២០១៤-២០១៨, គោលនយោបាយតាមវិស័យ និងផែនការយុទ្ធសាស្ត្រថវិកា ព្រមទាំងធ្វើការបន្សុីរចនាសម្ព័ន្ធ រដ្ឋបាលទៅនឹងគោលបំណងគោលនយោបាយ និងកម្មវិធីនៃផែនការយុទ្ធសាស្ត្រថវិកា ។

ក្នុងន័យនេះ តាមការអង្កេតជាក់ស្តែង ការរៀបចំរចនាសម្ព័ន្ធរដ្ឋបាល ទៅបន្សុីជាមួយគោលបំណងគោល- នយោបាយ, កម្មវិធី និងអនុវត្តកម្មវិធី អាចធ្វើទៅបានក្នុងដំណាក់កាលដំបូង ជាពិសេសជាមួយក្រសួង ស្ថាប័ន ក្នុង វិស័យរដ្ឋបាលតែប៉ុណ្ណោះ។ ចំណុចនេះ មានន័យថាវិធីសាស្ត្រក្នុងរៀបចំ និងអនុវត្តថវិកាកម្មវិធីត្រូវបានបែងចែកឱ្យ ដាច់គ្នារវាងក្រសួង ស្ថាប័នក្នុងវិស័យមួយ ទៅនឹងក្រសួង ស្ថាប័នក្នុងវិស័យមួយទៀត ពីព្រោះមានចរិតលក្ខណៈខុសគ្នា។ ចរិតលក្ខណៈខុសគ្នានេះ នឹងជះឥទ្ធិពលដល់គុណភាពរៀបចំកម្មវិធី និងសូចនាករកម្រិតលទ្ធផលចុងក្រោយ ដែល ពិបាកក្នុងការកំណត់ ។

ទន្ទឹមនេះ តាមរយៈការចុះជួបពិភាក្សាជាមួយក្រសួង ស្ថាប័ន និងរដ្ឋបាលរាជធានី ខេត្ត ការអនុវត្តថវិកាកម្មវិធី គឺត្រូវបានកំណត់នូវវឌ្ឍនភាព និងបញ្ហាប្រឈម ដូចខាងក្រោម÷

| ល.រ | វឌ្ឍនភាព | បញ្ហាប្រឈម |
|---|---|---|
| ១ | បង្កើននូវការចូលរួមលើការរៀបចំថវិកា (ផែនការយុទ្ធសាស្ត្រថវិកា និងកញ្ចប់ថវិកាប្រចាំឆ្នាំ) ពីគ្រប់អង្គភាពថវិកាទាំងអស់ | បង្កើតសកម្មភាពច្រើនហួសពីដែលធនធានមានកំណត់ជាពិសេស នៅរដ្ឋបាលរាជធានី ខេត្ត |
| ២ | បង្កើននូវតម្លាភាព និងគណនេយ្យភាពរបស់អង្គភាពថវិកាលើអនុវត្តថវិកា | សមត្ថភាពរបស់អង្គភាពថវិកានៅមានកម្រិត អង្គភាពលទ្ធកម្មនៃក្រសួង ស្ថាប័ន និងរដ្ឋបាលរាជធានី ខេត្ត លើការអនុវត្តថវិកាលើកិច្ចលទ្ធកម្មសាធារណៈថវិកាកម្រិតសិទ្ធិមានទំហំមិនទាន់សមស្របនៅឡើយ |
| ៣ | ក្រសួង ស្ថាប័ន ចាប់ផ្តើមធ្វើអាទិភាពភាវូបនីយកម្មនៃកម្មវិធី របស់ក្រសួង ស្ថាប័នសាមី ដោយធ្វើការរៀបចំផែនការយុទ្ធសាស្ត្រថវិកានិងកញ្ចប់ថវិកាប្រចាំឆ្នាំគឺមានកិច្ចប្រជុំពិភាក្សារវាងអង្គភាពហិរញ្ញវត្ថុ និង | ក្រសួង ស្ថាប័នពិបាកក្នុងកំណត់អាទិភាព ដោយសារតែការផ្លាស់ប្តូរគោលនយោបាយរបស់រាជរដ្ឋាភិបាល |

| ល.រ | ចន្លោះខ្វះខាត | បញ្ហាប្រឈម |
|---|---|---|
| | អង្គភាពថវិកា | |
| ៤ | អភិក្រមក្នុងការកំណត់អនុវត្តថវិកាកម្មវិធី | ក្រសួង ស្ថាប័ននៅក្នុងវិស័យរដ្ឋបាលទូទៅ គឺពិបាកក្នុងការកំណត់សូចនាករ និងលទ្ធផលចុងក្រោយ |

តាមរយៈកំណត់នូវវខ្លនភាព និងបញ្ហាប្រឈម រួមជាមួយ របាយការណ៍វឌ្ឍនភាពនៃការអនុវត្តផែនការសកម្មភាពរួមគាំទ្រកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ខាងលើ អ.គ.ហ. សូមស្នើនូវទិសដៅរយៈពេលមធ្យម ចាប់ពីឆ្នាំ២០១៨-២០២០ សម្រាប់ពង្រឹងប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈតាមក្រសួង ស្ថាប័ន ប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព ដូចមានចង្អុលបង្ហាញខាងក្រោម÷

| ល.រ. | សកម្មភាពអាទិភាព | គោលដៅ | |
|---|---|---|---|
| | | រយៈពេលខ្លី | រយៈពេលមធ្យម |
| ១ | បង្កើនគុណភាពនៃការរៀបចំផែនការយុទ្ធសាស្ត្រ និងថវិកាកម្មវិធី | កំណត់ក្រសួង ស្ថាប័ន ដែលត្រូវអនុវត្តថវិកាកម្មវិធីពេញលេញ ហើយក្រសួង ស្ថាប័នណាអនុវត្តថវិកាកម្មវិធីកម្រិតស្រាល | ស្នើគ្រប់ក្រសួង ស្ថាប័ន មានថ្នាក់ដឹកនាំសម្របសម្រួលអន្តរកម្មវិធី |
| ២ | ការគ្រោងកញ្ចប់ថវិកាសម្រាប់បន្ទុកបុគ្គលិក | សិក្សាអំពីការរៀបចំកញ្ចប់ថវិកាសម្រាប់បន្ទុកបុគ្គលិក ដាក់ឱ្យក្រសួង ស្ថាប័ននីមួយៗ អនុវត្ត | ការរៀបចំកញ្ចប់ថវិកាសម្រាប់បន្ទុកបុគ្គលិកតាមកម្មវិធី |
| ៣ | ការពង្រីកប្រព័ន្ធ FMIS នៅតាមក្រសួង ស្ថាប័ន ស្របតាមផែនការយុទ្ធសាស្ត្រ FMIS ដំណាក់កាលទី២ | ក្រសួង ស្ថាប័នយល់អំពីអត្ថប្រយោជន៍ប្រព័ន្ធ FMIS និងផ្សព្វផ្សាយស្តង់ដារនីតិវិធីប្រតិបត្តិការ (SOP) អង្គភាពថវិកាក្រោម | គ្រប់ក្រសួង ស្ថាប័ន ដាក់ឱ្យអនុវត្តប្រព័ន្ធ FMIS |
| ៤ | សន្ទានកម្មប្រព័ន្ធ FMIS | ប្រព័ន្ធពន្ធដារជាមួយ FMIS | ប្រព័ន្ធបៀរវត្សនិងប្រព័ន្ធ FMIS |

| ល.រ. | សកម្មភាពអាទិភាព | គោលដៅ | |
|---|---|---|---|
| | | រយៈពេលខ្លី | រយៈពេលមធ្យម |
| ៥ | ផ្តោតការយកចិត្តទុកដាក់ក្នុងការរៀបចំកម្មវិធីចំណូល-ចំណាយ | កសហវ គួរតែចាប់ផ្តើមបណ្តើរៗ រឹងបន្តឹងការរៀបចំ និង អនុវត្ត កម្មវិធីចំណូល ចំណាយ | កាត់បន្ថយគំហុកចំណាយ នៅត្រីមាសទី៤ នៃឆ្នាំអនុវត្តថវិកា |
| ៦ | បង្កើនការសម្របសម្រួលរវាងក្រសួង ស្ថាប័ន និង កសហវ | សិក្ខាសាលាចែករំលែកបទពិសោធស្តីពីការអនុវត្តថវិកាកម្មវិធី។ តាមរយៈសិក្ខាសាលានេះ នឹងអាចជួយដោះស្រាយបញ្ហាប្រឈម និងផ្តល់នូវបទពិសោធ ។ | បង្កើនការសម្របសម្រួលជាមួយក្រសួង ស្ថាប័នដែលអាចឱ្យមន្ត្រីតាមក្រសួង ស្ថាប័ន អាចសាកសួរអំពីពាក់ព័ន្ធនឹងការការរៀបចំ និងអនុវត្តថវិកា។ |

រីឯ ទិសដៅសម្រាប់ការរៀបចំប្រព័ន្ធ និងសមត្ថភាពគ្រប់គ្រងថវិកានៅរដ្ឋបាលថ្នាក់ក្រោមជាតិឱ្យប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព អង្គភាពពាក់ព័ន្ធគួររៀបចំ និងអនុវត្តផែនការសកម្មភាពជាជំហាន ដូចតទៅ÷

| ល.រ. | សកម្មភាពអាទិភាព | គោលដៅ | |
|---|---|---|---|
| | | រយៈពេលខ្លី | រយៈពេលមធ្យម |
| ១ | បង្កើនការរៀបចំវគ្គបណ្តុះបណ្តាលលម្អិតស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុ | បណ្តុះបណ្តាលផ្នែករដ្ឋបាលហិរញ្ញវត្ថុ | បណ្តុះបណ្តាលតាមបណ្តារាជធានី ខេត្ត |
| ២ | បង្កើនការផ្សព្វផ្សាយអំពីតួនាទី និងភារកិច្ចរបស់អង្គភាពថវិកា និងការចែករំលែកបទពិសោធន៍ស្តីពីការអនុវត្តកម្មវិធី | រដ្ឋបាលរាជធានី ខេត្ត ដែលបានអនុវត្តថវិកាកម្មវិធី និងរដ្ឋបាលរាជធានី ខេត្តដែលមិនដាក់ឱ្យអនុវត្តថវិកាកម្មវិធី | |
| ៣ | កែលម្អរចនាសម្ព័ន្ធផែនការយុទ្ធសាស្ត្រថវិកា | គោលការណ៍ណែនាំសូចនាករសមិទ្ធកម្មគួរត្រូវបានរៀបចំដើម្បីតម្រង់ទិសក្នុងការកំណត់សូចនាករ | ផែនការយុទ្ធសាស្ត្ររបស់រដ្ឋបាលរាជធានី ខេត្ត គឺធ្វើការបូកសរុប ដោយបញ្ចូលផែនការយុទ្ធសាស្ត្ររបស់មន្ទីរជំនាញ ជុំវិញខេត្ត, ថវិកាក្រុង ស្រុក និងឃុំ សង្កាត់។ |

| ល.រ. | សកម្មភាពអាទិភាព | គោលដៅ | |
|---|---|---|---|
| | | រយៈពេលខ្លី | រយៈពេលមធ្យម |
| ៤ | ផ្តោតការយកចិត្តទុកដាក់ក្នុងការរៀបចំកម្មវិធីចំណូល-ចំណាយ | អគ្គនាយកដ្ឋានថវិកា គួរតែចាប់ផ្តើមបណ្តើរៗ រឹងបន្តឹងការរៀបចំ និងអនុវត្តកម្មវិធីចំណូល-ចំណាយ | កាត់បន្ថយចំណាយគំហុកនៅត្រីមាសទី៤ នៃឆ្នាំអនុវត្តថវិកា |

## ១.៣. បញ្ហាប្រឈម

ក្នុងការអនុផែនការសកម្មភាពរួម ដំណាក់កាលទី៣ នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នាឆ្នាំដំបូង សម្រេចបាននូវវឌ្ឍនភាពគួរឱ្យកត់សម្គាល់ ទោះបីជាយ៉ាងណាក៏ដោយ បញ្ហាប្រឈមក៏កើតមានឡើងផងដែរ និងត្រូវបានកំណត់ និងបែងចែកជា ០២ប្រភេទ ដូចតទៅ÷

### ១.៣.១. ផ្នែកសម្របសម្រួល

១. ការផ្លាស់ប្តូររចនាសម្ព័ន្ធតាមក្រសួង ស្ថាប័ន ដែលនាំឱ្យបង្កើនបន្ទុកក្នុងការសម្របសម្រួល និងត្រូវការវេលាមួយរយៈពេល ដើម្បីស្វែងយល់ និងចូលរួមអនុវត្តកម្មវិធីកែទម្រង់

២. ការសម្របសម្រួលរវាងក្រសួង ស្ថាប័ន និង កសហវ ទាំងការរៀបចំ និងអនុវត្តថវិកាកម្មវិធីនៅមានកម្រិតនៅឡើយ

៣. ការសម្របសម្រួលរវាអង្គភាពហិរញ្ញវត្ថុ និងអង្គភាពថវិកានៃក្រសួង ស្ថាប័ននៅមានកម្រិត ដែលទាមទារឱ្យការជំរុញពី កសហវ ។

### ១.៣.២. ផ្នែកបច្ចេកទេស

១. ការកសាងសមត្ថភាពមន្ត្រីរាជការលើវិស័យហិរញ្ញវត្ថុសាធារណៈ ជាពិសេសការអនុវត្តថវិកាកម្មវិធី នៅតែជាបញ្ហាប្រឈមខ្លាំងនៅឡើយ

២. ការរៀបចំម៉ូដែលព្យាករណ៍របស់គយ និងទម្រង់សម្រាប់ព្យាករណ៍ចំណូលមិនមែនសារពើពន្ធ ត្រូវបានអូសបន្លាយពេលជាច្រើនឆ្នាំ ដោយសារកង្វះជំនួយបច្ចេកទេស

៣. ការគ្រប់គ្រងការផ្លាស់ប្តូរ និងនីតិវិធីការងាររបស់ក្រសួង ស្ថាប័ន ដើម្បីអនុវត្តប្រព័ន្ធ FMIS នៅមិនទាន់ច្បាស់លាស់ជាពិសេសការបែងចែកតួនាទី ភារកិច្ច និងការទទួលខុសត្រូវក្នុងប្រព័ន្ធ

៤. សន្ទានកម្មនៃប្រព័ន្ធ FMIS នឹងប្រព័ន្ធពន្ធដារ និងប្រព័ន្ធបៀវត្សរបស់ក្រសួងមុខងារសាធារណៈនៅមិនទាន់មានវឌ្ឍនភាពនៅឡើយ

៥. ការកំណត់គោលដៅឱ្យបានច្បាស់ផែនការពង្រីកគម្រោងប្រព័ន្ធ FMIS ដើម្បីចៀសវាងកង្វះថវិកាសម្រាប់អនុវត្តការគ្រោងកញ្ចប់ថវិកាសម្រាប់បន្ទុកបុគ្គលិកថវិកាកម្មវិធីតាមកម្មវិធីនីមួយៗ

៦. ការរៀបចំនិងអនុវត្តកម្មវិធីចំណូល-ចំណាយមិនក្លាយជាការងារអាទិភាពនៅឡើយ

៧. ការរៀបចំលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងលទ្ធកម្មសាធារណៈ និងការបង្កើនពិដានលើសិទ្ធសម្រេចលើលទ្ធកម្មសាធារណៈដល់ក្រសួង ស្ថាប័ន និងរដ្ឋបាលរាជធានី ខេត្ត
៨. ការរៀបចំច្បាប់ស្តីពីគ្រប់គ្រងគ្រងទ្រព្យសម្បត្តិរដ្ឋមិនទាន់ត្រូវបានបញ្ចប់តាមគោលដៅ
៩. នីតិវិធីនៃការជម្រះទ្រព្យសម្បត្តិរដ្ឋនៅមិនទាន់ច្បាស់លាស់, ការរៀបចំប័ណ្ណសម្គាល់ម្ចាស់កម្មសិទ្ធិលើអចលនទ្រព្យនៅមានចំនួនតិច និងភាពយឺតយ៉ាវនៃការផ្ទៀងផ្ទាត់បញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋប្រចាំឆ្នាំ
១០. ការរៀបចំច្បាប់ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ និងអនុក្រឹត្យស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ មានសភាពយឺតជាងការគ្រោងទុក
១១. មុខងារសវនកម្មផ្ទៃក្នុង និងអធិការកិច្ច នៅមិនទាន់ធ្វើសុខដុមនីយកម្ម និងមានការត្រួតត្រួតគ្នាទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដែលរវាងសវនកម្ម និងអធិការកិច្ច ។

## ១.៤. សំណើដំណោះស្រាយ

### ១.៤.១. ផ្នែកសម្របសម្រួល

១. ស្នើ កសហវ រៀបចំសិក្ខាសាលាជាប្រចាំឆ្នាំស្តីពីការបង្កើនការផ្សព្វផ្សាយអំពីតួនាទី និងភារកិច្ចរបស់អង្គភាពថវិកា និងការចែករំលែកបទពិសោធន៍ស្តីពីការអនុវត្តកម្មវិធី ដើម្បីក្រសួង ស្ថាប័ន អាចចែករំលែកបទ-ពិសោធទៅវិញទៅមក និងទទួលបានការណែនាំបន្ថែមពី កសហវ

- ✓ ការយល់ដឹងអំពីតួនាទី និងភារកិច្ចរបស់អង្គភាពហិរញ្ញវត្ថុ និងអង្គភាពថវិកា
- ✓ បទពិសោធស្តីពីនីតិវិធីការរៀបចំ និងអនុវត្តថវិកាកម្មវិធី។ល។

### ១.៤.២. ផ្នែកបច្ចេកទេស

១. ក្នុងបរិបទនៃការងារកែទម្រង់កាន់តែសីជម្រៅទាំងទិដ្ឋភាពជាគោលនយោបាយ និងបច្ចេកទេស, ក្រសួង ស្ថាប័ន និងរដ្ឋបាលរាជធានី ខេត្ត ស្នើឱ្យមានការបណ្តុះបណ្តាលជាពេលមធ្យម និងវែងលើការងារហិរញ្ញវត្ថុសាធារណៈ
២. ការបណ្តុះបណ្តាលក្នុងរយៈពេលខ្លី មិនទទួលបាននូវប្រសិទ្ធភាពខ្ពស់ទេ ដោយហេតុ ការងារពាក់ព័ន្ធនឹងហិរញ្ញវត្ថុសាធារណៈ គឺជាការងារបច្ចេកទេសខ្ពស់ ដែលត្រូវការបណ្តុះបណ្តាលក្នុងរយៈពេលមធ្យម និងរយៈពេលវែង
៣. ស្នើពង្រឹង និងពង្រីកវិមជ្ឈការលទ្ធកម្មសាធារណៈ ព្រមទាំងឱ្យក្រសួង ស្ថាប័នបង្កើនតម្លាភាពលទ្ធកម្មសាធារណៈ ដោយផ្សព្វផ្សាយផែនការលទ្ធកម្ម, ការផ្តល់កិច្ចសន្យាលទ្ធកម្ម និងឱកាសដេញថ្លៃ លើគេហទំព័រ
៤. បង្កើនតម្លាភាពលទ្ធកម្មសាធារណៈបន្ថែមទៀតតាមរយៈការប្រើប្រាស់វិធីសាស្ត្រលទ្ធកម្មសាធារណៈដោយបើកចំហ
៥. ក្នុងបរិការសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសព្វថ្ងៃ គួរពង្រឹងការរៀប និងការអនុវត្តកម្មវិធីចំណូល-ចំណាយ
៦. ស្នើ កសហវ ធ្វើការត្រួតពិនិត្យរបាយការណ៍សមិទ្ធកម្មរបស់ក្រសួង ស្ថាប័ន អាទិភាព និង ពិនិត្យលក្ខណៈសម្បត្តិអង្គភាពថវិកានៃអង្គភាពថវិកានៅតាមក្រសួង ស្ថាប័ន

៧. ស្នើអង្គភាពពាក់ព័ន្ធនឹងការរៀបចំលិខិតបដ្ឋានគិតយុត្តខាងលើនៅក្នុងឆ្នាំ២០១៨ ដើម្បីចៀសវាងការអូសបន្លាយពេលវេលាសម្រាប់អនុវត្តកម្មវិធីកែទម្រង់ប្រកបដោយប្រសិទ្ធភាពនិងស័ក្តិសិទ្ធភាព

៨. ស្នើបញ្ជ្រាបការគ្រប់គ្រងការផ្លាស់ប្តូរ និងពិនិត្យលើនីតិវិធីការងារគ្រប់ក្រសួង ស្ថាប័ន ដែលអនុវត្តគម្រោងប្រព័ន្ធ ជាពិសេសមានរបាយការណ៍បញ្ជាក់នីតិវិធីបច្ចុប្បន្នប៉ុន្មាន និងអនាគតប៉ុន្មាន

៩. ពន្លឿនការរៀបចំសន្ទានកម្មនៃប្រព័ន្ធ FMIS ជាមួយនិងប្រព័ន្ធពន្ធដារ និងប្រព័ន្ធបៀវត្ស ។

## ១.៥. សន្និដ្ឋាន

របាយការណ៍ត្រួតពិនិត្យវឌ្ឍនភាពកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈឆ្នាំ២០១៧ បានឆ្លុះបញ្ចាំងនូវភាពគ្រប់ជ្រុងជ្រោយ និងទិដ្ឋភាពនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលជាមូលដ្ឋានសំខាន់សម្រាប់ធ្វើការវិភាគ និងកំណត់ភាពខ្លាំងនឹងភាពខ្សោយនៃប្រព័ន្ធ ។ តាមយៈលទ្ធផលប្រចាំឆ្នាំ ២០១៧ នៃការអនុវត្តផែនការសកម្មភាពគាំទ្រកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ទទួលបានលទ្ធផលល្អ ជាមួយគ្នានេះសមិទ្ធកម្មតាមអង្គភាពនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានបង្ហាញនូវខិតខំនៃអង្គភាពនីមួយៗ ដើម្បីសម្រេចគោលដៅរួម នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។ ភាពជោគជ័យនៃការអនុវត្តកម្មវិធីកែទម្រង់ គឺនឹងជួយគាំទ្រដល់ការសម្រេចបានផងដែរនូវប្រព័ន្ធថវិកាថ្មីដោយផ្តោតជាសំខាន់លើគោលការណ៍ ០៣ រួមមាន បូរណភាពនៃការគោរពវិន័យថវិកា, ប្រសិទ្ធភាពនៃថវិកា ទាំងក្នុងផ្នែកវិភាជន៍ ទាំងក្នុងផ្នែកប្រតិបត្តិការ និងស័ក្តិសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ។ ក្នុងន័យនេះ គ.ហ.ស. បានកំណត់គោលដៅនៃអាទិភាពចំនួន ០៣ ដើម្បីអនុវត្តកម្មវិធីកែទម្រង់ដំណាក់កាលទី៣ គឺការពង្រឹងការគ្រប់គ្រងប្រមូលចំណូល, ការពង្រឹង និងពង្រីកការអនុវត្តប្រព័ន្ធ FMIS និងការពង្រឹង និងពង្រីកការអនុវត្តថវិកាកម្មវិធី ។

អាស្រ័យហេតុនេះ អ.គ.ហ. នឹងបន្តពង្រឹងមុខងារជាឧត្តមសេនាធិការជូន គ.ហ.ស. ដើម្បីបំពេញបេសកកម្មដ៏វិសេសនេះ រួមមាន សម្របសម្រួល និងជំរុញគ្រប់ក្រសួង ស្ថាប័ន ឱ្យចូលរួមអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈប្រកបដោយបុរេសកម្ម, សកម្ម និងអន្តរសកម្ម ព្រមទាំងគាំទ្រការអនុវត្តយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកា២០១៨-២០២៥, ការពង្រឹងការគ្រប់គ្រងការប្រមូលចំណូល និងការពង្រឹង និងពង្រីកការអនុវត្តប្រព័ន្ធ FMIS ដំណាក់កាលទី២ ។

ឆ្លងតាមរយៈលទ្ធផលនៃការត្រួតពិនិត្យវឌ្ឍនភាពកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈឆ្នាំ២០១៧ គ.ហ.ស.ធ្វើការធ្វើការវាយតម្លៃជារួម និងសន្និដ្ឋាន ដូចតទៅ÷

- **ភាពជឿទុកចិត្តនៃថវិកា**នៅតែអាចរក្សាបានជាសារវន្ត ប៉ុន្តែទាមទារឱ្យមានការពង្រឹងការព្យាករ និងការអនុវត្តកម្មវិធីចំណូល-ចំណាយប្រចាំត្រីមាស
- **ប្រព័ន្ធគណនេយ្យភាពហិរញ្ញវត្ថុ**បាននិងកំពុងកសាងតាមរយៈការដាក់ ឱ្យអនុវត្តប្រព័ន្ធ FMIS ដំណាក់កាលទី ២ ជាមួយភាពប្រុងប្រយ័ត្ន
- **ការពង្រឹង និងពង្រីកការអនុវត្តថវិកាកម្មវិធី** ជាមូលដ្ឋានគ្រឹះសម្រាប់រៀបចំ និងកំណត់ការផ្លាស់ប្រព័ន្ធថវិកាកម្ពុជា

- **យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាកម្ពុជា** ជាសមាសធាតុសំខាន់សំរាប់កំណត់ទិសដៅគណនេយ្យភាពសមិទ្ធកម្ម ដែលជាគោលដៅចុងក្រោយនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- **ការរៀបចំមូលនិធិនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ** គឺដើម្បីធានានូវប្រភពធនធានហិរញ្ញវត្ថុសម្រាប់កម្មវិធីកែទម្រង់ ក៏ដូចជាគាំទ្រដល់ក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៃក្រសួង ស្ថាប័ន និងអង្គភាពក្រោមឱវាទ កសហវ ព្រមទាំងនឹងជំរុញការធ្វើស្ថាប័ននីយកម្មឱ្យស្របតាមទិសដៅនៃការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។

# ជំពូកទី២÷ លទ្ធផលនៃការវាយតម្លៃប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

ការវាយតម្លៃចំណាយសាធារណៈ និងគណនេយ្យភាពហិរញ្ញវត្ថុឆ្នាំ២០១៧ គឺប្រើប្រាស់ទិន្នន័យឆ្នាំ២០១៤-២០១៦ ព្រមទាំងរួមបញ្ចូលវឌ្ឍនភាពនៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ឆ្នាំ២០១៧ ជាមូលដ្ឋាន ផងដែរ ។ ការវាយតម្លៃនេះ គឺរៀបចំឡើងក្នុងកម្រិតផ្ទៃក្នុង អ.គ.ហ. ដោយប្រើប្រាស់ក្របខ័ណ្ឌ PEFA តែប៉ុណ្ណោះ និងបានដាក់លទ្ធផលនៃការវាយតម្លៃនេះ ក្នុងកិច្ចប្រជុំគណៈកម្មការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៃ កសហវ និងកិច្ចប្រជុំក្រុមការងារបច្ចេកទេសរវាង អ.គ.ហ. និងដៃគូអភិវឌ្ឍន៍ ។ ទន្ទឹមនេះ សូចនាករពាក់ព័ន្ធដៃគូអភិវឌ្ឍន៍ចាប់ពី D1-D3 គឺមិនត្រូវបានធ្វើការវាយតម្លៃ ដែលស្ថិតនៅក្រៅវិសាលភាពនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។

ជាលទ្ធផលនៃការវាយតម្លៃ PEFA បង្ហាញថា សូចនាករសមិទ្ធកម្មចំនួន ៩ បានកើនឡើងពិន្ទុ ដោយក្នុងនោះរួមមាន PI-2, PI-4, PI-7, PI-9, PI-10, PI-13, PI-14, PI-18 និង PI-19 និងធ្លាក់ពិន្ទុចំនួន ២ រួមមាន PI-3 និង PI-16 ។

## ២.១. វិន័យថវិកា

វិន័យថវិកា ត្រូវបានឆ្លុះបញ្ចាំងតាមរយៈវិសាលភាពគ្របដណ្តប់នៃឯកសារថវិកា និងលទ្ធភាពវិភាជន៍ថវិកាទៅតាមផែនការ ។ ការគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ចមានសារៈសំខាន់ណាស់ក្នុងប្រព័ន្ធសេដ្ឋកិច្ចជាតិ ។ ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ជួយឱ្យរដ្ឋាភិបាលអាចសម្រេចបានលទ្ធផលនៃវិន័យថវិកា ។

កម្ពុជា ទទួលបានសមិទ្ធកម្មល្អ លើការអនុវត្តថវិកា ទាំងចំណូលក្នុងស្រុក (PI-3) និងចំណាយសាធារណៈ (PI-1)។ ដោយឡែក ភាពគ្រប់ជ្រុងជ្រោយនៃថវិកានៅមានភាពទន់ខ្សោយនៅឡើយ ដែលមានដូចជា (ក) ចំនួនច្រើនថ្ងៃនៃបំណុលកកស្ទះ (PI-4 សមាសធាតុ ១) ។ ភាពទន់ខ្សោយនេះ បណ្តាលមកពីភាពមិនគ្រប់ជ្រុងជ្រោយនៃព័ត៌មាន និងទិន្នន័យថវិកាដែលត្រូវដាក់បញ្ចូលក្នុងរបាយការណ៍ថវិកាប្រចាំឆ្នាំ ជាពិសេសសមិទ្ធកម្មពាក់ព័ន្ធនឹងប្រតិបត្តិការថវិការបស់រាជរដ្ឋាភិបាល ។

តាមរយៈលទ្ធផល PEFA ឆ្នាំ២០១៧ អ.គ.ហ. កត់សម្គាល់ឃើញការអនុវត្តថវិកាប្រចាំ២០១៤-២០១៦ គឺរក្សាបាននូវវិន័យថវិកាដែលការអនុវត្តថវិកា គឺស្ថិតក្នុងចន្លោះ +/-៥% ហើយប្រសិនបើវិភាគចំណាយតាមរដ្ឋបាល(ក្រសួងស្ថាប័ន)គម្លាតថវិកា កាន់តែរួមតូចជាងការវាយតម្លៃឆ្នាំ២០១៥ ។ រីឯ ការគ្រប់គ្រងការប្រមូលចំណូលក្នុងរយៈពេល ៣ ឆ្នាំ (ឆ្នាំ២០១៤=១១០,៦៩%, ឆ្នាំ២០១៥=១១១,៥១% និងឆ្នាំ២០១៦=១០៥,៩%) នេះ គឺលើសច្បាប់ថវិកា និងខ្ពស់ជាង ៥%។ បើប្រៀបធៀបនឹងរបាយការណ៍ឆ្នាំ២០១៥ គឺធ្លាក់ពិន្ទុ ពី A មក B ប៉ុន្តែនេះ គឺគ្រាន់ជាឧបករណ៍មួយដើម្បីធ្វើការកែលម្អបន្ថែមទៀត ជាពិសេស អង្គភាពប្រមូលចំណូល គួរបង្កើតម៉ូដែលព្យាករណ៍ដើម្បីធ្វើការព្យាករប្រកបដោយលក្ខណៈវិទ្យាសាស្ត្រ ។

ដំណើរការរៀបចំថវិកាតាមលំដាប់លំដោយ និងបានទាន់ពេលវេលា ទាមទារឱ្យគ្រប់អង្គភាពថវិកាទាំងអស់មានភាពជាម្ចាស់លើថវិការបស់ខ្លួន និងដឹងពីការវិភាជថវិកាចុងក្រោយកាន់តែច្បាស់ មុននឹងចាប់ផ្តើមឆ្នាំសារពើពន្ធថ្មី (PI-11)។ របាយការណ៍អនុវត្តថវិកា ត្រូវធានាភាពទាន់ពេលវេលាជាប្រចាំខែ ប្រកបដោយសុក្រឹតភាព និងសង្គតិភាព សម្រាប់ការតាមដានត្រួតពិនិត្យលើចំណូលនិងចំណាយសាធារណៈសរុប (PI-24) ។ ការត្រួតពិនិត្យល្អលើសហគ្រាសសាធារណៈ និងរដ្ឋបាលឃុំ/សង្កាត់ បានបង្ហាញថាស្ថាប័នទាំងនោះមិនបានស្នើថវិការដ្ឋបន្ថែម ក្រៅពីផែនការឡើយ (PI-9) ។

រីឯ តម្លាភាពថវិកា ស្ថិតក្នុង **PI-10 លទ្ធភាពរបស់សាធារណជនក្នុងការទទួលបានព័ត៌មានថវិកាសំខាន់ៗ** គឺកើនឡើងពិន្ទុពី D មក B ដោយរដ្ឋបាលបានផ្សព្វផ្សាយឯកសារច្រើនបានទាន់ពេលវេលាលើគេហទំព័ររបស់សាមីក្រសួងស្ថាប័ន ដែលបង្ករលក្ខណៈងាយស្រួលឱ្យសាធារណៈជនងាយស្វែងរកព័ត៌មានថវិកា ។ ទន្ទឹមនេះ ពាក់ព័ន្ធតម្លាភាពលទ្ធកម្មក្នុង **PI-19 តម្លាភាព ការប្រកួតប្រជែង និងយន្តការដោះស្រាយបណ្តឹងតវ៉ាក្នុងកិច្ចលទ្ធកម្ម** ក៏ទទួលបានពិន្ទុកើនឡើងដែរ ពី D+ ទៅ C ដោយសារការផ្សព្វផ្សាយផែនការលទ្ធកម្ម, សេចក្តីជូនដំណឹងដេញថ្លៃ និងការផ្តល់កិច្ចសន្យាលទ្ធកម្ម ។ ដើម្បីទទួលបានពិន្ទុខ្ពស់ជាងនេះ គឺត្រូវបង្កើត គណៈកម្មាធិការឯករាជ្យដោះស្រាយវិវាទលទ្ធកម្ម និងផ្សព្វផ្សាយលទ្ធផលនៃការដោះស្រាយ ។

ទន្ទឹមនេះ សូចនាករពាក់ព័ន្ធរដ្ឋបាលប្រមូលចំណូល **PI-13 តម្លាភាពនៃកាតព្វកិច្ចជាប់ពន្ធនិងបំណុលពន្ធរបស់អ្នកជាប់ពន្ធ** កើនឡើងពិន្ទុ C+ ទៅ B ដោយមានដំណើរការនៃយន្តការតវ៉ាពន្ធ និង **PI-14 ប្រសិទ្ធភាពនៃវិធានការសម្រាប់ចុះបញ្ជីអ្នកជាប់ពន្ធ** និងការវាយតម្លៃពន្ធ កើនឡើងពិន្ទុពី D+ ទៅ C ដោយសមាសធាតុទី១ ដោយសារការពង្រឹងការចុះបញ្ជីពន្ធ ។ រីឯ **PI-15 ប្រសិទ្ធភាពនៃការប្រមូលពន្ធ** មិនមែនការប្រែប្រួលពិន្ទុ ដោយការប្រមូលបំណុលពន្ធនៅមានកម្រិតទាបនៅឡើយ ។

ចំណែកឯ **PI-16 ភាពអាចប៉ាន់ប្រមាណបាននូវអត្ថិភាពថវិកាសម្រាប់ធានាចំណាយ** ពិន្ទុធ្លាក់ចុះពី C+ ទៅ C ដោយហេតុថាកម្មវិធីចំណូល ចំណាយ គឺមិនទាន់ត្រូវប្រើប្រាស់ជាឧបករណ៍សម្រាប់ការធានាចំណាយនៅឡើយ (ការទទួលខុសត្រូវរបស់អគ្គនាយកដ្ឋានថវិកា) ។ រីឯ ការព្យាករសាច់ប្រាក់ត្រូវបានធ្វើបច្ចុប្បន្នកម្មប្រចាំត្រីមាស ដោយផ្អែកលើលំហូសាច់ប្រាក់ជាក់ស្តែងត្រីមាសមុន និងព្យាករណ៍ឡើងវិញចំពោះពេលវេលាដែលនៅសល់ក្នុងឆ្នាំ ។ ប៉ុន្តែប្រសិទ្ធភាពវិញ គឺនៅមានលម្អៀងធំនៅឡើយ និងក្រសួង ស្ថាប័នផ្តល់ផែនការសាច់ប្រាក់មកអគ្គនាយកដ្ឋានរតនាគារជាតិ គឺនៅមានភាពយឺតយ៉ាវ នៅឡើយ ។ ជាវឌ្ឍនភាព គឺអគ្គនាយកដ្ឋានរតនាគារជាតិ បានកំពុងដាក់ឱ្យក្រសួងស្ថាប័ន អនុវត្តប្រព័ន្ធអនឡាញសម្រាប់រៀបចំផែនការសាច់ប្រាក់ ។ ដើម្បីទទួលបានពិន្ទុខ្ពស់ជាងនេះ លុះត្រាការរៀបចំផែនការសាច់ប្រាក់បានទាន់ពេលវេលា និងក្រសួង ស្ថាប័នផ្ញើផែនការសាច់ប្រាក់មកអគ្គនាយកដ្ឋានរតនាគារជាតិបានទាន់ពេលវេលា ។

ក្របខ័ណ្ឌថវិការយៈពេលមធ្យម ស្ថិតនៅក្នុងដំណាក់កាលរៀបចំបឋម ដែលការផ្សារភ្ជាប់ថវិកាពីវដ្តមួយទៅវដ្តមួយទៀត នៅមានកម្រិតនៅឡើយ (PI-12 សមាសធាតុ ១ និង ៤) ។ ការពិនិត្យហានិភ័យថវិកា ដែលមានបង្ហាញពីសំណើថវិកាជាយថាហេតុរបស់សហគ្រាសសាធារណៈ និងប្រតិបត្តិការថវិកាដទៃទៀត មិនទាន់ត្រូវបានរៀបចំ

នៅឡើយ (PI-9) រីឯការធានារបស់រដ្ឋលើកម្ចី មិនស្ថិតក្នុងដែនកំណត់នៃពិដានថវិកា ឬយន្តការប្រហាក់ប្រហែលឡើយ (PI-17 សមាសធាតុ ៣) ។ រីឯ ការរៀបចំផែនការសាច់ប្រាក់ ដែលផ្តល់នូវព័ត៌មានអាចទុកចិត្តបានអំពីសាច់ប្រាក់ សម្រាប់ក្រសួង ស្ថាប័នរៀបចំផែនការដើម្បីស្នើធានាចំណាយ ទទួលបានពិន្ទុមិនធ្លាក់ចុះ (PI-16) ។

កង្វះចន្លោះទាំងនេះ បានបង្ហាញឱ្យឃើញថា សមិទ្ធកម្មល្អលើវិន័យថវិកា អាចប្រឈមនឹងហានិភ័យ បើសិនជាការប្រមូលចំណូលក្នុងរយៈពេលខ្លីរបស់រាជរដ្ឋាភិបាល ជួបប្រទះបញ្ហា ឬកំណើនសេដ្ឋកិច្ចក្នុងរយៈពេលមធ្យមមានការធ្លាក់ចុះ ។

## ២.២. យុទ្ធសាស្ត្រវិភាជន៍ធនធាន

យុទ្ធសាស្ត្រវិភាជន៍ធនធាន ឆ្លុះបញ្ចាំងនូវលទ្ធភាពរបស់រាជរដ្ឋាភិបាលក្នុងការផ្តល់ធនធានហិរញ្ញវត្ថុសមស្របជូនអង្គភាពផ្តល់សេវាសាធារណៈ និងក្នុងការកៀរគរធនធានហិរញ្ញវត្ថុពីសាធារណជន និងសហគ្រាស ដើម្បីឆ្លើយតបទៅនឹងគោលបំណងគោលនយោបាយ និងគោលដៅ ។

ប្រព័ន្ធថវិកាដែលខ្លាំង គឺស្ថិតត្រង់ការរៀបចំប្រចាំឆ្នាំ ធ្វើឡើងតាមលំដាប់លំដោយ និងមានការចូលរួមខ្ពស់, ការត្រួតពិនិត្យដោយអង្គនីតិប្បញ្ញត្តិបានទាន់ពេលវេលា និងតាមនីតិវិធីរៀបរយត្រឹមត្រូវ (PI-11 និង PI-27 សមាស-ធាតុ ២), និងភាពទាន់ពេលវេលានិងភាពអាចជឿជាក់បាននៃព័ត៌មានអំពីការផ្ទេរធនធានទៅឱ្យឃុំ-សង្កាត់ ដែលមានស្វ័យភាពក្នុងការរៀបចំថវិកា (PI-8 សមាសធាតុ ១ និង ២) ។ បន្ថែមពីនេះ PI-15 ប្រសិទ្ធភាពនៃការគ្រប់គ្រងបញ្ជីបៀវត្ស មានភាពប្រសើរជាងការវាយតម្លៃឆ្នាំ២០១៥ លើសមាសធាតុទី៤ ដោយក្រសួងមុខងារសាធារណៈ បានពង្រឹងមុខងារអធិការកិច្ច និងបានរកឃើញកំហុសឆ្គងនៃការបើកប្រាក់បៀវត្ស ។

ដើម្បីសម្រេចបានជាអតិបរមានូវគោលបំណងគោលនយោបាយនៃការផ្តល់សេវាសាធារណៈ គឺទាមទារការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយក្នុងរយៈពេលមធ្យម ។ ប៉ុន្តែ ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ មិនទាន់អនុវត្តបានល្អនៅឡើយ ដោយសារតែការរៀបចំផែនការថវិកាពហុឆ្នាំសម្រាប់វិស័យអាទិភាពនៅមានភាពទន់ខ្សោយ លើកលែងតែវិស័យសុខាភិបាល និងវិស័យអប់រំ (PI-12 សមាសធាតុ ៣), ដែលនាំឱ្យមានកង្វះចន្លោះក្នុងការជ្រើសរើសគម្រោងវិនិយោគ និងកង្វះការគិតគូរល្អិតល្អន់អំពីផែនការចំណាយថវិកាចរន្តដែលបណ្តាលមកពីការបញ្ចប់គម្រោង (PI-12 សមាសធាតុ ៤) ។ លើសពីនេះ ក្របខ័ណ្ឌចំណាយរយៈពេលមធ្យម មិនទាន់ត្រូវបានបង្កើតនិងធ្វើសមាហរណកម្មពេញលេញទៅក្នុងដំណើរការរៀបចំថវិកា ជាមួយការផ្សារភ្ជាប់ថវិកាច្បាស់លាស់ពីវដ្តថវិកាមួយទៅវដ្តថវិកាមួយទៀតនោះទេ លើកលែងតែសម្រាប់ថវិកាសរុប (PI-12 សមាសធាតុ ១) ។

លើសពីនេះ ការត្រួតពិនិត្យតាមដានលើការវិភាជនិងការអនុវត្តថវិកា មិនត្រូវបានធ្វើឡើងបានពេញលេញឡើយដោយសារកង្វះប្លង់គណនេយ្យរួមដែលមានលក្ខណៈឯកភាព ដែលប្លង់គណនីនេះបង្ហាញពីចំណាត់ថ្នាក់ថវិកាទៅតាមវិស័យ, មុខងារ និងតាមកម្មវិធី (PI-5) និងកង្វះរបាយការណ៍លម្អិតអំពីការអនុវត្តគម្រោងដែលប្រើប្រាស់ហិរញ្ញប្បទានខាងក្រៅ, (PI-7 សមាសធាតុ ២, PI-24 និង D-2 សមាសធាតុ ២), ក៏ដូចជាភាពទន់ខ្សោយនៃប្រព័ន្ធតាមដានការផ្តល់ធនធានដល់អង្គភាពផ្តល់សេវាសាធារណៈ (PI-23) ។

## ២.៣. ប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ

ការផ្តល់សេវាសាធារណៈដ៏មានប្រសិទ្ធភាព ឆ្លុះបញ្ចាំងឱ្យឃើញពីការប្រើប្រាស់ធនធានហិរញ្ញវត្ថុបានត្រឹមត្រូវ, ចំគោលដៅនៃការផ្តល់សេវាសាធារណៈ និងការកាត់បន្ថយការប្រើប្រាស់ធនធានដោយខ្ជះខ្ជាយ ។ នេះជាការងារចាំបាច់ ដើម្បីបង្កើនប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈឱ្យសមស្របនឹងកំណើនការប្រមូលចំណូល ដែលនឹងនាំមកនូវគណនេយ្យភាពក្នុងការប្រើប្រាស់ធនធានសាធារណៈនៅគ្រប់កម្រិត ។

ភាពអាចប៉ាន់ប្រមាណបាននៃអត្ថិភាពថវិកា សម្រាប់ការអនុវត្តថវិការបស់ក្រសួង ស្ថាប័ន និងអង្គភាពរដ្ឋ (PI-16 សមាសធាតុ ២) និងរបស់ឃុំ/ សង្កាត់ (PI-8 សមាសធាតុ ២) នឹងជួយពង្រឹងប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ ។ ក៏ប៉ុន្តែ ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ មានភាពខ្លាំងកម្រិតណាក្នុងការទប់ទល់នឹងវិបត្តិធ្ងន់ធ្ងរដែលនាំឱ្យប៉ះពាល់ការប្រមូលចំណូល នៅមិនទាន់អាចសន្និដ្ឋានបាននៅឡើយ ដោយសារប្រព័ន្ធត្រួតពិនិត្យលើការធានាចំណាយនៅមិនទាន់មានលក្ខណៈពេញលេញ (PI-20 សមាសធាតុ ១) ។

ចំណុចដែលត្រូវយកចិត្តទុកដាក់ជាពិសេសដើម្បីពង្រឹងប្រសិទ្ធភាពនៃការប្រើប្រាស់ធនធាន មានដូចជាសមិទ្ធកម្មមិនល្អនៃការត្រួតពិនិត្យតាមដាន, បញ្ហាតម្លាភាពនៃប្រព័ន្ធលទ្ធកម្មសាធារណៈ និងកង្វះអង្គភាពដោះស្រាយបណ្តឹងឯក-រាជ្យក្នុងកិច្ចលទ្ធកម្ម (PI-19) ។

## ២.៤. ភាពគ្រប់ជ្រុងជ្រោយនៃព័ត៌មានថវិកា

ការវាយតម្លៃលើសូចនាករសមិទ្ធកម្មខាងលើ ពឹងផ្អែកលើភាពគ្រប់គ្រាន់នៃទិន្នន័យថវិកាដែលអាចប្រមូលបាន។ ក៏ប៉ុន្តែ ទិន្នន័យទាំងនេះនៅមិនទាន់អាចជឿទុកចិត្តបានទាំងស្រុងនៅឡើយ ។ ក្នុងន័យនេះ ចំណុចខ្សោយមួយចំនួនត្រូវបានកត់សម្គាល់។ ការគ្រប់គ្រងបំណុលកកស្ទះដែលនៅមិនទាន់បានគ្រប់ជ្រុងជ្រោយ (PI-4), កង្វះខាតចម្បងៗក៏ត្រូវបានកំណត់ និងត្រូវបានតាមដានត្រួតពិនិត្យជាទៀងទាត់ ដើម្បីធានាភាពគ្រប់ជ្រុងជ្រោយ និងសុក្រឹតភាពនៃការកត់ត្រាចំណូលនិងចំណាយ និងដើម្បីរៀបចំវិធានការទប់ស្កាត់ ឬកែលម្អកង្វះខាតនេះ រួមបញ្ចូលទាំងមុខងារសវនកម្មផ្ទៃក្នុង (PI-21) និងការឆ្លើយតបទៅនឹងសវនកម្មផ្ទៃក្រៅ (PI-26) ។

**តារាង 5: បម្រែបម្រួលលើលទ្ធផល/ សមិទ្ធកម្ម ធៀបនឹងការវាយតម្លៃឆ្នាំ២០១៥**

| *សូចនាករសមិទ្ធកម្មនៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ* | | វិធីសាស្ត្រដាក់ពិន្ទុ | ២០១៥ | ២០១៧ | ពិន្ទុអាចប្រៀបធៀបបាន | បម្រែបម្រួល |
|---|---|---|---|---|---|---|
| A. *លទ្ធផលនៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ÷ភាពជឿទុកចិត្តនៃថវិកា* | | | | | | |
| PI-1 | ចំណាយសរុបធៀបនឹងច្បាប់ថវិកាដែលបានអនុម័ត | M1 | A | A | បាន | គ្មាន |
| PI-2 | សមាសធាតុចំណាយធៀបនឹងច្បាប់ថវិកាដែលបានអនុម័ត | M1 | D+ | B | បាន | ↑ |
| PI-3 | ចំណូលសរុបធៀបនឹងច្បាប់ថវិកាដែលបានអនុម័ត | M1 | A | B | បាន | ↓ |
| PI-4 | សន្និធិបំណុលកកស្ទះ និងការតាមដានបំណុលកកស្ទះ | M1 | D+ | C+ | បាន | ↑ |
| B. *ការងារត្រួតស៊ីគ្នាសំខាន់ៗ÷ភាពគ្រប់ជ្រុងជ្រោយនិងតម្លាភាពនៃថវិកា* | | | | | | |

| *សូចនាករសមិទ្ធកម្មនៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ* | | វិធីសាស្ត្រដាក់ពិន្ទុ | ២០១៥ | ២០១៧ | ពិន្ទុអាចប្រៀបធៀបបាន | បម្រែបម្រួល |
|---|---|---|---|---|---|---|
| PI-5 | ចំណាត់ថ្នាក់ថវិកា | M1 | C | C | បាន | គ្មាន |
| PI-6 | ភាពគ្រប់ជ្រុងជ្រោយនៃព័ត៌មានដែលត្រូវបានបញ្ចូលនៅក្នុងឯកសារថវិកា | M1 | C | C | បាន | គ្មាន |
| PI-7 | ទំហំនៃប្រតិបត្តិការរបស់រដ្ឋាភិបាលដែលមិនត្រូវបានរាយការណ៍ | M1 | C | C+ | បាន | ↑ |
| PI-8 | តម្លាភាពនៃទំនាក់ទំនងហិរញ្ញវត្ថុនៅគ្រប់ថ្នាក់នៃរដ្ឋបាល | M2 | B | B | បាន | គ្មាន |
| PI-9 | ការត្រួតពិនិត្យហានិភ័យថវិកាពីអង្គភាពសាធារណៈដទៃទៀត ក្រៅពីក្រសួង-ស្ថាប័នរដ្ឋ | M1 | C+ | B+ | បាន | ↑ |
| PI-10 | លទ្ធភាពរបស់សាធារណជនក្នុងការទទួលបានព័ត៌មានថវិកាសំខាន់ៗ | M1 | D | B | បាន | ↑ |
| C. *វដ្តថវិកា* | | | | | | |
| C(i) *ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ* | | | | | | |
| PI-11 | កាលានុក្រមនិងការចូលរួមក្នុងកិច្ចដំណើរការរៀបចំថវិកាប្រចាំឆ្នាំ | M2 | A | A | បាន | គ្មាន |
| PI-12 | ទស្សនៈវិស័យច្រើនឆ្នាំក្នុងការធ្វើផែនការថវិកា, គោលនយោបាយចំណាយ និងការរៀបចំថវិកា | M2 | C+ | C+ | បាន | គ្មាន |
| C(ii) *ភាពអាចប៉ាន់ប្រមាណបាន និងការត្រួតពិនិត្យការអនុវត្តថវិកា* | | | | | | |
| PI-13 | តម្លាភាពនៃកាតព្វកិច្ចជាប់ពន្ធនិងបំណុលពន្ធរបស់អ្នកជាប់ពន្ធ | M2 | C+ | B | បាន | ↑ |
| PI-14 | ប្រសិទ្ធភាពនៃវិធានការសម្រាប់ចុះបញ្ជីអ្នកជាប់ពន្ធនិងការវាយតម្លៃពន្ធ | M2 | D+ | C | បាន | ↑ |
| PI-15 | ប្រសិទ្ធភាពនៃការប្រមូលពន្ធ | M1 | D+ | D+ | បាន | គ្មាន |
| PI-16 | ភាពអាចប៉ាន់ប្រមាណបាននូវអត្ថិភាពថវិកាសម្រាប់ធានាចំណាយ | M1 | C+ | C | បាន | ↓ |
| PI-17 | ការកត់ត្រានិងការគ្រប់គ្រងសមតុល្យសាច់ប្រាក់, បំណុលនិងការធានា | M2 | C+ | C+ | បាន | គ្មាន |
| PI-18 | ប្រសិទ្ធភាពនៃការត្រួតពិនិត្យបញ្ជីប្រាក់បៀវត្ស | M1 | D+ | C+ | បាន | ↑ |
| PI-19 | តម្លាភាព ការប្រកួតប្រជែង និងយន្តការដោះស្រាយបណ្តឹងតវ៉ាក្នុងកិច្ចលទ្ធកម្ម | M2 | D+ | C | បាន | ↑ |
| PI-20 | ប្រសិទ្ធភាពនៃការត្រួតពិនិត្យផ្ទៃក្នុងទៅលើ | M1 | C | C | បាន | គ្មាន |

| សូចនាករសមិទ្ធកម្មនៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ | | វិធីសាស្រ្ត ដាក់ពិន្ទុ | ២០១៥ | ២០១៧ | ពិន្ទុអាច ប្រៀបធៀប បាន | បម្រែបម្រួល |
|---|---|---|---|---|---|---|
| | ចំណាយមិនមែនបៀវត្ស | | | | | |
| PI-21 | ប្រសិទ្ធភាពនៃសវនកម្មផ្ទៃក្នុង | M1 | C | C | បាន | គ្មាន |
| C(iii) *គណនេយ្យ, ការកត់ត្រា និងរបាយការណ៍* | | | | | | |
| PI-22 | ភាពទាន់ពេលនិងភាពទៀងទាត់នៃការផ្ទៀងផ្ទាត់គណនី | M2 | C | C | បាន | គ្មាន |
| PI-23 | អត្ថិភាពនៃព័ត៌មានស្តីពីធនធាន ដែលទទួលបានពីអង្គភាពផ្តល់សេវា | M1 | D | D | បាន | គ្មាន |
| PI-24 | គុណភាពនិងភាពទាន់ពេលនៃរបាយការណ៍ថវិកាក្នុងឆ្នាំ | M1 | C+ | C+ | បាន | គ្មាន |
| PI-25 | គុណភាពនិងភាពទាន់ពេលវេលានៃរបាយការណ៍ ហិរញ្ញវត្ថុប្រចាំឆ្នាំ | M1 | D+ | D+ | បាន | គ្មាន |
| C(iv) *ការត្រួតពិនិត្យ និងសវនកម្មផ្ទៃក្រៅ* | | | | | | |
| PI-26 | វិសាលភាព/ ចរិតលក្ខណៈ និង ការតាមដានបន្តនៃសវនកម្មផ្ទៃក្រៅ | M1 | NR | D+ | មិនបាន | - |
| PI-27 | ការត្រួតពិនិត្យលើច្បាប់ថវិកាប្រចាំឆ្នាំ ដោយអង្គនីតិបញ្ញត្តិ | M1 | C+ | C+ | បាន | គ្មាន |
| PI-28 | ការត្រួតពិនិត្យលើរបាយការណ៍សវនកម្មផ្ទៃក្រៅ ដោយអង្គនីតិបញ្ញត្តិ | M1 | B | B | បាន | គ្មាន |
| D. *ការអនុវត្តរបស់ដៃគូអភិវឌ្ឍន៍ (ផ្នែកនេះ គឺមិនត្រូវបានធ្វើការវាយតម្លៃដោយមិនពាក់ព័ន្ធដោយផ្ទាល់សម្រាប់ប្រព័ន្ធ* PFM) | | | | | | |
| D-1 | ការប៉ាន់ប្រមាណនៃការគាំទ្រថវិកាដោយផ្ទាល់ | M1 | D | NR | មិនបាន | - |
| D-2 | ព័ត៌មានហិរញ្ញវត្ថុដែលត្រូវបានផ្តល់ដោយដៃគូអភិវឌ្ឍន៍ សម្រាប់ការរៀបចំថវិកានិងការរាយការណ៍ពីហិរញ្ញ-ប្បទានសម្រាប់គម្រោងនិងកម្មវិធី | M1 | D+ | NR | មិនបាន | - |
| D-3 | ទំហំនៃហិរញ្ញប្បទានដែលត្រូវបានគ្រប់គ្រងតាមនីតិវិធី ជាតិ | M1 | D | NR | មិនបាន | - |

# ឧបសម្ព័ន្ធ

## ឧបសម្ព័ន្ធទី១÷ តារាងភាគរយសមិទ្ធកម្មតាមអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

*ឯកតា÷ រៀល*

| ល.រ | អង្គភាព ក្រោមឱវាទ កសហវ | មុខងារកែទម្រង់ | | | | ចំនួនទឹកប្រាក់ទទួលបានពី PFMRP (អនុវត្ត) | ចំនួនទឹកប្រាក់សរុប (ឯកតា÷រៀល) |
|---|---|---|---|---|---|---|---|
| | | ចំនួនសកម្មភាពសម្រេចបាន | វឌ្ឍនភាព (%) | ចំនួនមន្ត្រី | ប្រាក់ឧបត្ថម្ភមុខងារឧបត្ថម្ភ | | |
| | | 1 | 2 | 3 | 4 | 5 | 6=4+5 |
| ១ | អគ្គនាយកដ្ឋានគោលនយោបាយ | 22/25 | 91 | 42 | 1,510,545,600 | 916,851,452 | 2,427,397,052 |
| ២ | អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា | 7/13 | 84 | 0 | - | 340,608,432 | 340,608,432 |
| ៣ | អគ្គនាយកដ្ឋានពន្ធដារ | 27/42 | 99 | 0 | - | 732,538,236 | 732,538,236 |
| ៤ | អគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ | 6/11 | 98 | 0 | - | 104,807,820 | 104,807,820 |
| ៥ | អគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ | 6/9 | 84 | 0 | - | 72,360,990 | 72,360,990 |
| ៦ | អគ្គនាយកដ្ឋានថវិកា | 62/72 | 97 | 80* | 2,843,443,200 | 329,697,048 | 3,173,140,248 |
| ៧ | អគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ | 30/43 | 95 | 28 | 338,671,200 | 744,481,289 | 1,083,152,489 |
| ៨ | អគ្គនាយកដ្ឋានរតនាគារជាតិ | 29/31 | 99 | 47 | 532,243,200 | 363,279,560 | 895,522,760 |
| ៩ | អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ | 6/14 | 97 | 17 | 187,416,000 | 276,644,590 | 464,060,590 |
| ១០ | អគ្គលេខាធិការដ្ឋានក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | 29/44 | 93 | 51 | 582,494,400 | 565,128,750 | 1,147,623,150 |
| ១១ | អគ្គាធិការដ្ឋាន | 24/29 | 97 | 18 | 211,401,600 | 163,207,520 | 374,609,120 |
| ១២ | អគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង | 20/24 | 99 | 21 | 419,976,000 | 320,501,110 | 740,477,110 |
| ១៣ | អគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងគ្រប់គ្រងបំណុល | 17/25 | 99 | - | - | 120,083,110 | 120,083,110 |
| ១៤ | វិទ្យាស្ថាន សេដ្ឋកិច្ច និងហិរញ្ញវត្ថុ | 19/34 | 90 | 15 | 188,510,400 | 342,120,445 | 530,630,845 |
| ១៥ | ក្រុមការងារ FMWG | 14/16 | 99 | 64 | 2,748,499,200 | 14,060,725,284 | 16,809,224,484 |
| ១៦ | ក្រុមប្រឹក្សានីតិកម្ម | 11/11 | 100 | 18 | 558,189,600 | 108,980,000 | 667,169,600 |
| ១៧ | ក្រុមប្រឹក្សាជាតិគណនេយ្យ | 1/3 | 51 | 0 | - | 52,426,460 | 52,426,460 |
| **សរុប** | | | | | **10,121,390,400** | **19,614,442,096** | **29,735,832,496** |

* រួមបញ្ចូលក្រុមការងារ FMIS នៅអគ្គនាយកដ្ឋានថវិកាចំនួន ១៨ រូប

ប្រភព÷ អ.គ.ហ និងនាយកដ្ឋានបុគ្គលិក នៃអគ្គលេខាធិការដ្ឋាន កសហវ

## ឧបសម្ព័ន្ធទី២៖ វឌ្ឍនភាពសង្ខេបតាមផ្នែកនីមួយៗ នៃក្របខ័ណ្ឌផែនការសកម្មភាពរួមដំណាក់កាលទី៣

| ចង្កោមសកម្មភាព | វឌ្ឍនភាពសម្រេចបាន នៃសូចនាករសមិទ្ធកម្មគន្លឹះ | ពិន្ទុភាគរយ |
|---|---|---|
| **ផ្នែកទី១៖ បន្តពង្រឹងភាពជឿទុកចិត្តនៃថវិកា** | | **៩១%** |
| គោលបំណង ១១. បន្តពង្រឹងការប្រមូលចំណូលនិងការអនុវត្តផែនការប្រមូលចំណូល | | ៨៥% |
| ១១.១. ពង្រឹងការអនុវត្តយុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យម | ១. របាយការណ៍វឌ្ឍនភាពនៃការអនុវត្តយុទ្ធសាស្ត្រកៀរគរចំណូលប្រចាំឆ្នាំត្រូវបានរៀបចំ<br>២. ប្រព័ន្ធគ្រប់គ្រងធនធានមនុស្សតាមប្រព័ន្ធព័ត៌មានវិទ្យានៃ អ.គ.រ. ត្រូវបានអភិវឌ្ឍរួច និងអនុម័តបឋមនិងដាក់ឱ្យអនុវត្តសាកល្បង<br>៣. ប្រកាសស្ដីពីការផ្ទេរថ្លៃ (Transfer Pricing Guideline) និងសៀវភៅណែនាំស្ដីពីសវនកម្មលើវិស័យទូរគមនាគមន៍ ត្រូវបានដាក់ឱ្យអនុវត្ត<br>៤. សេចក្ដីព្រាងសៀវភៅណែនាំលើវិស័យដឹកជញ្ជូនត្រូវបានបោះពុម្ព និងដាក់ឱ្យអនុវត្ត<br>៥. ការធ្វើអង្កេតសហគ្រាសនៅខណ្ឌនៃរាជធានីភ្នំពេញ និងខេត្តអាទិភាព (សៀមរាប, បាត់ដំបង, ព្រះសីហនុ, កំពង់ចាម, កំពង់ស្ពឺ, និងកណ្ដាល) ត្រូវបានបញ្ចប់<br>៦. សេចក្ដីព្រាងច្បាប់ស្ដីពីការគ្រប់គ្រងល្បែងពាណិជ្ជកម្មត្រូវបានដាក់ប្រជុំឆ្លងជាមួយអន្តរក្រសួង<br>៧. របាយការណ៍លទ្ធផលស្ដីពីការបង្ក្រាប និងទប់ស្កាត់ការធ្វើអាជីវកម្មល្បែងស៊ីសងខុសច្បាប់គ្រប់ប្រភេទព្រមទាំងអាជីវ-កម្មបញ្ចាំ និងប្រតិភោគដោយអនុប្បទានដែលពុំមានអាជ្ញា-ប័ណ្ណនៅទូទាំងប្រទេស<br>៨. របាយការណ៍ស្ដីពីលទ្ធផលនៃការចុះសិក្សាបច្ចេកទេសល្បែង និងវិធាននៃការលេងល្បែងនៅតាមក្រុមហ៊ុនកាស៊ីណូនៅតំបន់ព្រំដែនកម្ពុជា-វៀតណាម<br>៩. សេចក្ដីព្រាងច្បាប់ស្ដីពីការគ្រប់គ្រង ការប្រើប្រាស់ និងការចាត់ចែងលើទ្រព្យសម្បត្តិរដ្ឋ ត្រូវបានរៀបចំតាក់តែងជាសេចក្ដីព្រាងចុងក្រោយកម្រិតបច្ចេកទេស | ៨៥% |

| ចង្កោមសកម្មភាព | វឌ្ឍនភាពសម្រេចបាន នៃសូចនាករសមិទ្ធកម្មគន្លឹះ | ពិន្ទុ ភាគរយ |
|---|---|---|
| | ១០. សេចក្តីព្រាងអនុក្រឹត្យស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធត្រូវបានរៀបចំតាក់តែងជាសេចក្តីព្រាងចុងក្រោយកម្រិតបច្ចេកទេស<br>១១. សេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រចំណូលមិនមែនសារពើពន្ធត្រូវបានរៀបចំតាក់តែងជាសេចក្តីព្រាងចុងក្រោយកម្រិតបច្ចេកទេស ។ | |
| ១១.២. បន្តកែលម្អគោល-នយោបាយ និងរដ្ឋបាលគយពន្ធដារ និងចំណូលមិនមែនសារពើពន្ធ | ១. របាយការណ៍ស្តីពីលទ្ធភាពលើការដាក់ចេញ និងកែសម្រួលគោលនយោបាយពន្ធនៅកម្ពុជា<br>២. របាយការណ៍បឋមស្តីពីការកំណត់ក្រុមមុខទំនិញអាទិភាពក្នុងការ កែសម្រួលបន្ទាត់ពន្ធគយ (តាមជំពូកទំនិញក្នុងការសិក្សាកន្លងមក និងគិតគូជំពូកថ្មីបន្ថែមតាមលទ្ធភាពជាក់ស្តែង)។<br>៣. របាយការណ៍ស្តីពីការពិភាក្សាបឋមជាមួយវិស័យឯកជនសម្រាប់ការវាយតម្លៃផលប៉ះពាល់នៃការតម្លើងអត្រាអាករពិសេសលើ វិស័យ អាទិភាពមួយចំនួន រួមមាន បារី និងភេសជ្ជៈជាដើម<br>៤. អនុក្រឹតស្តីពីការលើកលែងពន្ធ និងអនុគ្រោះពន្ធប្រថាប់ត្រាត្រូវបានអនុម័ត និងដាក់ឱ្យអនុវត្ត<br>៥. ប្រកាសណែនំអនុវត្តអនុក្រឹតស្តីពីការលើកលែងពន្ធ និងអនុគ្រោះពន្ធប្រថាប់ត្រា ត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត។<br>៦. បទប្បញ្ញត្តិស្តីពីពន្ធលើប្រតិបត្តិការប្រេងកាតនិងធនធានរ៉ែត្រូវបានរៀបចំ ពិនិត្យសម្រេចដោយ កសហវ និងបញ្ជូនទៅគណៈរដ្ឋមន្ត្រី<br>៧. សេចក្តីព្រាងប្រកាសស្តីពីការអនុវត្តការប្រមូលពន្ធលើប្រតិបត្តិការប្រេងកាត និងធនធានរ៉ែ ត្រូវបានពិនិត្យ និងសម្រេចដោយ អពដ<br>៨. ប្រកាសស្តីពីវិធាន និងនីតិវិធីនៃការបង់ពន្ធលើប្រាក់ចំណូលសម្រាប់សហគ្រាសធានារ៉ាប់រង ត្រូវបានរៀបចំ | ៩០% |

| ចង្កោមសកម្មភាព | វឌ្ឍនភាពសម្រេចបាន នៃសូចនាករសមិទ្ធកម្មគន្លឹះ | ពិន្ទុ ភាគរយ |
|---|---|---|
| | ៩. អនុក្រឹតស្តីពីការលើកទឹកចិត្តផ្នែកពន្ធដារសម្រាប់សហគ្រាសធុនតូច និងមធ្យម ចំពោះការចុះបញ្ជីពន្ធដារដោយស្ម័គ្រចិត្ត ត្រូវបានអនុម័ត និងដាក់ឱ្យអនុវត្ត<br>១០. ប្រកាសស្តីពីការកំណត់សេវាជាមូលដ្ឋានខាងហិរញ្ញវត្ថុ ត្រូវបានរៀបចំនិងសម្រេចដោយ កសហវ<br>១១. ប្រកាសស្តីពីលក្ខណៈវិនិច្ឆ័យនៃការកាន់បញ្ជីកាគណនេយ្យមិនត្រឹមត្រូវនិងនីតិវិធីក្នុងការបង់ពន្ធអប្បបរមា ត្រូវបានដាក់ឱ្យអនុវត្ត<br>១២. ប្រកាសស្តីពីវិធាន និងនីតិវិធី នៃការប្រមូលពន្ធលើប្រាក់ចំណូលសម្រាប់សាខាក្រុមហ៊ុនបរទេស ត្រូវបានដាក់ឱ្យអនុវត្ត<br>១៣. ការិយាល័យពិគ្រោះយោបល់ពន្ធដារត្រូវបានដាក់ឱ្យដំណើរការនៅនាយកដ្ឋានសេវាអ្នកជាប់ពន្ធ និងបំណុលពន្ធ<br>១៤. សេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋត្រូវបានប្រជុំប្រមូលធាតុចូលបន្ថែមនៅកម្រិតអន្តរអគ្គនាយកដ្ឋាន និងនាយកដ្ឋាននីតិកម្ម កសហវ ។ | |
| ១១.៣. ពង្រឹងការវិភាគការព្យាករចំណូល | ១. លទ្ធផលព្យាករណ៍ចំណូលពន្ធដារ មានកម្រិតលម្អៀងត្រឹម +/- ៥%<br>២. Centralized Database សម្រាប់អគ្គនាយកដ្ឋានពន្ធដារត្រូវបានដាក់ឱ្យដំណើរការ<br>៣. មានលទ្ធផលនៃការព្យាករណ៍ចំណូលប្រចាំឆ្នាំនីមួយៗ និងអត្រាកាតព្វកិច្ចប្រមូលចំណូលកាស៊ីណូធៀបនឹងផែនការសម្រេចបានក្នុងរង្វង់ ១០% ។ | ៨១% |
| គោលបំណង ១២. បន្តពង្រឹងការគ្រប់គ្រងបំណុល | | ៩៥% |
| ១២.១. ពង្រឹងការអនុវត្តយុទ្ធសាស្ត្រគ្រប់គ្រងបំណុលសាធារណៈ ប្រកបដោយស័ក្តិសិទ្ធភាព និងប្រសិទ្ធភាព | ១. សេចក្តីព្រាងទី២នៃស្តង់ដារនីតិវិធីប្រតិបត្តិការសម្រាប់ការគ្រប់គ្រងបំណុលសាធារណៈ ត្រូវបានរៀបចំ និងដាក់ឆ្លងកិច្ចពិគ្រោះយោបល់កម្រិតអគ្គនាយកដ្ឋាន ជាលើកទី២ ។<br>២. ព្រឹត្តិបត្រស្ថិតិបំណុលសាធារណៈ លេខរៀងទី៣ (Volume 3) និងទី៤ (Volume 4) ត្រូវបានបោះផ្សាយ និង ផ្សព្វផ្សាយ | ៩២% |

| ចង្កោមសកម្មភាព | វឌ្ឍនភាពសម្រេចបាន នៃសូចនាករសមិទ្ធកម្មគន្លឹះ | ពិន្ទុភាគរយ |
|---|---|---|
| | ៣. សេចក្ដីព្រាងទី២ នៃរបាយការណ៍ស្ដីពីការវាយតម្លៃប្រតិបត្តិការនៃការគ្រប់គ្រង បំណុលសាធារណៈ ត្រូវបានរៀបចំ និងដាក់ឆ្លងកិច្ចប្រជុំពិគ្រោះយោបល់កម្រិតអគ្គនាយកដ្ឋាន ជាលើកទី២<br>៤. សេចក្ដីព្រាងទី២ នៃប្រកាសស្ដីពីគោលការណ៍ និងនីតិវិធីគ្រប់គ្រងការគាំទ្រហិរញ្ញវត្ថុ និងការធានារបស់រដ្ឋ លើគម្រោងវិនិយោគសាធារណៈ តាមយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន ត្រូវបានរៀបចំ និង ដាក់ឆ្លងកិច្ចប្រជុំអន្តរក្រសួង<br>៥. សេចក្ដីព្រាងបឋមយុទ្ធសាស្ត្រស្ដីពីការគ្រប់គ្រងបំណុលសាធារណៈឆ្នាំ ២០១៩-២០២៣ ត្រូវបានពិនិត្យ និងកែសម្រួលកម្រិតនាយកដ្ឋាន ។ | |
| ១២.២. ពង្រឹងប្រសិទ្ធភាពនៃការគ្រប់គ្រងបំណុលត្រូវទារក្នុងឆ្នាំ | ១. បំណុលពន្ធប្រមូលបានមានចំនួន ២០%នៃបំណុលពន្ធសុទ្ធសរុប បន្ទាប់ពីលុបចោលនូវបំណុលពន្ធដែលមិនអាចប្រមូលបានសរុបឆ្នាំ N<br>២. បំណុលត្រូវទារក្នុងឆ្នាំត្រូវបានប្រមូលឱ្យសម្រេចបាន៥០%នៃបំណុលសរុប។ | ៩៥% |
| គោលបំណង ១៣. ពង្រឹងការគ្រប់គ្រងសាច់ប្រាក់ និងគណនី | | ៩៦% |
| ១៣.១. បន្តកែលម្អ និងពង្រឹងការរៀបចំផែនការសាច់ប្រាក់ (ចាប់ផ្ដើមពី ប្រចាំត្រីមាស/ប្រចាំខែ និងឈានទៅរកការរៀបចំផែនការសាច់ប្រាក់ប្រចាំសប្ដាហ៍ និងប្រចាំថ្ងៃ) | ១. ការព្យាករណ៍លំហូរសាច់ប្រាក់ត្រូវបានកែលម្អឱ្យស្ថិតក្នុងរង្វង់ (+/- ៥%)<br>២. សមតុល្យសាច់ប្រាក់ត្រូវបានតាមដានជាប្រចាំតាមរយៈរបាយ-ការណ៍ធនាគារ<br>៣. របាយការណ៍នៃការព្យាករណ៍លំហូរសាច់ប្រាក់រយៈពេល៣ខែរំកិលត្រូវបានរៀបចំនិងកែលម្អ<br>៤. ការព្យាករណ៍ចំណូលនិងចំណាយត្រូវបានពង្រឹងនិងកែលម្អឱ្យកាន់តែប្រសើរឡើង។ | ១០០% |
| ១៣.២. បន្តពង្រឹងការប្រើប្រាស់ប្រព័ន្ធធនាគារ ព្រមទាំងសិក្សានិងពិនិត្យលទ្ធភាពឈានទៅអនុវត្តការទូទាត់តាម E-transfer | ១. ការបើកប្រាក់បៀវត្សតាមប្រព័ន្ធធនាគារ ត្រូវបានអនុវត្តទូទាំងប្រទេសយ៉ាងរលូន | ៧៥% |

| ចង្កោមសកម្មភាព | វឌ្ឍនភាពសម្រេចបាន នៃសូចនាករសមិទ្ធកម្មគន្លឹះ | ពិន្ទុភាគរយ |
|---|---|---|
| ១៣.៣. រៀបចំយន្តការប្រមូលផ្តុំ និងបូកសរុបរបាយការណ៍អនុវត្តថវិកាគម្រោងរបស់ដៃគូអភិវឌ្ឍន៍ ដែលនៅក្រៅប្រព័ន្ធរតនាគារ ជាជំហានៗ និងបន្តពង្រឹងគណនីទោលរតនាគារ | ១. ប្លង់គណនេយ្យសាធារណៈ (CoA) ត្រូវបានផ្សព្វផ្សាយនិងសាកល្បងដាក់ឱ្យអង្គភាពចំនួនមួយ ដែលអនុវត្តថវិកាគម្រោងរបស់ដៃគូអភិវឌ្ឍន៍អនុវត្ត។ | ១០០% |
| ១៣.៤. បន្តតាមដានបំណុលកកស្ទះ និងអាយុកាលរបស់វា | ១. ពង្រឹងយន្តការតាមដានដើម្បីកុំឱ្យមានបំណុលកកស្ទះ (អាយុកាលលើសពី៦០ថ្ងៃ) លើសពី ២%នៃច្បាប់ថវិកាប្រចាំឆ្នាំ<br>២. ការធ្វើសមាហរណកម្មបំណុលនិងការធ្វើបច្ចុប្បន្នភាព និងកត់ត្រាតួលេខបំណុលនឹងត្រូវធ្វើឡើង តាមប្រព័ន្ធ FMIS ដោយសមាហរណកម្មជាមួយ នឹងប្រព័ន្ធ ASYCUDA និង DMFAS ។ | ១០០% |
| ១៣.៥. ពន្លឿនការទូទាត់បុរេប្រទានឱ្យបានទាន់ពេលវេលា | ១. ប្រព័ន្ធតាមដានត្រួតពិនិត្យលើសំណើសុំបុរេប្រទានរបស់ក្រសួងស្ថាប័នត្រូវបានរៀបចំនិងដាក់ឱ្យអនុវត្ត ។ | ១០០% |
| គោលបំណង ១៤. កែលម្អការអនុវត្តថវិកា និងពង្រឹងការអនុវត្តផែនការចំណាយ | | ៩២% |
| ១៤.១. ការធ្វើសុខដុមនីយកម្មរវាងការអនុវត្តវិធាន និងបទប្បញ្ញត្តិស្តីពីលទ្ធកម្មសាធារណៈ (IRRPP) និងស្តង់ដារនីតិវិធីរួម (SOP/PM) | ១. សកម្មភាពនៅក្នុង ១៤.១ មិនត្រូវបានវាយតម្លៃទេ ដោយសារប្រធាន គ.ហ.ស. បានសម្រេចឱ្យរៀបចំយុទ្ធសាស្ត្រកែទម្រង់ប្រព័ន្ធលទ្ធសាធារណៈដោយគិតគូរការធ្វើសុខដុមនីយកម្ម IRPP និង SOP/PM នៅក្នុងយុទ្ធសាស្ត្រនោះតែម្តង ។ | |
| ១៤.២. ពង្រឹងការរៀបចំនិងអនុវត្តផែនការចំណាយឱ្យមានសុក្រឹត្យភាព | ១. ទម្រង់កម្មវិធីចំណូល-ចំណាយផ្ទៃក្នុង កសហវ អនុលោមតាមថវិកាកម្មវិធីត្រូវបានរៀបចំ<br>២. ទម្រង់កត់ត្រាការអនុវត្តចំណាយថវិកាកម្មវិធី តាមមាតិកាកម្មវិធី និងមាតិកាសេដ្ឋកិច្ចត្រូវបានកែសម្រួលរួចរាល់និងត្រៀមដាក់ឱ្យអនុវត្តនៅក្នុងឆ្នាំ២០១៨ ។ | ១០០% |
| ១៤.៣. បន្តពង្រឹងប្រសិទ្ធភាពចំណាយវិនិយោគសាធារណៈ | ១. ច្បាប់ស្តីពីសម្បទាន និងច្បាប់ពាក់ព័ន្ធនឹងការ អនុវត្តយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន ត្រូវបានពិនិត្យឡើងវិញ និងមានរបាយការណ៍។ សំណើសុំធ្វើវិសោធនកម្ម ឬសេចក្តីព្រាងច្បាប់ថ្មី ស្តីពីយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន ត្រូវបានរៀបចំ និងបានដាក់ឱ្យពិគ្រោះយោបល់ កែសម្រួល | ៩៥% |

| ចង្កោមសកម្មភាព | វឌ្ឍនភាពសម្រេចបាន នៃសូចនាករសមិទ្ធកម្មគន្លឹះ | ពិន្ទុភាគរយ |
|---|---|---|
| | ២. សេចក្តីព្រាងនីតិវិធីការធ្វើអត្តសញ្ញាណកម្ម និងជ្រើសរើសគម្រោង តាមយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន ត្រូវបានរៀបចំ ដាក់ឱ្យពិភាក្សា និងកែសម្រួល<br>៣. សេចក្តីព្រាងនីតិវិធីមូលនិធិអភិវឌ្ឍន៍គម្រោង តាមយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជនត្រូវបានរៀបចំ ដាក់ឱ្យពិភាក្សា និងកែសម្រួល<br>៤. សេចក្តីព្រាងនីតិវិធី កិច្ចលទ្ធកម្មគម្រោងផ្នែកទី១ ផ្នែកទី២ និងផ្នែកទី៣ តាមយន្តការភាពជាដៃគូ រវាងរដ្ឋ និងឯកជន ត្រូវបានរៀបចំ ដាក់ឱ្យពិភាក្សាពិនិត្យ និងកែសម្រួល<br>៥. កិច្ចព្រមព្រៀងហិរញ្ញប្បទានផ្តល់ ជំនួយបច្ចេកទេសសម្រាប់គម្រោង Strengthening Capacity for Improved Implantation of Externally-Funded Projects in Cambodia ត្រូវបានចុះហត្ថលេខារវាង ADB ជាមួយ MEF ។ | |
| ១៤.៤. ពង្រឹងប្រសិទ្ធភាពគ្រប់គ្រង និងការអនុវត្តការងារជួសជុលនិងថែទាំហេដ្ឋារចនា-សម្ព័ន្ធសាធារណៈ | ១. សេចក្តីព្រាងលើកទី៤ សារាចរណែនាំស្តីពីការរៀបចំ អនុវត្ត និងគ្រប់គ្រងការងារជួសជុលថែទាំហេដ្ឋារចនាសម្ព័ន្ធសាធារណៈហិរញ្ញប្បទានដោយថវិកាជាតិ ត្រូវបានរៀបចំ និងអនុម័ត ។ ដោយបច្ចុប្បន្នបាននិងកំពុងកែសម្រួលសេចក្តីព្រាងលើកទី៣។ | ៧០% |
| **ផ្នែកទី២÷ បន្តពង្រឹងគណនេយ្យភាពហិរញ្ញវត្ថុ** | | **៩៤.២៥%** |
| គោលបំណង ២១. ពង្រឹងការអនុវត្តមាតិកាថវិកាថ្មី និងប្លង់គណនេយ្យថ្មី | | ១០០% |
| ២១.១. បន្តកែលម្អប្លង់គណនេយ្យថ្មី និងចំណាត់ថ្នាក់ថវិកាថ្មី (ភូមិសាស្ត្រ, អង្គភាពប្រតិបត្តិនិងរដ្ឋបាល, កម្មវិធីនិងសេដ្ឋកិច្ច) និងអនុវត្តចំណាត់ថ្នាក់ ៣ បន្ថែមទៀត (មុខងារ មូលនិធិ និងគម្រោង) | ១. សមាសភាពក្រុមការងារ FMIS សម្រាប់អនុវត្តបរិបទថ្មីនៃប្រព័ន្ធ FMIS ដែលនឹងត្រូវដាក់ឱ្យអនុវត្តក្នុងជំហានទី២ ត្រូវបានរៀបចំកែសម្រួល<br>២. ប្រកាសស្តីពីការកែសម្រួល និងបំពេញបន្ថែមចំណាត់ថ្នាក់ភូមិ-សាស្ត្រនៃមាតិកាថវិកាត្រូវបានអនុម័ត និងដាក់ឱ្យអនុវត្ត<br>៣. សេចក្តីណែនាំស្តីពីបច្ចុប្បន្នភាពចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកាពាក់ព័ន្ធនឹងរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបានដាក់ឱ្យអនុវត្ត<br>៤. ប្លង់គណនេយ្យរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាលត្រូវបានរៀបចំ និងតាមដានកែលំអស្របតាមប្លង់គណនេយ្យ | ១០០% |

| ចង្កោមសកម្មភាព | វឌ្ឍនភាពសម្រេចបាន នៃសូចនាករសមិទ្ធកម្មគន្លឹះ | ពិន្ទុ ភាគរយ |
|---|---|---|
| | សាធារណៈ<br>៥. ឧបសម្ព័ន្ធចំណាត់ថ្នាក់មុខងារត្រូវបានរៀបចំ<br>៦. ក្រសួង ស្ថាប័នត្រូវបានណែនាំ និងផ្តល់យោបល់ជាប្រចាំអំពីបរិបទថ្មីនៃប្រព័ន្ធ FMIS នៅពេលមានសំណើសុំធានាចំណាយ និងសំណើសុំទូទាត់។ ក្រសួង ស្ថាប័នមានការយល់ដឹងពីលំហូរនៃឯកសារពាក់ព័ន្ធនឹងប្រព័ន្ធ FMIS។<br>៧. ក្រុមការងារ FMIS បានជួយបណ្តុះបណ្តាលដល់ក្រសួង ស្ថាប័ន ១០ ដែលនឹងអនុវត្ត FMIS នៅឆ្នាំ២០១៨។ រីឯបែបបទ និងបរិបទចំណាយផ្ទាល់ ត្រូវរង់ចាំខាង FMIS រៀបចំដាក់ប្រព័ន្ធដល់ក្រសួង ស្ថាប័នជាមុនសិន ។ | |
| គោលបំណង ២២. ពង្រឹងការអនុវត្តប្រព័ន្ធអនុវត្តថវិកាថ្មី និងដំណើរការប្រតិបត្តិការថ្មី | | ៩៦% |
| ២២.១. រៀបចំបរិបទនៃប្រតិបត្តិការចំណាយ (សំណើសុំធានាចំណាយ, កិច្ចលទ្ធកម្ម និងសំណើសុំទូទាត់) នៅតាមក្រសួង ស្ថាប័នឱ្យស្របតាមប្រព័ន្ធ FMIS | ១. សេចក្តីព្រាងបរិបទនៃប្រតិបត្តិការចំណាយមូលធន និងជួសជុលថែទាំ (សំណើសុំធានាចំណាយ, កិច្ចលទ្ធកម្ម និងសំណើសុំទូទាត់) នៅតាមក្រសួងស្ថាប័ន ត្រូវបានរៀបចំឱ្យស្របតាមប្រព័ន្ធ FMIS របស់នាយកដ្ឋានវិនិយោគ<br>២. ការអនុវត្តប្រព័ន្ធ FMIS ត្រូវបានចូលរួមប្រកបដោយប្រសិទ្ធភាព ពោលរាល់ប្រតិបត្តិការចំណូលចំណាយ ការបិទបញ្ជី របាយការណ៍ វឌ្ឍនភាព និងការរៀបចំរបាយការណ៍ចំណាយត្រូវបានអនុវត្តក្នុង FMIS ជំនួសប្រព័ន្ធ KIT ទាំងស្រុង<br>៣. ប្រព័ន្ធ FMIS ក្នុងគ្រប់អគ្គនាយកដ្ឋាន ត្រូវបានដាក់ឱ្យអនុវត្ត ។ | ១០០% |
| ២២.២. កែលម្អប្រតិបត្តិការគណនេយ្យ ហិរញ្ញវត្ថុនៅ ក្នុងកសហវ/ក្រសួង-ស្ថាប័ន ដើម្បីឱ្យស្រប ទៅនឹងការវិវឌ្ឍន៍នៃប្លង់គណនី និង បទដ្ឋានគណនេយ្យ ព្រមទាំងធ្វើការផ្ទៀងផ្ទាត់គណនីធនាគារជាប្រចាំ | ១. លិខិតបទដ្ឋានគតិយុត្តថ្នាក់ក្រោមជាតិ ត្រូវបានរៀបចំរួចរាល់ ក្នុងនោះ មានសេចក្តីណែនាំកិច្ចបញ្ជិការរជ្ជទេយ្យចំណូលសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ដើម្បីពង្រឹងការអនុវត្តថវិកា និងធ្វើបច្ចុប្បន្នភាពនីតិវិធីអនុវត្តថវិកានៅរដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ។<br>២. ការបណ្តុះបណ្តាលនិងផ្សព្វផ្សាយណែនាំអំពីនីតិវិធីនៃការអនុវត្តចំណូល ចំណាយថវិកា ផ្អែកតាមលិខិតបទដ្ឋានគតិយុត្តិពាក់ព័ន្ធទាំងឡាយដល់មន្ត្រីជំនាញពាក់ពន្ធ័នៃអគ្គនាយកដ្ឋានរតនាគារជាតិ ដើម្បីត្រួតពិនិត្យលើការអនុវត្តថវិកា ជាពិសេសក្រសួង | ៧០% |

| ចង្កោមសកម្មភាព | វឌ្ឍនភាពសម្រេចបាន នៃសូចនាករសមិទ្ធកម្មគន្លឹះ | ពិន្ទុ ភាគរយ |
|---|---|---|
| | ស្ថាប័នពាក់ព័ន្ធនានាដើម្បី អនុវត្តថវិកាឱ្យបានត្រឹមត្រូវស្រម តាមនិតិវិធីហិរញ្ញវត្ថុ ។ | |
| ២២.៣ បង្កើនកម្រិតយល់ដឹង ភាពជាម្ចាស់ការចូលរួមនិង សមត្ថភាពផ្នែក FMIS ដល់ក សហវ ក្រសួង-ស្ថាប័ន និងរដ្ឋបា លថ្នាក់ក្រោមជាតិ | ១. ការយល់ដឹង ការគាំទ្រ និងការបង្កើនភាពជាម្ចាស់លើប្រព័ន្ធ FMIS ដល់ក្រសួងស្ថាប័ន ត្រូវបានពង្រីក និងពង្រឹង ។ ជាក់-ស្តែង ពិធីប្រកាសផ្លូវការនៃការអនុវត្តគម្រោង FMIS ជំហានទី២ ត្រូវបានចូលរួមពីថ្នាក់ដឹកនាំជាន់ខ្ពស់នៃក្រសួងស្ថាប័ន និងការចូលរួមទស្សនកិច្ចសិក្សានៅប្រទេសសិង្ហបុរីដកពិសោធន៍អំពីការរៀបចំ និងកសាងមជ្ឈមណ្ឌលទិន្នន័យទ្រទ្រង់ដល់ការអនុវត្តប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុ ។<br>២. សិក្ខាសាលាស្តីពីវឌ្ឍនភាពនៃប្រព័ន្ធ FMIS ត្រូវបានរៀបចំ ដើម្បីពង្រីកការយល់ដឹង ពង្រឹងការគាំទ្រ និងបង្កើនភាពជាម្ចាស់លើប្រព័ន្ធ FMIS ដល់រតនាគារ និងមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រាជធានី ខេត្ត ។<br>៣. ការយល់ដឹងពី FMIS ត្រូវបានផ្សព្វផ្សាយតាមប្រព័ន្ធផ្សព្វផ្សាយនានា ដូចជា វីដេអូខ្លីៗ ទូរទស្សន៍ និងបណ្តាញសារព័ត៌មានផ្សេងៗ ជូនមន្ត្រីរាជការ និងសាធារណៈជនទូទៅ ។ | ១០០% |
| ២២.៤.កសាងសមត្ថភាព គ្រប់គ្រងគម្រោង FMIS ដោយ រួមទាំងនៅកសហវ ក្រសួង ស្ថា ប័ន និងអង្គភាពថ្នាក់ក្រោមជាតិ | ១. ការកសាងសមត្ថភាពមន្ត្រីក្រុមការងារគ្រប់គ្រងគម្រោង FMIS ត្រូវបានធ្វើឡើងតាមរយៈការបណ្តុះបណ្តាលផ្នែក Soft Skill ផ្នែកគ្រប់គ្រងគម្រោង ព័ត៌មានវិទ្យា PRINCE2 Practitioner និងគ្រប់គ្រងការផ្លាស់ប្តូរ នៅប្រទេសសិង្ហបុរី និង វគ្គបណ្តុះបណ្តាលមូលដ្ឋានលើមុខងារ (Oracle PeopleTools, Oracle Database, Oracle ZFS Storage, Oracle Solaris, Programming, Cisco Networking)<br>២. ការកសាងសមត្ថភាពមន្ត្រីនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងស្ថាប័នលើការប្រើប្រាស់ប្រព័ន្ធ FMIS ត្រូវបានធ្វើឡើងតាមរយៈការរៀបចំវគ្គបណ្តុះបណ្តាលបំប៉នបន្ថែមស្តីពី FMIS Refreshment Training មូលដ្ឋានគ្រឹះផ្នែកព័ត៌មានវិទ្យា និងការប្រើប្រាស់ប្រព័ន្ធ FMIS សម្រាប់ត្រៀមអនុវត្តប្រព័ន្ធ FMIS ជំហានទី២ ។ | ៩៥% |

| ចង្កោមសកម្មភាព | វឌ្ឍនភាពសម្រេចបាន នៃសូចនាករសមិទ្ធកម្មគន្លឹះ | ពិន្ទុ ភាគរយ |
|---|---|---|
| ២២.៥. អនុវត្តសាកល្បងជំហានដំបូង និងពង្រីកការអនុវត្ត FMIS (ម៉ូឌុលស្នូល និងម៉ូឌុលសម្រាប់ថវិកានិងពង្រីកការអនុវត្ត FMIS ទៅក្រសួងស្ថាប័ន) | ១. ប្រព័ន្ធ FMIS ត្រូវបានរៀបចំរួចរាល់ឆ្លើយតបទៅនឹងតម្រូវការនីតិវិធីអនុវត្តការងាររបស់ក្រសួងស្ថាប័នចំនួន ១០ ដោយបានកែសម្រួលមួយចំនួនលើ នីតិវិធីលំហូរនៃការអនុម័តនៅក្នុងប្រព័ន្ធ FMIS, ការរៀបចំ Security Matrix, ការរៀបចំនិងកែសម្រួលលើរបាយការណ៍ និងកែលម្អលើបច្ចេកទេសផ្សេងៗទៀត<br>២. ហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យាព័ត៌មានបានកសាងរួចរាល់នៅក្រសួងស្ថាប័នចំនួន ១០ ដែលអាចទ្រទ្រង់បានសម្រាប់អ្នកប្រើ-ប្រាស់ជាង ២០០រូប ដែលរួមមាន ការដំឡើងរួចរាល់នូវបណ្តាញតភ្ជាប់ WAN/LAN ពីក្រសួងស្ថាប័នទាំង១០ មកមជ្ឈមណ្ឌលទិន្នន័យរួមរបស់ FMIS<br>៣. ក្រសួង ស្ថាប័នចំនួន ១០ មានមន្ត្រីប្រមាណ២០០ រូបបានទទួលការបណ្តុះបណ្តាលការប្រើប្រាស់ប្រព័ន្ធ FMIS នឹងបានសាកល្បងប្រើប្រាស់ប្រព័ន្ធ FMIS ដើម្បីត្រៀមលក្ខណៈអនុវត្តប្រព័ន្ធ FMIS ជាផ្លូវការចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០១៨ តទៅ<br>៤. ក្រុមការងារគ្រប់គ្រងគម្រោង FMIS បាននិងកំពុងសិក្សាស្រាវជ្រាវបន្ថែម ដើម្បីរៀបចំនិងកសាងប្រព័ន្ធ FMIS លើមុខងារបន្ថែមថ្មីគឺការគ្រប់គ្រងការរៀបចំថវិកា ការធ្វើលទ្ធកម្ម និងគ្រប់គ្រងកិច្ចសន្យា ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ និងការគ្រប់គ្រងសន្និធិ ។ | ១០០% |
| គោលបំណង ២៣. ពង្រឹងការអនុវត្តប្រព័ន្ធគណនេយ្យថ្មី ប្រព័ន្ធកត់ត្រាថ្មី ប្រព័ន្ធរបាយការណ៍ថ្មី | | ៧៩% |
| ២៣.១. រៀបចំស្តង់ដារគណនេយ្យសាធារណៈស្របតាមស្តង់ដារIPSAS និងដាក់ឱ្យអនុវត្តជាបណ្តើរៗតាមលំដាប់លំដោយ ព្រមទាំងផ្សារភ្ជាប់ទៅនឹងការពង្រីកការប្រើប្រាស់ | ១. របាយការណ៍ហិរញ្ញវត្ថុតាមស្តង់ដារ IPSAS Cash Basis ត្រូវបានផលិតចេញពីប្រព័ន្ធ FMIS ។ | ៤៣% |

| ចង្កោមសកម្មភាព | វឌ្ឍនភាពសម្រេចបាន នៃសូចនាករសមិទ្ធកម្មគន្លឹះ | ពិន្ទុភាគរយ |
|---|---|---|
| FMIS ស្របតាមតម្រូវការជាក់ស្តែងនិងបង្កើតជម្រើសសម្រាប់ការអនុវត្តជាជំហានៗ ទៅរកការអនុវត្តគណនេយ្យបង្គរ | | |
| ២៣.២.កែលម្អទម្រង់របាយការណ៍អនុវត្តថវិកាដែលត្រូវផ្ញើទៅគណៈរដ្ឋមន្ត្រី និងស្ថាប័ននីតិប្បញ្ញត្តិ | ១. ទម្រង់តារាងទិន្នន័យចំណូល-ចំណាយ និងរបាយការណ៍ស្តីពីការអនុវត្តថវិកាត្រូវបានសិក្សាឡើងវិញ និងកែលម្អ<br>២. ច្បាប់ទូទាត់ថវិកាប្រចាំឆ្នាំត្រូវបានរៀបចំ និង កែលម្អ មុនដាក់ជូនគណៈរដ្ឋមន្ត្រី ។ | ១០០% |
| ២៣.៣.ដាក់ឱ្យអនុវត្តយន្តការដើម្បីបញ្ចប់ការចុះបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋ និងធ្វើបច្ចុប្បន្នភាពជាប្រចាំ | ១. អនុក្រឹត្យស្តីពីវិធាន និងនីតិវិធីនៃការគ្រប់គ្រងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋត្រូវបានចុះហត្ថលេខា និងចូលជាធរមាននៅថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១៧ និងត្រូវបានធ្វើសិក្ខាសាលាផ្សព្វផ្សាយដល់គ្រប់ក្រសួង-ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ និងនិតិបុគ្គលសាធារណៈ<br>២. ប្រព័ន្ធគ្រប់គ្រងទិន្នន័យបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ ត្រូវបានរៀបចំក្នុងដំណាក់កាលដំបូង និងកំពុងធ្វើការសាកល្បងប្រើប្រាស់ ដោយមន្ត្រីរបស់នាយកដ្ឋានជំនាញ<br>៣. ដើម្បីរកបញ្ហាប្រឈមធ្វើការកែសម្រួលមុនដាក់អោយអនុវត្តជាផ្លូវការ<br>៤. នីតិវិធីនៃការរៀបចំបញ្ជីសារពើភណ្ឌ ត្រូវបានផ្សព្វផ្សាយនិងណែនាំដល់ក្រុមការងាររៀបចំបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋនៅថ្នាក់កណ្តាលចំនួន ២០អង្គភាពប្រើប្រាស់ និងអង្គភាពប្រើប្រាស់ថ្នាក់មូលដ្ឋានចំនួន២៥ រាជធានី ខេត្ត ដើម្បីបង្កើនសមត្ថភាពបន្ថែមលើការរៀបចំបញ្ជីសារពើភណ្ឌប្រចាំឆ្នាំ<br>៥. ប្រព័ន្ធគ្រប់គ្រងទិន្នន័យបញ្ជីសារពើភណ្ឌរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវបានអនុវត្តសាកល្បង និងត្រៀមដាក់ឱ្យអនុវត្តពេញលេញនៅដើមឆ្នាំ២០១៨ ។ | ១០០% |
| គោលបំណង ២៤. ពង្រឹងការអនុវត្តឧបករណ៍ និងយន្តការដើម្បីបង្កើនការទទួលខុសត្រូវ និងគណនេយ្យភាព | | ៩៩% |

| ចង្កោមសកម្មភាព | វឌ្ឍនភាពសម្រេចបាន នៃសូចនាករសមិទ្ធកម្មគន្លឹះ | ពិន្ទុ ភាគរយ |
|---|---|---|
| ២៤.១. បង្កើតឱ្យមានទណ្ឌកម្មរដ្ឋបាលសមស្រប ចំពោះកំហុសឆ្គង ឬការគ្រប់គ្រងធនធាន សាធារណៈមិនសមស្រប និងគ្មានប្រសិទ្ធភាព ។ ទណ្ឌកម្មនេះត្រូវចែងនៅក្នុងលិខិតបទដ្ឋានគតិយុត្ត និង ធ្វើការផ្សព្វផ្សាយ និងណែនាំឱ្យបានទូលំទូលាយ | ១. ទណ្ឌកម្មរដ្ឋបាលសមស្រប ចំពោះកំហុសឆ្គង ឬការគ្រប់គ្រងធនធានសាធារណៈមិនសមស្រប និងគ្មានប្រសិទ្ធភាព ដែលនៅមានជាធរមាន ត្រូវបានបញ្ចប់ការរៀបចំចងក្រង<br>២. សេចក្តីព្រាងកម្រងទណ្ឌកម្មរដ្ឋបាលក្នុងវិស័យហិរញ្ញវត្ថុសាធារណៈត្រូវបានរៀបចំ តាមការសម្រេចដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តមបណ្ឌិតសភាចារ្យទេសរដ្ឋមន្ត្រី នាថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១៧ ដែលកម្រងនេះ នឹងក្លាយជាមូលដ្ឋានសម្រាប់ស្រាវជ្រាវបញ្ចូលជាទណ្ឌកម្ម ក្នុងសេចក្តីព្រាងច្បាប់វិសោធនកម្មច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ នាឆ្នាំ២០១៨ ។ | ១០០% |
| ២៤.២. ត្រួតពិនិត្យឡើងវិញ លើការអនុវត្តសិទ្ធិអំណាចនិងភាពទន់ភ្លន់ដែលបានផ្តល់ជូនអង្គភាពថវិកានិងធ្វើបច្ចុប្បន្នភាព | ១. គោលការណ៍ណែនាំស្តីពីការរៀបចំ និងដាក់ឱ្យអនុវត្តថវិកាកម្មវិធី ត្រូវបានធ្វើបច្ចុប្បន្នភាព<br>២. អង្គភាពថវិកាក្រសួងស្ថាប័នចំនួន ៨៤៨ ដែលក្នុងនោះថ្នាក់កណ្តាលមាន ២៤៦ អង្គភាព និងថ្នាក់រាជធានី ខេត្តមានចំនួន ៦០២អង្គភាព ត្រូវបានពិនិត្យកែសម្រួល និងរៀបចំដាក់ឱ្យអនុវត្ត<br>៣. ក្រសួង ស្ថាប័នចំនួន ៣៩ ត្រូវបានដាក់ឱ្យអនុវត្តអង្គភាពថវិកា<br>៤. សិទ្ធិអំណាចរបស់អង្គភាពថវិកា និងអង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធ ត្រូវបានកែលម្អ ដោយការពិនិត្យ និងកែសម្រួល÷ (១). ការផ្តល់សិទ្ធប្រើប្រាស់រជ្ជទេយ្យបុរេប្រទានក្នុងការទិញផ្ទាល់ពីក្រុមហ៊ុន, (២). សិទ្ធរបស់មន្ត្រីទទួលហិរញ្ញវត្ថុ ក្នុងការចូលរួមរៀបចំ និងតាមដានលើអនុវត្តថវិកា និង (៣). សិទ្ធិចាត់ចែងលើការរៀបចំនិងអនុវត្តថវិការបស់អង្គភាពថវិកា ។ | ១០០% |
| ២៤.៣. រៀបចំនិងដាក់ឱ្យអនុវត្តទម្រង់របាយការណ៍វឌ្ឍនភាពអនុវត្តថវិកាប្រចាំត្រីមាស ឆមាសនិងប្រចាំឆ្នាំ(ដោយរំលេចពី ការរៀបចំថវិកា លទ្ធផលសម្រេចបាននិង ព្រមទាំងវិធាន | ១. ទម្រង់របាយការណ៍វឌ្ឍនភាពអនុវត្តថវិកា (របាយការណ៍ហិរញ្ញវត្ថុ) ប្រចាំត្រីមាស, ឆមាស និងប្រចាំឆ្នាំ និងទម្រង់សំណើថវិកាកម្មវិធី ត្រូវបានកែសម្រួល<br>២. សេចក្តីណែនាំលេខ០០៥សហវ ស្តីពីគោលការណ៍និងនីតិវិធីផ្ទេរក្នុងសម្រាប់ការអនុវត្តថវិកាកម្មវិធីរបស់ កសហវ ត្រូវបាន | ៩៨% |

| ចង្កោមសកម្មភាព | វឌ្ឍនភាពសម្រេចបាន នៃសូចនាករសមិទ្ធកម្មគន្លឹះ | ពិន្ទុភាគរយ |
|---|---|---|
| ការដោះស្រាយ ពីក្រសួងស្ថាប័នទៅ កសហវ វត្ថុ និងនៅផ្ទៃក្នុងក្រសួងនីមួយៗ) | សម្រេចបានសេចក្តីព្រាងបឋមកម្រិតអគ្គលេខាធិការដ្ឋាននិងត្រៀមប្រជុំពិភាក្សាជាមួយអគ្គនាយកដ្ឋានពាក់ព័ន្ធ ។ | |
| គោលបំណង ២៥. បង្កើនតម្លាភាពថវិកា | | ៩៦% |
| ២៥.១. បង្កើនការចូលរួមសាធារណៈជនក្នុងដំណើរការថវិកា | ១. វេទិកាសាធារណៈស្តីពីក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ច ត្រូវបានរៀបចំក្រោមប្រធានបទ "ក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈ" និងបានរៀបចំរបាយការណ៍ជូនសម្តេចនាយក-រដ្ឋមន្ត្រី<br>២. សិក្ខាសាលាពិគ្រោះយោបល់លើវិស័យអាទិភាពចំនួន ០៤ រួមមានវិស័យកសិកម្ម, អប់រំ, បណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ, និងឡជីស្ទីក ត្រូវបានរៀបចំរួចរាល់<br>៣. របាយការណ៍សេដ្ឋកិច្ចនិងហិរញ្ញវត្ថុសាធារណៈត្រូវបានផ្សព្វផ្សាយលើគេហទំព័រក្រសួងសេដ្ឋកិច្ច បានទាន់ពេលវេលា (ព្រឹត្តិបត្រស្ថិតិសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាទម្រង់របាយ-ការណ៍)<br>៤. របាយការណ៍ស្តីពីសេចក្តីពន្យល់សង្ខេបស្តីពីសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំ ត្រូវបានផ្សព្វផ្សាយ ។ | ១០០% |
| ២៥.២. បង្កើនការផ្សព្វផ្សាយឯកសារថវិកា | ១. របាយការណ៍សង្ខេបស្តីពីសេចក្តីព្រាងច្បាប់ថវិកាប្រចាំឆ្នាំត្រូវបានផ្សព្វផ្សាយ<br>២. សៀវភៅថវិកាសង្ខេបនៃច្បាប់ថវិកាប្រចាំឆ្នាំ ត្រូវបានផ្សព្វផ្សាយបន្ទាប់ពីទម្រង់សៀវភៅថវិកាសង្ខេបនៃច្បាប់ថវិកាប្រចាំឆ្នាំ ត្រូវបានសិក្សាឡើងវិញ និងកែលម្អ<br>៣. កិច្ចប្រជុំបូកសរុប និងវាយតម្លៃការអនុវត្តផែនការសកម្មភាពប្រចាំឆ្នាំ របស់អគ្គនាយកដ្ឋានថវិកា ត្រូវបានសម្របសម្រួលរៀបចំ<br>៤. គេហទំព័ររបស់ អ.ស.ក. ត្រូវបានដាក់ឱ្យដំណើរការ និងធ្វើបច្ចុប្បន្នភាពជាប្រចាំ ។ | ១០០% |

| ចង្កោមសកម្មភាព | វឌ្ឍនភាពសម្រេចបាន នៃសូចនាករសមិទ្ធកម្មគន្លឹះ | ពិន្ទុភាគរយ |
|---|---|---|
| ២៥.៣. បង្កើនតម្លាភាពកិច្ចលទ្ធកម្មសាធារណៈ | ១. សេចក្ដីណែនាំស្ដីពីនីតិវិធីនៃការធ្វើចំណាត់ប្រភេទ និងចំណាត់ថ្នាក់អ្នកទទួលការសាងសង់ត្រូវបានឯកឧត្ដមបណ្ឌិតសភាចារ្យ ទេសរដ្ឋមន្ត្រីចុះហត្ថលេខាដាក់ឱ្យអនុវត្ត តាមសេចក្ដីណែនាំលេខ ០១៣ សហវ ចុះថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១៧<br>២. វគ្គបណ្ដុះបណ្ដាលជំនាញលទ្ធកម្មដល់ក្រុមលទ្ធកម្មថ្នាក់ជាតិត្រូវបានរៀបចំ<br>៣. សៀវភៅណែនាំស្ដីពីការត្រួតពិនិត្យកិច្ចលទ្ធកម្មតាមក្រោយត្រូវបានបោះពុម្ព និងបានធ្វើសិក្ខាសាលាផ្សព្វផ្សាយអនុវត្តរួចរាល់ជូនសមាជិក សមាជិការលទ្ធកម្ម និងមន្ត្រីអង្គភាពលទ្ធកម្មនៃស្ថាប័នអនុវត្តលទ្ធកម្ម និងមន្ត្រីក្រុមលទ្ធកម្មនៃអង្គភាពថវិកា ចាប់ពីថ្ងៃទី២៧ ដល់ថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៧<br>៤. ប្រព័ន្ធគ្រប់គ្រងលទ្ធកម្មសាធារណៈតាមប្រព័ន្ធព័ត៌មានវិទ្យា (Public Procurement Management Information System - PPMIS) សម្រាប់ប្រើប្រាស់ផ្ទៃក្នុង GDPP ត្រូវបង្កើតរួចរាល់នូវមុខងារគ្រប់គ្រងផែនការលទ្ធកម្ម និងបានដាក់ឱ្យមន្ត្រីពាក់ព័ន្ធនៃការិយាល័យផែនការ ស្ថិតិ និងព័ត៌មានវិទ្យាអនុវត្ត<br>៥. ផែនការលទ្ធកម្ម កសហវ ត្រូវបានបូកសរុប និងដាក់ឱ្យអនុវត្តទាន់ពេលវេលា ។ | ៩០% |
| **ផ្នែកទី៣÷ ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ** | | ៩៤% |
| គោលបំណង ៣១. ពង្រឹង និងពង្រីកការអនុវត្តថវិកាកម្មវិធី | | ៩៩% |
| ៣១.១. ការពិនិត្យឡើងវិញនិងការកែលម្អការអនុវត្តថវិកាកម្មវិធី | ១. ផែនទីបង្ហាញផ្លូវនៃការអនុវត្តថវិកាកម្មវិធី ត្រូវបានរៀបចំ និងផ្សព្វផ្សាយ<br>២. ទម្រង់តារាងសម្រាប់តាមដានចលនាឥណទានសរុបរបាយ-ការណ៍ស្ដីពីចលនាឥណទានប្រចាំឆ្នាំ ត្រូវបានរៀបចំ<br>៣. ទម្រង់ជំនួយស្មារតីចរចាថវិកាប្រចាំឆ្នាំ ត្រូវបានកែសម្រួល និងត្រូវបានដាក់ឱ្យប្រើប្រាស់<br>៤. កម្មវិធីបណ្ដុះបណ្ដាលស្ដីពីឧបករណ៍តាមដានសម្រាប់រចនា-សម្ព័ន្ធថវិកាកម្មវិធី និងសូចនាករ ត្រូវបានរៀបចំឡើងដោយជំនាញការកណាដា | ៩៨% |

| | | |
|---|---|---|
| | ៥. របាយការណ៍ស្តីពីលទ្ធផលនិងការប្រឈមនៃការអនុវត្តថវិកាកម្មវិធីត្រូវបានរៀបចំ និងត្រូវបានដាក់ជូនឯកឧត្តមទេសរដ្ឋមន្ត្រីដើម្បីផ្តល់អនុសាសន៍<br>៦. ការអនុវត្តថវិកាកម្មវិធីត្រូវបានត្រួតពិនិត្យឡើងវិញលើការងារវឌ្ឍនភាព បញ្ហាប្រឈម ជាមូលដ្ឋានសម្រាប់ដោះស្រាយបញ្ហាពាក់ព័ន្ធផ្សេងៗនិងកំណត់ទិសដៅអនុវត្តដើម្បីធានា បាននូវប្រសិទ្ធភាពនៃការអនុវត្តថវិកាកម្មវិធី ។ | |
| ៣១.២. ការរៀបចំយុទ្ធសាស្ត្រដើម្បីពង្រីកថវិកាកម្មវិធី | ១. សេចក្តីព្រាងយុទ្ធសាស្ត្រស្តីពីការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ ២០១៧-២០២៥ បានដាក់ឆ្លងគណៈរដ្ឋមន្ត្រី ដើម្បីអនុម័ត<br>២. ក្រសួង ស្ថាប័នទាំង ៣៦ ត្រូវបានដាក់ឱ្យអនុវត្តថវិកាកម្មវិធីពេញលេញ ។ | ១០០% |
| ៣១.៣. ការអនុវត្តផែនការបណ្តុះបណ្តាលនិងការកសាងសមត្ថភាពសម្រាប់ការពង្រឹងនិងពង្រីកការអនុវត្តថវិកាតាមកម្មវិធី | ១. ឯកសារបង្រៀនថវិកាកម្មវិធីរបស់អគ្គនាយកដ្ឋានថវិកា ត្រូវបានធ្វើបច្ចុប្បន្នភាព<br>២. ក្រសួងចំនួន៣ចុងក្រោយក្នុងនោះក៏មានមន្ត្រីជំនាញនៃស្នងការរាជធានី-ខេត្ត ចំនួន ២តំបន់ (៦ ខេត្ត) បានទទួលបណ្តុះ-បណ្តាលដើម្បីត្រៀមដាក់ឱ្យអនុវត្តថវិកាកម្មវិធីនៅឆ្នាំ ២០១៨<br>៣. មន្ត្រីនៃនាយកដ្ឋានថវិកានីយកម្មទទួលបានការបណ្តុះបណ្តាលស្តីពីការត្រួតពិនិត្យការអនុវត្តថវិកាកម្មវិធី<br>៤. កម្មវិធីបណ្តុះបណ្តាល សម្រាប់បណ្តុះបណ្តាលមន្ត្រីទទួលបន្ទុកហិរញ្ញវត្ថុរបស់ក្រសួង ស្ថាប័ន ជាពិសេស ចំពោះក្រសួង ស្ថាប័នដែលទើបចាប់ផ្តើមអនុវត្តថវិកាកម្មវិធី (វិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសហការជាមួយអគ្គនាយកដ្ឋានពាក់ព័ន្ធនៃ កសហវ) ។ | ១០០% |
| គោលបំណង ៣២. រៀបចំថវិកាឱ្យមានលក្ខណៈគ្រប់ជ្រុងជ្រោយ និងធ្វើសមាហរណកម្មថវិកា | | ៩៨% |
| ៣២.១. បន្តកែលម្អការធ្វើសមាហរណកម្មថវិកាចរន្តនិងថវិកាមូលធន តាមរយៈក្របខ័ណ្ឌចំណាយរយៈពេលមធ្យម (MTEF), ផែនការយុទ្ធសាស្ត្រថវិកា (BSP) និងថវិកាកម្មវិធី (PB) | ១. គោលការណ៍ណែនាំស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកាត្រូវបានធ្វើបច្ចុប្បន្នភាព<br>២. ផែនការយុទ្ធសាស្ត្រថវិការបស់ក្រសួងថវិកាកម្មវិធីទាំង ១០ ត្រូវបានត្រួតពិនិត្យវាយតម្លៃ<br>៣. ការបណ្តុះបណ្តាលដល់ក្រសួង ស្ថាប័ន ស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកា និងថវិកាកម្មវិធី ត្រូវបានរៀបចំ | ៩៦% |

| | | |
|---|---|---|
| | ៤. ក្របខ័ណ្ឌចំណាយមូលធន និងជួសជុលថែទាំ រយៈពេលមធ្យម ហិរញ្ញប្បទានដោយថវិកាជាតិត្រូវបានរៀបចំ និងបញ្ចូនក្នុងក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ចឆ្នាំ២០១៨-២០២០ ។ | |
| ៣២.២.ការបញ្ចូលចំណូល-ចំណាយដែលនៅក្រៅបរិបទថវិកាទៅក្នុងថវិកាប្រចាំឆ្នាំ ដោយរួមទាំងថវិកាដៃគូអភិវឌ្ឍន៍ | ១. ស្ថាប័នអនុវត្តគម្រោង ចំនួន ០១ (អ.គ.ហ.) បានអនុវត្តមាតិកាគណនីនៃប្លង់គណនេយ្យ (COA) ថ្មីសម្រាប់គម្រោង/កម្មវិធី ហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍ ។ | ១០០% |
| គោលបំណង ៣៣. រៀបចំនិងដាក់ឱ្យអនុវត្តប្រព័ន្ធ បន្ទាត់គណនេយ្យភាព (រវាងនិតិបញ្ញត្តិ និង និតិប្រតិបត្តិ, រវាងកសហវ និងក្រសួង ស្ថាប័ន និងនៅក្នុងក្រសួង ស្ថាប័ន) | | ៩៣% |
| ៣៣.១.ការពិនិត្យឡើងវិញ និងរៀបចំលិខិតបទដ្ឋានគតិយុត្តក្នុងក្របខ័ណ្ឌនៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់រដ្ឋាភិបាលក្នុងបរិបទនៃការអនុវត្តថវិកាកម្មវិធី | ១. របាយការណ៍ស្តីពីការពិនិត្យឡើងវិញ និងសំណើរៀបចំលិខិតបទដ្ឋានគតិយុត្តិ នៃការអនុវត្តថវិកាកម្មវិធី បានរៀបចំនិងបញ្ជូនរួចរាល់ (អគ្គនាយកដ្ឋានរតនាគារជាតិ) ។ | ១០០% |
| ៣៣.២.កំណត់ឱ្យបានច្បាស់នូវបន្ទាត់គណនេយ្យភាពក្នុងការរៀបចំកម្មវិធីវិនិយោគសាធារណៈដើម្បីធានាសង្គតិភាពក្នុងថវិកាប្រចាំឆ្នាំ (កំណត់ពីការទទួលខុសត្រូវឱ្យបានច្បាស់លាស់រវាងក្រសួង ស្ថាប័ននីមួយៗ រួមមាន ក្រសួងផែនការ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងកសហវ) | ពុំមានគ្រោងសកម្មភាពអនុវត្ត | - |
| ៣៣.៣.ធ្វើបច្ចុប្បន្នភាពនិងផ្សព្វផ្សាយនីតិវិធីណែនាំដែលពន្យល់ពីការផ្តល់សិទ្ធិអំណាច និងការទទួលខុសត្រូវដល់អង្គ | ១. ប្រកាសលេខ ១២៨២ សហវ.ប្រក. ចុះថ្ងៃទី ១៧ ខែតុលា ឆ្នាំ ២០១៦ ស្តីពីសិទ្ធិអំណាច ការទទួលខុសត្រូវ និង នីតិវិធីនៃការអនុវត្តថវិកាកម្មវិធីរបស់អង្គភាពថវិកា ត្រូវបានប្រកាសដាក់ឱ្យប្រើប្រាស់ និងផ្សព្វផ្សាយជូនក្រសួង ស្ថាប័ន | ៨០% |

| | | |
|---|---|---|
| ភាពថវិកា និងអ្នកគ្រប់គ្រងថវិកាតាមកម្មវិធី | ២. របាយការណ៍លទ្ធផលនៃការអនុវត្តគោលការណ៍ស្តីពីការទទួលខុសត្រូវនិងនីតិវិធីអនុវត្តថវិកាកម្មវិធីរបស់អង្គភាពថវិកា ត្រូវបានរៀបចំ ពិនិត្យ និងមានចំណាររបស់ឯកឧត្តមបណ្ឌិតសភាចារ្យ<br>៣. កម្រងនីតិវិធីណែនាំអំពីសិទ្ធអំណាច និងការទទួលខុសត្រូវរបស់អង្គភាពថវិកាដែលជាសមត្ថកិច្ចរបស់ អគ្គនាយកដ្ឋានរតនាគារជាតិ បានប្រមូលចងក្រង និងរៀបចំជាសៀវភៅ ដែលមាន ៦ ផ្នែកធំៗ គឺ÷ (១). បទបញ្ញាទូទៅនៃគណនេយ្យសាធារណៈ, (២). នីតិវិធីរជ្ជទេយ្យចំណូល និង កិច្ចបញ្ជិកាគណនេយ្យកាន់កាប់ដោយរជ្ជទេយ្យករចំណូល, (៣). នីតិវិធីរជ្ជទេយ្យបុរេប្រទាន និងកិច្ចបញ្ជិកាគណនេយ្យកាន់កាប់ ដោយរជ្ជទេយ្យករបុរេប្រទាន, (៤). គ្រឹះស្ថានសាធារណៈរដ្ឋបាល, (៥). ចំណាត់ថ្នាក់ថវិកានិងប្លង់ គណនេយ្យ, (៦). បទបង្ហាញសម្រាប់បណ្តុះបណ្តាលដល់ក្រសួង ស្ថាប័ន និងមន្ទីរ អង្គភាពអនុវត្តថវិកាកម្មវិធី ។ | |
| ៣៣.៤. កែសម្រួលរចនាសម្ព័ន្ធស្ថាប័នឱ្យឆ្លើយតបទៅនឹងប្រព័ន្ធដំណើរការការងារថ្មីដែលត្រូវបានបង្កើតដោយ រួមទាំងការត្រួតពិនិត្យមើលឡើងវិញលើមុខងារនិងការទទួលខុសត្រូវរបស់មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុដែលត្រូវបានបញ្ជូនទៅតាមក្រសួង-ស្ថាប័ន | ១. ប្រកាស និងលិខិតបទដ្ឋាននានាពាក់ព័ន្ធនានា(អនុក្រឹត្យលេខ ១៥២អនក្រ, ប្រកាសលេខ៦៥០ សហវ.ប្រក, ប្រកាសអន្តរក្រសួងលេខ៥០៣ សហវ.ប្រក និងប្រកាសអន្តរក្រសួងលេខ ៧៤១ សហវ.ប្រក) ពាក់ព័ន្ធរបស់សាមីក្រសួង ស្ថាប័នពាក់ព័ន្ធសម្រាប់កែសម្រួលការអនុវត្តថវិការបស់ក្រសួង ស្ថាប័ន ត្រូវបានរៀបចំនិងដាក់ឱ្យអនុវត្តឱ្យឆ្លើយតបទៅនឹងប្រព័ន្ធដំណើរការការងារថ្មីត្រូវបានរៀបចំនិងដាក់ឱ្យអនុវត្តថវិកា<br>២. ប្រកាសលេខ ១៧១ សហវ.ប្រក ចុះថ្ងៃទី ១៦-០២-២០១៧ ស្តីពីនីតិវិធីអនុវត្តថវិការបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវបានផ្សព្វផ្សាយជូនគ្រឹះស្ថានសាធារណៈរដ្ឋបាលទាំងអស់ដែលមាននៅតាមក្រសួង ស្ថាប័ន ។ | ១០០% |
| គោលបំណង ៣៤. ពង្រឹងការរៀបចំគោលនយោបាយនិងការធ្វើផែនការហិរញ្ញវត្ថុសាធារណៈ (ការរៀបចំគោលនយោបាយនិងផែនការចំណូលនិងចំណាយរយៈពេលមធ្យម) | | ៩០% |
| ៣៤.១. ពង្រឹងសមត្ថភាពរៀបចំ និងបង្កើនស័ក្តិសិទ្ធភាព និង | ១. សេចក្តីព្រាងក្របខ័ណ្ឌគោលនយោបាយ និងទិសដៅថវិកាសម្រាប់វិស័យអាទិភាពចំនួន ៣ ត្រូវបានរៀបចំ ដោយតម្រូវឱ្យមានធាតុចូលពីក្រុមការងារជំនាញពាក់ព័ន្ធ | ៩៧% |

| | | |
|---|---|---|
| ប្រសិទ្ធភាពនៃក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច | ២. ក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច ត្រូវបានកែសម្រួលផ្អែកលើការវិភាគ និងវាយតម្លៃស្ថានភាពម៉ាក្រូសេដ្ឋកិច្ចពាក់កណ្តាលឆ្នាំ ២០១៧ និងបានដាក់ជូនថ្នាក់ដឹកនាំពិនិត្យ និងសម្រេច<br>៣. របាយការណ៍តាមដាន និងវាយតម្លៃពាណិជ្ជកម្មក្រៅប្រទេសរបស់កម្ពុជា (REER/NEER) ត្រូវបានរៀបចំ ដោយមានទាំងការសិក្សាស្វែងយល់ពីការកត់ត្រាទិន្នន័យពាណិជ្ជកម្មអន្តរជាតិ និងរបាយការណ៍ស្តីពីការចុះតាមដាន និងពិភាក្សាលើទិន្នន័យ និងស្ថានភាពវិស័យទេសចរណ៍ ឆ្នាំ២០១៧ ត្រូវបានរៀបចំ ។ | |
| ៣៤.២. ពង្រឹងសមត្ថភាពរៀបចំ និងបង្កើនស័ក្តិសិទ្ធភាព និងប្រសិទ្ធភាពនៃក្របខ័ណ្ឌចំណូល-ចំណាយរយៈពេលមធ្យម | ១. មន្ត្រីពាក់ព័ន្ធនានា ទទួលបានការបណ្តុះបណ្តាលលើប្រធានបទការរៀបចំក្របខ័ណ្ឌចំណាយរយៈពេលមធ្យម (MTEF) ពីអ្នកជំនាញការរបស់ IMF ។ | ៨០% |
| ៣៤.៣. ពង្រឹងសមត្ថភាពវិភាគ និងព្យាករណ៍ស្ថានភាពសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ១. ម៉ូដែលព្យាករម៉ាក្រូសេដ្ឋកិច្ចកម្ពុជា (Cambodia Macroeconomic Forecasting Model - CMFM) ត្រូវបានធ្វើបច្ចុប្បន្នកម្ម និងប្រើប្រាស់ (version ២.០) សម្រាប់ព្យាករសេដ្ឋកិច្ច<br>២. ទិន្នន័យវិស័យចំនួន ៤ ក្នុងទម្រង់ Financial Programming and Policies ត្រូវបានធ្វើបច្ចុប្បន្នកម្ម និងមានរបាយការណ៍ប្រចាំឆ្នាំស្តីពីលទ្ធផលវិភាគសេដ្ឋកិច្ចតាមរយៈការប្រើប្រាស់ទម្រង់ FPP<br>៣. ស្តង់ដារស្ថិតិប្រតិបត្តិការហិរញ្ញវត្ថុ TOFE ថ្នាក់ក្រោមជាតិ ត្រូវបានរៀបចំ និងសិក្ខាសាលាផ្សព្វផ្សាយ TOFE & GFS និងពង្រឹងការប្រមូលទិន្នន័យពីស្ថាប័នពាក់ព័ន្ធថ្នាក់ជាតិនិងក្រោមជាតិក្នុង ១ឆ្នាំ១ដង ត្រូវបានរៀបចំ<br>៤. ស្ថិតិតាមស្តង់ដារ GFS (GFS 2014 framework) ត្រូវបានពិនិត្យ និងផ្ទៀងផ្ទាត់ដោយជំនាញការ GFS របស់ IMF និងមានទិន្នន័យប្រតិបត្តិការហិរញ្ញវត្ថុថ្នាក់ក្រោមជាតិ GFS ឆ្នាំ ២០១៦ ដោយបានសាកល្បងបញ្ចូលទិន្នន័យ Extra- | ៩៨% |

| | | |
|---|---|---|
| | budgetary (ទិន្នន័យ គំរូ) ក្នុង GFS ថ្នាក់ជាតិនៃអង្គភាពសាធារណៈរដ្ឋបាល ( សាកល្បងទិន្នន័យឆ្នាំ ២០១៦)<br>៥. របាយការណ៍ស្តីពីវិភាគលើផលប៉ះពាល់នៃការចរចា និងការអនុវត្តកិច្ចព្រមព្រៀងពាណិជ្ជកម្មទំនិញអាស៊ាន (ATIGA), ស្តីពីវិភាគលើផលប៉ះពាល់នៃការចរចា និងការអនុវត្តកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន-ចិន (ACFTA), ស្តីពីវិភាគលើផលប៉ះពាល់នៃការចរចា និងការអនុវត្តកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន-អូស្ត្រាលី-ណូវែលហ្សេឡង់ (AANZFTA), ស្តីពីវិភាគលើផលប៉ះពាល់នៃការចរចា និងការអនុវត្តភាពជាដៃគូសេដ្ឋកិច្ចទូលំទូលាយអាស៊ាន-ជប៉ុន (AJCEP), ស្តីពីវិភាគលើផលប៉ះពាល់នៃការចរចា និងការអនុវត្តកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន-កូរ៉េ (AKFTA) ត្រូវបានរៀបចំ<br>៦. របាយការណ៍ស្តីពីវិភាគលើផលប៉ះពាល់នៃការចរចា និងការអនុវត្តជាដៃគូសេដ្ឋកិច្ចទូលំទូលាយតំបន់ និងស្តីពីវិភាគលើផលប៉ះពាល់នៃការចរចា និងការអនុវត្តកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន-ហុងកុង (AHKFTA) ត្រូវបានរៀបចំ<br>៧. របាយការណ៍ ស្តីពីការសិក្សាស្រាវជ្រាវ កំណត់ និងផ្តល់អនុសាសន៍លើវិធានពាក់ព័ន្ធនឹងការរឹងត្បិតពាណិជ្ជកម្មបំផុតត្រូវបានរៀបចំ<br>៨. របាយការណ៍ស្តីពីការកែលម្អ និងការធ្វើបច្ចុប្បន្នភាពលើគេហទំព័រ និហិតដ្ឋានជាតិព័ត៌មានពាក់ព័ន្ធនឹងពាណិជ្ជកម្ម និងស្តីពីការវាយតម្លៃលើប្រសិទ្ធភាព និងអត្ថប្រយោជន៍នៃនិហិតដ្ឋានជាតិព័ត៌មានពាក់ព័ន្ធនឹងពាណិជ្ជកម្មត្រូវបានរៀបចំ។ | |
| គោលបំណង ៣៥. រៀបចំប្រព័ន្ធត្រួតពិនិត្យ | | ៩៦% |
| ៣៥.១. ត្រួតពិនិត្យមើលឡើងវិញពីប្រព័ន្ធត្រួតពិនិត្យ អធិការកិច្ច សវនកម្ម និងសវនកម្មផ្ទៃក្នុង នាពេលបច្ចុប្បន្ននៅគ្រប់ក្រសួង ស្ថាប័ន | ១. សេចក្តីព្រាងនីតិវិធីនៃផែនការចុះសវនកម្ម ត្រូវបានសរសេរ និងបញ្ចប់<br>២. សេចក្តីព្រាងនីតិវិធីនៃការអនុវត្តសវនកម្មផ្ទៃក្នុង ត្រូវបានសរសេរ និងបញ្ចប់<br>៣. តារាងផែនកពីភាពសមស្របនិងគ្រប់គ្រាន់នៃការតាក់តែងរចនាសម្ព័ន្ធគ្រប់គ្រងនិងការបែងចែកមុខងារ, ពីភាពសមស្របនិងគ្រប់គ្រាន់នៃការតាក់តែងប្រព័ន្ធគ្រប់គ្រងមន្ត្រីរាជការនិង | ៩៩% |

| | | |
|---|---|---|
| | បុគ្គលិកកិច្ចសន្យា, ពីភាពសមស្របនិងគ្រប់គ្រាន់នៃការតាក់តែងប្រព័ន្ធគ្រប់គ្រងឯកសាររដ្ឋបាល និងពីភាពសមស្របនិងគ្រប់គ្រាន់នៃការតាក់តែងប្រព័ន្ធស្តង់ដាសេវាសាធារណៈ ត្រូវបានរៀបចំ<br>៤. របាយការណ៍ស្តីពីប្រសិទ្ធភាពនៃការអនុវត្តតាមរចនាសម្ព័ន្ធគ្រប់គ្រងនិងការបែងចែកមុខងារ, ស្តីពីភាពសមស្របនិងគ្រប់គ្រាន់នៃការតាក់តែងប្រព័ន្ធគ្រប់គ្រងមន្ត្រីរាជការនិងបុគ្គលិកកិច្ចសន្យា, ស្តីពីភាពសមស្របនិងគ្រប់គ្រាន់នៃការតាក់តែងប្រព័ន្ធគ្រប់គ្រងឯកសាររដ្ឋបាល និងស្តីពីភាពសមស្របនិងគ្រប់គ្រាន់នៃការតាក់តែងប្រព័ន្ធស្តង់ដាសេវាសាធារណៈ ត្រូវបានចេញផ្សាយ<br>៥. សេចក្តីព្រាងរបាយការណ៍អង្កេតស្តីពី“ ស្ថានភាពជាក់ស្តែងនៃប្រព័ន្ធអធិការកិច្ច និងសវនកម្មពេលបច្ចុប្បន្នតាមបណ្តា ក្រសួងស្ថាប័ន” បានបញ្ចប់ការពិភាក្សាកម្រិតបច្ចេកទេស ត្រឹមថ្ងៃទី ២៧ ខែធ្នូ ឆ្នាំ២០១៧<br>៦. សេចក្តីព្រាងចុងក្រោយស្តីពីវិធាននិងនីតិវិធីនៃការគ្រប់គ្រងនិងអនុវត្តអធិការកិច្ចហិរញ្ញវត្ថុកម្រិតបច្ចេកទេសអន្តរអគ្គនាយកដ្ឋាន ត្រូវបានរៀបចំ ហើយដាក់ឆ្លងកិច្ចប្រជុំអន្តរក្រសួង ។ | |
| ៣៥.២. រៀបចំប្រព័ន្ធត្រួតពិនិត្យថ្មីឱ្យមានប្រសិទ្ធភាព ស័ក្តិសិទ្ធភាព និងឆ្លើយតបបានទៅនឹងបរិបទថ្មី ដើម្បីបំពេញមុខងារគ្នាទៅវិញទៅមក សម្រាប់ការគ្រប់គ្រងក្រសួងស្ថាប័ន | ១. លិខិតបទដ្ឋាន និងស្ថិតិសំខាន់ៗយ៉ាងតិច ២០ច្បាប់ត្រូវបានប្រមូល និងបញ្ចូលក្នុង Box cloud នៃ Database<br>២. ប្រព័ន្ធគ្រប់គ្រងឯកសាររដ្ឋបាល DMS ជំហានទី១ មាន ៤ ជំហាន រួមមាន÷ ១. សរសេរជាគំរោង DMS, ២. រៀបចំហេដ្ឋារចនាសម្ព័ន្ធ នៃ DMS, ៣. រៀបចំ User matrix ត្រូវបានរៀបចំ<br>៣. របាយការណ៍ស្តីពីលទ្ធផលត្រួតពិនិត្យប្រសិទ្ធភាពនៃការអនុវត្តថវិកាកម្មវិធីសម្រេចបាន ២៥ គោលដៅ ត្រូវបានចេញផ្សាយ<br>៤. ទិន្នន័យពីប្រព័ន្ធ FMIS ដំណាក់កាលទី៣ សរុបចំនួន ១៨៥ ឯកសារ និងបំលែងទិន្នន័យទាំងនេះ ត្រូវបានទាញចេញ តាមតម្រូវការប្រតិភូអធិការកិច្ចហិរញ្ញវត្ថុ<br>៥. មុខងារផលិត"ឧបសម្ព័ន្ធនៃរបាយការណ៍ចុះធ្វើអធិការកិច្ច | ៩៨% |

| | | |
|---|---|---|
| | ហិរញ្ញវត្ថុ" ក្នុងប្រព័ន្ធ FIDS ត្រូវបានដាក់ប្រើប្រាស់ក្នុងការិយាល័យ អធិការកិច្ចហិរញ្ញវត្ថុតាមបច្ចេកវិទ្យាព័ត៌មាន ក្នុងត្រីមាសទី៤ ឆ្នាំ២០១៧<br>៦. Business Process លើមុខងារ "គ្រប់គ្រងដំណើរការ ការងារផ្ទៃក្នុង" និងមុខងារ "គ្រប់គ្រងដំណើរការការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈអគ្គាធិការដ្ឋាន" ក្នុងប្រព័ន្ធ FIDS ត្រូវបានរៀបចំបញ្ចប់<br>៧. លក្ខខណ្ឌនៃមុខងារ "គ្រប់គ្រងធនធានឯកសារ និងព័ត៌មាន" និងមុខងារ "គ្រប់គ្រងថវិកាកម្មវិធីនៅអគ្គាធិការដ្ឋាន (PB Management- PBM)" ត្រូវបានរៀបចំនិងដាក់ឱ្យអនុវត្តជាមួយនឹងការបណ្តុះបណ្តាលដល់មន្ត្រីបង្គោល ។ | |
| ៣៥.៣.កែលម្អយន្តការត្រួតពិនិត្យ ដើម្បីធានាការឆ្លើយតបក្នុងការបំពេញមុខងាររវាងសវនកម្មផ្ទៃក្នុង និងអធិការកិច្ចប្រកបដោយប្រសិទ្ធភាពទៅនឹងលទ្ធផល ដែលរកឃើញដោយសវនកម្មផ្ទៃក្នុង និងអធិការកិច្ច | ១. របាយការណ៍ស្តីពីលទ្ធផលតាមដានកែលម្អតាមអនុសាសន៍សវនកម្មផ្ទៃក្នុង ចំនួន ២៥ គោលដៅ និងចេញលិខិតជំរុញចំនួន ៩ លិខិតសរុប ៣៤ គោលដៅ ត្រូវបានរៀបចំ<br>២. អនុសាសន៍របស់ NAA យ៉ាងតិច ២ គោលដៅ ត្រូវបានតាមដានដោយបានចេញលិខិតទៅសវនដ្ឋាន<br>៣. របាយការណ៍សរុបស្តីពីលទ្ធផលសវនកម្មផ្ទៃក្នុងប្រចាំឆ្នាំ២០១៥ (ការិយបរិច្ឆេទ២០១៤) និង របាយការណ៍សរុបស្តីពីលទ្ធផលសវនកម្មផ្ទៃក្នុងឆ្នាំ ២០១៦ (ការិយបរិច្ឆេទ២០១៥) ត្រូវបានរៀបចំជូនឯកឧត្តមបណ្ឌិតសភាចារ្យទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី កសហវ<br>៤. សេចក្តីព្រាងសៀវភៅគោលស្តីពីការគ្រប់គ្រងការងារអធិការកិច្ចហិរញ្ញវត្ថុតាមបច្ចេកវិទ្យាព័ត៌មាន បានបញ្ចប់ការឆ្លងយោបល់ថ្នាក់ដឹកនាំ អគ្គាធិការដ្ឋាន នាសម័យប្រជុំថ្ងៃទី ២៦ ខែធ្នូ ឆ្នាំ ២០១៧<br>៥. សេចក្តីព្រាងសៀវភៅគោលស្តីពីការងារអធិការកិច្ចហិរញ្ញវត្ថុករណីបណ្តឹងតវ៉ា និងបរិហារ ត្រូវបានបញ្ចប់កិច្ចពិភាក្សាកម្រិតថ្នាក់ដឹកនាំអគ្គាធិការដ្ឋាន កសហវ នាថ្ងៃទី ២៦ ខែធ្នូ ឆ្នាំ ២០១៧ និងត្រូវដាក់ឱ្យប្រើប្រាស់ នៅថ្ងៃទី ២៩ ខែធ្នូ ឆ្នាំ ២០១៧ | ៩៤% |

| | | |
|---|---|---|
| | ៦. ទម្រង់របាយការណ៍សរុបលទ្ធផលអធិការកិច្ចហិរញ្ញវត្ថុ ត្រូវបានថ្នាក់ដឹកនាំ អគ្គាធិការដ្ឋាន សម្រេចដាក់ឱ្យប្រើប្រាស់ នាសម័យប្រជុំថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ២០១៧<br>៧. នីតិវិធីនិងវិធីសាស្ត្រធ្វើអធិការកិច្ចហិរញ្ញវត្ថុលើអនុលោមភាពលើរបាយការណ៍ហិរញ្ញវត្ថុ ដោយការត្រួតពិនិត្យជាក់ស្តែងនៅបណ្តាមន្ទីរជំនាញមួយចំនួនក្នុងខេត្តកំពង់ចាម ត្រូវបានប្រើប្រាស់<br>៨. យន្តការនិងនីតិវិធីអធិការកិច្ចលើការងារគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៅគ្រឹះស្ថានសាធារណៈរដ្ឋបាល ក្នុងត្រីមាសទី៣ ត្រូវបានដាក់ឱ្យអនុវត្ត<br>៩. សេចក្តីព្រាងនៃយន្តការធ្វើអធិការកិច្ចហិរញ្ញវត្ថុ នៅបណ្តាសហជីព សមាគម និងអង្គការក្រៅរដ្ឋាភិបាល នាថ្ងៃទី ២៦ ខែធ្នូ ឆ្នាំ២០១៧ ត្រូវបានបញ្ចប់ការពិភាក្សា<br>១០. ទម្រង់របាយការណ៍ធ្វើអធិការកិច្ចហិរញ្ញវត្ថុលើអនុលោមភាពត្រូវបានបញ្ចប់ការពិភាក្សាកម្រិតថ្នាក់ដឹកនាំអគ្គាធិការដ្ឋាននាថ្ងៃទី ២៦ ខែធ្នូ ឆ្នាំ២០១៧<br>១១. សេចក្តីព្រាងទម្រង់កំណត់ហេតុស្តីពីការធ្វើអធិការកិច្ចហិរញ្ញវត្ថុនៅសហជីព សមាគមន និងអង្គការក្រៅរដ្ឋាភិបាល នៅថ្ងៃទី ២៦ ខែធ្នូ ឆ្នាំ២០១៧ ត្រូវបានបញ្ចប់ការពិភាក្សាកម្រិតថ្នាក់ដឹកនាំអគ្គាធិការដ្ឋាន<br>១២. ឯកសារគតិយុត្តសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបានបញ្ចូលនៅក្នុង Web App របស់អគ្គាធិការដ្ឋាន កសហវ រួចរាល់ នៅថ្ងៃទី ២៩ ខែកញ្ញា ឆ្នាំ២០១៧<br>១៣. នីតិវិធីធ្វើអធិការកិច្ចហិរញ្ញវត្ថុនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបានសម្រេច និងដាក់ឱ្យប្រើប្រាស់ដោយថ្នាក់ដឹកនាំអគ្គាធិ-ការដ្ឋាន នៅថ្ងៃទី ២៩ ខែធ្នូ ឆ្នាំ២០១៧ ។ | |

| | | |
|---|---|---|
| ៣៥.៤.រៀបចំនិងកែលម្អផែនការសកម្មភាព និងកម្មវិធីសវនកម្ម/អធិការកិច្ច ប្រចាំឆ្នាំរបស់ក្រសួង-ស្ថាប័ន ដោយផ្អែកលើលក្ខណៈវិនិច្ឆ័យ និងចាត់វិធានការវាយតម្លៃហានិភ័យ ដែលផ្តល់អនុសាសន៍ដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ១. ក្រសួង ស្ថាប័ន យ៉ាងតិច ៨ គោលដៅត្រូវបានពិនិត្យប្រសិទ្ធភាពនៃមុខងារសវនកម្មផ្ទៃក្នុង និងមានរបាយការណ៍ត្រួតពិនិត្យ<br>២. សៀវភៅណែនាំនីតិវិធីសវនកម្មផ្ទៃក្នុងជូនក្រសួង ស្ថាប័ន មានសិក្ខាកាមចូលរួមចំនួន ១២៥ នាក់ ត្រូវបានចងក្រង និងរៀបចំសិក្ខាសាលាផ្សព្វផ្សាយ<br>៣. ផែនការសកម្មភាពយ៉ាងហោច ៨០%នៃផែនការសកម្មភាពដែលមាននៅក្នុងផែនការសវនកម្មប្រចាំឆ្នាំ របស់ កសហវ ចំនួន ១០៥ គោលដៅ ត្រូវបានអនុវត្ត<br>៤. របាយការណ៍ស្តីពីការពិនិត្យនិងផ្តល់យោបល់លើរបាយការណ៍សវនកម្មរបស់ក្រសួងស្ថាប័ន យ៉ាងតិច ២០ គោលដៅក្នុង១ឆ្នាំ ត្រូវបានរៀបចំ និងចេញផ្សាយ<br>៥. ផែនការយុទ្ធសាស្ត្រគ្រប់គ្រងការងារអធិការកិច្ចហិរញ្ញវត្ថុតាមបច្ចេកវិទ្យាព័ត៌មានឆ្នាំ ២០១៨ត្រូវបានដាក់ឱ្យអនុវត្ត នៅថ្ងៃទី ២៩ ខែធ្នូ ឆ្នាំ២០១៧<br>៦. ផែនការយុទ្ធសាស្ត្រអធិការកិច្ចហិរញ្ញវត្ថុឆ្នាំ២០១៨-២០២០ត្រូវបានបញ្ចប់ការឆ្លងយោបល់ថ្នាក់ដឹកនាំអគ្គាធិការដ្ឋាន នាថ្ងៃទី ២៦ ខែធ្នូ ឆ្នាំ២០១៧ និងសម្រេចដាក់ឱ្យអនុវត្តនៅថ្ងៃទី ២៩ ខែធ្នូ ឆ្នាំ២០១៧<br>៧. ផែនការកសាងសមត្ថភាពមន្ត្រីអគ្គាធិការដ្ឋានឆ្នាំ២០១៨ត្រូវបានដាក់ ឱ្យប្រើ នៅថ្ងៃទី ២៩ ខែធ្នូ ឆ្នាំ២០១៧<br>៨. កម្មវិធីនៃកិច្ចប្រតិបត្តិការអធិការកិច្ចហិរញ្ញវត្ថុ បានប្រជុំសម្រេចនៅថ្ងៃទី ២៦ ខែធ្នូ ឆ្នាំ២០១៧ និងបានដាក់ឱ្យប្រើប្រាស់នៅថ្ងៃទី ២៩ ខែធ្នូ ឆ្នាំ២០១៧ ។ | ៩២% |
| ៣៥.៥.ពង្រីកនិងពង្រឹងការធ្វើសវនកម្មផ្ទៃក្រៅ | សកម្មភាពត្រូវបានគ្រោងអនុវត្តដោយអាជ្ញាធរសវនកម្មជាតិ | - |
| គោលបំណង ៣៦. ពង្រឹងការអនុវត្តគោលនយោបាយវិមជ្ឈការហិរញ្ញវត្ថុ | | ៨៨% |
| ៣៦.១.ពិនិត្យមើលឡើងវិញនិងអនុវត្តគោលនយោបាយស្តីពីវិមជ្ឈការហិរញ្ញវត្ថុរយៈពេលមធ្យមនិងវែង | ១. អនុក្រឹត្យស្តីពីការកំណត់ប្រាក់ឧបត្ថម្ភសមាជិកក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបានរៀបចំរួច និងដាក់ឱ្យអនុវត្ត<br>២. សេចក្តីព្រាងអនុក្រឹត្យស្តីពីការផ្ទេរធនធានថវិការដ្ឋជូនមូលនិធិក្រុង ស្រុក ត្រូវបានរៀបចំនិងដាក់ប្រជុំពិភាក្សាអ្នកពាក់ព័ន្ធ | ៧២% |

| | | |
|---|---|---|
| | ៣. សេចក្តីព្រាងអនុក្រឹត្យស្តីពីការផ្ទេរធនធានថវិការដ្ឋជូនមូលនិធិឃុំសង្កាត់ ត្រូវបានរៀបចំ និងដាក់ប្រជុំពិភាក្សាអ្នកពាក់ព័ន្ធ ។ | |
| ៣៦.២.អនុវត្តការប្រមូលចំណូលផ្ទាល់របស់រដ្ឋបាលថ្នាក់ក្រោមជាតិ | ១. ប្រកាសស្តីពីការបែងចែកពន្ធលើអចលនទ្រព្យជូនរដ្ឋបាលខណ្ឌ និងសង្កាត់ត្រូវបានអនុម័ត និងដាក់ឱ្យអនុវត្ត<br>២. សេចក្តីព្រាងលិខិតបទដ្ឋានគតិយុត្តស្តីពីការចែករំលែកចំណូលរវាងរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបានដាក់ប្រជុំពិភាក្សាអង្គភាពពាក់ព័ន្ធក្នុង គសហវ | ៩១% |
| ៣៦.៣.អនុវត្តសាកល្បងនិងពង្រីកមូលនិធិវិនិយោគសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ (SNIF) | ១. សេចក្តីព្រាងគោលការណ៍ណែនាំស្តីពីការវាយតម្លៃលក្ខណៈសម្បត្តិប្រចាំឆ្នាំ (APA) សម្រាប់រដ្ឋបាល ស្រុក ត្រូវបានរៀបចំរួច និងដាក់ឱ្យអនុវត្ត<br>២. គោលការណ៍ណែនាំស្តីពីការវាយតម្លៃលក្ខណៈសម្បត្តិប្រចាំឆ្នាំ (APA) សម្រាប់រដ្ឋបាលស្រុក ត្រូវបានផ្សព្វផ្សាយនិងបណ្តុះបណ្តាលប្រកបដោយប្រសិទ្ធភាព<br>៣. រដ្ឋបាលស្រុកចំនួនយ៉ាងតិច ១៩ ត្រូវបានជ្រើសរើសវាយតម្លៃបឋមរួច ដើម្បីអនុវត្តមូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិ។ | ៧៨% |
| ៣៦.៤.ពិនិត្យមើលឡើងវិញ និងដាក់ឱ្យអនុវត្តគោលការណ៍ណែនាំស្តីពីផែនការយុទ្ធសាស្ត្រថវិកាសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ | ១. គោលការណ៍ណែនាំស្តីពីផែនការយុទ្ធសាស្ត្រថវិកាត្រូវបានធ្វើបច្ចុប្បន្នភាព និងដាក់ឱ្យអនុវត្ត និងត្រូវបានផ្សព្វផ្សាយ និងបណ្តុះបណ្តាល ជូនរដ្ឋបាលរាជធានី ខេត្តទាំង២៥ប្រកបដោយប្រសិទ្ធភាព | ១០០% |
| ៣៦.៥.រៀបចំនិងអនុវត្តការផ្ទេរធនធានមានភ្ជាប់លក្ខខណ្ឌ | ១. អនុក្រឹត្យស្តីពីការផ្ទេរធនធានហិរញ្ញវត្ថុមានភ្ជាប់លក្ខខណ្ឌ ត្រូវបានផ្សព្វផ្សាយប្រកបដោយ ប្រសិទ្ធភាព<br>២. មានរបាយការណ៍វាយតម្លៃលទ្ធផលនៃការអនុវត្តការផ្ទេរធនធានហិរញ្ញវត្ថុមានភ្ជាប់លក្ខខណ្ឌជូនរដ្ឋបាលថ្នាក់ក្រោមជាតិ(ក្រសួងបរិស្ថាន, និងក្រសួងអភិវឌ្ឍន៍ជនបទ) ។ | ៨៣% |
| ៣៦.៦.រៀបចំគោលការណ៍ណែនាំស្តីពីការរៀបចំនិងការអនុវត្តថវិកាកម្មវិធីពេញលេញ និងអង្គភាពថវិកាសម្រាប់ថវិការដ្ឋបាលថ្នាក់ក្រោមជាតិ | ១. ប្រកាសស្តីពីការដាក់ឱ្យអនុវត្តគោលការណ៍ណែនាំស្តីពីនីតិវិធីអនុវត្តថវិកាកម្មវិធីរបស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានរៀបចំរួច និងដាក់ឱ្យអនុវត្ត និងត្រូវបានបណ្តុះបណ្តាលជូនរដ្ឋបាលរាជធានី ខេត្តទាំង៦ | ១០០% |

| | | |
|---|---|---|
| | ២. ប្រកាសដាក់រដ្ឋបាលខេត្តចំនួន ៦ អនុវត្តថវិកាកម្មវិធីឆ្នាំ២០១៨ ត្រូវបានរៀបចំរួច និងដាក់ឱ្យអនុវត្ត<br>៣. គោលការណ៍ណែនាំស្តីពីការរៀបចំថវិកាកម្មវិធីត្រូវបានបន្តកែលម្អឱ្យបានគ្រប់ជ្រុងជ្រោយ និងត្រូវបានបណ្តុះបណ្តាលជូនរដ្ឋបាលខេត្តប្រកបដោយប្រសិទ្ធភាពសម្រាប់រដ្ឋបាលខេត្តដែលត្រូវបានជ្រើសរើសបន្ថែម<br>៤. គោលការណ៍ណែនាំស្តីពីនីតិវិធីអនុវត្តថវិកាកម្មវិធីសម្រាប់រដ្ឋបាលខេត្តដែលត្រូវបានជ្រើសរើសបន្ថែមត្រូវបានបណ្តុះបណ្តាលជូនរដ្ឋបាលខេត្តប្រកបដោយប្រសិទ្ធភាព ។ | |
| **ផ្នែកទី៤÷ការត្រៀមខ្លួនសម្រាប់ជំហានបន្ទាប់** | | ៩២% |
| គោលបំណង ៤១. បង្កើតក្របខ័ណ្ឌថវិកាដោយផ្អែកលើសមិទ្ធកម្ម | | ៩៨,៨០% |
| ៤១.១. សិក្សា និងរៀបចំក្របខ័ណ្ឌគោលនៃគោលការណ៍ថវិកាផ្អែកលើសមិទ្ធកម្ម (Performance Based Budgeting PBB) | ១. ក្របខ័ណ្ឌគតិយុត្តសម្រាប់ជាមូលដ្ឋាននៃការអនុវត្តថវិកាកម្មវិធី និងថវិកាសមិទ្ធកម្មត្រូវបានរៀបចំ | ១០០% |
| ៤១.២. ពិគ្រោះយោបល់លើគោលការណ៍ថវិកាផ្អែកលើសមិទ្ធកម្ម | ១. គោលការណ៍ណែនាំស្តីពីថវិកាសមិទ្ធកម្មត្រូវបានពិគ្រោះយោបល់ និងកែសម្រួលតាមមិតយោបល់ដែលទទួលបាន ។ | ៩៦% |
| គោលបំណង ៤២. បង្កើតក្របខ័ណ្ឌគណនេយ្យភាពនៃសមិទ្ធកម្ម | | |
| ៤២.១. សិក្សានិងរៀបចំក្រប-ខណ្ឌគោលនៃការគ្រប់គ្រងផ្អែកលើសមិទ្ធកម្ម (Performance Based Management-PBM) | | |
| ៤២.២. ពិគ្រោះយោបល់លើគោលការណ៍គ្រប់គ្រងផ្អែកលើសមិទ្ធកម្ម | | |
| គោលបំណង ៤៣. បង្កើតក្របខ័ណ្ឌសវនកម្មលើសមិទ្ធកម្ម | | |
| ៤៣.១. សិក្សានិងរៀបចំក្របខ័ណ្ឌគោលនៃសវនកម្មផ្អែកលើសមិទ្ធកម្ម | | |

| | | |
|---|---|---|
| (Performance Based Auditing-PBA) | | |
| ៤៣.២. ពិគ្រោះយោបល់លើគោលការណ៍សវនកម្មផ្អែកលើសមិទ្ធកម្ម | | |
| គោលបំណង ៤៤. រៀបចំ និងអនុវត្តផែនការកសាងសមត្ថភាព (ដោយរួមទាំងស្ថាប័ននីតិបញ្ញត្តិ និងអាជ្ញាធរសវនកម្មជាតិ) | | ៩៥% |
| ៤៤.១. រៀបចំផែនការកសាងសមត្ថភាព (Capacity Development Plan-CDP) | ១. ផែនការយុទ្ធសាស្ត្រស្តីពីការកសាង និងអភិវឌ្ឍសមត្ថភាព ក្នុងក្របខ័ណ្ឌកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ត្រូវបានរៀបចំ | ៩៦% |
| ៤៤.២. ពិគ្រោះយោបល់និងអនុម័តផែនការកសាងសមត្ថភាព | ផែនការយុទ្ធសាស្ត្រស្តីពីការកសាង និងអភិវឌ្ឍសមត្ថភាពក្នុងក្របខ័ណ្ឌកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ត្រូវបានរៀបចំពិគ្រោះយោបល់ និង អនុម័ត | ៩៣% |
| ៤៤.៣. ផ្សព្វផ្សាយនិងអនុវត្តផែនការកសាងសមត្ថភាព | | |
| **ផ្នែកទី៥÷ការគាំទ្រដល់ការអនុវត្តកម្មវិធីកែទម្រង់ប្រកបដោយជោគជ័យ និងចីរភាព** | | **៩២%** |
| គោលបំណង ៥១. បង្កើនភាពជាអ្នកដឹកនាំ សមត្ថភាព គ្រប់គ្រង និងបណ្ដុះឆន្ទៈកំណែទម្រង់ ព្រមទាំងបង្កើនភាពជាម្ចាស់ និងការទទួល ខុសត្រូវ | | ៩៤% |
| ៥១.១. ពង្រឹងភាពជាអ្នកដឹកនាំ និង សមត្ថភាពគ្រប់គ្រង | ១. មន្ត្រីរាជការក្រសួងស្ថាប័ន ចំនួន ៩០ នាក់ ទទួលការបណ្ដុះបណ្ដាល និង កម្មវិធីទស្សនកិច្ចសិក្សាផ្លាស់ប្ដូរបទពិសោធជាតិនិងអន្តរជាតិ ពាក់ព័ន្ធភាពជាអ្នកដឹកនាំក្នុងវិស័យសាធារណៈ, រដ្ឋបាលសាធារណៈ និង គោលនយោបាយសាធារណៈនិងអភិបាលកិច្ចល្អ ចំនួន ៣ វគ្គ<br>២. មន្ត្រីរាជការក្រសួងស្ថាប័ន ចំនួន ១២០ នាក់ ទទួលការបណ្ដុះបណ្ដាល និង កម្មវិធីទស្សនកិច្ចសិក្សាផ្លាស់ប្ដូរបទពិសោធជាតិនិងអន្តរជាតិ ពាក់ព័ន្ធការកែទម្រង់ហិរញ្ញវត្ថុសាធារណៈ និងភាពជាដៃគូរវាងរដ្ឋនិងវិស័យឯកជន បទពិសោធន៍ប្រទេសចិន<br>៣. ឯកសារទស្សនាទានស្តីពីការអភិវឌ្ឍកម្មវិធីបណ្តុះបណ្តាល និងវិធីសាស្ត្របង្រៀនត្រូវបានដាក់ឱ្យអនុវត្តក្នុងក្របខ័ណ្ឌគ្រូបង្គោលនៃវិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងអគ្គនាយកដ្ឋានពាក់ព័ន្ធនៃកសហវ | ៨៦% |

| | | |
|---|---|---|
| | ៤. ផែនការសកម្មភាពរួម GDAP3 សម្រាប់ការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុ ដំណាក់កាលទី៣ ត្រូវបានរៀបចំ និងផ្សព្វផ្សាយ ដោយមានកិច្ចសហការរវាងថ្នាក់ដឹកនាំអគ្គនាយកដ្ឋានរតនាគារជាតិ និងមន្ត្រីក្រោម ឱវាទត្រូវបានបង្កើនតាមរយៈកិច្ចប្រជុំ<br>៥. របាយការណ៍វឌ្ឍនភាពការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈប្រចាំត្រីមាសរបស់អគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបានរៀបចំរួចទាន់ ពេលវេលា<br>៦. អត្ថបទពាក់ព័ន្ធនឹងការរៀបចំ ការអនុវត្តថវិកា រដ្ឋបាលថ្នាក់ក្រោមជាតិ និងវិមជ្ឈការហិរញ្ញវត្ថុសម្រាប់ចុះផ្សាយក្នុងព្រឹត្តិបត្រកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈត្រូវបានចុះផ្សាយសម្រាប់ព្រឹត្តិបត្រ<br>៧. ចក្ខុវិស័យ បេសកកម្ម របស់ប្រធានការិយាល័យ អនុប្រធាននាយកដ្ឋានប្រធាននាយកដ្ឋាន ត្រូវបានរៀបចំចងក្រងនិងដាក់ឱ្យអនុវត្ត<br>៨. កម្រងសម្រង់បទប្បញ្ញត្តិច្បាប់សំខាន់ៗ ទាក់ទង សមត្ថកិច្ច កសហវ ក្រោយឆ្នាំ២០១៣ ដល់២០១៧ ត្រូវបានរៀបចំ និងចងក្រង<br>៩. របាយការណ៍វឌ្ឍនភាពប្រចាំត្រីមាស និងបញ្ហាប្រឈមនៃការអនុវត្តផែនការសកម្មភាពរួម ដំណាក់កាលទី៣ (២០១៧-២០២០) របស់អគ្គលេខាធិការដ្ឋាន ត្រូវបានរៀបចំ និងដោះស្រាយ ។ | |
| ៥១.២.រៀបចំប្រព័ន្ធគ្រប់គ្រងការផ្លាស់ប្តូរ (Change Management) | ១. មានផែនការបង្កើនកម្រិតយល់ដឹង ភាពជាម្ចាស់ការចូលរួម និងសមត្ថភាពផ្នែក FMIS ដល់ កសហវ ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ<br>២. មានផែនការកសាងសមត្ថភាពមន្ត្រីគ្រប់គ្រង និងអនុវត្តគម្រោង FMIS ជំហានទី២<br>៣. មានឧបករណ៍វាយតម្លៃលទ្ធផលនៃការអនុវត្តផែនការបណ្តុះបណ្តាលក្រុមការងារគ្រប់គ្រង និងក្រុមការងារអនុវត្តគម្រោង FMIS និងមន្ត្រីអនុវត្តប្រព័ន្ធ FMIS | ១០០% |

| | | |
|---|---|---|
| | ៤. គ្រប់គន្លឹនៃកម្រងសម្រង់ ត្រូវបានពិនិត្យផ្ទៀងផ្ទាត់គ្រប់ទិដ្ឋភាព កម្រិតផ្នែកជំនាញនៃ លកន និងកម្រិតអនុប្រធានលេខាធិការដ្ឋានក្រុមប្រឹក្សានីតិកម្ម<br>៥. កម្រងសម្រង់បទប្បញ្ញត្តិគតិយុត្ត ពាក់ព័ន្ធឧស្សាហកម្មហិរញ្ញវត្ថុ ត្រូវបានរៀបចំចងក្រងរួចសម្រាប់ការបោះពុម្ព<br>៦. កម្រងសម្រង់បទប្បញ្ញត្តិគតិយុត្ត ពាក់ព័ន្ធគណនេយ្យត្រូវបាន រៀបចំចងក្រងរួចសម្រាប់ការបោះពុម្ព<br>៧. កម្មវិធីបច្ចេកវិទ្យាព័ត៌មានតាមវឌ្ឍនភាពនៃកម្រងសម្រង់នីមួយៗ ត្រូវបានរៀបចំនិងដាក់ឱ្យដំណើការ<br>៨. សិក្ខាសាលាផ្សព្វផ្សាយបង្កើនសមត្ថភាពនិងលើកកម្ពស់ការ អនុវត្តច្បាប់ពាក់ព័ន្ធសារពើពន្ធ ដល់វិស័យឯកជនត្រូវបានរៀបចំ<br>៩. បង្កើនការយល់ដឹងច្បាប់សេដ្ឋកិច្ចនិងហិរញ្ញវត្ថុក្នុងចំណោមមន្ត្រីរាជការនៅថ្នាក់ក្រោមជាតិសិក្ខាសាលាចំនួន ០៥ ។ | |
| ៥១.៣. បង្កើនឆន្ទៈកំណែទម្រង់ ភាពជាម្ចាស់ និងការទទួលខុសត្រូវ | ១. យន្តការតាមដាននិងគ្រប់គ្រងសមិទ្ធកម្មការងារ និងប្រព័ន្ធវាយតម្លៃលើការចូលរួមអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅអគ្គនាយកដ្ឋានរតនាគារជាតិត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត។<br>២. កិច្ចប្រជុំប្រចាំខែស្តីពីការអនុវត្តផែនការសកម្មភាពកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ របស់អគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបានរៀបចំ និងមានរបាយការណ៍ ។ | ៩៨% |
| គោលបំណង ៥២. បង្កើនប្រសិទ្ធភាពនៃការកសាងសមត្ថភាព និងវិធានការលើកទឹកចិត្ត | | ១០០% |
| ៥២.១. ពិនិត្យមើលឡើងវិញពីប្រសិទ្ធភាពនិង ស័ក្តិសិទ្ធភាពនៃការបណ្តុះបណ្តាលនិងរៀបចំផែនការកសាងសមត្ថភាពថ្មី | ១. លទ្ធផលនៃការវាយតម្លៃអំពីប្រសិទ្ធភាពនៃការបណ្តុះបណ្តាល បានរៀបចំចងក្រង វិភាគ និង រៀបចំជារបាយការណ៍<br>២. មន្ត្រីរាជការ និងគ្រូបង្គោលចំនួន ៤០នាក់ នៃវិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ទទួលបានការបណ្តុះបណ្តាលស្តីពី ការត្រួតពិនិត្យនិងវាយតម្លៃ លើការងារបណ្តុះបណ្តាល<br>៣. ប្រកាសស្តីពី វិធាន និងនីតិវិធី នៃការរៀបចំ ការអនុវត្ត ការត្រួតពិនិត្យ និងវាយតម្លៃ នៃការអភិវឌ្ឍសមត្ថភាពមន្ត្រីរាជការ នៃកសហវត្រូវបានដាក់ជូនថ្នាក់ដឹកនាំ ពិនិត្យសម្រេច<br>៤. ផែនការបណ្តុះបណ្តាល សម្រាប់ឆ្នាំ ២០១៧-២០១៨ របស់ | ១០០% |

| | | |
|---|---|---|
| | អគ្គលេខាធិការដ្ឋាន ត្រូវបានអនុម័ត ។ | |
| ៥២.២.ពិនិត្យមើលឡើងវិញពីយន្តការនិងអភិក្រមនៃការផ្តល់ការលើកទឹកចិត្តរយៈពេលកន្លងមក និងរៀបចំឱ្យមានយន្តការ និង អភិក្រមថ្មីស្តីពីការផ្តល់ការលើកទឹកចិត្តដែលមានសមធម៌ និងសង្គតិភាព | ១. ប្រព័ន្ធលើកទឹកចិត្តក្នុងក្របខ័ណ្ឌវិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវបានត្រួតពិនិត្យ និងអនុវត្តចំពោះមន្ត្រីដែលមានសមិទ្ធកម្មការងារល្អ<br>២. មន្ត្រីអគ្គាធិការដ្ឋានចំនួន៨០នាក់ទទួលបានវគ្គបំប៉ននេះរយៈពេល២ថ្ងៃ ស្តីពីប្រព័ន្ធគណនេយ្យសហគ្រាសសាធារណៈ និងក្រុមហ៊ុនឯកជន<br>៣. មន្ត្រីអគ្គាធិការដ្ឋានកសហវ ចំនួន៥នាក់ បានបំពេញទស្សកិច្ចសិក្សាដកស្រង់បទពិសោធន៍ អំពីការងារអធិការកិច្ចហិរញ្ញវត្ថុនៅក្នុងតំបន់អាស៊ីរយៈពេល៥ថ្ងៃ<br>៤. កិច្ចពិភាក្សាផ្លាស់ប្តូរបទពិសោធន៍ Peer Review ការងារអធិការកិច្ចហិរញ្ញវត្ថុ ក្នុងឆ្នាំ២០១៧ត្រូវបានរៀបចំរួច ដែលមានអ្នកចូលរួមចំនួន ៨០នាក់រយៈពេល១ថ្ងៃ ។ | ១០០% |
| គោលបំណង ៥៣. ពង្រឹងការកសាងសមត្ថភាពសម្រាប់អនុវត្ត កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី៣ | | ៨៣% |
| ៥៣.១.រៀបចំស្ថាប័នដើម្បីឆ្លើយតប នឹងដំណាក់កាលទី៣ ដោយរួមមាន÷ (១)ការបញ្ចប់វិភាគមុខងារនៅ គ្រប់អគ្គនាយកដ្ឋាននៃកសហវ និង នាយកដ្ឋានរដ្ឋបាល ហិរញ្ញវត្ថុនៃក្រសួង ស្ថាប័ន។ (២)រៀបចំ និងអនុវត្តផែនការកែសម្រួលរចនាសម្ព័ន្ធរបស់អគ្គនាយកដ្ឋាន និងនាយកដ្ឋាននីមួយៗ។ (៣) រៀបចំនិង ផ្សព្វផ្សាយឯកសារណែនាំស្តីពីប្រព័ន្ធគ្រប់គ្រងថ្មី។ (៤) រៀបចំគោលនយោបាយសម្រាប់យុទ្ធសាស្ត្រគ្រប់គ្រងព័ត៌មានវិទ្យានៅ កសហវ (៥) ការប្រើប្រាស់ជំនួយ បច្ចេកទេស | ១. ការវិភាគមុខងារមន្ត្រី និងរចនាសម្ព័ន្ធគ្រប់គ្រងរបស់នាយកដ្ឋានទាំងបី នៃ វសហ បានធ្វើបច្ចុប្បន្នកម្ម<br>២. ឯកសារស្តីពីការធ្វើបច្ចុប្បន្នកម្មរចនាសម្ព័ន្ធគ្រប់គ្រង និង ការវិភាគមុខងារ របស់ វសហបានចងក្រង និងផ្សព្វផ្សាយដល់មន្ត្រីនៃវសហ<br>៣. មន្ត្រីរាជការ វសហចំនួន ៦០ នាក់ទទួលបានការបណ្តុះបណ្តាលស្តីពីការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មានវិទ្យា<br>៤. ប្រព័ន្ធគ្រប់គ្រងឯកសារលិខិតគតិយុត្តិផ្សេងៗ ត្រូវបានកែលម្អ និងអភិវឌ្ឍឱ្យបានកាន់តែ ប្រសើរឡើង។<br>៥. ការអនុវត្តការងាររបស់មន្ត្រីរតនាគារទាំងថ្នាក់ កណ្តាលនិងថ្នាក់ខេត្តត្រូវបានកែលម្អនិងកាន់តែមានប្រសិទ្ធិភាពជាងមុនតាមរយៈការបណ្តុះបណ្តាលពីការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យា។<br>៦. មានរបាយការណ៍សិក្សា និងការវិភាគ មុខងារ (អគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ)<br>៧. អនុក្រឹត្យស្តីពីការកែសម្រួលការរៀបចំនិងប្រព្រឹត្តទៅនៃ | ៩៣% |

| | | |
|---|---|---|
| ប្រកបដោយប្រសិទ្ធភាព។ (៦) កែលម្អការអនុវត្តការងារតាមរយៈការបង្កើនការប្រើប្រាស់បច្ចេកវិទ្យា | អគ្គនាយកដ្ឋានត្រូវបានរៀបចំរួច និងដាក់ឱ្យអនុវត្ត (អគ្គនាយក-ដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ)<br>៨. ប្រកាសស្តីពីការរៀបចំនិងប្រព្រឹត្តទៅនៃអគ្គនាយកដ្ឋានត្រូវបានរៀបចំរួច និងដាក់ឱ្យអនុវត្ត (អគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ)<br>៩. សៀវភៅណែនាំស្តីពីការគ្រប់គ្រងមន្ត្រីពន្ធដារត្រូវបានដាក់ឱ្យអនុវត្ត និងផ្សព្វផ្សាយដល់មន្ត្រីនៃនាយកដ្ឋានថ្នាក់កណ្តាល និងសាខាពន្ធដារខេត្ត ខណ្ឌ<br>១០. ប្រព័ន្ធវាយតម្លៃលទ្ធផលការងាររបស់មន្ត្រីពន្ធដារត្រូវបានដាក់ឱ្យអនុវត្តជាផ្លូវការនៅគ្រប់អង្គភាពពន្ធដារ និងតាមដានត្រួតពិនិត្យ និងវាយតម្លៃ<br>១១. មន្ត្រីរាជការពន្ធដារទាំងអស់ត្រូវបានទទួលការបណ្តុះបណ្តាលដើម្បីមានសមត្ថភាពធ្វើការផ្លាស់ប្តូរព័ត៌មានផ្ទាល់ខ្លួន នៅក្នុងប្រព័ន្ធគ្រប់គ្រងមន្ត្រីរាជការពន្ធដារទៅតាមគោលការណ៍ដែលអគ្គនាយកដ្ឋានពន្ធដារបានកំណត់<br>១២. ប្រព័ន្ធព័ត៌មានវិទ្យាគ្រប់គ្រងការប្រមូលចំណូលមិនមែនសារពើពន្ធត្រូវបានរៀបចំ និងកសាងរួចរាល់តាមផែនការ<br>១៣. មានកម្មវិធីវចនានុក្រមវាកសព្ទសេដ្ឋកិច្ចនិងសង្គម ខ្មែរ-អង់គ្លេស ដំណើរការលើម៉ាស៊ីនកុំព្យូទ័រ និងទូរស័ព្ទដៃ (iOS & Android)<br>១៤. កម្រងអត្ថបទគតិយុទ្ធសម្រាប់ការរៀបចំនិងប្រព្រឹត្តិទៅ នៃកសហវត្រូវបានកែលម្អ រចនាសម្រាប់ការបោះពុម្ព<br>១៥. យន្តការច្រកចេញចូលតែមួយត្រូវបានដាក់ឱ្យអនុវត្តក្នុងទីស្តីការកសហវ និងត្រូវបានរៀបចំត្រួតពិនិត្យនិងវាយតម្លៃប្រចាំឆ្នាំ<br>១៦. បច្ចុប្បន្នកម្មមគ្គុទេសក៍សេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានីខេត្តត្រូវបានត្រួតពិនិត្យ កែលម្អ អនុម័ត និងបោះពុម្ព<br>១៧. យន្តការនៃការគ្រប់គ្រងបញ្ជីបៀវត្ស របស់មន្ត្រី កសហវ ត្រូវបានបង្កើត និងកែលម្អ និងប្រព័ន្ធផ្តល់ព័ត៌មានបៀវត្សនិងបណ្តឹងតវ៉ាត្រូវបានបង្កើត | |

| | | |
|---|---|---|
| | ១៨. ប្រព័ន្ធគ្រប់គ្រងទិន្នន័យមន្ត្រីរាជការ ត្រូវបាន សាកល្បងប្រើប្រាស់ និងរក្សាទុកឯកសារពាក់ព័ន្ធប្រវត្តិរូបមន្ត្រីរាជការក្នុងទម្រង់អេឡិកត្រូនិក<br>១៩. ការពិព័ពណ៌នាមុខតំណែងត្រូវបានកែលម្អ និងរៀបចំចងក្រងជាសៀវភៅដាក់ ជូនថ្នាក់ដឹកនាំអនុម័ត និងនីតិវិធីនិងទម្រង់បែបបទនៃលក្ខខណ្ឌការងាររបស់មន្ត្រីរាជការត្រូវបានរៀបចំ<br>២០. ផែនការកសាងសម្ថភាពមន្ត្រី កសហវ លើផ្នែកព័ត៌មានវិទ្យាកម្រិតមូលដ្ឋាន បានរៀបចំរួចរាល់ និងផ្ញើជូនអង្គភាពរៀបចំការបណ្តុះបណ្តាលសម្រាប់ការអនុវត្ត និងមានឧបករណ៍វាយតម្លៃការអនុវត្តផែនការកសាងសមត្ថភាពមន្ត្រី កសហវ លើចំណេះដឹងមូលដ្ឋានផ្នែកបច្ចេកវិទ្យាព័ត៌មាន បានរៀបចំ និងចងក្រងរួចរាល់<br>២១. បានបណ្តុះបណ្តាលមន្ត្រីនៃនាយកដ្ឋានព័ត៌មានវិទ្យាដោយមន្ត្រីនាយកដ្ឋានបច្ចេកវិទ្យាចំនួន ១៩រូប បានសិក្សាផ្នែក UI & UX Interface Design, Mobile Development and Security, និង Secure Web Development នៅវិទ្យាស្ថាន Instinct មន្ត្រីនាយកដ្ឋានបច្ចេកវិទ្យាចំនួន ៤រូប ផ្សេងទៀតបានសិក្សាផ្នែក Juniper ។ | |
| ៥៣.២.ការអភិវឌ្ឍធនធានមនុស្សសម្រាប់ដំណាក់កាលទី ៣ ដែលរួមមានការបណ្តុះបណ្តាល ជំនាញទាំងនៅក្នុងកសហវ និង ក្រសួង ស្ថាប័ន | ១. មន្ត្រីរាជការនៃវិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ចំនួន ២៥ នាក់ ទទួលបានការបណ្តុះបណ្តាលស្តីពី នីតិវិធីអនុវត្តថវិកាកម្មវិធី និងភាពជាអ្នកដឹកនាំ<br>២. គ្រូបង្គោលនៃវសហ ចំនួន៣០ នាក់ ទទួលបានការបណ្តុះបណ្តាលស្តីពីវិធីសាស្ត្របង្រៀន និងគម្រោងមុខវិជ្ជា លើការអនុវត្តថវិកាកម្មវិធី<br>៣. គ្រូបង្គោលនៃក្រសួង ស្ថាប័ន ចំនួន ៦០ នាក់ ទទួលបានការបណ្តុះបណ្តាលស្តីពីការអនុវត្តថវិកាកម្មវិធី<br>៤. មន្ត្រីរាជការចំនួន ៧៧៥ នាក់ នៃក្រសួង ស្ថាប័ន ចំនួន ១១ និងមន្ទីរអង្គភាពក្រោមឱវាទនៅថ្នាក់មូលដ្ឋាននៃរាជធានី ខេត្ត ដែលត្រូវអនុវត្តថវិកាកម្មវិធីពេញលេញសាកល្បងនៅឆ្នាំ ២០១៧ ទទួលបានការបណ្តុះបណ្តាលស្តីពី នីតិវិធីអនុវត្តថវិកាកម្មវិធីសម្រាប់អង្គភាពថវិកា | ៩៤% |

| | | |
|---|---|---|
| | ៥. ចំនួនមន្ត្រីនាយកដ្ឋានថវិកានីយកម្មទទួលបានការបណ្តុះបណ្តាលជំនាញអំពីថវិកាផ្អែកលើសមិទ្ធកម្ម<br>៦. ចំនួនមន្ត្រីនាយកដ្ឋានថវិកានីយកម្មទទួលបានការបណ្តុះបណ្តាលលើជំនាញភាពជាអ្នកដឹកនាំ<br>៧. សិក្ខាសាលាស្តីពីកម្មវិធីកែទម្រង់ហិរញ្ញវត្ថុសាធារណៈនិងថវិកាកម្មវិធី និងវគ្គបណ្តុះបណ្តាលជំនាញបច្ចេកទេសចំនួន ៦វគ្គសម្រាប់មន្ត្រីគយត្រូវបានរៀបចំ<br>៨. មន្ត្រីចំនួន៥០%នៃក្រុមការងារកែទម្រង់ត្រូវបានចូលរួមវគ្គបណ្តុះបណ្តាលនិងសិក្ខាសាលាផ្សេងៗរយៈពេលខ្លីៗក្នុងនិងក្រៅប្រទេស (អគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ<br>៩. សវនករផ្ទៃក្នុងនៃ កសហវ ទទួល បានការយល់ដឹងពី Quick book accounting និង DMS<br>១០. Checklist ទាំង៤ ប្រភេទត្រូវបានចងក្រង (Checklist សម្រាប់ IT governance and management, Checklist សម្រាប់ Data management, Checklist សម្រាប់ Business continuity planning, Checklist for information securities)<br>១១. សវនករ IT នៃ GDIA ត្រូវបានទទួលការបណ្តុះបណ្តាលជំនាញរយៈពេលខ្លីនៅក្រៅប្រទេសចំនួន ២វគ្គ<br>១២. សវនករនៃកសហវទាំងអស់ ត្រូវទទួលបានការបង្ហាត់បង្ហាញអំពីការតាក់តែង និងប្រតិបត្តិការនៃប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុង ២វគ្គ<br>១៣. មន្ត្រីចាំបាច់មួយចំនួនមានសមត្ថភាពគ្រប់គ្រាន់ ទាំងគណនេយ្យ និង IT ដើម្បីប្រើប្រាស់ប្រព័ន្ធ FMIS។ (អគ្គ.រតនាគារជាតិ)<br>១៤. មន្ត្រីចាំបាច់មួយចំនួនមានសមត្ថភាពគ្រប់គ្រាន់ លើមុខជំនាញផ្សេងៗ (ជំនាញដឹកនាំ/គ្រប់គ្រង ឬជំនាញបច្ចេកទេស)ដែលបានទទួលនូវការ បណ្តុះបណ្តាល។ (អគ្គ.រតនាគារជាតិ)<br>១៥. គម្រោងថវិកាសម្រាប់ការបណ្តុះបណ្តាល និងសិក្ខាសាលាត្រូវបានរៀបចំបញ្ជូនទៅអគ្គលេខាធិការដ្ឋាន PFM (អគ្គ.លទ្ធកម្មសាធារណៈ)<br>១៦. វគ្គចែករំលែកចំណេះដឹងដើម្បីពង្រឹងសមត្ថភាពមន្ត្រីលទ្ធកម្មដល់ក្រសួង ស្ថាប័ន រាជធានី ខេត្ត ត្រូវបានរៀបចំឡើង | |

| | | |
|---|---|---|
| | ១៧. មន្ត្រីនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ ទាំង ១៩៧ ទទួលបានបណ្តុះបណ្តាលស្តីពីការរៀបចំនិងអនុវត្តថវិការដ្ឋបាលថ្នាក់ក្រោមជាតិប្រកបដោយប្រសិទ្ធភាព<br>១៨. មន្ត្រីចំនួន ៧០ នាក់ នៃអគ្គនាយកដ្ឋាន ហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមទទួលបាន ការបណ្តុះបណ្តាលស្តីពីការរៀបចំនិង នីតិវិធីអនុវត្តថវិកាកម្មវិធីរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ<br>១៩. មន្ត្រីទទួលបន្ទុកថវិកាកម្មវិធីត្រូវបានបណ្តុះបណ្តាល និងយល់ដឹងពីការអនុវត្តថវិកាកម្មវិធី (អគ្គ.ពន្ធដារ)<br>២០. មន្ត្រីពន្ធដារត្រូវបានទទួលវគ្គបណ្តុះបណ្តាលស្តីពីជំនាញមួយចំនួនដើម្បីលើកកម្ពស់សមត្ថភាពការងារ<br>២១. មន្ត្រី និងអ្នកជាប់ពន្ធត្រូវបានបណ្តុះបណ្តាលអំពីវប្បធម៌បង់ពន្ធ និងការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងយុទ្ធសាស្ត្រកៀរគរចំណូល (បែងចែកជា ៥ តំបន់)<br>២២. សិក្ខាសាលាពាក់ព័ន្ធនឹងពន្ធប្រថាប់ត្រា និងការលើកទឹកចិត្តផ្នែកពន្ធដារសម្រាប់សហគ្រាសធនតូច និងមធ្យមត្រូវបានរៀបចំ<br>២៣. សិក្ខាសាលាស្តីពីការចៀសវាងការយកពន្ធត្រួតគ្នា (Double Taxation Agreement - DTA) ត្រូវបានរៀបចំ<br>២៤. មន្ត្រីចំនួន ២០ រូប ចូលរួមវគ្គបណ្តុះបណ្តាលកម្មវិធីគណនេយ្យ និងហិរញ្ញវត្ថុ<br>២៥. មន្ត្រីចំនួន១៨រូប ធ្វើទស្សនកិច្ចសិក្សាដកបទពិសោធនៅប្រទេសហ្វីលីពីនអំពីការរៀបចំត្រួតពិនិត្យ តាមដាន និងវាយតម្លៃការអនុវត្តថវិកាកម្មវិធី<br>២៦. មន្ត្រីចំនួន១៨រូប ធ្វើទស្សនកិច្ចសិក្សាដកបទពិសោធនៅប្រទេសថៃលើការរៀបចំមគ្គុទេសក៍គ្រប់គ្រងហិរញ្ញវត្ថុ<br>២៧. សិក្ខាសាលាផ្សព្វផ្សាយណែនាំអនុវត្តបច្ចេកទេស នៃការរៀបចំថវិកា ត្រូវបានរៀបចំ<br>២៨. វិបស្សនាស្តីពីការរៀបចំ កំណត់សូចនាករគន្លឹះ និងការរៀបចំផែនការយុទ្ធសាស្ត្រថវិកានៃកសហវវិបស្សនាត្រូវបានរៀបចំ (អគ្គលេខាធិការដ្ឋាន)<br>២៩. របាយការណ៍អនុវត្តថវិកាពាក់កណ្តាលឆ្នាំរបស់ កសហវ ត្រូវបានបូកសរុប និងដាក់ប្រជុំត្រួតពិនិត្យ | |

| | | |
|---|---|---|
| ៥៣.៣.អនុវត្តយុទ្ធសាស្ត្រទំនាក់ទំនង និងសម្របសម្រួលសម្រាប់ដំណាក់កាលទី៣ | ពុំមានសកម្មភាពសម្រេចបាន ១០០% ទេ ។ | ៤០% |

## ឧបសម្ព័ន្ធទី៣÷ សេចក្តីសង្ខេបសូចនាករនៃក្របខ័ណ្ឌវាស់សមិទ្ធកម្មនៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

| ល.រ | សូចនាករ | ពិន្ទុ ឆ្នាំ២០១៥ | ពិន្ទុ ឆ្នាំ២០១៧ | អំណះអំណាងសម្រាប់ពិន្ទុឆ្នាំ២០១៧ | ការប្រៀបធៀបពិន្ទុ និងការពន្យល់អំពីបម្រែបម្រួលពីការវាយតម្លៃលើកមុន |
|---|---|---|---|---|---|
| **១** | **លទ្ធផលនៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ÷ ភាពជឿទុកចិត្តនៃថវិកា** | | | | |
| **PI-1** | **ចំណាយសរុបធៀបនឹងច្បាប់ថវិកា ដែលបានអនុម័ត** | A | A | គម្លាតនៃការអនុវត្តចំណាយធៀបនឹងច្បាប់ថវិកា ដែលជាតម្លៃដាច់ខាត គឺ ឆ្នាំ២០១៤ (៩៨,១២%), ឆ្នាំ២០១៥ (៩៩,៣៤%) និងឆ្នាំ២០១៦ (៩៦,៣៨ %) | គ្មានបម្រែបម្រួល។ |
| **PI-2** | **សមាសធាតុចំណាយធៀបនឹងច្បាប់ថវិកាដែលបានអនុម័ត** | D+ | B | វិធីសាស្ត្រផ្តល់ពិន្ទុ M1 | ពិន្ទុបានកើនឡើង លើសមាសធាតុទី១ ដោយគម្លាតថវិកាតាមរចនាសម្ព័ន្ធរដ្ឋបាល ថយចុះជាលំដាប់។ |
| (១) | កម្រិតនៃការប្រែប្រួលក្នុងសមាសភាពចំណាយ នៅក្នុងរយៈពេលបីឆ្នាំចុងក្រោយដោយមិនគិតបញ្ចូលនូវចំណាយមិនបានគ្រោងទុក | D | B | គម្លាតនៃសមាសធាតុក្នុងការអនុវត្តចំណាយមានលើសពី ៥% ក្នុង រយៈពេល៣ឆ្នាំចុងក្រោយនេះ គឺឆ្នាំ២០១៤ (១៤,៨៧%) ឆ្នាំ២០១៥ (៧,៤៧%) និងឆ្នាំ២០១៦ (៥,១៤%)។ | គម្លាតសម្រាប់ PI-2 (១) គឺមានភាពប្រសើរជាងការវាតយតម្លៃឆ្នាំ ២០១៥ ដោយប្រើប្រាស់ទិន្នន័យឆ្នាំ ២០១១, ២០១២ និងឆ្នាំ២០១៣។ ក្នុងន័យនេះ ចំនួនក្រសួង ស្ថាប័ន ដែលទទួលថវិកា វិនិយោគក្នុងស្រុកមានកើនឡើងពី ៤ ក្នុងឆ្នាំ២០១៥ ទៅ ៧ ក្រសួង ស្ថាប័ន ក្នុងឆ្នាំ ២០១៦។ សម្រាប់ឆ្នាំ២០១៧ គឺរួមមាន ក្រសួងមហាផ្ទៃ, ក្រសួងអប់រំ យុវជន និងកីឡា, ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, ក្រសួងអភិវឌ្ឍន៍ជនបទ, ក្រសួងសាធារណការ និងដឹកជញ្ជូន, ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងក្រសួងធនធានទឹក និងឧតុនិយម។ ម្យ៉ាងទៀត ទំហំចំណាយវិនិយោគដែលមិនទាន់បែងចែក គឺថយចុះពីមួយឆ្នាំទៅមួយឆ្នាំ ផងដែរ។ |
| (២) | ចំនួនជាមធ្យមនៃការចំណាយដែលបានកើតឡើងជាក់ស្តែងក្នុងខ្ទង់ចំណាយដែលមិនបានគ្រោងទុកនៅក្នុងរយៈពេលបីឆ្នាំចុងក្រោយ | B | B | ចំណាយមិនបានគ្រោងទុកជាក់ស្តែងជាមធ្យមសម្រាប់ឆ្នាំ២០១៤, ឆ្នាំ២០១៥ និង២០១៦ ស្មើនឹង ៣,៥% នៃច្បាប់ថវិកា។ | ពិន្ទុមិនប្រែប្រួល ប៉ុន្តែទំហំនៃចំណាយមិនបានគ្រោងទុក គឺថយចុះ ៥,៣% មក ៣,៥%។ |

| ល.រ | សូចនាករ | ពិន្ទុ ឆ្នាំ២០១៥ | ពិន្ទុ ឆ្នាំ២០១៧ | អំណះអំណាងសម្រាប់ពិន្ទុឆ្នាំ២០១៧ | ការប្រៀបធៀបពិន្ទុ និងការពន្យល់អំពីបម្រែបម្រួលពីការវាយតម្លៃលើកមុន |
|---|---|---|---|---|---|
| PI-3 | **ចំណូលសរុបធៀបនឹងច្បាប់ថវិកាដែលបានអនុម័ត** | A | B | ចំណូលក្នុងស្រុកសរុបធៀបនឹងច្បាប់ថវិកាក្នុងឆ្នាំ២០១៤ (១១០,៦៩%), ២០១៥ (១១១,៥២%) និង ២០១៦ (១០៥,៩០%)។ ការអនុវត្តនេះ គឺស្ថិតចន្លោះ ៩៤%-១១២% សម្រាប់២ឆ្នាំ នៃរយៈពេល៣ ឆ្នាំចុងក្រោយនេះ។ | រាជរដ្ឋាភិបាលពង្រឹងការអនុវត្តការប្រមូលចំណូលតាមរយៈការអនុវត្តយុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យមឆ្នាំ២០១៤-២០១៨។ យុទ្ធសាស្ត្រមានគោលដៅពង្រឹងរដ្ឋបាលប្រមូលចំណូល ដោយមិនបង្កើតប្រភេទពន្ធថ្មីឡើយ។ ក្នុងកាលៈទេសៈ នេះ រដ្ឋបាលប្រមូលចំណូលគួរតែពន្លឿនការរៀបចំម៉ូដែលព្យាករសម្រាប់ចំណូលពន្ធ និងទម្រង់ព្យាករណ៍សម្រាប់ចំណូលមិនមែនពន្ធ។ |
| PI-4 | **សន្និធិបំណុលកកស្ទះនិងការត្រួត-ពិនិត្យតាមដានបំណុលកកស្ទះ** | D+ | C+ | វិធីសាស្ត្រផ្តល់ពិន្ទុ M1 | មានបម្រែបម្រួលពិន្ទុនៅសមាសធាតុទី២ ដោយសារមិនមែនបំណុលកកស្ទះលើបៀវត្ស។ |
| (១) | កម្រិតស្តុកនៃចំណាយដែលនៅជំពាក់ គិតជាភាគរយនៃចំណាយ) សរុបជាក់ស្តែងសម្រាប់ឆ្នាំថវិកា និងការប្រែប្រួលថ្មីៗ (ដែលពាក់ព័ន្ធនៅក្នុងស្តុកចំណាយដែលនៅជំពាក់នេះ | D | B | សន្និធិសរុបនៃបំណុលកកស្ទះ មានទំហំធំតិចជាង ១២% នៃចំណាយសរុប។ ការគណនានេះ គឺបញ្ចូលការប្រាក់ និងការពិន័យលើបំណុលចាស់ ឬ ហៅថាបំណុលកេរមរតកជំពាក់ប្រទេសរុស្ស៊ី និងសហរដ្ឋអាមេរិក ដែលនៅសល់ពីសម័យសង្គ្រាម មានចំនួន ២៨០ លានដុល្លារអាមេរិក ស្មើនឹងប្រមាណ ១១៤៣ ពាន់លានរៀល។ ជាទូទៅ ការវាយតម្លៃលើបំណុលកកស្ទះ គឺត្រូវរាប់បញ្ចូលបំណុលទាំងអស់ដែលមិនទាន់ជម្រះ។ ជាមួយគ្នានេះ រាជរដ្ឋាភិបាលកម្ពុជា គឺបាននិងកំពុងចរចារលើបំណុលនេះ។ | ពិន្ទុបានកើនឡើង ពោលគឺមិនមានបំណុលកកស្ទះនៃបៀវត្ស ឬ សេវាបំណុលឡើយ វីសេវាបំណុលវិញគឺ ជាបំណុលកេមរតក។ បៀវត្សត្រូវបានបើកតាមប្រព័ន្ធធនាគារ ហើយត្រូវបើកយ៉ាងយូរត្រឹមសប្តាហ៍ទី៤ក្នុងខែ។ |
| (២) | ទិន្នន័យដែលអាចស្វែងរកបានសម្រាប់ការត្រួតពិនិត្យតាមដាននៃចំណាយដែលនៅជំពាក់ | C | C | បង្កើត Query ដើម្បីទាញទិន្នន័យពីប្រព័ន្ធ FMIS។ អគ្គនាយកដ្ឋានរតនាគារជាតិធ្វើការត្រួតពិនិត្យជាប្រចាំខែ។ ប៉ុន្តែមុខងារនេះមិនបំពេញតម្រូវការរបស់អ្នកប្រើប្រាស់នៅឡើយ ដោយមិនមានជាប្រព័ន្ធស្វ័យប្រវត្តិកម្មនោះទេ ហើយការត្រួតពិនិត្យនេះ និងការងារនេះ មិនទាន់ក្លាយជាការងារជាប្រចាំថ្ងៃនៅឡើយ។ | ការប្រើប្រាស់ Query ទាញទិន្នន័យ ឬការប្រើប្រាស់ Excel មិនអាចជាប្រព័ន្ធស្វ័យប្រវត្តកម្មសម្រាប់ alert ដល់អ្នកប្រើប្រាស់នៅឡើយ។ |

| ល.រ | សូចនាករ | ពិន្ទុ ឆ្នាំ២០១៥ | ពិន្ទុ ឆ្នាំ២០១៧ | អំណះអំណាងសម្រាប់ពិន្ទុឆ្នាំ២០១៧ | ការប្រៀបធៀបពិន្ទុ និងការពន្យល់អំពីបម្រែបម្រួលពីការវាយតម្លៃលើកមុន |
|---|---|---|---|---|---|
| | | | | ដើម្បីទទួលពិន្ទុខ្ពស់ជាងនេះ GDNT និង FMWG គួរសិក្សា និងរៀបចំមុខងារមួយដែលអាចតាមដានកាលបរិច្ឆេទលើសក្ដីបត្រ ចាប់ថ្ងៃទទួលបានពីអ្នកផ្គត់ផ្គង់ រហូតដល់ថ្ងៃទូទាត់ និងអាច alert ជូនអ្នកប្រើប្រាស់ផងដែរ។ | |
| ២ | **ការធានាគ្រួតស៊ីគ្នាសំខាន់ៗ ÷ ភាពគ្រប់ជ្រុងជ្រោយ និងតម្លាភាពនៃថវិកា** | | | | |
| PI-5 | ចំណាត់ថ្នាក់ថវិកា | C | C | មាតិកាដែលត្រូវបានប្រើប្រាស់សម្រាប់ការរៀបចំថវិកានិងគណនេយ្យ មានតែចំណាត់ថ្នាក់រដ្ឋបាលនិងចំណាត់ថ្នាក់សេដ្ឋកិច្ច និងចំណាត់ថ្នាក់កម្មវិធី។ បន្ថែមពីនេះ ឆ្នាំ២០១៧ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានដាក់ឱ្យអនុវត្តប្រកាសស្ដីពីចំណាត់ថ្នាក់រដ្ឋបាល ចំណាត់ថ្នាក់ , ចំណាត់ថ្នាក់ភូមិសាស្ត្រ , ចំណាត់ថ្នាក់មុខងារ , គម្រោង និងប្រភពមូលនិធិ។ | ភាពប្រសើរជាងការវាយតម្លៃលើមុនគឺការដាក់ឱ្យអនុវត្តចំណាត់ថ្នាក់កម្មវិធី។ |
| PI-6 | ភាពគ្រប់ជ្រុងជ្រោយនៃពត៌មានដែលត្រូវបានបញ្ចូលនៅក្នុងឯកសារថវិកា | C | C | ឯកសារថវិកាចំនួន ៣ ក្នុងចំណោមឯកសារថវិកាសរុបចំនួន ៩ (១, ៣, ៨) មានក្នុងឯកសារសំណើថវិកា ដែលត្រូវបានបញ្ជូនទៅអង្គនីតិបញ្ញត្តិ ក្នុងឆ្នាំ២០១៥។ | គ្មានបម្រែបម្រួល។ |
| PI-7 | ទំហំនៃប្រតិបត្តិការរបស់រដ្ឋាភិបាលដែលមិនត្រូវបានរាយការណ៍ | C | C+ | វិធីសាស្ត្រផ្ដល់ពិន្ទុ M1 | ពិន្ទុកើនពី C ទៅ C+ ពីព្រោះ ការកើនឡើងនៃពិន្ទុនៃសមាសធាតុទី១។ |
| (១) | ចំណាយថវិកាបន្ថែមដែលមិនត្រូវបានរាយការណ៍ | C | A | យោងមាត្រា១៤ នៃច្បាប់ស្ដីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ចែងថាគ្រឹះស្ថានសាធារណៈរដ្ឋបាលត្រូវមានថវិកាស្វយ័ត។ ប្រភពធនធានជាប្រចាំរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាលរួមមានចំណូលផ្ទាល់ និងចំណូលយថាហេតុ មានការឧបត្ថម្ភតុល្យភាពដោយថវិការដ្ឋ។ រីឯចំណាយជាប្រចាំគ្រឹះស្ថានសាធារណៈរដ្ឋ- | ពិន្ទុកើនឡើងពី C ទៅ A ដោយហេតុថារាជរដ្ឋាភិបាលបានរៀបចំបទបញ្ញត្តិបន្ថែម ដើម្បីអនុវត្តច្បាប់ស្ដីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ រួមមាន (១) ព្រះរាជក្រឹត្យស្ដីពីលក្ខខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល, (២) អនុក្រឹត្យស្ដីពីការគ្រប់គ្រងថវិកា និងទ្រព្យសម្បត្តិរដ្ឋ នៃគ្រឹះស្ថានសាធារណៈរដ្ឋបាល, (៣) ប្រកាសស្ដីពីការប្រគល់សិទ្ធិជាអភិបាលហិរញ្ញវត្ថុជូនមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុប្រចាំ |

| ល.រ | សូចនាករ | ពិន្ទុ ឆ្នាំ២០១៥ | ពិន្ទុ ឆ្នាំ២០១៧ | អំណះអំណាងសម្រាប់ពិន្ទុឆ្នាំ២០១៧ | ការប្រៀបធៀបពិន្ទុ និងការពន្យល់អំពីបម្រែបម្រួលពីការវាយតម្លៃលើកមុន |
|---|---|---|---|---|---|
| | | | | បាល ត្រូវគោរពតាមវិធាននៃចំណាត់ថ្នាក់ និងការគ្រប់គ្រងដូចចំណាយជាប្រចាំរបស់រដ្ឋដែរ។ ការកត់ត្រាចំណាយត្រូវបានបញ្ចូលក្នុងរបាយការណ៍ហិរញ្ញវត្ថុ និងស្ទើតែគ្រប់គ្រឹះស្ថានសាធារណៈរដ្ឋបាលមានមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុនៅប្រចាំការ។ | គ្រឹះស្ថានសាធារណៈរដ្ឋបាល, (៤) ប្រកាសស្តីពីនីតិវិធីចំណាយតាមរជ្ជទេយ្យបុរេប្រទានសម្រាប់គ្រឹះស្ថានសាធារណៈរដ្ឋបាល និង (៥) គោលការណ៍ណែនាំស្តីពីកិច្ចបញ្ជីកាគណនេយ្យទូទៅគណនេយ្យរជ្ជទេយ្យបុរេប្រទាន និងគណនេយ្យ រជ្ជទេយ្យចំណូលរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល |
| (២) | ព័ត៌មានស្តីពីចំណូល/ចំណាយសម្រាប់គម្រោងដែលគាំទ្រដោយហិរញ្ញប្បទានដៃគូអភិវឌ្ឍន៍ | C | C | ច្បាប់ទូទាត់ថវិកា បង្ហាញប្រតិបត្តិការឆ្លងកាត់រតនាគារ និងប្រតិបត្តិការមិនឆ្លងកាត់រតនាគារ ដែលគ្រប់គ្រងដោយអគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងគ្រប់គ្រងបំណុល។ គម្រោងដោយហិរញ្ញប្បទានដៃគូអភិវឌ្ឍន៍ គឺធ្វើឡើងតាមកម្មវិធីវិនិយោគសាធារណៈ (PIP)។ | គ្មានការផ្លាស់ប្តូរ នៅក្នុងលទ្ធផល។ កសហវ បានកំពុងដាក់ឱ្យអនុវត្តចំណាត់គម្រោង និងប្រភពមូលនិធិ ដើម្បីងាយស្រួលក្នុងការគ្រប់គ្រងគម្រោងដោយហិរញ្ញប្បទានដៃគូអភិវឌ្ឍន៍ និងកត់ត្រារាល់ប្រតិបត្តិការ។ |
| PI-8 | **តម្លាភាពនៃទំនាក់ទំនងហិរញ្ញវត្ថុនៅគ្រប់ថ្នាក់នៃរដ្ឋបាល ថ្នាក់ជាតិនិង) (ក្រោមជាតិ** | B | B | វិធីសាស្រ្តផ្តល់ពិន្ទុ M2 | គ្មានបម្រែបម្រួល។ |
| (១) | តម្លាភាព និងភាពមិនលម្អៀងក្នុងការបែងចែកធនធានក្នុងចំណោមរដ្ឋបាលថ្នាក់ក្រោមជាតិ | A | A | ឃុំសង្កាត់ ជាទូទៅពឹងផ្អែកទាំងស្រុងលើ ឧបត្ថម្ភធនពីមូលនិធិឃុំ-សង្កាត់។ ការវិភាជតាមខ្សែបណ្តោយ (Vertical) ទៅមូលនិធិ និងការវិភាជតាមខ្សែទទឹង (Horizontal) ទៅគ្រប់ឃុំ សង្កាត់ ផ្អែកលើប្រព័ន្ធដែលមានតម្លាភាពនិងមានរូបមន្តច្បាស់លាស់។ | គ្មានការផ្លាស់ប្តូរ នៅក្នុងលទ្ធផល។ ការវិភាជតាមខ្សែទទឹង (Horizontal) គឺត្រូវកំណត់តាមរូបមន្ត ឬវិធីសាស្រ្តជាក់លាក់សម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ និងត្រូវបានបែងចែកជាសមាសធាតុរដ្ឋបាល និងសមាសធាតុអភិវឌ្ឍន៍។ សម្រាប់ឃុំ សង្កាត់ ការវិភាជមានដូចខាងក្រោម÷<br>• ១/៣ ត្រូវបានវិភាជទៅសមាសធាតុរដ្ឋបាលសម្រាប់ចំណាយចរន្ត (បុគ្គលិក ប្រតិបត្តិការ និងការថែទាំ) និង ២/៣ ត្រូវបានវិភាជទៅគម្រោងអភិវឌ្ឍន៍ផ្ទាល់នៅមូលដ្ឋាន |

| ល.រ | សូចនាករ | ពិន្ទុ ឆ្នាំ២០១៥ | ពិន្ទុ ឆ្នាំ២០១៧ | អំណះអំណាងសម្រាប់ពិន្ទុឆ្នាំ២០១៧ | ការប្រៀបធៀបពិន្ទុ និងការពន្យល់អំពីបម្រែបម្រួលពីការវាយតម្លៃលើកមុន |
|---|---|---|---|---|---|
| | | | | | • តួលេខសម្រាប់សមាសធាតុរដ្ឋបាល ត្រូវបានកំណត់ដូចតទៅ ÷ ៣០% ស្មើគ្នាជូនគ្រប់ឃុំ សង្កាត់, ៦០% ដោយយោងលើចំនួនសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ និង ១០%ទៀតផ្អែកលើសន្ទស្សន៍នៃភាពក្រីក្រ<br>• សមាសធាតុអភិវឌ្ឍន៍ផ្ទាល់នៅមូលដ្ឋាន ត្រូវបានកំណត់ដូចតទៅ÷ ៣០% ស្មើគ្នាជូនគ្រប់ឃុំ សង្កាត់, ៣០% ផ្អែកលើចំនួនប្រជាជនក្នុងឃុំ សង្កាត់, ៣០% ផ្អែកលើសន្ទស្សន៍នៃភាពក្រីក្រ និង ១០%សម្រាប់ចំនួនភូមិនៅក្នុងឃុំ-សង្កាត់។ |
| (២) | ភាពទាន់ពេលវេលានៃព័ត៌មានដែលអាចជឿទុកចិត្តបានស្តីពីការវិភាជថវិកា សម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ | A | A | ឃុំ សង្កាត់ត្រូវបានផ្តល់ព័ត៌មានអំពីឧបត្ថម្ភធនដែលនឹងត្រូវទទួលបាន ក្នុងរវាងប៉ុន្មានខែ មុននឹងបញ្ចប់ការរៀបចំថវិការបស់ខ្លួន រីឯការផ្តល់ថវិកាធ្វើឡើងតាមកាលវិភាគច្បាស់លាស់ ដោយមានការពន្យារពេលតែចំពោះ ឃុំ សង្កាត់ណាដែលមិនបានផ្តល់របាយការណ៍ត្រីមាសទាន់ពេលវេលា | គ្មានការផ្លាស់ប្តូរនៅក្នុងលទ្ធផល។ |
| (៣) | កម្រិតនៃការប្រមូលសរុបទិន្នន័យហិរញ្ញវត្ថុ របស់រដ្ឋាភិបាលដោយអនុលោមតាមយុទ្ធសាស្ត្រតាមវិស័យ | D | D | ក្នុងឆ្នាំ២០១៤-២០១៦ នេះ ចំណាត់ថ្នាក់មុខងារ ឬវិស័យ នៃចំណាយ មិនត្រូវបានបញ្ចូលទាំងក្នុងប្លង់គណនេយ្យរបស់រដ្ឋបាលថ្នាក់ជាតិ និងរបស់រដ្ឋបាលឃុំ សង្កាត់។<br>ដើម្បីទទួលបានពិន្ទុខ្ពស់ជាងនេះ ការអនុវត្តចំណាត់មុខងារនៅថ្នាក់ក្រោមជាតិ នឹងជំរុញឱ្យប្រសិទ្ធភាពវិភាគ និងវិភាជន៍។ | គ្មានការផ្លាស់ប្តូរ នៅក្នុងលទ្ធផល។ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានធ្វើការកែសម្រួលប្លង់គណនេយ្យថ្មីឱ្យស្របតាមស្តង់ដារអន្តរជាតិ ហើយដាក់ឱ្យអនុវត្តប្រកាសស្តីពីការដាក់ឱ្យអនុវត្តចំណាត់ថ្នាក់មុខងារនៃមាតិកាថវិការបស់រដ្ឋបាលថ្នាក់ជាតិនិងរដ្ឋបាលថ្នាក់ក្រោមជាតិ។ |
| PI-9 | **ការត្រួតពិនិត្យហានិភ័យថវិកាពីអង្គភាពសាធារណៈដទៃទៀតក្រៅពីក្រសួង-ស្ថាប័នរដ្ឋ** | C+ | B+ | វិធីសាស្ត្រផ្តល់ពិន្ទុ M1 | ពិន្ទុ អាចប្រៀបធៀបនឹងគ្នាបាន។ គ្មានការផ្លាស់ប្តូរគួរឱ្យកត់សម្គាល់ចាប់ពីឆ្នាំ២០១៥។ |

| ល.រ | សូចនាករ | ពិន្ទុឆ្នាំ២០១៥ | ពិន្ទុឆ្នាំ២០១៧ | អំណះអំណាងសម្រាប់ពិន្ទុឆ្នាំ២០១៧ | ការប្រៀបធៀបពិន្ទុ និងការពន្យល់អំពីបម្រែបម្រួលពីការវាយតម្លៃលើកមុន |
|---|---|---|---|---|---|
| (១) | កម្រិតនៃការតាមដានរបស់រដ្ឋបាលថ្នាក់កណ្តាលទៅលើអង្គភាពស្វ័យតនិងសហគ្រាសរដ្ឋ | C | B | អគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធទទួលបានរបាយការណ៍ប្រចាំឆ្នាំពីគ្រប់សហគ្រាសសាធារណៈនិងភាគច្រើននៃគ្រឹះស្ថានសាធារណៈរដ្ឋបាល។ ការបូកសរុបរួមនៃរបាយការណ៍ថវិកាត្រូវបានរៀបចំ (មិនរាប់បញ្ចូលធនាគារជាតិនៃកម្ពុជា)។ កម្រិតហានិភ័យ គឺនៅមានកម្រិតទាប ដោយសារច្បាប់ប្រព័ន្ធរាល់ការខ្ចី គឺត្រូវមានការអនុញ្ញាតពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ | មានការរីកចម្រើនតិចតួច។ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានរៀបចំព្រះរាជក្រឹត្យស្តីពីការគ្រប់គ្រងគ្រឹះស្ថានសាធារណៈរដ្ឋបាល ឱ្យស្របតាមបរិបទនៃការកែទម្រង់ប្រព័ន្ធថវិកា។ ថវិការបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល គឺជាឧបសម្ព័ន្ធនៃថវិការបស់ក្រសួង ស្ថាប័ន ជាអាណាបាលបច្ចេកទេស។ |
| (២) | កម្រិតនៃការតាមដានរបស់រដ្ឋបាលថ្នាក់ជាតិទៅលើស្ថានភាពហិរញ្ញវត្ថុរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ | A | A | ស្ថានភាពហិរញ្ញវត្ថុនៅគ្រប់កម្រិតនៃរដ្ឋបាលថ្នាក់ក្រោមជាតិ គឺត្រូវបានតាមដានជាត្រីមាស និងរៀបចំជារបាយការណ៍ដាច់ដោយឡែកពីគ្នា សម្រាប់ថ្នាក់នីមួយៗនៃរដ្ឋបាលថ្នាក់ក្រោមជាតិ។ ជាក់ស្តែង របាយការណ៍នេះមិនបានកំណត់ ឬ វិភាគពីបញ្ហាហានិភ័យហិរញ្ញវត្ថុទេ តាមការអនុវត្ត ឃុំ សង្កាត់មិនអាចបង្កើតជាហានិភ័យទៅលើរដ្ឋបាលថ្នាក់ជាតិបានទេ។ | គ្មានការផ្លាស់ប្តូរនៅក្នុងលទ្ធផល។ |
| PI-10 | **លទ្ធភាពរបស់សាធារណជនក្នុងការទទួលបានព័ត៌មានថវិកាសំខាន់ៗ** | D | B | មានលក្ខខណ្ឌចំនួន ៣ ក្នុងចំណោម ៦ ឯកសារ ត្រូវបានបំពេញ។ ទោះបីជាមានឯកសារចំនួន ២ ឯកសារ គឺត្រូវបានផ្សព្វផ្សាយជាសាធារណៈ ក៏មានការយឺតយ៉ាវក្នុងការផ្សព្វផ្សាយដែរ។ | ពិន្ទុអាចប្រៀបធៀបនឹងគ្នាបាន។ ពិន្ទុ គឺកើនឡើង ដោយសារការផ្សព្វផ្សាយឯកសារចំនួន ៣ ទាន់ពេលវេលា រួមមាន ច្បាប់ទូទាត់ថវិកា, របាយការណ៍សវនកម្មឯករាជ្យ និងកិច្ចសន្យាលទ្ធកម្មសាធារណៈ។ សម្រាប់របាយការណ៍អនុវត្តថវិកា គឺផ្សព្វផ្សាយយឺត ពោលគឺលើសពី១ខែ ដល់ ២ ខែ និង ឯកសារថវិកាគឺផ្សព្វផ្សាយ នៅពេលសភាអនុម័តរឺឯ លក្ខខណ្ឌ [vi] មិនត្រូវបានផ្សព្វផ្សាយឱ្យបានទូលំទូលាយនោះទេ។ |
| ៣ | **វដ្តថវិកា** | | | | |
| ៣.១ | **ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ** | | | | |

| ល.រ | សូចនាករ | ពិន្ទុ ឆ្នាំ២០១៥ | ពិន្ទុ ឆ្នាំ២០១៧ | អំណះអំណាងសម្រាប់ពិន្ទុឆ្នាំ២០១៧ | ការប្រៀបធៀបពិន្ទុ និងការពន្យល់អំពីបម្រែបម្រួលពីការវាយតម្លៃលើកមុន |
|---|---|---|---|---|---|
| PI-11 | **កាលានុក្រមនិងការចូលរួមក្នុងកិច្ចដំណើរការរៀបចំថវិកាប្រចាំឆ្នាំ** | A | A | វិធីសាស្រ្តផ្តល់ពិន្ទុ M2 | ពិន្ទុ អាចប្រៀបធៀបនឹងគ្នាបាន។ |
| (១) | អត្ថិភាព និងការប្រកាន់ខ្ជាប់កាលវិភាគថវិកា | A | A | ក្រសួង ស្ថាប័នមានរយៈពេល ៤ ទៅ ៥សប្តាហ៍ ក្នុងមួយដំណាក់-កាល ដើម្បីរៀបចំថវិកាទាំងពីរដំណាក់កាល ពោលគឺសរុបប្រហែល ៩ សប្តាហ៍។ ដំណាក់កាលទាំង២ មានពិដានថវិកា (ទន់ភ្លន់) ដែលត្រូវបានអនុម័តដោយគណៈរដ្ឋមន្ត្រី។ ទន្ទឹមនេះមានការពន្យាររយៈពេលខ្លីដោយក្រសួង-ស្ថាប័នមួយចំនួន តែមិនមានអ្វីគួរឱ្យកត់សម្គាល់ទេ និងមិនមានអ្វីប៉ះពាល់ដល់ការអនុវត្តតាមកាលវិភាគឡើយ។ | គ្មានការផ្លាស់ប្តូរនៅក្នុងលទ្ធផល។ |
| (២) | ភាពច្បាស់លាស់ភាពគ្រប់ជ្រុង/ជ្រោយនិងការចូលរួមផ្នែកនយោបាយ ក្នុងការណែនាំអំពីការរៀបចំដាក់សំណើថវិកា | A | A | សារាចរផែនការយុទ្ធសាស្រ្តថវិកា ត្រូវបានដាក់ចេញដោយរាជរដ្ឋាភិបាល ដោយផ្អែកលើការអនុម័តក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ចនិងការសើរើ និងការធ្វើអាទិភាវូបនីយកម្មឡើងវិញនូវគោលនយោបាយ។ សារាចររៀបចំកញ្ចប់ថវិកា ត្រូវបានដាក់ចេញដោយរាជរដ្ឋាភិបាល និងផ្ញើជូនគ្រប់ក្រសួង ស្ថាប័ន និងរាជធានី ខេត្ត។ ការកំណត់ពិដានពីលើចុះក្រោម គឺកំណត់សម្រាប់ចំណាយសរុប (ថវិកាចរន្ត និងថវិកាមូលធន ត្រូវកំណត់ដាច់ពីគ្នា) និងសម្រាប់វិស័យទាំង ៤ (សង្គមកិច្ច សេដ្ឋកិច្ច រដ្ឋបាលទូទៅ និងការពារជាតិនិងសន្តិសុខសាធារណៈ) ជាភាគរយ នៃ ផ.ស.ស (ជាការចង្អុលបង្ហាញ)។ ការរៀបចំគម្រោងថវិកាលម្អិត ដោយក្រសួង ស្ថាប័ននិងរាជធានី ខេត្ត ត្រូវផ្អែកលើ កម្រិតកំណើនធៀបនឹងឆ្នាំចាស់ដែលអនុញ្ញាត សម្រាប់ចំណាត់ថ្នាក់សេដ្ឋកិច្ច នីមួយៗ។ | គ្មានការផ្លាស់ប្តូរនៅក្នុងលទ្ធផល។ |

| ល.រ | សូចនាករ | ពិន្ទុ ឆ្នាំ២០១៥ | ពិន្ទុ ឆ្នាំ២០១៧ | អំណះអំណាងសម្រាប់ពិន្ទុឆ្នាំ២០១៧ | ការប្រៀបធៀបពិន្ទុ និងការពន្យល់អំពីបម្រែបម្រួលពីការវាយតម្លៃលើកមុន |
|---|---|---|---|---|---|
| (៣) | ការអនុម័តថវិកាទាន់ពេលវេលា ដោយអង្គនីតិប្បញ្ញត្តិ ឬស្ថាប័នមានសមត្ថកិច្ចប្រហាក់ប្រហែល | A | A | ច្បាប់ថវិកាត្រូវបានអនុម័តដោយអង្គនីតិប្បញ្ញត្តិ និងឡាយព្រះហស្ថលេខាដោយព្រះមហាក្សត្រមុនថ្ងៃទី៣១ ខែធ្នូ សម្រាប់៣ឆ្នាំសារពើពន្ធចុងក្រោយនេះ | គ្មានការផ្លាស់ប្តូរនៅក្នុងលទ្ធផល។ |
| PI-12 | **ទស្សនៈវិស័យច្រើនឆ្នាំក្នុងការធ្វើផែនការថវិកា គោលនយោបាយ ចំណាយនិងការរៀបចំថវិកា** | C+ | C+ | វិធីសាស្ត្រផ្តល់ពិន្ទុ M2 | គ្មានការផ្លាស់ប្តូរនៅក្នុងលទ្ធផល។ |
| (១) | ការរៀបចំនូវការព្យាករណ៍ថវិកាពហុឆ្នាំ និងការវិភាជតាមមុខងារ | C | C | ការព្យាករណ៍ថវិកាសរុបរយៈពេល៣ឆ្នាំ ត្រូវបានរៀបចំជារៀងរាល់ឆ្នាំដោយផ្អែកលើសមាសធាតុធំៗ នៃសេដ្ឋកិច្ច។ ប៉ុន្តែមិនមានការញែកចេញជាចំណាត់ថ្នាក់វិស័យ មុខងារ ឬរដ្ឋបាល ហើយ បម្រែបម្រួលពីមួយឆ្នាំទៅមួយឆ្នាំទៀតក៏មិនត្រូវបានពន្យល់លម្អិតឡើយ។ | មានការផ្លាស់ប្តូរបន្តិចបន្តួចប៉ុណ្ណោះ នៅក្នុងលទ្ធផលនៃសមាសធាតុនេះ។ |
| (២) | វិសាលភាពនិងភាពញឹកញាប់នៃការវិភាគនិរន្តរភាពបំណុល | A | A | ការវិភាគចីរភាពបំណុលដែលគ្របដណ្តប់បំណុលបរទេស និងក្នុងស្រុក ត្រូវបានគ្រប់គ្រងនិងពិនិត្យជាប្រចាំឆ្នាំដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ | "ការវិភាគចីរភាពបំណុល" នៅតែត្រូវបានបន្តធ្វើបច្ចុប្បន្នកម្មជាប្រចាំឆ្នាំ (មិនមានការផ្លាស់ប្តូរពិន្ទុ)។ ទោះយ៉ាងណា សមត្ថភាពក្នុងការរៀបចំ "ការវិភាគចីរភាពបំណុល" ត្រូវបានបង្កើននៅក្នុង កសហវ ដែលកំពុងរ៉ាប់រងមុខងារនេះដោយខ្លួនឯង ដែលកាលពីក្នុងការវាយតម្លៃលើកមុន មុខងារនេះ គឺរ៉ាប់រងដោយមូលនិធិរូបិយវត្ថុអន្តរជាតិ និងធនាគារពិភព-លោក។ |

| ល.រ | សូចនាករ | ពិន្ទុ ឆ្នាំ២០១៥ | ពិន្ទុ ឆ្នាំ២០១៧ | អំណះអំណាងសម្រាប់ពិន្ទុឆ្នាំ២០១៧ | ការប្រៀបធៀបពិន្ទុ និងការពន្យល់អំពីបម្រែបម្រួលពីការវាយតម្លៃលើកមុន |
|---|---|---|---|---|---|
| (៣) | យុទ្ធសាស្ត្រតាមវិស័យដែលមានការគណនាចំណាយចរន្តនិងចំណាយវិនិយោគសម្រាប់រយៈពេលច្រើនឆ្នាំ | C | C | វិស័យអប់រំ និងវិស័យសុខាភិបាលបានធ្វើការកំណត់ចំណាយយ៉ាងពេញលេញក្នុងផែនការយុទ្ធសាស្ត្រដោយបានតម្រឹមជាមួយនឹងថវិកាសរុប។ វិស័យទាំងពីរនេះ ស្មើនឹងប្រមាណ ២៤%នៃចំណាយគោលសរុប។ ដោយឡែក សម្រាប់វិស័យផ្សេងទៀតក៏មានផែនការយុទ្ធសាស្ត្រដែរ ប៉ុន្តែមិនមានការព្យាករណ៍ចំណាយច្បាស់លាស់ និងនៅមិនទាន់មានសង្គតិភាព។ | សមិទ្ធកម្មមានការផ្លាស់ប្តូរតិចតួចប៉ុណ្ណោះ។ វិស័យអប់រំនិងសុខាភិបាលនៅតែជាវិស័យដែលមានការរៀបចំចំណាយក្នុង យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យ ឱ្យមានសង្គតិភាពទៅនឹងការព្យាករណ៍ ថវិកា។ ទោះយ៉ាងណាសារៈសំខាន់នៃវិស័យទាំងនេះ គឺស្ថិតក្នុងចន្លោះពី ២៣% មក ២៤%នៃចំណាយថវិកា ដូចនេះ ពិន្ទុទទួលបានគឺ C ដោយសារកម្រិតចំណាយថវិកាក្នុងវិស័យទាំងនេះ ត្រូវមានយ៉ាងតិច ២៥% នៃចំណាយថវិកាគោលសរុប ដើម្បីបានពិន្ទុលើសពីនេះ។ |
| (៤) | ការផ្សារភ្ជាប់គ្នារវាងថវិកាវិនិយោគ និងការព្យាករណ៍ចំណាយរំកិល | C | C | ការសម្រេចចិត្តវិនិយោគ គឺធ្វើឡើងដោយផ្អែកលើប្រភពធនធានខាងក្រៅច្បាស់លាស់ ជាជាងការយកយុទ្ធសាស្ត្រវិស័យជាមូលដ្ឋាន។ បច្ច័យជាចំណាយចរន្តសម្រាប់អាទិភាពគម្រោងមិនបានដាក់បញ្ចូលធាតុផ្សំសំខាន់សម្រាប់ការជ្រើសរើស និងមានតែនៅក្នុងវិស័យផ្លូវថ្នល់ និងធារាសាស្ត្រ អមដោយថវិកាចរន្តសម្រាប់ប្រតិបត្តិការ និងការថែទាំ។ | សមិទ្ធកម្មមានភាពខុសគ្នាតិចតួចប៉ុណ្ណោះ ព្រោះការរៀបចំថវិកាចរន្ត និង វិនិយោគ នៅតែរៀបចំតាមដំណើរការដាច់ដោយឡែកពីគ្នាដដែល រីឯការផ្សារភ្ជាប់រវាងសេចក្តីសម្រេចវិនិយោគ និងយុទ្ធសាស្ត្រសម្រាប់វិស័យ នៅមិនទាន់ល្អនៅឡើយ។ |
| **៣.២** | **ភាពអាចប៉ាន់ប្រមាណបាន និងការត្រួតពិនិត្យការអនុវត្តថវិកា** | | | | |
| **PI-13** | **តម្លាភាពនៃកាតព្វកិច្ចជាប់ពន្ធ និងបំណុលពន្ធរបស់អ្នកជាប់ពន្ធ** | **C+** | **B** | វិធីសាស្ត្រផ្តល់ពិន្ទុ M2 | ការកើនឡើងពិន្ទុសមាសធាតុទី៣ គឺមានដំណើរការនៃយន្តការតវ៉ាពន្ធ។ |
| (១) | ភាពច្បាស់លាស់ និងភាពគ្រប់ជ្រុងជ្រោយ នៃគោលការណ៍ច្បាប់ និងនីតិវិធីរដ្ឋបាលស្តីពីបំណុលពន្ធ | C | C | យោងសៀវសរឆ្នាំ២០១៧ រៀបចំដោយសភាពាណិជ្ជកម្មសហភាពអឺរ៉ុប គឺលិខិតបដ្ឋានគតិយុត្តិ គឺមានកង្វះខាតនៅឡើយដែលទាមទារឱ្យមានការរៀបចំគោលការណ៍ណែនាំ ឬនីតិវិធីលម្អិត លើប្រភេទពន្ធដូចជា អាករតម្លៃបន្ថែម, ពន្ធកាត់ទុក, ពន្ធលើប្រាក់ចំណូល។ល។ រីឯ ពាក់ពន្ធនឹងគយវិញរួមមាន ការទូទាត់ថ្លៃការ ដល់មន្ត្រីគយ សម្រាប់ការបំពេញការងារក្រៅម៉ោងធ្វើការ | មិនការប្រែប្រួលពិន្ទុ ប៉ុន្តែវឌ្ឍនភាពច្រើនពាក់ព័ន្ធការពង្រឹងរដ្ឋបាលប្រមូលចំណូល និងការបង្កើនវប្បធម៌បង់ពន្ធ តាមរយៈការផ្សព្វផ្សាយតាមសិក្ខាសាលាផ្សព្វផ្សាយអំពីកាតព្វកិច្ចរបស់អ្នកជាប់ពន្ធ ជាដើម។ |

| ល.រ | សូចនាករ | ពិន្ទុ ឆ្នាំ២០១៥ | ពិន្ទុ ឆ្នាំ២០១៧ | អំណះអំណាងសម្រាប់ពិន្ទុឆ្នាំ២០១៧ | ការប្រៀបធៀបពិន្ទុ និងការពន្យល់អំពីបម្រែបម្រួលពីការវាយតម្លៃលើកមុន |
|---|---|---|---|---|---|
| | | | | ជាដើម។ ការរៀបចំបំពេញបន្ថែមលិខិតបទដ្ឋានគតិយុត្តនេះ គឺជាឧបករណ៍សំខាន់ ដើម្បីចៀសមន្ត្រីរដ្ឋបាលចំណូលប្រើប្រាស់សិទ្ធិអំណាចរបស់មន្ត្រីរដ្ឋក្នុងការសម្រេច ឬការបកស្រាយភាពមិនច្បាស់លាស់នៃលិខិតបទដ្ឋានគតិយុត្ត។ | |
| (២) | លទ្ធភាពរបស់អ្នកជាប់ពន្ធក្នុងការទទួលបាននូវព័ត៌មានស្តីពីកាតព្វកិច្ចបង់ពន្ធ បំណុលពន្ធ និងនីតិវិធីរដ្ឋបាល | B | B | មានព័ត៌មានជាច្រើន ត្រូវបានផ្សព្វផ្សាយនៅក្នុងគេហទំព័ររបស់អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា និងមានវេទិកាដែលជំរុញការជជែកពិភាក្សា រវាងរដ្ឋាភិបាលនិងវិស័យឯកជន។ ចាប់តាំងពីការដាក់ឱ្យអនុវត្តយុទ្ធសាស្ត្រកៀរគរចំណូល ឆ្នាំ២០១៤-២០១៨ រដ្ឋបាលពន្ធបានបង្កើនគុណភាពការផ្តល់សេវា តាមរយៈការបង្កើតបញ្ជរព័ត៌មាន និងអនុវត្តប្រព័ន្ធព័ត៌មានវិទ្យា, ពង្រឹងរដ្ឋបាលប្រមូលចំណូល, និងការផ្សព្វផ្សាយអំពីកាតព្វកិច្ចរបស់អ្នកជាប់ពន្ធបានយ៉ាងទូលំទូលាយ ផងដែរ។ ទោះបីជាយ៉ាងណាក៏ដោយ ការផ្តល់សេវានេះ គឺមិនទាន់មានភាពគ្រប់ជ្រុងជ្រោយនៅឡើយ ប៉ុន្តែការអនុវត្តគឺមានវឌ្ឍនភាពជាលំដាប់។ | ព័ត៌មានកាន់តែមានច្រើនជាងមុន នៅលើគេហទំព័ររបស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា និងអគ្គនាយកដ្ឋានពន្ធដារ, កិច្ចសន្ទនា និងការអប់រំសម្រាប់អ្នកបង់ពន្ធ។ យ៉ាងនេះក៏ដោយ បញ្ហាកង្វះធនធាន ជាឧបសគ្គនៃការពង្រីកវិសាលភាពសេវាសម្រាប់អ្នកបង់ពន្ធ ដែលនាំឱ្យសមិទ្ធកម្មទាំងមូល មិនមានការផ្លាស់ប្តូរគួរឱ្យកត់សម្គាល់ពីការវាយតម្លៃលើកមុន។ |
| (៣) | មានដំណើរការនៃយន្តការតវ៉ាពន្ធ | C | B | អនុក្រឹត្យស្តីពីការរៀបចំ និងប្រព្រឹត្តិទៅនៃគណៈកម្មាធិការដោះស្រាយវិវាទសារពើពន្ធ ត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្តក្នុងឆ្នាំ២០១៦ ដោយបានបញ្ជាក់យ៉ាងច្បាស់នូវយន្តការ និងនីតិវិធីនៃដោះស្រាយបណ្តឹង។ | ពិន្ទុកើនឡើងពី C ទៅ B ដោយបង្កើននូវប្រសិទ្ធភាព និងតម្លាភាពពន្ធ។ |

| ល.រ | សូចនាករ | ពិន្ទុ ឆ្នាំ២០១៥ | ពិន្ទុ ឆ្នាំ២០១៧ | អំណះអំណាងសម្រាប់ពិន្ទុឆ្នាំ២០១៧ | ការប្រៀបធៀបពិន្ទុ និងការពន្យល់អំពីបម្រែបម្រួលពីការវាយតម្លៃលើកមុន |
|---|---|---|---|---|---|
| PI-14 | **ប្រសិទ្ធភាពនៃវិធានការសម្រាប់ចុះបញ្ជីអ្នកជាប់ពន្ធ និងការវាយតម្លៃពន្ធ** | D+ | C | វិធីសាស្ត្រផ្តល់ពិន្ទុ M2 | ពិន្ទុកើនឡើងពី D+ ទៅ C ដោយសមាសធាតុទី១ គឺកើនឡើងពិន្ទុ ដោយការពង្រឹងការចុះបញ្ជីពន្ធ។ |
| (១) | ការត្រួតពិនិត្យប្រព័ន្ធចុះបញ្ជីអ្នកជាប់ពន្ធ | D | C | ឆ្នាំ២០១៦ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានដាក់ឱ្យអនុវត្តប្រកាសស្តីពីការចុះបញ្ជីពន្ធដារ ដើម្បីពង្រឹងការអនុវត្តមាត្រា១១ នៃច្បាប់សារពើពន្ធ។ ប្រកាសនេះ បានកំណត់បុគ្គលទាំងឡាយត្រូវទៅចុះបញ្ជីសារពើពន្ធក្នុងរយៈពេល ១៥ ថ្ងៃ នៃថ្ងៃធ្វើការក្រោយបុគ្គលនោះចាប់ផ្តើមធ្វើសកម្មភាពសេដ្ឋកិច្ច ឬក្រោយពីពេលទទួលលិខិតបញ្ជាក់ការចុះបញ្ជី ឬលិខិតអនុញ្ញាតចេញដោយក្រសួង ឬ ស្ថាប័នពាក់ព័ន្ធ។ ការស្នើសុំចុះបញ្ជីដោយផ្ទាល់នៅរដ្ឋបាលសារពើពន្ធ ឬតាមប្រព័ន្ធអេឡិកត្រូនិក (E-registration) ដោយត្រូវបំពេញទម្រង់ចុះបញ្ជីដែលបានកំណត់ដោយអគ្គនាយកដ្ឋានពន្ធដារ។<br>យោងតាមរបាយការណ៍សវនកម្មរបស់អាជ្ញាធរសវនកម្មជាតិ អគ្គនាយកដ្ឋានពន្ធដារនៅមានកង្វះចន្លោះក្នុងការប្រមូលព័ត៌មានអំពីសហគ្រាសដែលបានចុះបញ្ជីតាមក្រសួង ស្ថាប័នមួយចំនួន។ | ពិន្ទុកើនឡើងពី D ទៅ C។ ដើម្បីទទួលបានពិន្ទុខ្ពស់ជាងនេះ ប្រព័ន្ធចុះបញ្ជីពន្ធត្រូវផ្សារភ្ជាប់ជាមួយប្រព័ន្ធចុះបញ្ជីនៃក្រសួង ស្ថាប័នពាក់ព័ន្ធ និងស្ថាប័នវិស័យហិរញ្ញវត្ថុ។ |
| (២) | ប្រសិទ្ធភាពនៃការដាក់ទោសទណ្ឌសម្រាប់ការមិនអនុវត្តតាមកាតព្វកិច្ចចុះបញ្ជីពន្ធ និងការប្រកាសពន្ធ | C | C | នីតិវិធីច្បាប់នៃការដាក់ទោសទណ្ឌសម្រាប់ការមិនអនុវត្តតាមកាតព្វកិច្ចចុះបញ្ជីពន្ធ និងការប្រកាសពន្ធមិនត្រូវបានអនុវត្តប្រកបដោយប្រសិទ្ធភាពដោយហេតុថា (១) ការផាកពិន័យនៅមានកម្រិតទាប (២) មានបញ្ហាប្រឈមច្រើន ក្នុងការតាមដាន និងការចាប់បង្ខំឱ្យអនុវត្តតាមច្បាប់។<br>នាពេលបច្ចុប្បន្ន ដើម្បីគ្រប់គ្រងអ្នកជាប់ពន្ធបានបង្កើតប្រព័ន្ធ Auto Printout ដើម្បីព្រីនលិខិតជូនដំណឹងសម្រាប់អ្នកជាប់ពន្ធ | ពន្ទុមិនប្រែប្រួល ប៉ុន្តែជាវឌ្ឍនភាពមានការប្រែប្រួលចំពោះពង្រឹងយន្តការសម្រាប់គ្រប់គ្រងជាប់ពន្ធមិនបានបំពេញកតព្វកិច្ច។ ដើម្បីទទួលបានពិន្ទុខ្ពស់ជាងនេះ គឺត្រូវដាក់ទោសទណ្ឌតាមច្បាប់ដែលមានជាធរមាន។ |

| ល.រ | សូចនាករ | ពិន្ទុ ឆ្នាំ២០១៥ | ពិន្ទុ ឆ្នាំ២០១៧ | អំណះអំណាងសម្រាប់ពិន្ទុឆ្នាំ២០១៧ | ការប្រៀបធៀបពិន្ទុ និងការពន្យល់អំពីបម្រែបម្រួលពីការវាយតម្លៃលើកមុន |
|---|---|---|---|---|---|
| | | | | ទៅដល់ក្រុមហ៊ុន សហគ្រាសទាំងនោះ ឱ្យមកបំពេញកាតព្វកិច្ចសារពើពន្ធ។ នៅឆ្នាំ២០១៦ ទំហំប្រាក់ពិន័យ និងទោសបញ្ញត្តិសារពើពន្ធប្រមូលបានចំនួន ៨៤ ៥៩២ ០២៧ ៦៦៥ រៀល (ប្រមាណ ២១ លានដុល្លារអាមេរិក) លើច្បាប់ថវិកាចំនួន ១១៩,៦១%។ | |
| (៣) | ការធ្វើផែនការ និងការត្រួតពិនិត្យតាមដានកម្មវិធីសវនកម្មពន្ធ និងកម្មវិធីស៊ើបអង្កេតការគេចវេសពន្ធ | C | C | នៅពេលដែលការអនុវត្តសវនកម្មពន្ធត្រូវបានកែលម្អនឹងពង្រឹងលក្ខណៈវិនិច្ឆ័យវាយតម្លៃហានិភ័យនៃការគេចវេសពន្ធ មិនទាន់ត្រូវបានរៀបចំបានពេញលេញ និងតាមស្តង់ដារ។ លើសពីនេះទៅទៀត វិសាលភាពនៃការអនុវត្តសវនកម្មនៅមានកម្រិត គឺត្រូវបានអនុវត្តទៅលើតែទំនិញនាំចូលនិងនាំចេញ (ចំពោះអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា) និងគ្របដណ្តប់លើអ្នកជាប់ពន្ធធំតាមរបបពិត តិចតួចប៉ុណ្ណោះ (ចំពោះអគ្គនាយកដ្ឋានពន្ធដារ)។ ដើម្បីពង្រឹងការធ្វើសវនកម្មលើក្រុមហ៊ុន ឬសហគ្រាស អគ្គ-នាយកដ្ឋានពន្ធដារបាននិងកំពុងរៀបចំសៀវភៅគោលការណ៍ណែនាំសហគ្រាស និងកំពុងជំរុញឱ្យឱ្យអ្នកជាប់ពន្ធតាមវិស័យមួយចំនួនដែលស្ថិតក្រោមគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ គឺតម្រូវឱ្យមានរបាយការណ៍ហិរញ្ញវត្ថុពីស្នងការគណនេយ្យឯករាជ្យ។ | ពន្ធមិនប្រែប្រួល។ ដើម្បីទទួលបានពិន្ទុខ្ពស់ជាងនេះ លក្ខខណ្ឌវិនិច្ឆ័យហានិភ័យត្រូវកំណត់ឱ្យបានច្បាស់លាស់ និងផែនការសវនកម្មគឺត្រូវផ្អែកលើកម្រិតហានិភ័យ។ |
| **PI-15** | **ប្រសិទ្ធភាពនៃការប្រមូលពន្ធ** | D+ | D+ | វិធីសាស្ត្រនៃការផ្តល់ពិន្ទុ M1 | គ្មានបម្រែបម្រួល។ |

| ល.រ | សូចនាករ | ពិន្ទុ ឆ្នាំ២០១៥ | ពិន្ទុ ឆ្នាំ២០១៧ | អំណះអំណាងសម្រាប់ពិន្ទុឆ្នាំ២០១៧ | ការប្រៀបធៀបពិន្ទុ និងការពន្យល់អំពីបម្រែបម្រួលពីការវាយតម្លៃលើកមុន |
|---|---|---|---|---|---|
| (១) | អនុបាតប្រមូលពន្ធចំពោះបំណុលពន្ធដុល ដែលជាភាគរយនៃបំណុលពន្ធនៅដើមឆ្នាំសារពើពន្ធ និងដែលត្រូវបានប្រមូលក្នុងឆ្នាំសារពើពន្ធនោះ | D | D | បំណុលពន្ធសរុបមានទំហំធំ ហើយអនុបាតប្រមូលពន្ធក្នុងឆ្នាំ២០១៤ ដល់ឆ្នាំ២០១៦ ស្ថិតក្រោម ៦០% (៨,៣២% ក្នុងឆ្នាំ២០១៤, ៩,៣៩% នៅក្នុង២០១៥ និង ៨,៨៦% នៅឆ្នាំ២០១៦) | គ្មានការប្រែប្រួល។ |
| (២) | ប្រសិទ្ធភាពនៃការផ្ទេរប្រាក់ពន្ធដែលប្រមូលបានទៅរតនាគារ ដោយរដ្ឋបាលចំណូល | B | B | ចំណូលភាគច្រើនត្រូវបានផ្ទេរទៅកាន់ រតនាគារជាតិជារៀងរាល់ថ្ងៃ។ ចំណូលពន្ធមួយចំនួនត្រូវបានប្រមូលដោយការិយាល័យគយនិងរដ្ឋាករកម្ពុជា និងសាខាពន្ធដារខេត្ត ខណ្ឌ និងត្រូវបានរក្សាទុកនៅធនាគារ។ ប្រាក់ទាំងនេះមិនត្រូវបានផ្ទេរជារៀងរាល់ថ្ងៃទេ ប៉ុន្តែយ៉ាងហោចណាស់ជារៀងរាល់សប្តាហ៍។ | គ្មានបម្រែបម្រួល។ |
| (៣) | ពេលវេលា នៃការផ្ទៀងផ្ទាត់គណនីពេញលេញដោយរតនាគាររវាងការវាយតម្លៃពន្ធ, ការប្រមូលពន្ធ, កំណត់ត្រាបំណុលពន្ធ និងវិក្កយបត្រ | C | C | ពន្ធដែលប្រមូលបានត្រូវបានផ្ទៀងផ្ទាត់ជារៀងរាល់ថ្ងៃ រវាងអគ្គនាយកដ្ឋានរដ្ឋាភគារជាតិ និងធនាគារជាតិ។ ប៉ុន្តែការផ្ទួរផ្ទួរតួលេខចំណូលពន្ធរវាងសាខាពន្ធដារ និងរតនាគាររាជធានី ខេត្ត និងសាខាគយនិងរដ្ឋាករកម្ពុជា និងរតនាគាររាជធានី ខេត្ត ត្រូវធ្វើជាប្រចាំខែ រីឯការផ្ទួរផ្ទួងតួលេខថ្នាក់កណ្តាល គឺត្រូវបានធ្វើជាប្រចាំឆ្នាំ។ | គ្មានបម្រែបម្រួល។ |
| PI-16 | **ភាពអាចប៉ាន់ប្រមាណបាននូវអត្ថិភាពថវិកាសម្រាប់ធានាចំណាយ** | C+ | C | វិធីសាស្ត្រផ្តល់ពិន្ទុ M1 | ពិន្ទុនេះ ធ្លាក់ចុះពី C+ ទៅ C ដោយហេតុថាកម្មវិធីចំណូល-ចំណាយ គឺមិនទាន់ត្រូវប្រើប្រាស់ជាឧបករណ៍សម្រាប់ការធានាចំណាយនៅឡើយ។ |
| (១) | វិសាលភាពដែលលំហូរសាច់ប្រាក់អាចព្យាករណ៍បាន និងត្រូវបានត្រួតពិនិត្យ | B | C | ការព្យាករសាច់ប្រាក់ត្រូវបានធ្វើបច្ចុប្បន្នកម្មប្រចាំត្រីមាស ដោយផ្អែកលើលំហូសាច់ប្រាក់ជាក់ស្តែងត្រីមាសមុន និងព្យាករណ៍ឡើងវិញចំពោះពេលវេលាដែលនៅសល់ក្នុងឆ្នាំ។ ប៉ុន្តែប្រសិទ្ធភាពវិញ | ពិន្ទុទទួលបាន C ដោយសារក្រសួង ស្ថាប័ន គឺធ្វើផែនការសាច់ប្រាក់ប្រចាំត្រីមាសមិនទាន់ពេលវេលា និងគុណភាព គឺនៅមានកម្រិតនៅឡើយ។ |

| ល.រ | សូចនាករ | ពិន្ទុ ឆ្នាំ២០១៥ | ពិន្ទុ ឆ្នាំ២០១៧ | អំណះអំណាងសម្រាប់ពិន្ទុឆ្នាំ២០១៧ | ការប្រៀបធៀបពិន្ទុ និងការពន្យល់អំពីបម្រែបម្រួលពីការវាយតម្លៃលើកមុន |
|---|---|---|---|---|---|
| | | | | គឺនៅមានលម្អៀងធំនៅឡើយ និងតួលេខក្រសួង ស្ថាប័នផ្តល់មក គឺនៅមានភាពយឺតយ៉ាវ។ អ្វីជាវឌ្ឍនភាព គឺអគ្គនាយកដ្ឋានរតនៈគារជាតិ បានកំពុងដាក់ឱ្យក្រសួង ស្ថាប័ន អនុវត្តប្រព័ន្ធអនឡាញសម្រាប់រៀបចំផែនការសាច់ប្រាក់។ | |
| (២) | ការជឿទុកចិត្ត និងកំឡុងពេលក្នុងឆ្នាំនៃការផ្តល់ព័ត៌មានថវិកាស្តីពីការកំណត់ពិដានសម្រាប់ការធានាចំណាយ ដល់ក្រសួង ស្ថាប័ន | B | C | ក្រសួង ស្ថាប័ន អាចរៀបចំកម្មវិធីចំណូល និងចំណាយរបស់ខ្លួនជារៀងរាល់ត្រីមាស ប៉ុន្តែក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួង ស្ថាប័ន គឺមិនទាន់ផ្តល់អាទិភាពលើការអនុវត្តកម្មវិធីចំណូល ចំណាយនៅឡើយ។ ជាការអនុវត្តជាក់ស្តែង ត្រីមាសទី១ ថវិកាជាតិអនុវត្តបានទាប និងសម្រុកចំណាយនៅត្រីមាសទី៤ នៃឆ្នាំ។ | ពិន្ទុធ្លាក់ចុះមក C ដោយសារការអនុកម្មវិធីចំណូល ចំណាយ គឺមិនទាន់ស្របទៅផែនការសកម្មភាពក្នុងឆ្នាំរបស់ក្រសួង ស្ថាប័ននៅឡើយ។ |
| (៣) | អត្រានៃការកើតឡើង និងតម្លាភាពនៃការផ្ទេរថវិកាដែលត្រូវបានសម្រេចលើសពីសមត្ថកិច្ចរបស់ក្រសួង ស្ថាប័ន | C | C | ការផ្ទេរថវិកាក្នុងឆ្នាំ មានចំនួនច្រើននិងកើតឡើងច្រើនដង ប៉ុន្តែមានតម្លាភាព ស្របបទប្បញ្ញត្តិយុត្តជាធរមាន។ តាមរយៈការអនុវត្តថវិកាកម្មវិធី ក្រសួង ស្ថាប័នទើបនឹងចូលអនុវត្ត គឺជួបប្រទះបញ្ហាប្រឈមខ្លាំងចំពោះការរៀបចំថវិកាផ្សារភ្ជាប់ទៅនឹងគោលនយោបាយ និងនីតិវិធីការអនុវត្តថវិកាកម្មវិធី។ ជាក់ស្តែង ក្រសួងអប់រំ យុវជន និងកីឡា ធ្វើការនិយ័តថវិកាជាញឹកញាប់ ដោយមួយអង្គភាពថវិកាយ៉ាងហោចណាស់ពី ៣ ទៅ៤ ដងក្នុងឆ្នាំ។ | គ្មានបម្រែបម្រួល។ |
| **PI-17** | **ការកត់ត្រានិងការគ្រប់គ្រង សមតុល្យសាច់ប្រាក់, បំណុល និងការធានា** | C+ | C+ | វិធីសាស្ត្រផ្តល់ពិន្ទុ M2 | ពិន្ទុ អាចប្រៀបធៀបនឹងគ្នាបាន។ វឌ្ឍនភាពជាងឆ្នាំ២០១៥ នោះគឺការរៀបចំគោលនយោបាយ PPP។ |

| ល.រ | សូចនាករ | ពិន្ទុ ឆ្នាំ២០១៥ | ពិន្ទុ ឆ្នាំ២០១៧ | អំណះអំណាងសម្រាប់ពិន្ទុឆ្នាំ២០១៧ | ការប្រៀបធៀបពិន្ទុ និងការពន្យល់អំពីបម្រែបម្រួលពីការវាយតម្លៃលើកមុន |
|---|---|---|---|---|---|
| (១) | គុណភាពនៃកំណត់ត្រា និងការរាយការណ៍ទិន្នន័យបំណុល | C | C | កំណត់ត្រាបំណុលក្នុងស្រុក និងក្រៅស្រុក មានភាពពេញលេញ និងត្រូវបានធ្វើបច្ចុប្បន្នកម្ម និងផ្ទៀងផ្ទាត់ជាមួយនឹងរបាយការណ៍ឥណទាយីជារៀងរាល់ឆ្នាំ។<br>ដើម្បីទទួលបានពិន្ទុខ្ពស់ជាងនេះ គឺធ្វើបច្ចុប្បន្នកម្ម និងផ្ទៀងផ្ទាត់ជាប្រចាំត្រីមាស។ | គ្មានការប្រែប្រួល។ អគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងគ្រប់គ្រងបំណុល បានធ្វើការផ្សព្វផ្សាយទិន្នន័យបំណុលក្នុង១ ឆ្នាំចំនួន ២ ដង។ |
| (២) | វិសាលភាពនៃការបូកសរុបសមតុល្យសាច់ប្រាក់របស់រាជរដ្ឋាភិបាល | B | B | តុល្យភាពសាច់ប្រាក់ភាគច្រើនត្រូវបានគណនា និងបូកសរុបយ៉ាងហោចណាស់មួយសប្តាហ៍ម្តង។ | គ្មានការប្រែប្រួល។ ដើម្បីទទួលបានពិន្ទុខ្ពស់ជាងនេះ គឺត្រូវធ្វើទាំងគ្រឹះស្ថានសាធារណៈរដ្ឋបាល បន្ថែមទៀត។ |
| (៣) | ប្រព័ន្ធនៃការចុះកិច្ចសន្យាខ្ចី និងការចេញផ្សាយការធានា | C | C | ការចុះកិច្ចសន្យាកម្ចី និងការធានា សុទ្ធសឹងត្រូវបានអនុម័តដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្នុងដែនកំណត់សម្រាប់បំណុលសរុប ប៉ុន្តែគោលការណ៍ណែនាំ និងលក្ខខណ្ឌវិនិច្ឆ័យ មិនទាន់ត្រូវបានរៀបចំរួចរាល់នៅឡើយ។ | គ្មានការប្រែប្រួល។ បន្ថែមពីនេះ អ.ប.ស. បានរៀបចំគោលនយោបាយ PPP និងកំពុងរៀបចំគោលការណ៍ណែនាំ និងនីតិវិធីលម្អិត។ |
| **PI-18** | **ប្រសិទ្ធភាពនៃការត្រួតពិនិត្យបញ្ជីប្រាក់បៀវត្ស** | **D+** | **C+** | វិធីសាស្ត្រផ្តល់ពិន្ទុ M1 | ពិន្ទុ មានការប្រែប្រួលលើសមាសភាពទី៤ ដោយក្រសួងមុខងារសាធារណៈ បានពង្រឹងមុខងារអធិការកិច្ច និងរកឃើញនូវភាពមិនប្រកតីនៃការបើកប្រាក់បៀវត្ស។ |
| (១) | ការធ្វើសមាហរណកម្ម និងការផ្ទៀងផ្ទាត់រវាងទិន្នន័យចំនួនបុគ្គលិក និងបញ្ជីប្រាក់បៀវត្ស | B | B | គ្មានការភ្ជាប់គ្នាដោយផ្ទាល់រវាងបញ្ជីបុគ្គលិក និងបញ្ជីប្រាក់បៀវត្ស។ ប៉ុន្តែបញ្ជីប្រាក់បៀវត្សប្រចាំខែនីមួយៗ មានភ្ជាប់មកជាមួយឯកសារយោងគ្រប់គ្រាន់ ហើយក្រសួង ស្ថាប័នបានពិនិត្យ និងផ្ទៀងផ្ទាត់ត្រឹមត្រូវ ទៅលើបញ្ជីប្រាក់បៀវត្សប្រចាំខែនីមួយៗ។ | គ្មានបម្រែបម្រួល នៅក្នុងលទ្ធផល។ |

| ល.រ | សូចនាករ | ពិន្ទុ ឆ្នាំ២០១៥ | ពិន្ទុ ឆ្នាំ២០១៧ | អំណះអំណាងសម្រាប់ពិន្ទុឆ្នាំ២០១៧ | ការប្រៀបធៀបពិន្ទុ និងការពន្យល់អំពីបម្រែបម្រួលពីការវាយតម្លៃលើកមុន |
|---|---|---|---|---|---|
| (២) | ភាពទាន់ពេលវេលានៃការកែសម្រួលព័ត៌មានបុគ្គលិក និងបញ្ជីប្រាក់បៀវត្ស | C | C | មានការយឺតយ៉ាវរហូតដល់ទៅ ៣ខែ ក្នុងការធ្វើបច្ចុប្បន្នភាពបញ្ជីប្រាក់បៀវត្ស ព្រមទាំងមាននិយ័តកម្មច្រើនលើបញ្ជីទាំងនោះ ។ | គ្មានបម្រែបម្រួល។ |
| (៣) | ការត្រួតពិនិត្យផ្ទៃក្នុងទៅលើបម្រែបម្រួលព័ត៌មានបុគ្គលិក និងបញ្ជីប្រាក់បៀវត្ស | B | B | សិទ្ធអំណាចនៃការសម្រេចលើការផ្លាស់ប្តូរស្ថានភាពមន្ត្រី និងបញ្ជីប្រាក់បៀវត្ស មានចែងច្បាស់លាស់ និងមានការកំណត់សិទ្ធអំណាចច្បាស់លាសក្នុងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ដោយមិនកែប្រែលើសពីសិទ្ធិអំណាចឡើយ។ | គ្មានបម្រែបម្រួល។ |
| (៤) | ការធ្វើសវនកម្មលើបញ្ជីប្រាក់បៀវត្សដែលបង្ហាញពីចំណុចខ្សោយនៃការត្រួតពិនិត្យ និង/ឬ ចំនួនមន្ត្រីខ្មោច | D | C | ក្រសួងមុខងារសាធារណៈ បានចុះធ្វើអធិការកិច្ចលើបុគ្គលិក និងបៀវត្សទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ជាពិសេស មន្ត្រីរាជការក្នុងវិស័យអប់រំ។ ករណីបើកបៀវត្សលើសនៅតាមក្រសួង ស្ថាប័ន និងអង្គភាពនានាថ្នាក់ក្រោមជាតិចំនួន ៦១ ករណី និងបានរកឃើញបើកបៀវត្សលើសចំនួន ៣៩១ ១០០ ៦៣៤ រៀល និងបានចាត់វិធានការតាមនីតិវិធីដោយឱ្យបង្វែរថវិកាដែលបើកលើសចូលរតនាគារខេត្តវិញបានរួចរាល់ចំនួន ៧៥ ៧២២ ៦៣០ រៀល ព្រមទាំងធ្វើការតាមដាន និងត្រួតពិនិត្យលើការបង្វែរបៀវត្ស ដែលបើកលើសចូលរតនាគារាជធានី ខេត្ត។ | ពិន្ទុកើនឡើងពី D ទៅ C។ |
| PI-19 | **តម្លាភាព ការប្រកួតប្រជែងនិងយន្ត-ការដោះស្រាយបណ្តឹងតវ៉ាក្នុងកិច្ចលទ្ធកម្ម** | D | C | វិធីសាស្ត្រវាយតម្លៃផ្តល់ពិន្ទុ M2 | ការកើនឡើងពិន្ទុនេះ គឺមកពីការផ្សព្វផ្សាយនូវផែនការលទ្ធកម្ម, ការប្រគល់កិច្ចសន្យា និងព័ត៌មានដេញថ្លៃ។ |
| (១) | មានក្របខ័ណ្ឌគតិយុត្តសម្រាប់ធានា | B | B | ច្បាប់ស្តីពីលទ្ធកម្មសាធារណៈ ឆ្លើយតបបានតាម (២០១២) លក្ខខណ្ឌតម្រូវចំនួន ៥ ក្នុងចំណោម ៦។ | ពិន្ទុនេះ រក្សាដដែល ប៉ុន្តែមានវឌ្ឍនភាពជាងការវាយតម្លៃឆ្នាំ២០១៥ ដោយបានបំពេញមួយលក្ខខណ្ឌបន្ថែម នោះគឺការផ្តល់ព័ត៌មានស្តីពី |

| ល.រ | សូចនាករ | ពិន្ទុ ឆ្នាំ២០១៥ | ពិន្ទុ ឆ្នាំ២០១៧ | អំណះអំណាងសម្រាប់ពិន្ទុឆ្នាំ២០១៧ | ការប្រៀបធៀបពិន្ទុ និងការពន្យល់អំពីបម្រែបម្រួលពីការវាយតម្លៃលើកមុន |
|---|---|---|---|---|---|
| | តម្លាភាព ភាពគ្រប់ជ្រុងជ្រោយ និងការប្រកួតប្រជែងក្នុងកិច្ចលទ្ធកម្ម | | | | លទ្ធកម្មសាធារណៈ រួមមាន ការផ្សព្វផ្សាយផែនការលទ្ធកម្ម ឯកសារដេញថ្លៃ និងការផ្តល់កិច្ចសន្យា រីឯ ទិន្នន័យស្តីពីការដោះស្រាយបណ្តឹងតវ៉ា គឺមិនទាន់មានការផ្សព្វផ្សាយទេ។ |
| (២) | ការប្រើប្រាស់វិធីសាស្ត្រប្រកួតប្រជែងក្នុងកិច្ចលទ្ធកម្ម | D | D | នៅឆ្នាំ២០១៦ កិច្ចសន្យាចំនួន ៤៧២ ស្មើនឹង ១ ៤៧៩ ៥៥៤,២១ លានរៀល និងកិច្ចសន្យាតាមប្រភពតែមួយ (Single Source) មានចំនួនកិច្ចសន្យាចំនួន ៣៤២ ស្មើនឹង ១ ៤៥៨ ៩៧៩,៧៨ លានរៀល។ ដូចនេះ ការប្រើប្រាស់វិធីសាស្ត្រតាមប្រភពតែមួយ គឺមានប្រមាណ ៥០% នៃកិច្ចសន្យាសរុប។ ទោះបីជាយ៉ាងណាក៏ដោយ តួលេខបញ្ជាក់ថានៅចំនួនដែលមិនអនុលោមតាមបទប្បញ្ញត្តិ គឺពុំមានការបញ្ជាក់នោះទេ។ | មាត្រា១៣ នៃច្បាប់ស្តីពីលទ្ធកម្មសាធារណៈ បានបញ្ជាក់ពីលក្ខខណ្ឌនៃការអនុវត្តវិធីសាស្ត្រលទ្ធកម្មដោយឡែក (វិធីសាស្ត្រលទ្ធកម្មមិនមានការដេញថ្លៃ) ដូចខាងក្រោម÷<br>ក. ការចុះកិច្ចសន្យាផ្ទាល់:<br>• មុខសញ្ញាលទ្ធកម្មមានប្រភពតែមួយ<br>• មុខសញ្ញាលទ្ធកម្មមួយចំនួន ដែលទទួលបានគោលការណ៍ពី រាជរដ្ឋាភិបាលក្នុងការចុះកិច្ចសន្យាផ្ទាល់ជាមួយក្រុមហ៊ុនផ្គត់ផ្គង់ផ្ទាល់មុខ (ដូចជាកិច្ចសន្យាផ្គត់ផ្គង់រថយន្តជាដើម)<br>• មុខសញ្ញាលទ្ធកម្មដែលត្រូវបានដេញថ្លៃប្រកួតប្រជែងជាសាធារណៈម្តងរួចមកហើយ ហើយជាតម្រូវការចាំបាច់បន្ទាន់ និងមិនមានពេលគ្រប់គ្រាន់សម្រាប់ធ្វើការដេញថ្លៃដោយប្រកួតប្រជែងជាសាធារណៈលើកទី២<br>• ការដេញថ្លៃដោយប្រកួតប្រជែងជាសាធារណៈលើកទី២ មិនទទួលបានជោគជ័យ<br>• តម្រូវការចាំបាច់បន្ទាន់ក្នុងពេលមានគ្រោះមហន្តរាយធម្មជាតិ ឬគ្រោះអាសន្នផ្សេងទៀត ហើយមានរយៈពេលខ្លីមិនអាចរង់ចាំឱ្យប្រើវិធីសាស្ត្រផ្សេងទៀតបាន<br>• សម្រាប់គោលបំណងសិក្សាស្រាវជ្រាវ ដកបទពិសោធ ឬអភិវឌ្ឍ។ |

| ល.រ | សូចនាករ | ពិន្ទុ ឆ្នាំ២០១៥ | ពិន្ទុ ឆ្នាំ២០១៧ | អំណះអំណាងសម្រាប់ពិន្ទុឆ្នាំ២០១៧ | ការប្រៀបធៀបពិន្ទុ និងការពន្យល់អំពីបម្រែបម្រួលពីការវាយតម្លៃលើកមុន |
|---|---|---|---|---|---|
| | | | | | ខ .ការបន្តចុះកិច្ចសន្យា:<br>• មុខសញ្ញាលទ្ធកម្មដូចគ្នានឹងមុខសញ្ញាលទ្ធកម្មក្នុងកិច្ចសន្យាដើម ដែលទទួលបានតាមរយៈការដេញថ្លៃ<br>• ស្ថិតក្នុងអំឡុងពេលមិនលើស ៦ខែ បន្ទាប់ពីកិច្ចសន្យាដើមចូលជាធរមាន និងស្ថិតក្នុងឆ្នាំថវិកាតែមួយ<br>• តម្លៃឯកតាស្មើ ឬទាបជាងតម្លៃឯកតាក្នុងកិច្ចសន្យាដើម<br>• តម្លៃសរុបលើសពី ២៥ ភាគរយនៃតម្លៃកិច្ចសន្យាដើម។<br>គ. ការចុះកិច្ចសន្យាជាមួយអង្គភាពជំនាញនៃស្ថាប័នរដ្ឋ ជាវិធីសាស្ត្រតម្រូវឱ្យមានការចរចារថ្លៃ និងបច្ចេលទេសផ្ទាល់ជាមួយនឹងអង្គភាពជំនាញរបស់ស្ថាប័នរដ្ឋដែលមានធនធាន គ្រឿងចក្រ ឧបករណ៍ សម្ភារៈ និងកម្លាំងពលកម្មគ្រប់គ្រាន់សម្រាប់អនុវត្តកិច្ចសន្យា។<br>ឃ. ការចុះកិច្ចសន្យាជាមួយនឹងសហគមន៍។ |
| (៣) | សាធារណជនអាចទទួលបានព័ត៌មានស្តីពីកិច្ចលទ្ធកម្មបានគ្រប់ជ្រុងជ្រោយ ទាន់ពេលវេលា និងអាចទុកចិត្តបាន | D | B | អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ បានផ្សព្វផ្សាយផែនការលទ្ធ-កម្ម, ឯកសារដេញថ្លៃ, ការផ្តល់កិច្ចសន្យា ដែលស្ថិតនៅលើសិទ្ធិសម្រេច និង ងរបាយការណ៍ត្រួតពិនិត្យលទ្ធកម្មតាមក្រោយ នៅលើគេហទំព័រ។ | ពិន្ទុកើនឡើងពី D ទៅ B។ |
| (៤) | មានយន្តការឯករាជ្យសម្រាប់ដោះស្រាយរាល់បណ្តឹងតវ៉ាលើកិច្ចលទ្ធកម្ម | D | D | គ្មានស្ថាប័នឯករាជ្យសម្រាប់ដោះស្រាយបណ្តឹងតវ៉ាលើកិច្ចលទ្ធកម្មទេ។ ថ្មីៗនេះ អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈបាននិងកំពុងរៀបចំអនុក្រឹត្យស្តីពីយន្តការតវ៉ាបណ្តឹងលទ្ធកម្មសាធារណៈ។ | ពិន្ទុគ្មានការប្រែប្រួល។ |
| **PI-20** | **ប្រសិទ្ធភាពនៃការត្រួតពិនិត្យផ្ទៃក្នុងទៅលើចំណាយមិនមែនបៀវត្ស** | C | C | វិធីសាស្ត្រផ្តល់ពិន្ទុ M1 | ពិន្ទុ មិនអាចប្រៀបធៀបនឹងគ្នាបាន ទាំងស្រុង។ ទោះយ៉ាងណា គ្មានបម្រែបម្រួលគួរឱ្យកត់សម្គាល់ នៅក្នុងលទ្ធផលឡើយ។ |

| ល.រ | សូចនាករ | ពិន្ទុ ឆ្នាំ២០១៥ | ពិន្ទុ ឆ្នាំ២០១៧ | អំណះអំណាងសម្រាប់ពិន្ទុឆ្នាំ២០១៧ | ការប្រៀបធៀបពិន្ទុ និងការពន្យល់អំពីបម្រែបម្រួលពីការវាយតម្លៃលើកមុន |
|---|---|---|---|---|---|
| (១) | ប្រសិទ្ធភាពនៃប្រព័ន្ធត្រួតពិនិត្យនៃការធានាចំណាយ | C | C | គោលការណ៍ណែនាំបានណែនាំតែអំពីនីតិវិធីសម្រាប់ធានាចំណាយចរន្តប៉ុណ្ណោះ។ លើសពីនេះទៅទៀត សំណើធានាចំណាយបន្ទាន់ ឬ សំណើធានាចំណាយពិសេស មិនត្រូវបានអនុវត្តតាមនីតិវិធីទាំងស្រុងទេ។ | គ្មានបម្រែបម្រួល។ |
| (២) | ភាពគ្រប់ជ្រុងជ្រោយ ភាពសមស្រប និងការយល់ដឹងពីលិខិតបទដ្ឋានគតិយុត្ត និងនីតិវិធីនៃការត្រួតពិនិត្យផ្ទៃក្នុង | C | C | មានគោលការណ៍ណែនាំស្តីពីនីតិវិធីអនុវត្តថវិកាកម្មវិធី ត្រូវបានរៀបចំឡើងសម្រាប់ក្រសួង ស្ថាប័ន ចូលអនុវត្តថវិកាកម្មវិធី។ គោលការណ៍ត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្តនៅថ្ងៃ៣១ ខែធ្នូ ឆ្នាំ២០១៤។ ដើម្បីឱ្យបានពិន្ទុខ្ពស់ជាងនេះ កសហវ គួរពន្លឿនការរៀបចំមគ្គុទេសក៍គ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ របស់រាជរដ្ឋាភិបាល ដើម្បីពង្រឹងការអនុវត្តផ្ទៃក្នុង។ | គ្មានបម្រែបម្រួល។ |
| (៣) | កម្រិតនៃអនុលោមភាពទៅនឹងវិធាននៃកិច្ចដំណើរការនិងការកត់ត្រាកិច្ចប្រតិបត្តិការ | C | C | ក្រសួង ស្ថាប័នមួយចំនួនធំបានប្រកាន់ភ្ជាប់នូវនីតិវិធី និងវិធានមានជាធរមាន។ ប៉ុន្តែមានក្រសួង ស្ថាប័ន មួយចំនួនមិនទាន់អនុវត្តបាននៅឡើយ។ | គ្មានបម្រែបម្រួល។ |
| **PI-21** | **ប្រសិទ្ធភាពនៃសវនកម្មផ្ទៃក្នុង** | **C** | **C** | វិធីសាស្ត្រផ្តល់ពិន្ទុ M1 | ពិន្ទុអាចប្រៀបធៀបនឹងគ្នាបាន។ មានវឌ្ឍភាពនៅក្នុងសមាសធាតុ (២)។ |
| (១) | វិសាលភាពនិងគុណភាពនៃមុខងាររបស់សវនកម្មផ្ទៃក្នុង | C | C | មុខងារជាសវនកម្មផ្ទៃក្នុង គ្របដណ្តប់ក្រសួង ស្ថាប័ននិងអង្គភាពរបស់រាជរដ្ឋាភិបាលនិងការពិនិត្យជាប្រព័ន្ធ | ពិន្ទុ បានកើនឡើងលើសពីឆ្នាំ២០១០ ដែលបានត្រឹម D ដោយហេតុថាកាលពីលើកមុនមិនមានការផ្តោតទៅលើបញ្ហាដែលមានលក្ខណៈជាប្រព័ន្ធ។ |
| (២) | ភាពទៀងទាត់និងការចែកចាយនៃរបាយការណ៍សវនកម្មផ្ទៃក្នុង | C | C | សវនកម្មផ្ទៃក្នុងដាក់របាយការណ៍ជូនប្រធានស្ថាប័នសាមី និងផ្ញើជូនអគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុងនៃ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ប៉ុន្តែការផ្ញើមកអាជ្ញាធរសវនកម្មជាតិនៅមានកម្រិតនៅឡើយ | ពិន្ទុមិនប្រែប្រួល។ ដើម្បីទទួលបានពិន្ទុខ្ពស់ជាងនេះ គួរតែកំណត់ពេលវេលានៃការផ្ញើរបាយការណ៍សវនកម្មមកអង្គភាពទាំង ២។ |

| ល.រ | សូចនាករ | ពិន្ទុ ឆ្នាំ២០១៥ | ពិន្ទុ ឆ្នាំ២០១៧ | អំណះអំណាងសម្រាប់ពិន្ទុឆ្នាំ២០១៧ | ការប្រៀបធៀបពិន្ទុ និងការពន្យល់អំពីបម្រែបម្រួលពីការវាយតម្លៃលើកមុន |
|---|---|---|---|---|---|
| (៣) | ការអនុវត្តទៅតាមអនុសាសន៍ដែលសវនកម្មផ្ទៃក្នុងបានលើកឡើង | C | C | អនុសាសន៍របស់សវនករត្រូវបានយកទៅអនុវត្តតាម នៅក្រសួង ស្ថាប័នមួយចំនួនប៉ុណ្ណោះ ពិសេសបញ្ហាប្រឈមចំបង ប៉ុន្តែជាញឹកញាប់មានការពន្យារពេលអនុវត្ត។ | ការបញ្ជ្រាបការយល់ដឹងអំពីមុខងារ និងតួនាទី គឺមានសារៈសំខាន់ដើម្បីពង្រឹងមុខងារសវនកម្មនៅតាមក្រសួង ស្ថាប័ន។ |
| **៣.៣** | **គណនេយ្យ, ការកត់ត្រា និងរបាយការណ៍** | | | | |
| **PI-22** | **ភាពទាន់ពេលនិងភាពទៀងទាត់នៃការផ្ទៀងផ្ទាត់គណនី** | C | C | វិធីសាស្ត្រដាក់ពិន្ទុ M2 | |
| (១) | ភាពទៀងទាត់នៃការផ្ទៀងផ្ទាត់ធនាគារ | B | B | ការផ្ទៀងផ្ទាត់គណនីធនាគារដែលគ្រប់គ្រងដោយរតនាគារជាតិទាំងអស់ត្រូវបានបញ្ចប់ប្រចាំខែនៅក្នុងរយៈពេល ២ សប្តាហ៍។ ប៉ុន្តែគណនីធនាគារចំណាយមិនឆ្លងកាត់រតនាគារត្រូវបានផ្ទៀង-ផ្ទាត់ជាប្រចាំឆ្នាំ។ | គ្មានបម្រែបម្រួលទេ។ |
| (២) | ភាពទៀងទាត់នៃការផ្ទៀងផ្ទាត់និងការទូទាត់គណនីរង់ចាំនិងគណនីបុរេប្រទាន | D | D | ការផ្ទៀងផ្ទាត់និងការទូទាត់នៃគណនីបុរេប្រទានភាគច្រើនចំណាយពេលវេលាយូររហូតដល់ ២ ខែ ដោយសារភាពយឺតយ៉ាវសម្រាប់ការទូទាត់ និងដំណើរការនៃការទូទាត់ដោយសាមីក្រសួងត្រូវចំណាយពេលណាប្រមូលសាក្ខីបត្រហើយធ្វើការបោះផ្សាយអាណត្តិទូទាត់មកវិញរួចបញ្ជូនមករតនាគារជាតិ ដើម្បីទូទាត់បុរេប្រទាន។ | គ្មានបម្រែបម្រួលទេ។ |
| **PI-23** | **អត្ថិភាពនៃព័ត៌មានស្តីពីធនធានដែលទទួលបានពីអង្គភាពផ្តល់សេវា** | D | D | មិនមានការប្រមូលទិន្នន័យព័ត៌មានគ្រប់ជ្រុងជ្រោយអំពីធនធានដែលទទួលបានដោយសាលាបឋមសិក្សា និងមណ្ឌលសុខភាពនោះទេ។ | គ្មានបម្រែបម្រួលទេ។ |
| **PI-24** | **គុណភាព និងភាពទាន់ពេលនៃរបាយការណ៍ថវិកាក្នុងឆ្នាំ** | C+ | C+ | វិធីសាស្ត្រដាក់ពិន្ទុ M1 | គ្មានបម្រែបម្រួល។ |

| ល.រ | សូចនាករ | ពិន្ទុ ឆ្នាំ២០១៥ | ពិន្ទុ ឆ្នាំ២០១៧ | អំណះអំណាងសម្រាប់ពិន្ទុឆ្នាំ២០១៧ | ការប្រៀបធៀបពិន្ទុ និងការពន្យល់អំពីបម្រែបម្រួលពីការវាយតម្លៃលើកមុន |
|---|---|---|---|---|---|
| (១) | វិសាលភាពនៃរបាយការណ៍ថវិកាក្នុងឆ្នាំ ក្នុងន័យវិសាលភាពនិងសមិតភាពជាមួយនឹងការព្យាករណ៍ថវិកា | C | C | ការធ្វើចំណាត់ថ្នាក់ទិន្នន័យនៅក្នុងរបាយការណ៍នានា អាចនាំឱ្យការប្រៀបធៀប ធ្វើទៅបានជាមួយថវិកានៃគ្រប់អង្គភាពរដ្ឋបាលសំខាន់ៗ ប៉ុន្តែនៅត្រឹមតែដំណាក់កាលទូទាត់ប៉ុណ្ណោះ។ ដើម្បីទទួលបានពិន្ទុខ្ពស់ជាងនេះ គឺត្រូវបញ្ចូលតួលេខនៃធានាចំណាយបន្ថែមទៀត។ | គ្មានបម្រែបម្រួល។ |
| (២) | ភាពទាន់ពេលវេលានៃការចេញផ្សាយរបាយការណ៍ | A | A | របាយការណ៍ត្រូវបានរៀបចំប្រចាំខែ និងចេញផ្សាយនៅក្នុងរយៈពេលពី ៤ ទៅ ៨ សប្តាហ៍។ | គ្មានបម្រែបម្រួល។ |
| (៣) | គុណភាពនៃព័ត៌មាន | C | C | ចំណាយក្រោមគម្រោងហិរញ្ញប្បទានពីខាងក្រៅ ពុំមានដាក់បញ្ចូលក្នុងរបាយការណ៍ តែបញ្ហាអំពីសុក្រឹតភាព មានតិចតួចប៉ុណ្ណោះ និងមិនប៉ះពាល់ដល់គុណភាពនៃរបាយការណ៍ឡើយ។ បន្ថែមពីនេះ តួលេខពាក់គម្រោងដោយហិរញ្ញប្បទានបរទេស ត្រូវបានធ្វើឡើង ជាប្រចាំឆ្នាំ។ | គ្មានបម្រែបម្រួល។ |
| **PI-25** | **គុណភាព និងភាពទាន់ពេលវេលានៃរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ** | **D+** | **D+** | វិធីសាស្ត្រដាក់ពិន្ទុ M1 | ពិន្ទុអាចប្រៀបធៀបនឹងគ្នាបាន។ មានវឌ្ឍនភាពនៅក្នុង សមាសធាតុ (១) និង (៣) ។ |
| (១) | ភាពពេញលេញនៃរបាយការណ៍ហិរញ្ញវត្ថុ | D | D | ព័ត៌មានសំខាន់ៗ មិនមាននៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ដោយក្នុងនោះរួមមាន ទិន្នន័យស្តុលបំណុល, ទ្រព្យហិរញ្ញវត្ថុ និងសមតុល្យធនាគារ។ ច្បាប់ទូទាត់ថវិកាប្រចាំឆ្នាំ គឺបង្ហាញត្រឹមតែសេចក្តីលម្អិតចំណូល និងចំណាយលម្អិត តាមចំណាត់ថ្នាក់សេដ្ឋកិច្ចនិងចំណាត់ថ្នាក់រដ្ឋបាល។ | គ្មានបម្រែបម្រួល។ |
| (២) | ភាពទាន់ពេលវេលានៃការបញ្ជូនរបាយការណ៍ហិរញ្ញវត្ថុ | C | B | របាយការណ៍ហិរញ្ញវត្ថុសម្រាប់ឆ្នាំ២០១៤, ២០១៥ និង ២០១៦ ត្រូវបានដាក់បញ្ជូនទៅ NAA នៅក្នុងរយៈពេល ១០ ខែបន្ទាប់ពីដំណាច់ឆ្នាំ។ ដើម្បីទទួលបានពិន្ទុខ្ពស់ជាងនេះ គឺត្រូវរៀបចំ និង | ភាពទាន់ពេលវេលានៃរបាយការណ៍ហិរញ្ញវត្ថុ ដែលត្រូវបានបញ្ជូនមកលឿនជាងមុន ពី៣ ទៅ ៥ខែ។ |

| ល.រ | សូចនាករ | ពិន្ទុ ឆ្នាំ២០១៥ | ពិន្ទុ ឆ្នាំ២០១៧ | អំណះអំណាងសម្រាប់ពិន្ទុឆ្នាំ២០១៧ | ការប្រៀបធៀបពិន្ទុ និងការពន្យល់អំពីបម្រែបម្រួលពីការវាយតម្លៃលើកមុន |
|---|---|---|---|---|---|
| | | | | ផ្ញើទៅ អាជ្ញាធរសវនកម្មជាតិក្នុងរយៈពេល ៦ ខែ បន្ទាប់បញ្ចប់ការិយបរិច្ឆេទនៃការរៀបចំរបាយការណ៍។ | |
| (៣) | បទដ្ឋានគណនេយ្យដែលត្រូវបានប្រើប្រាស់ | C | C | របាយការណ៍នានាត្រូវបានរៀបចំ ដោយមានសង្គតិភាពខ្លះទៅនឹងទម្រង់នៃបទដ្ឋានគណនេយ្យ។ | គ្មានការប្រែប្រួល។ វឌ្ឍនភាពឆ្នាំ២០១៧ ថ្មី គឺបង្ហាញថាប្លង់គណនេយ្យត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត។ |
| **៣.៤** | **ការត្រួតពិនិត្យ និងសវនកម្មខាងក្រៅ** | | | | |
| **PI-26** | **វិសាលភាព ចរិតលក្ខណៈ និង ការតាមដានបន្តនៃសវនកម្មពីខាងក្រៅ** | **NR** | **D+** | វិធីសាស្ត្រវាយតម្លៃ M1 | មិនអាចប្រៀបធៀប។ |
| (១) | វិសាលភាព/ចរិតលក្ខណៈរបស់សវនកម្មដែលត្រូវបានធ្វើឡើង (រួមទាំងការគោរពទៅតាមបទដ្ឋានសវនកម្ម) | NR | D | ការធ្វើសវនកម្មលើចំណាយសរុបមានប្រមាណជាង តិចជាង ៥០% នៃចំណាយសរុប។ ឆ្នាំ២០១៧ អាជ្ញាធរសវនកម្មជាតិ បានសវនកម្មលើការិយបរិច្ឆេទឆ្នាំ២០១៦ លើក្រសួង ស្ថាប័នចំនួន ៨ រួមមាន ក្រសួងសុខាភិបាល, ក្រសួងព័ត៌មាន, ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់, រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល និងក្រសួងមុខងារសាធារណៈ ព្រមទាំងរដ្ឋបាលខេត្តចំនួន ១៧ និងគ្រឹះស្ថានសាធារណៈរដ្ឋបាលចំនួន ៦។ | ការធ្វើសនកម្មកម្មគឺផ្តោតលើហានិភ័យ។ |
| (២) | ភាពទាន់ពេលវេលានៃការបញ្ជូនរបាយការណ៍សវនកម្មទៅកាន់សភា | A | A | របាយការណ៍សវនកម្ម ត្រូវបានបញ្ជូនទៅរដ្ឋសភាក្នុងអំឡុងពេល ០៤ ខែ បន្ទាប់ពីទទួលបានរបាយការណ៍ទូទាត់ថវិកា | គ្មានការប្រែប្រួល។ |

| ល.រ | សូចនាករ | ពិន្ទុ ឆ្នាំ២០១៥ | ពិន្ទុ ឆ្នាំ២០១៧ | អំណះអំណាងសម្រាប់ពិន្ទុឆ្នាំ២០១៧ | ការប្រៀបធៀបពិន្ទុ និងការពន្យល់អំពីបម្រែបម្រួលពីការវាយតម្លៃលើកមុន |
|---|---|---|---|---|---|
| (៣) | ភស្តុតាងនៃការតាមដានបន្តទៅលើអនុសាសន៍សវនកម្ម | C | C | របាយការណ៍សវនកម្មលើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ការិយបរិច្ឆេទឆ្នាំ២០១៦ បានបញ្ជាក់ថា អនុសាសន៍កែលម្អចំណុចកង្វះខាត ដែលអាជ្ញាធរសវនកម្មជាតិផ្តល់ជូន អង្គភាពរងសវនកម្មបានយកចិត្តទុកដាក់កែលម្អ ប៉ុន្តែមិនបញ្ជាក់ជាភាគរយការសម្រេចបាននូវអនុសាសន៍ដែលបានលើកឡើងនោះទេ។ | គ្មានការប្រែប្រួល។ |
| PI-27 | **ការត្រួតពិនិត្យលើច្បាប់ថវិកាប្រចាំឆ្នាំដោយអង្គនីតិប្បញ្ញត្តិ** | C+ | C+ | វិធីសាស្ត្រវាយតម្លៃដាក់ពិន្ទុ M1 | មានការប្រែប្រួលសម្រាប់សមាសធាតុទី៣។ |
| (១) | វិសាលភាពនៃការត្រួតពិនិត្យរបស់អង្គនីតិប្បញ្ញត្តិ | C | C | អង្គនីតិប្បញ្ញត្តិត្រួតពិនិត្យលើសេចក្តីលម្អិតនៃចំណូល-ចំណាយ នៅដំណាក់កាលដែលសេចក្តីព្រាងចំណូល-ចំណាយលម្អិត ត្រូវបានរៀបចំបញ្ចប់ដោយរាជរដ្ឋាភិបាលរួចទៅហើយ។ ដើម្បីទទួលបានពិន្ទុខ្ពស់ជាង អង្គនីតិប្រតិបត្តិ អនុវត្តយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ២០១៨-២០២៥ ដោយធ្វើរៀបចំក្របខណ្ឌហិរញ្ញវត្ថុរយៈពេលមធ្យម រួចបញ្ជូនទៅអង្គនីប្បញ្ញត្តិ ដើម្បីធ្វើការពិនិត្យ។ | គ្មានការប្រែប្រួល។ |
| (២) | កម្រិតនៃការរៀបចំនីតិវិធីបានល្អ និងការអនុវត្តនីតិវិធីបានត្រឹមត្រូវក្នុងអង្គនីតិប្បញ្ញត្តិ | B | B | មាននីតិវិធីសាមញ្ញសម្រាប់ការពិនិត្យនិងអនុម័តដោយអង្គនីតិប្បញ្ញត្តិ អនុលោមតាមច្បាប់ប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ។ ដើម្បីទទួលបានពិន្ទុខ្ពស់ជាងនេះ គឺត្រូវរៀបចំនីតិវិធីត្រួតពិនិត្យផ្ទៃក្នុងលម្អិត។ | គ្មានការប្រែប្រួល។ |
| (៣) | ពេលវេលាគ្រប់គ្រាន់សម្រាប់អង្គនីតិប្បញ្ញត្តិ ក្នុងការឆ្លើយតបទៅនឹងសំណើថវិកា | C | B | រយៈពេលសម្រាប់ការពិនិត្យ និងអនុម័តដោយ អង្គនីតិប្បញ្ញត្តិមានប្រមាណ ៧ សប្តាហ៍។ ក្នុងការអនុវត្តជាក់ស្តែង អង្គនីតិប្បញ្ញត្តិ ត្រូវការពេលវេលាតិចជាងនេះសម្រាប់ពិនិត្យនិងអនុម័តសេចក្តីព្រាងច្បាប់ថវិកា។ | សមាសធាតុទី៣ នេះ មានលក្ខខណ្ឌវិនិច្ឆ័យទទួលបានពិន្ទុ B និង C ដូចគ្នា ពោលគឺ អង្គនីតិប្បញ្ញត្តិ មានរយៈពេល យ៉ាងតិចមួយខែដើម្បីពិនិត្យសេចក្តីព្រាងច្បាប់សម្រាប់គ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ ការផ្តល់ពិន្ទុ B គឺមានភាពប្រសើរជាង។ |

| ល.រ | សូចនាករ | ពិន្ទុ ឆ្នាំ២០១៥ | ពិន្ទុ ឆ្នាំ២០១៧ | អំណះអំណាងសម្រាប់ពិន្ទុឆ្នាំ២០១៧ | ការប្រៀបធៀបពិន្ទុ និងការពន្យល់អំពីបម្រែបម្រួលពីការវាយតម្លៃលើកមុន |
|---|---|---|---|---|---|
| (៤) | វិធានស្តីពីការកែតម្រូវថវិកាក្នុងឆ្នាំ ដោយពុំចាំបាច់មានការយល់ព្រមជាមុនឬក្រោយពីអង្គនីតិបញ្ញត្តិ | B | B | បទប្បញ្ញត្តិសម្រាប់ការកែសម្រួលឥណទានថវិកានៅក្នុងឆ្នាំអនុវត្តថវិកាដោយពុំចាំបាច់មានការអនុម័តជាមុនពីអង្គនីតិបញ្ញត្តិ ត្រូវបានចែងនិងអនុវត្តតាមច្បាស់លាស់, ព្រមទាំងពុំអនុញ្ញាតឱ្យមានការបង្កើនចំណាយនៅក្នុងឆ្នាំឡើយ ទោះបីជាការប្រមូលចំណូល ) (ទទួលបានលើសពីការចែងក្នុងច្បាប់ក៏ដោយ។ *ជំពូក ៤ ស្តីពីការអនុវត្តថវិកា ត្រង់មាត្រា ៥៥ និងនិងមាត្រា ៦១ នៃច្បាប់ប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ។*<br>ដើម្បីទទួលបានពិន្ទុខ្ពស់ជាងនេះ គឺត្រូវកំណត់កម្រិតនៃពិដាននិងប្រកាន់ខ្ជាប់នូវបទប្បញ្ញត្តិជាធរមាន។ | គ្មានការប្រែប្រួល។ |
| **PI-28** | **ការត្រួតពិនិត្យលើរបាយការណ៍សវនកម្មពីខាងក្រៅ ដោយអង្គនីតិបញ្ញត្តិ** | **B** | **B** | វិធីសាស្ត្រវាយតម្លៃ M1 | គ្មានការប្រែប្រួល។ |
| (១) | ភាពទាន់ពេលវេលានៃការពិនិត្យលើរបាយការណ៍សវនកម្ម ដោយអង្គនីតិបញ្ញត្តិ | B | B | របាយការណ៍សវនកម្មត្រូវបានពិនិត្យ ហើយការត្រួតពិនិត្យដោយអង្គនីតិបញ្ញត្តិ ត្រូវបានបញ្ចប់ក្នុងរយៈពេល ៣ ខែជាមធ្យម ក្នុងអំឡុងពេលពីរឆ្នាំចុងក្រោយនេះ។ | គ្មានការប្រែប្រួល។ |
| (២) | ការរៀបចំសវនាការដោយអង្គនីតិ-បញ្ញត្តិ លើរបកគំហើញគន្លឹះ | B | B | សវនាការលម្អិតត្រូវបានរៀបចំ ដោយមាន ការចូលរួមពីមន្ត្រីពាក់ព័ន្ធនៃអង្គភាពរងសវនកម្ម ប៉ុន្តែពុំត្រូវបានរៀបចំសម្រាប់គ្រប់ស្ថាប័នរងសវនកម្មឡើយ។ | គ្មានការប្រែប្រួល។ |
| (៣) | អនុសាសន៍របស់អង្គនីតិបញ្ញត្តិ និងការអនុវត្តសកម្មភាពអនុលោមតាមអនុសាសន៍ដោយអង្គនីតិប្រតិបត្តិ | B | B | អង្គនីតិបញ្ញត្តិបានផ្តល់អនុសាសន៍ដល់អង្គនីតិប្រតិបត្តិ ហើយអនុសាសន៍មួយចំនួនត្រូវបានអនុវត្តតាម។ | គ្មានការប្រែប្រួល។ |

# បម្រែបម្រួល នៃសមាសភាគថវិកាក្នុងឆ្នាំ២០១៤ (ឯកតា:រៀល)

| ល.រ | ក្រសួង ស្ថាប័ន | ច្បាប់ថវិកា | អនុវត្តថវិកា | ថវិកាកែតម្រូវ | គម្លាត | គម្លាតតម្លៃដាច់ខាត | ភាគរយ |
|---|---|---|---|---|---|---|---|
| | | 1 | 2 | 3 | 4=2-3 | 5=abs(4) | 6=5/3 |
| 1 | អប់រំ យុវជន និងកីឡា | 1,342,650,000,000 | 1,296,023,591,621 | 1,234,879,065,332 | (61,144,526,289) | 61,144,526,289 | 5% |
| 2 | ការពារជាតិ | 1,130,572,400,000 | 1,154,093,899,129 | 1,039,824,368,675 | (114,269,530,454) | 114,269,530,454 | 11% |
| 3 | សុខាភិបាល | 979,149,900,000 | 823,701,290,433 | 900,556,148,908 | 76,854,858,475 | 76,854,858,475 | 9% |
| 4 | មហាផ្ទៃ (សន្តិសុខសាធារណៈ) | 753,298,300,000 | 773,933,193,524 | 692,833,054,497 | (81,100,139,027) | 81,100,139,027 | 12% |
| 5 | សង្គមកិច្ច អតីតយុទ្ធជននិងយុវនីតិសម្បទា | 564,258,000,000 | 514,939,621,345 | 518,966,515,209 | 4,026,893,864 | 4,026,893,864 | 1% |
| 6 | សាធារណៈការ និងដឹកជញ្ជូន | 560,921,300,000 | 393,309,708,850 | 515,897,643,219 | 122,587,934,369 | 122,587,934,369 | 24% |
| 7 | ទីស្តីការគណៈរដ្ឋមន្ត្រី | 350,203,100,000 | 247,697,359,941 | 322,093,231,150 | 74,395,871,209 | 74,395,871,209 | 23% |
| 8 | កសហវ | 289,005,000,000 | 367,145,038,954 | 265,807,339,423 | (101,337,699,531) | 101,337,699,531 | 38% |
| 9 | អភិវឌ្ឍន៍ជនបទ | 227,887,000,000 | 302,112,507,456 | 209,595,118,282 | (92,517,389,174) | 92,517,389,174 | 44% |
| 10 | រ៉ែ និងថាមពល | 202,156,300,000 | 9,469,710,799 | 185,929,752,947 | 176,460,042,148 | 176,460,042,148 | 95% |
| 11 | ធនធានទឹក និងឧតុនិយម | 181,512,400,000 | 184,844,773,549 | 166,942,883,743 | (17,901,889,806) | 17,901,889,806 | 11% |
| 12 | កសិកម្ម រុក្ខាប្រមាញ់ និង នេសាទ | 159,457,400,000 | 162,521,675,965 | 146,658,179,773 | (15,863,496,192) | 15,863,496,192 | 11% |

| ល.រ | ក្រសួង ស្ថាប័ន | ច្បាប់ថវិកា | អនុវត្តថវិកា | ថវិកាកែតម្រូវ | គម្លាត | គម្លាតតម្លៃដាច់ខាត | ភាគរយ |
|---|---|---|---|---|---|---|---|
| 13 | រដ្ឋសភា | 116,538,000,000 | 116,498,158,727 | 107,183,805,545 | (9,314,353,182) | 9,314,353,182 | 9% |
| 14 | រៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | 96,334,600,000 | 76,978,594,599 | 88,602,078,581 | 11,623,483,982 | 11,623,483,982 | 13% |
| 15 | ពាណិជ្ជកម្ម | 96,258,100,000 | 104,321,142,698 | 88,531,719,032 | (15,789,423,666) | 15,789,423,666 | 18% |
| 16 | ក្រសួង ស្ថាប័ន ២៣ ផ្សេងទៀត | 916,609,700,000 | 881,083,113,400 | 843,035,883,968 | (38,047,229,432) | 38,047,229,432 | 5% |
| | ចំណាយគ្រោងទុកមានមុខសញ្ញា | 1,586,476,000,000 | 1,246,318,849,351 | 1,459,133,802,593 | 212,814,953,242 | 212,814,953,242 | 15% |
| | រដ្ឋបាលរាជធានី ខេត្ត | 375,326,000,000.00 | 476,677,943,508 | 345,199,582,970 | (131,478,360,538) | 131,478,360,538 | 38% |
| | ចំណាយដែលត្រូវបានវិភាជន៍ | 9,928,613,500,000.00 | 9,131,670,173,849 | 9,131,670,173,849 | - | 1,357,528,074,581 | 15% |
| | ចំណាយមិនបានគ្រោងទុក | 20,538,500,000.00 | 630,511,300,000 | | | | |
| | ចំណាយគោលសរុប | 9,949,152,000,000.00 | 9,762,181,473,849 | | | | |
| | បម្រែបម្រួល (PI-1) | | | | | | 98.1% |
| | បម្រែបម្រួលសមាសធាតុ (PI-2) | | | | | | 14.9% |
| | ចំណាយមិនបានគ្រោងទុករួមចំណែកក្នុងថវិកា | | | | | | 6.3% |

## បម្រែបម្រួល នៃសមាសភាគថវិកាក្នុងឆ្នាំ២០១៥ (ឯកតា៖រៀល)

| ល.រ | ក្រសួង ស្ថាប័ន | ច្បាប់ថវិកា | អនុវត្តថវិកា | ថវិកាកែតម្រូវ | គម្លាត | គម្លាតតម្លៃដាច់ខាត | ភាគរយ |
|---|---|---|---|---|---|---|---|
| | | 1 | 2 | 3 | 4=2-3 | 5=abs(4) | 6=5/3 |
| 1 | អប់រំ យុវជន និងកីឡា | 1,623,954,608,000 | 1,519,484,723,769 | 1,588,639,303,539 | 69,154,579,770 | 69,154,579,770 | 4% |
| 2 | ការពារជាតិ | 1,323,398,400,000 | 1,324,342,734,689 | 1,294,619,136,596 | (29,723,598,093) | 29,723,598,093 | 2% |
| 3 | សុខាភិបាល | 1,026,091,000,000 | 956,819,649,151 | 1,003,777,127,499 | 46,957,478,348 | 46,957,478,348 | 5% |
| 4 | មហាផ្ទៃ (សន្តិសុខសាធារណៈ) | 878,995,000,000 | 862,363,626,455 | 859,879,948,451 | (2,483,678,004) | 2,483,678,004 | 0% |
| 5 | សាធារណៈការ និងដឹកជញ្ជូន | 809,037,800,000 | 818,653,317,567 | 791,444,071,649 | (27,209,245,918) | 27,209,245,918 | 3% |
| 6 | សង្គមកិច្ច អតីតយុទ្ធជននិងយុវនីតិសម្បទា | 646,987,497,000 | 597,385,171,793 | 632,917,793,126 | 35,532,621,333 | 35,532,621,333 | 6% |
| 7 | កសហវ | 427,637,600,000 | 378,818,490,191 | 418,337,985,363 | 39,519,495,172 | 39,519,495,172 | 9% |
| 8 | ទីស្តីការគណៈរដ្ឋមន្ត្រី | 419,364,000,000 | 264,896,868,196 | 410,244,307,081 | 145,347,438,885 | 145,347,438,885 | 35% |
| 9 | អភិវឌ្ឍន៍ជនបទ | 330,342,100,000 | 319,748,689,426 | 323,158,320,490 | 3,409,631,064 | 3,409,631,064 | 1% |
| 10 | ធនធានទឹក និងឧត្តុនិយម | 202,873,400,000 | 189,730,322,141 | 198,461,616,658 | 8,731,294,517 | 8,731,294,517 | 4% |
| 11 | កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | 170,696,500,000 | 169,403,103,726 | 166,984,451,130 | (2,418,652,596) | 2,418,652,596 | 1% |
| 12 | រដ្ឋសភា | 132,528,400,000 | 127,782,010,155 | 129,646,373,142 | 1,864,362,987 | 1,864,362,987 | 1% |

| ល.រ | ក្រសួង ស្ថាប័ន | ច្បាប់ថវិកា | អនុវត្តថវិកា | ថវិកាកែតម្រូវ | គម្លាត | គម្លាតតម្លៃដាច់ខាត | ភាគរយ |
|---|---|---|---|---|---|---|---|
| 13 | ពាណិជ្ជកម្ម | 116,978,800,000 | 114,091,316,012 | 114,434,922,285 | 343,606,273 | 343,606,273 | 0% |
| 14 | ការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ | 116,855,709,000 | 115,766,526,442 | 114,314,508,082 | (1,452,018,360) | 1,452,018,360 | 1% |
| 15 | រៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | 109,734,273,000 | 89,929,569,644 | 107,347,938,282 | 17,418,368,638 | 17,418,368,638 | 16% |
| 16 | ក្រសួង ស្ថាប័ន ២៣ ផ្សេងទៀត | 989,648,525,000 | 932,441,302,305 | 968,127,148,234 | 35,685,845,929 | 35,685,845,929 | 4% |
| | ចំណាយគ្រោងទុកមានមុខសញ្ញា | 1,287,483,000,000 | 1,413,521,299,856 | 1,259,484,770,302 | (154,036,529,554) | 154,036,529,554 | 12% |
| | រដ្ឋបាលរាជធានី ខេត្ត | 442,896,000,000 | 619,905,569,188 | 433,264,568,796 | (186,641,000,392) | 186,641,000,392 | 43% |
| | ចំណាយដែលត្រូវបានវិភាជន៍ | 11,055,502,612,000.00 | 10,815,084,290,706.00 | 10,815,084,290,706 | - | 807,929,445,833 | 7% |
| | ចំណាយមិនបានគ្រោងទុក | 22,673,388,000 | 189,661,100,000 | | | | |
| | ចំណាយគោលសរុប | 11,078,176,000,000.00 | 11,004,745,390,706.00 | | | | |
| | បម្រែបម្រួល (PI-1) | | | | | | 99.3% |
| | បម្រែបម្រួលសមាសធាតុ (PI-2) | | | | | | 7.5% |
| | ចំណាយមិនបានគ្រោងទុករួមចំណែកក្នុងថវិកា | | | | | | 1.7% |

## បម្រែបម្រួល នៃសមាសភាគថវិកាក្នុងឆ្នាំ២០១៦ (ឯកតា:រៀល)

| ល.រ | ក្រសួង ស្ថាប័ន | ច្បាប់ថវិកា | អនុវត្តថវិកា | ថវិកាកែតម្រូវ | គម្លាត | គម្លាតតម្លៃដាច់ខាត | ភាគរយ |
|---|---|---|---|---|---|---|---|
| | | 1 | 2 | 3 | 4=2-3 | 5=abs(4) | 6=5/3 |
| 1 | អប់រំ យុវជន និងកីឡា | 2,072,620,900,000 | 1,880,270,455,782 | 1,955,206,046,836 | 74,935,591,054 | 74,935,591,054 | 4% |
| 2 | ការពារជាតិ | 1,567,580,000,000 | 1,603,166,045,445 | 1,478,775,928,053 | (124,390,117,392) | 124,390,117,392 | 8% |
| 3 | មហាផ្ទៃ (សន្តិសុខសាធារណ:) | 1,091,058,000,000 | 1,098,131,387,254 | 1,029,249,101,487 | (68,882,285,767) | 68,882,285,767 | 7% |
| 4 | សុខាភិបាល | 1,111,789,900,000 | 1,049,133,001,895 | 1,048,806,530,558 | (326,471,337) | 326,471,337 | 0% |
| 5 | សាធារណ:ការ និងដឹកជញ្ជូន | 996,794,100,000 | 957,386,734,489 | 940,325,291,408 | (17,061,443,081) | 17,061,443,081 | 2% |
| 6 | សង្គមកិច្ច អតីតយុទ្ធជននិងយុវនីតិសម្បទា | 718,810,900,000 | 682,033,951,215 | 678,089,957,605 | (3,943,993,610) | 3,943,993,610 | 1% |
| 7 | កសហវ | 594,043,000,000 | 560,566,932,377 | 560,390,212,065 | (176,720,312) | 176,720,312 | 0% |
| 8 | ទីស្តីការគណ:រដ្ឋមន្ត្រី | 507,814,700,000 | 357,481,024,918 | 479,046,781,837 | 121,565,756,919 | 121,565,756,919 | 25% |
| 9 | អភិវឌ្ឍន៍ជនបទ | 321,124,500,000 | 302,082,726,343 | 302,932,660,858 | 849,934,515 | 849,934,515 | 0% |
| 10 | ធនធានទឹក និងឧត្តុនិយម | 239,947,100,000 | 235,639,674,133 | 226,353,995,003 | (9,285,679,130) | 9,285,679,130 | 4% |
| 11 | កសិកម្ម រុក្ខាប្រមាញ់ និង នេសាទ | 211,024,800,000 | 197,355,685,658 | 199,070,155,566 | 1,714,469,908 | 1,714,469,908 | 1% |

| ល.រ | ក្រសួង ស្ថាប័ន | ច្បាប់ថវិកា | អនុវត្តថវិកា | ថវិកាកែតម្រូវ | គម្លាត | គម្លាតតម្លៃដាច់ខាត | ភាគរយ |
|---|---|---|---|---|---|---|---|
| 12 | ការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ | 171,745,800,000 | 166,560,221,813 | 162,016,327,578 | (4,543,894,235) | 4,543,894,235 | 3% |
| 13 | មហាផ្ទៃ (រដ្ឋបាលទូទៅ) | 142,466,500,000 | 143,822,592,385 | 134,395,712,343 | (9,426,880,042) | 9,426,880,042 | 7% |
| 14 | រដ្ឋសភា | 141,066,500,000 | 141,590,141,843 | 133,075,022,936 | (8,515,118,907) | 8,515,118,907 | 6% |
| 15 | រៀបចំដែនដី នគរូបនីយកម្ម និង សំណង់ | 139,900,400,000 | 126,959,357,227 | 131,974,982,996 | 5,015,625,769 | 5,015,625,769 | 4% |
| 16 | ក្រសួង ស្ថាប័ន ២៣ ផ្សេងទៀត | 1,280,732,600,000 | 1,159,010,186,047 | 1,208,178,554,940 | 49,168,368,893 | 49,168,368,893 | 4% |
| | ចំណាយគ្រោងទុកមានមុខសញ្ញា | 1,476,873,000,000 | 1,323,992,961,645 | 1,393,207,518,080 | 69,214,556,435 | 69,214,556,435 | 5% |
| | រដ្ឋបាលរាជធានី ខេត្ត | 513,283,000,000 | 560,117,000,000 | 484,205,300,322 | (75,911,699,678) | 75,911,699,678 | 16% |
| | ចំណាយដែលត្រូវបានវិភាជន៍ | 13,298,675,700,000 | 12,545,300,080,469 | 12,545,300,080,469 | - | 644,928,606,985 | |
| | ចំណាយមិនបានគ្រោងទុក | 42,117,300,000 | 313,099,700,000 | | | | |
| | ចំណាយគោលសរុប (Primary Expenditure) | 13,340,793,000,000 | 12,858,399,780,469 | | | | |
| | បម្រែបម្រួល (PI-1) | | | | | | 96.4% |
| | បម្រែបម្រួលសមាសធាតុ (PI-2) | | | | | | 5.14% |
| | ចំណាយមិនបានគ្រោងទុករួម ចំណែកក្នុងថវិកា | | | | | | 2.35% |

## លទ្ធផលនៃការអនុវត្តចំណូលឆ្នាំ២០១៤-២០១៧ (ឯកតា: លានរៀល)

| ប្រភេទចំណាយ | ២០១៤ | | | ២០១៥ | | | ២០១៦ | | | ២០១៧ (បណ្តោះអាសន្ន) | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | ច្បាប់ថវិកា | អនុវត្ត | % នៃ ច្បាប់ ថវិកា | ច្បាប់ថវិកា | អនុវត្ត | % នៃ ច្បាប់ថវិកា | ច្បាប់ថវិកា | អនុវត្ត | % នៃ ច្បាប់ ថវិកា | ច្បាប់ថវិកា | អនុវត្ត | % នៃ ច្បាប់ ថវិកា |
| **ចំណូលចរន្ត** | 10,283,195 | 11,456,025 | 111.41% | 11,675,343 | 13,048,078 | 111.76% | 14,216,157 | 15,073,351 | 106.03% | 16,457,998 | 17,538,582 | 106.57% |
| + ថ្នាក់ជាតិ | 9,712,627 | 10,829,697 | 111.50% | 11,014,644 | 12,245,639 | 111.18% | 13,407,263 | 14,277,623 | 106.49% | 15,501,469 | 16,615,189 | 107.18% |
| ចំណូលសារពើពន្ធ | 8,308,621 | 9,336,508 | 112.37% | 9,548,391 | 10,839,849 | 113.53% | 11,555,055 | 12,197,748 | 105.56% | 13,209,100 | 14,310,865 | 108.34% |
| ចំណូលមិនមែនសារពើពន្ធ | 1,404,006 | 1,493,189 | 106.35% | 1,466,253 | 1,405,791 | 95.88% | 1,852,208 | 2,079,875 | 112.29% | 2,292,369 | 2,304,324 | 100.52% |
| + ថ្នាក់ក្រោមជាតិ | 570,568 | 626,328 | 109.77% | 660,699 | 802,439 | 121.45% | 808,894 | 795,728 | 98.37% | 956,529 | 923,393 | 96.54% |
| រដ្ឋបាលរាជធានី ខេត្ត | 570,568 | 626,328 | 109.77% | 660,699 | 802,439 | 121.45% | 808,894 | 795,728 | 98.37% | 956,529 | 923,393 | 96.54% |
| **ចំណូលមូលធន** | 233,000 | 183,996 | 78.97% | 133,586 | 121,383 | 90.87% | 130,864 | 119,900 | 91.62% | 148,431 | 128,972 | 86.89% |
| មូលធនក្នុងស្រុក | 233,000 | 183,996 | 78.97% | 133,586 | 121,383 | 90.87% | 130,864 | 119,900 | 91.62% | 148,431 | 128,972 | 86.89% |
| **ចំណូលក្នុងស្រុកសរុប** | **10,516,195** | **11,640,021** | **110.69%** | **11,808,929** | **13,169,461** | **111.52%** | **14,347,021** | **15,193,250** | **105.90%** | **16,606,429** | **17,667,554** | **106.39%** |
| **ផ.ស.ស. ថ្លៃបច្ចុប្បន្ន** | | **67,740,450** | | | **73,422,702** | | | **81,241,866** | | | **89,509,422** | |
| **ចំណូលចរន្ត/ផ.ស.ស.** | | **16.91%** | | | **17.77%** | | | **18.55%** | | | **19.59%** | |
| **កំណើនចំណូលចរន្ត** | | **1.86%** | | | **0.86%** | | | **0.78%** | | | **1.04%** | |

# ការវិភាគបំណុលកកស្ទះ

| | ២០១៤ | ២០១៥ | ២០១៦ |
|---|---|---|---|
| ចំណាយសរុប (ឯកតា÷ពាន់លានរៀល) | 9,762 | 11,005 | 12,858 |
| សន្និធិនៃអាណត្តិទូទាត់លើសពី៦០ថ្ងៃ នៅចុងឆ្នាំ | - | - | - |
| បៀវត្សមិនទាន់ទូទាត់នៅចុងឆ្នាំ | - | - | - |
| បំណុលកកស្ទះលើសេវាបំណុល | 1,143 | 1,143 | 1,143 |
| បំណុលកកស្ទះសរុប (ពាន់លានរៀល) | 1,143 | 1,143 | 1,143 |
| **ភាគរយនៃចំណាយសរុប** | **12%** | **10%** | **9%** |

## ឧបសម្ព័ន្ធទី៤ ÷ តារាងតាមដានការអនុវត្តអនុសាសន៍ គ.ហ.ស.

| ល.រ | អនុសាសន៍ ដែលបានលើកឡើង | កាលបរិច្ឆេទ | អង្គភាពទទួលបន្ទុក | លទ្ធផលសម្រេចបាន |
|---|---|---|---|---|
| ១ | រៀបចំមូលនិធិកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ | គ.ម.ទី៤ ឆ្នាំ២០១៦ | អ.គ.ហ. | (១). សម្តេចតេជោបានឯកភាព និងដាក់ឱ្យអនុវត្តសេចក្តីសម្រេចស្តីពីការប្រើប្រាស់ចំណូលមិនមែនសារពើពន្ធរបស់ក្រសួង ស្ថាប័នប្រមូលចំណូលសម្រាប់ការផ្តល់ការលើកទឹកចិត្តលើការងារកែទម្រង់ PFM<br>(២). អ.គ.ហ. បានដឹកនាំកិច្ចប្រជុំអន្តរអគ្គនាយកដ្ឋានដើម្បីរៀបចំសារាចរ និងប្រកាសអនុវត្តមូលនិធិនេះ<br>(៣). អ.គ.ហ. បានរៀបចំកិច្ចប្រជុំជាមួយក្រសួង ស្ថាប័នប្រមូលចំណូលទាំង ២២ ដើម្បីអនុវត្តមូលនិធិនេះ |
| ២ | ត្រួតពិនិត្យនិងកែលម្អលើប្រព័ន្ធវាយតម្លៃការអនុវត្តផែនការសកម្មភាពរួមដំណាក់កាលទី៣ សម្រាប់ឆ្នាំ២០១៧ | គ.ម.ទី៤ ឆ្នាំ២០១៦ | អ.គ.ហ. | បាននិងកំពុងរៀបចំ (១).ទម្រង់តាមចង្កោមសកម្មភាព គោលបំណង និងផ្នែកនៃ CAP3 និង (២).ប្រព័ន្ធត្រួតពិនិត្យតាមដាននិងវាយតម្លៃសម្រាប់កម្មវិធីទាំងមូល (Online) |

| ល.រ | អនុសាសន៍ ដែលបានលើកឡើង | កាលបរិច្ឆេទ | អង្គភាពទទួលបន្ទុក | លទ្ធផលសម្រេចបាន |
|---|---|---|---|---|
| ៣ | បញ្ចប់ការរៀបចំផែនការយុទ្ធ-សាស្ត្រស្តីពីការកសាង និងអភិវឌ្ឍន៍សមត្ថភាពក្នុងក្របខ័ណ្ឌកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ | ត.ម.ទី៤ ឆ្នាំ២០១៦ | វ.ស.ហ. | ឯកឧត្តមបណ្ឌិតសភាចារ្យទេសរដ្ឋមន្ត្រី កសហវ ឯកភាពលើយុទ្ធសាស្ត្រនេះ នៅថ្ងៃទី០៥ ខែមករា ឆ្នាំ២០១៨ |
| ៤ | ស្នើឯកឧត្តម ចាន់ សុធី និងឯកឧត្តម ផាន់ ផល្លា សិក្សាអំពីទម្រង់សំណើថវិកាសង្ខេបថវិកាជាតិប្រចាំឆ្នាំសម្រាប់ធ្វើការផ្សព្វផ្សាយជាសាធារណៈ បន្ទាប់ពីគណៈរដ្ឋមន្ត្រីអនុម័តសំណើកញ្ចប់ថវិកា | ត.ម.ទី៤ ឆ្នាំ២០១៦ | អ.ថ. និង អ.គ.ប. | បានរៀបចំ និងផ្សព្វផ្សាយសំណើថវិកាសង្ខេបជាតិប្រចាំឆ្នាំ២០១៨ លើគេហទំព័ររបស់ កសហវ នៅថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៧ ។ តំណភ្ជាប់÷ http://mef.gov.kh/documents/mustsee/Executive-summary.pdf |
| ៥ | បញ្ចប់ការរៀបចំយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ ២០១៨-២០២៥ | ត.ម.ទី៤ ឆ្នាំ២០១៥ | អ.ថ. | គណៈរដ្ឋមន្ត្រី បានអនុម័តយុទ្ធសាស្ត្រនេះ នៅថ្ងៃទី១២ ខែមករា ឆ្នាំ២០១៨ |

| ល.រ | អនុសាសន៍ ដែលបានលើកឡើង | កាលបរិច្ឆេទ | អង្គភាពទទួលបន្ទុក | លទ្ធផលសម្រេចបាន |
|---|---|---|---|---|
| ៦ | រៀបចំមគ្គុទេសក៍គ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់រាជរដ្ឋាភិបាល | គ.ម.ទី៤ ឆ្នាំ២០១៥ | អ.គ.ហ. | បាននិងកំពុងជ្រើសរើសទីប្រឹក្សាជាតិ |
| ៧ | បញ្ចប់សេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រង ការប្រើប្រាស់ និងការចាត់ចែងទ្រព្យសម្បត្តិរដ្ឋ | គ.ម.ទី៣ ឆ្នាំ២០១៧ | អ.ទ.ច. | បានរៀបចំសេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រង ការប្រើប្រាស់ និងការចាត់ចែងទ្រព្យសម្បត្តិរដ្ឋ |
| ៨ | បញ្ចប់ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ IPSAS-Cash Basis ដែលត្រូវផលិតចេញពីប្រព័ន្ធ | គ.ម.ទី៣ ឆ្នាំ២០១៧ | អគ្គ.រតនាគារជាតិ | បានបញ្ចប់រៀបចំរបាយការណ៍ហិរញ្ញវត្ថុស្របតាមស្តង់ដារ IPSAS-Cash Basis និងកំពុងពិនិត្យលើគុណភាពនៃរបាយការណ៍ |
| ៩ | រៀបចំយុទ្ធសាស្ត្រនៃការកែ-ទម្រង់ប្រព័ន្ធលទ្ធកម្មសាធារណៈឆ្នាំ២០១៩-២០២៥ | គ.ម.ទី៣ ឆ្នាំ២០១៧ | អគ្គ.លទ្ធកម្ម | -បានបង្កើតក្រុមការងារ<br>-បានរៀបចំមាតិកាឯកសារយុទ្ធសាស្ត្រនេះ |

| ល.រ | អនុសាសន៍ ដែលបានលើកឡើង | កាលបរិច្ឆេទ | អង្គភាពទទួលបន្ទុក | លទ្ធផលសម្រេចបាន |
|---|---|---|---|---|
| ១០ | រៀបចំលិខិតបទដ្ឋានគតិយុត្តិពាក់ព័ន្ធនឹងអនុក្រឹត្យ និង ប្រកាសពាក់ព័ន្ធលទ្ធកម្មសាធារណៈ | ត.ម.ទី១ ឆ្នាំ ២០១៧ | អគ្គ.លទ្ធកម្ម | នៅសល់អនុក្រឹត្យមួយ និងប្រកាសចំនួន៣ |
| ១១ | បញ្ចប់ការរៀបចំអនុក្រឹត្យស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ | ត.ម.ទី១ ឆ្នាំ ២០១៧ | អ.ទ.ច. | បញ្ចប់កិច្ចប្រជុំកម្រិតអន្តរក្រសួង ស្ថាប័ន នៅថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១៨ |

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

លេខ.......................................សហវ.........

ទីស្តីការគណៈកម្មាធិការ ក.ស.ផ.ស.

ចូលថ្ងៃទី 19/3/18 ម៉ោង..........

លេខ........KM18.026.LL..........

# របាយការណ៍

# ស្តីពី

# លទ្ធផលនៃកិច្ចប្រជុំគណៈកម្មការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ស្តីពីរបាយការណ៍ត្រួតពិនិត្យវឌ្ឍនភាពនៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ប្រចាំត្រីមាសទី៤ និងប្រចាំឆ្នាំ២០១៧

នៅថ្ងៃចន្ទ ០៤រោច ខែផល្គុន ឆ្នាំរកា នព្វស័ក ព.ស.២៥៦១ ត្រូវនឹងថ្ងៃទី០៥ ខែមីនា ឆ្នាំ ២០១៨ វេលាម៉ោង ០៩:០០ នាទីព្រឹក នៅទីស្តីការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានរៀបចំកិច្ចប្រជុំគណៈកម្មការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ស្តីពីរបាយការណ៍ត្រួតពិនិត្យវឌ្ឍនភាពកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ប្រចាំត្រីមាសទី៤ និងប្រចាំឆ្នាំ២០១៧ ក្រោមការដឹកនាំដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តមបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយមានការចូលរួមពីឯកឧត្តម លោកជំទាវ រដ្ឋលេខាធិការ, ឯកឧត្តម លោកជំទាវ អនុរដ្ឋលេខាធិការ និងសមាជិកក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

គោលបំណង នៃការត្រួតពិនិត្យវឌ្ឍនភាពនេះ គឺដើម្បីពង្រឹងប្រសិទ្ធភាពនៃការអនុវត្តផែនការសកម្មភាពរួម នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី៣ និងដើម្បីកំណត់ភាពខ្លាំង និងភាពខ្សោយនៃប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។ ក្នុងន័យនេះ របាយការណ៍នេះ បានបង្ហាញទាំងលទ្ធផលក្នុងឆ្នាំ (Outputs) តាមរយៈវឌ្ឍនភាពប្រចាំឆ្នាំ២០១៧ និងលទ្ធផលចុងក្រោយ (Outcomes) តាមរយៈការប្រើប្រាស់ក្របខ័ណ្ឌចំណាយសាធារណៈ និងគណនេយ្យភាពហិរញ្ញវត្ថុ (Framework for Public Expenditure and Financial Accountability-PEFA) ឆ្នាំ ២០១១ ដោយផ្អែកលើទិន្នន័យឆ្នាំ២០១៤-២០១៦ និងវឌ្ឍនភាពឆ្នាំ២០១៧ ជាមូលដ្ឋាន។

ឯកឧត្តម **រស់ សីលវ៉ា** អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (អ.គ.ហ.) បានធ្វើការបូកសរុបវឌ្ឍនភាពជារួម ដូចតទៅ÷

១. ភាពជឿទុកចិត្តនៃថវិកានៅតែរក្សាបានជាសារវន្ត ប៉ុន្តែទាមទារឱ្យមានការពង្រឹងការព្យាករ និងការអនុវត្តកម្មវិធីចំណូល-ចំណាយប្រចាំត្រីមាស។

២. ប្រព័ន្ធគណនេយ្យភាពបាននិងកំពុងកសាងតាមរយៈការដាក់ឱ្យអនុវត្តប្រព័ន្ធ FMIS ដំណាក់កាលទី២ ជាមួយនឹងភាពប្រុងប្រយ័ត្នខ្ពស់។

៣. ការពង្រឹង និងពង្រីកការអនុវត្តថវិកាកម្មវិធី ជាមូលដ្ឋានគ្រឹះសម្រាប់រៀបចំ និងកំណត់ការផ្លាស់ប្តូរប្រព័ន្ធថវិកាកម្ពុជា។

៤. យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ២០១៨-២០២៥ ជាសមាសធាតុសំខាន់សម្រាប់កំណត់ទិសដៅប្រព័ន្ធថវិកាសមិទ្ធកម្ម ដែលជាគោលដៅចុងក្រោយនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St,92 Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤
Phone : 855-23-724 664
ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Fax: 855-23-427 798

៥. ការរៀបចំប្រព័ន្ធលើកទឹកចិត្ត នឹងជំរុញការធ្វើស្ថាប័ននីយកម្មឱ្យស្របតាមការធ្វើទំនើបកម្មនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

កិច្ចប្រជុំគណៈកម្មការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ សម្រេចបានលទ្ធផល ដូចតទៅ÷

១. ស្នើ អ.គ.ហ. រៀបចំរបាយការណ៍វឌ្ឍនភាពសង្ខេបនៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈប្រចាំឆ្នាំ២០១៧ ដើម្បីគោរពជូន **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** អនុលោមតាមសារាចរណែនាំរបស់រាជរដ្ឋាភិបាលលេខ ០៩ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១៥ ស្តីពី "វិធាន និងនីតិវិធីនៃការរៀបចំ ការអនុវត្ត ការត្រួតពិនិត្យតាមដាន និងការវាយតម្លៃលើការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ"។

២. ស្នើ អ.គ.ហ. រៀបចំរបាយការណ៍វឌ្ឍនភាពនៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈឆ្នាំ២០១៧ និងផ្ញើជូនអគ្គនាយកដ្ឋានថវិកា ដើម្បីជាមូលដ្ឋានមួយសម្រាប់អគ្គនាយកដ្ឋានថវិកា ប្រើប្រាស់ក្នុងការចរចារកញ្ចប់ថវិកាប្រចាំឆ្នាំជាមួយក្រសួង ស្ថាប័ន។

៣. ស្នើ អ.គ.ហ. រៀបចំរបាយការណ៍ស្តីពីវឌ្ឍនភាពនៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដោយបង្ហាញសមិទ្ធផលសម្រេចបានរយៈពេល ៥ ឆ្នាំ, បញ្ហាប្រឈម និងទិសដៅនៃកម្មវិធីកែទម្រង់រយៈពេល ៥ ឆ្នាំ ទៅមុខ។ បន្ថែមពីនេះ អ.គ.ហ. គួរពិនិត្យ និងសិក្សាចំណុចចំនួន ០៣ បន្ថែមទៀត ដែលជាបច្ច័យ (Impact) នៃការកែទម្រង់ក្នុងរបាយការណ៍ឆ្នាំ២០១៧ នេះ រួមមាន (១). ការគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, (២). សមត្ថភាពគ្រប់គ្រងនិងដឹកនាំស្ថាប័ន និង (៣). ការប្រែប្រួលចរិតរបស់ក្រសួង ស្ថាប័ន ក្នុងការរៀបចំ និងអនុវត្តថវិកា ស្របតាមបរិបទថវិកាថ្មី។

៤. ស្នើ អ.គ.ហ. បន្តជំរុញការរៀបចំមគ្គុទេសក៍គ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMM) របស់រាជរដ្ឋាភិបាល ដើម្បីពង្រឹងប្រសិទ្ធភាពនៃការរៀបចំ, អនុវត្ត និង ត្រួតពិនិត្យនិងវាយតម្លៃថវិកា។

៥. ស្នើឯកឧត្តម **ចាន់ សុធី** អនុរដ្ឋលេខាធិការនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ធ្វើបទបង្ហាញស្តីពីយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ២០១៨-២០២៥ នៅក្នុងកិច្ចប្រជុំត្រួតពិនិត្យប្រចាំឆ្នាំ២០១៧។

៦. ស្នើអគ្គលេខាធិការដ្ឋានក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រៀបចំសេចក្តីព្រាងចក្ខុវិស័យ និងយុទ្ធសាស្ត្រនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងត្រូវដាក់ឱ្យពិគ្រោះយោបល់នៅក្នុងកិច្ចប្រជុំត្រួតពិនិត្យប្រចាំឆ្នាំ២០១៧ នាខែមេសា ឆ្នាំ២០១៨ ខាងមុខនេះ។

៧. ស្នើគ្រប់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ផ្តោតការយកចិត្តទុកដាក់លើរបាយការណ៍ត្រួតពិនិត្យវឌ្ឍនភាពកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈឆ្នាំ២០១៧ ដើម្បីជាធាតុចូលសម្រាប់ការរៀបចំ និងកែលម្អផែនការសកម្មភាព (GDAP) របស់អង្គភាពខ្លួន។

៨. អនុញ្ញាតឱ្យបញ្ចូលការរៀបចំផែនទីបង្ហាញផ្លូវគណនេយ្យបង្គរ នៅក្នុងទិសដៅនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈឆ្នាំ២០១៨-២០២៣។

៩. ស្នើអគ្គនាយកដ្ឋានពន្ធដារសហការជាមួយក្រុមការងារ FMWG ធ្វើសន្ទានកម្មរវាងប្រព័ន្ធទិន្នន័យពន្ធដារ និងប្រព័ន្ធ FMIS ដោយមិនចាំបាច់ឱ្យមានការចុះអនុស្សរណៈយោគយល់គ្នា (MOU) នោះទេ ស្របតាមអនុសាសន៍ណែនាំដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តមបណ្ឌិតសភាចារ្យទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

១០. ស្នើក្រុមការងារ FMWG ធ្វើការសិក្សាជាមួយក្រសួងមុខងារសាធារណៈបន្ថែមទៀត ដើម្បីពិនិត្យលទ្ធភាពនៃការធ្វើសន្ទានកម្មរវាងប្រព័ន្ធបៀវត្ស និងប្រព័ន្ធ FMIS។

១១. ស្នើក្រុមការងារ FMWG អញ្ជើញ អ.គ.ហ. ចូលរួមកិច្ចប្រជុំពាក់ព័ន្ធនឹងគម្រោង FMIS ដើម្បីបង្កើនការចូលរួម និងការយល់គ្នាទៅវិញទៅមក ដើម្បីជំរុញការអនុវត្តប្រព័ន្ធ FMIS ប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព។

១២. ស្នើក្រុមការងារ FMWG កំណត់ពេលវេលាសមស្របណាមួយ ដើម្បីអញ្ជើញគ្រប់ថ្នាក់ដឹកនាំនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ចូលរួមកិច្ចប្រជុំផ្សព្វផ្សាយស្តីពីការបង្កើនការយល់ដឹងពីអត្ថប្រយោជន៍នៃប្រព័ន្ធ FMIS, ការគ្រប់គ្រងការផ្លាស់ប្តូរ (Change Management) និងនីតិវិធីបច្ចុប្បន្នកម្មរួម (Standard Operation Procedure-SOP)។

១៣. ស្នើអគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ ធ្វើការពិនិត្យលទ្ធភាពនៃការធ្វើវិមជ្ឈការលទ្ធកម្មសាធារណៈបន្ថែមទៀត ដោយដំឡើងទំហំថវិកាក្រោមសិទ្ធិសម្រេចលើស្ថាប័នអនុវត្តលទ្ធកម្ម។ ការធ្វើវិមជ្ឈការលទ្ធកម្មសាធារណៈនេះ គឺត្រូវប្រកាន់ខ្ជាប់នូវគោលការណ៍អនុលោមភាពជាមូលដ្ឋាន ពោលគឺមិនត្រូវបង្កើនទំហំថវិកាក្រោមសិទ្ធិសម្រេចគ្រប់ស្ថាប័នអនុវត្តលទ្ធកម្ម នូវទំហំស្មើគ្នានោះទេ។ ការប្រកាន់ខ្ជាប់នូវគោលការណ៍អនុលោមភាពជាមូលដ្ឋាន គឺក្នុងគោលបំណងលើកទឹកចិត្តដល់ស្ថាប័នអនុវត្តលទ្ធកម្ម ដែលខិតខំអនុវត្ត និងប្រកាន់ខ្ជាប់នូវការអនុវត្តស្របតាមនីតិវិធី និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

១៤. បន្តពង្រឹងទំនាក់ទំនងល្អ និងកិច្ចសហការជាមួយអង្គការមិនមែនរដ្ឋាភិបាល លើការវាយតម្លៃតម្លាភាពថវិកានៅកម្ពុជា ដើម្បីឱ្យលទ្ធផលនៃការវាយតម្លៃឆ្លុះបញ្ចាំងអំពីតថភាពពិតប្រាកដនៅកម្ពុជា។

១៥. ដោយសារកត្តាពេលវេលា អង្គប្រជុំសម្រេចលើកកិច្ចប្រជុំគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលគ្រោងនឹងរៀបចំនៅថ្ងៃទី២០ ខែមីនា ឆ្នាំ២០១៨ ទៅដាក់ជាមួយកិច្ចប្រជុំត្រួតពិនិត្យប្រចាំឆ្នាំ២០១៧ ដែលនឹងប្រព្រឹត្តទៅនៅសប្តាហ៍ទី២ នៃខែមេសា ឆ្នាំ២០១៨។

ជាចុងបញ្ចប់ ឯកឧត្តមបណ្ឌិតសភាចារ្យទេសរដ្ឋមន្ត្រី បានកោតសរសើរ និងថ្លែងអំណរគុណចំពោះ អ.គ.ហ. ដែលបានរៀបចំរបាយការណ៍ត្រួតពិនិត្យវឌ្ឍនភាពកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ប្រកបដោយភាពគ្រប់ជ្រុងជ្រោយ ដោយឆ្លុះបញ្ចាំងទាំងទិដ្ឋភាពការងារកែទម្រង់ និងប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

អង្គប្រជុំបានបញ្ចប់នៅថ្ងៃដដែល វេលាម៉ោង ១៣:៣០នាទី រសៀល ប្រកបដោយបរិយាកាសស្និទ្ធស្នាល។

ថ្ងៃចន្ទ ០៣កើត ខែចេត្រ ឆ្នាំរកា នព្វស័ក ព.ស២៥៦១
រាជធានីភ្នំពេញ ថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១៨
អ្នករៀបចំរបាយការណ៍

**អ៊ិច សោភ័ណ**

បានឃើញ និងឯកភាព

សូមគោរពជូនឯកឧត្តមបណ្ឌិតទេសរដ្ឋមន្ត្រី ពិនិត្យ និងសម្រេច

ថ្ងៃ ពុធ ០៣កើត ខែចេត្រ ឆ្នាំរកា នព្វស័ក ព.ស២៥៦១

រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែមីនា ឆ្នាំ២០១៨

**អគ្គលេខាធិការ**

**អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំ**

**ការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**

**រស់ សីលវ៉ា**

ថ្ងៃ ពុធ ០៥កើត ខែ ចេត្រ ឆ្នាំរកា នព្វស័ក ព.ស២៥៦១

រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ មីនា ឆ្នាំ២០១៨

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធាន**

**គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**

**បណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

លេខ.......................សហវ.........

## សេចក្តីសម្រេច
## កិច្ចប្រជុំគណៈកម្មការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
## នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ថ្ងៃទី០៥ ខែមីនា ឆ្នាំ២០១៨

លទ្ធផលកិច្ចប្រជុំគណៈកម្មការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ កាលពីថ្ងៃចន្ទ ០៤រោច ខែផល្គុន ឆ្នាំរកា នព្វស័ក ព.ស.២៥៦១ ត្រូវនឹងថ្ងៃទី០៥ ខែមីនា ឆ្នាំ២០១៨ បានដាក់ចេញសេចក្តីសម្រេច ដើម្បីលើកជាវិធានការអនុវត្ត ដូចតទៅ÷

១. ស្នើ អ.គ.ហ. រៀបចំរបាយការណ៍វឌ្ឍនភាពសង្ខេបនៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈប្រចាំឆ្នាំ២០១៧ ដើម្បីគោរពជូន **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** អនុលោមតាមសារាចរណែនាំរបស់រាជរដ្ឋាភិបាលលេខ ០៩ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១៥ ស្តីពី "វិធាន និងនីតិវិធីនៃការរៀបចំ ការអនុវត្ត ការត្រួតពិនិត្យ តាមដាន និងការវាយតម្លៃលើការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ"។

២. ស្នើ អ.គ.ហ. រៀបចំរបាយការណ៍វឌ្ឍនភាពនៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈឆ្នាំ២០១៧ និងផ្ញើជូនអគ្គនាយកដ្ឋានថវិកា ដើម្បីជាមូលដ្ឋានសម្រាប់អគ្គនាយកដ្ឋានថវិកា ធ្វើការចរចារកញ្ចប់ថវិកាប្រចាំឆ្នាំជាមួយក្រសួង ស្ថាប័ន។

៣. ស្នើ អ.គ.ហ. រៀបចំរបាយការណ៍ស្តីពីវឌ្ឍនភាពនៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដោយបង្ហាញសមិទ្ធផលសម្រេចបានរយៈពេល ៥ ឆ្នាំ, បញ្ហាប្រឈម និងទិសដៅនៃកម្មវិធីកែទម្រង់រយៈពេល ៥ ឆ្នាំ ទៅមុខ។ បន្ថែមពីនេះ អ.គ.ហ. គួរពិនិត្យ និងសិក្សាចំណុចចំនួន ០៣ បន្ថែមទៀត ដែលជាបច្ច័យ (Impact) នៃការកែទម្រង់ក្នុងរបាយការណ៍ឆ្នាំ២០១៧ នេះ រួមមាន (១).ការគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, (២).សមត្ថភាពគ្រប់គ្រង និងដឹកនាំស្ថាប័ន និង (៣). ការប្រែប្រួលចរិតរបស់ក្រសួង ស្ថាប័ន ក្នុងការរៀបចំ និងអនុវត្តថវិកា ស្របតាមបរិបទថវិកាថ្មី។

៤. ស្នើ អ.គ.ហ. បន្តជំរុញការរៀបចំមគ្គុទេសក៍គ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMM) របស់រាជរដ្ឋាភិបាល ដើម្បីពង្រឹងប្រសិទ្ធភាពនៃការរៀបចំ, អនុវត្ត និងត្រួតពិនិត្យនិងវាយតម្លៃថវិកា។

៥. ស្នើអគ្គលេខាធិការដ្ឋានក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រៀបចំសេចក្តីព្រាងចក្ខុវិស័យ និងយុទ្ធសាស្ត្រនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងត្រូវដាក់ឱ្យពិគ្រោះយោបល់នៅក្នុងកិច្ចប្រជុំត្រួតពិនិត្យប្រចាំឆ្នាំ២០១៧ នាខែមេសា ឆ្នាំ២០១៨ ខាងមុខនេះ។

៦. ស្នើគ្រប់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ផ្តោតការយកចិត្តទុកដាក់លើរបាយការណ៍ត្រួតពិនិត្យវឌ្ឍនភាពកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈឆ្នាំ២០១៧ ដើម្បីជាធាតុចូលសម្រាប់ការរៀបចំ និងកែលម្អផែនការសកម្មភាព (GDAP) របស់អង្គភាពខ្លួន។

៧. អនុញ្ញាតឱ្យបញ្ចូលការរៀបចំផែនទីបង្ហាញផ្លូវគណនេយ្យបង្គរ នៅក្នុងទិសដៅនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ឆ្នាំ២០១៨-២០២៣។

៨. ស្នើអគ្គនាយកដ្ឋានពន្ធដារសហការជាមួយក្រុមការងារ FMWG ធ្វើសន្ទានកម្មរវាងប្រព័ន្ធទិន្នន័យពន្ធដារ និងប្រព័ន្ធ FMIS ដោយមិនចាំបាច់ឱ្យមានការចុះអនុស្សរណៈយោគយល់គ្នា (MOU) នោះទេ ស្របតាមអនុសាសន៍ណែនាំដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តមបណ្ឌិតសភាចារ្យទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

៩. ស្នើក្រុមការងារ FMWG ធ្វើការសិក្សាជាមួយក្រសួងមុខងារសាធារណៈបន្ថែមទៀត ដើម្បីពិនិត្យលទ្ធភាពនៃការធ្វើសន្ទានកម្មរវាងប្រព័ន្ធបៀវត្ស និងប្រព័ន្ធ FMIS។

១០. ស្នើក្រុមការងារ FMWG អញ្ជើញ អ.គ.ហ. ចូលរួមកិច្ចប្រជុំពាក់ព័ន្ធនឹងគម្រោង FMIS ដើម្បីបង្កើនការចូលរួម និងការយល់គ្នាទៅវិញទៅមក ដើម្បីជំរុញការអនុវត្តប្រព័ន្ធ FMIS ប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព។

១១. ស្នើអគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ ធ្វើការពិនិត្យលទ្ធភាពនៃការធ្វើវិមជ្ឈការលទ្ធកម្មសាធារណៈបន្ថែមទៀត ដោយដំឡើងទំហំថវិកាក្រោមសិទ្ធិសម្រេចលើស្ថាប័នអនុវត្តលទ្ធកម្ម។ ការធ្វើវិមជ្ឈការលទ្ធកម្មសាធារណៈនេះ គឺត្រូវប្រកាន់ខ្ជាប់នូវគោលការណ៍អនុលោមភាពជាមូលដ្ឋាន ពោលគឺមិនត្រូវបង្កើនទំហំថវិកាក្រោមសិទ្ធិសម្រេចគ្រប់ស្ថាប័នអនុវត្តលទ្ធកម្មនូវទំហំស្មើគ្នានោះទេ។ ការប្រកាន់ខ្ជាប់នូវគោលការណ៍អនុលោមភាពជាមូលដ្ឋាន គឺក្នុងគោលបំណងលើកទឹកចិត្តដល់ស្ថាប័នអនុវត្តលទ្ធកម្ម ដែលខិតខំអនុវត្ត និងប្រកាន់ខ្ជាប់នូវការអនុវត្តស្របតាមនីតិវិធី និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

១២. បន្តពង្រឹងទំនាក់ទំនងល្អ និងកិច្ចសហការជាមួយអង្គការមិនមែនរដ្ឋាភិបាល លើការវាយតម្លៃតម្លាភាពថវិកានៅកម្ពុជា ដើម្បីឱ្យលទ្ធផលនៃការវាយតម្លៃឆ្លុះបញ្ចាំងអំពីតថភាពពិតប្រាកដនៅកម្ពុជា។

ថ្ងៃ ៣ ៨ ០៥ កើត ខែ ចេត្រ ឆ្នាំរកា នព្វស័ក ព.ស ២៥៦១

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ មីនា ឆ្នាំ២០១៨

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធាន**

**គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**

**បណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

# កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ គឺជាការងារកែទម្រង់ស្នូលនៃយុទ្ធសាស្ត្រចតុកោណ ដើម្បីបង្កើន និងពង្រឹងអភិបាលកិច្ច។ កម្មវិធីកែទម្រង់នេះ បាននឹងកំពុងកសាង "ប្រព័ន្ធ យន្តការ ក្របខ័ណ្ឌគតិយុត្ត និងធនធានមនុស្ស" ដែលជាកត្តាគន្លឹះកំណត់ជោគជ័យ ធានាវិន័យ តម្លាភាព គណនេយ្យភាព ស័ក្តិសិទ្ធភាព និងប្រសិទ្ធភាពនៃប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ។

ជាក់ស្តែង គោលបំណង នៃការរៀបចំរបាយការណ៍ត្រួតពិនិត្យវឌ្ឍនភាពកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈឆ្នាំ២០១៧នេះ គឺធ្វើវាយតម្លៃភាពខ្លាំង និងភាពខ្សោយនៃប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក៏ដូចជាដើម្បីពង្រឹងការអនុវត្ត និងកែលម្អក្របខ័ណ្ឌផែនការសកម្មភាពរួមសម្រាប់អនុវត្តនាឆ្នាំបន្តបន្ទាប់ទៀត។ របាយការណ៍នេះ នឹងឆ្លុះបញ្ចាំងនូវភាពគ្រប់ជ្រុងជ្រោយនៃប្រព័ន្ធ ព្រមទាំងលទ្ធផលក្នុងឆ្នាំ (Outputs) និងលទ្ធផលចុងក្រោយ (Outcomes) ។ ក្នុងន័យនេះ អ.គ.ហ.បានជ្រើសរើសវិធីសាស្ត្រចំនួន ៣ ដើម្បីធ្វើការសិក្សារៀបចំរបាយការណ៍នេះឡើង រួមមាន (១).ត្រួតពិនិត្យ និងបូកសរុបវឌ្ឍនភាពស្របតាមក្របខ័ណ្ឌផែនការសកម្មភាពរួម ដំណាក់កាលទី៣ ឆ្នាំ ២០១៧-២០២០, (២). ចុះជួបពិភាក្សាជាមួយក្រសួង ស្ថាប័ន និងរដ្ឋបាលរាជធានី ខេត្ត និង (៣).សិក្សាអំពីភាពខ្លាំង និងភាពខ្សោយនៃប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដោយប្រើប្រាស់ក្របខ័ណ្ឌចំណាយសាធារណៈ និងគណនេយ្យ-ភាពហិរញ្ញវត្ថុ (Framework for Public Expenditure and Financial Accountability-PEFA) ឆ្នាំ២០១១។